# រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# របាយការណ៍វាយតម្លៃការអនុវត្ត
# ផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២ ឆ្នាំ២០២១-២០២២
# និងការវាយតម្លៃបុរេលក្ខខណ្ឌសម្រាប់ឈានទៅអនុវត្ត
# “គណនេយ្យភាពសមិទ្ធកម្ម”

អគ្គលេខាធិការដ្ឋាន

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# មាតិកានុក្រម


**សេចក្តីសង្ខេបប្រតិបត្តិ** ........ ១

**១. សេចក្តីផ្តើម** ........ ៧

១.១. សាវតារ ........ ៧

១.២. គោលបំណង ........ ៨

១.៣. វិធីសាស្រ្តវាយតម្លៃ ........ ៨

១.៤. ការងារបន្តក្នុងដំណាក់កាលទី៣ ប្ញូក ២ ........ ៩

**២. ការវាយតម្លៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ ប្ញូក ២** ........ ១១

២.១. សង្ខេបវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់អង្គភាព ........ ១១

២.២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ ប្ញូក ២ ........ ១១

ផ្នែកទី១÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា ........ ១១

ផ្នែកទី២÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ........ ១៩

ផ្នែកទី៣÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ........ ២៧

ផ្នែកទី៤÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម ........ ៣៣

ផ្នែកទី៥÷ ការកែទម្រង់ប្រកបដោយចីរភាពនិងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត ........ ៣៩

**៣. ការវាយតម្លៃលើបុរេលក្ខខណ្ឌជាមូលដ្ឋានសម្រាប់ឈានទៅអនុវត្ត "គណនេយ្យភាពសមិទ្ធកម្ម"** ........ ៤៣

ផ្នែកទី១÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា ........ ៤៣

ផ្នែកទី២÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ........ ៤៥

ផ្នែកទី៣÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ........ ៤៦

ផ្នែកទី៤÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម ........ ៤៧

ផ្នែកទី៥÷ ការកែទម្រង់ប្រកបដោយចីរភាពនិងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត ........ ៤៩

**៤. អាទិភាពក្នុងដំណាក់កាលទី៤** ........ ៥១

**៥. ការគ្រប់គ្រងហានិភ័យ** ........ ៥៤

**៦. សន្និដ្ឋាន** ........ ៥៨

**ឧបសម្ព័ន្ធ** ........ ៦០

# អក្សរកាត់

| | | |
|---|---|---|
| ACAR | Accounting and Auditing Regulator | និយ័តករគណនេយ្យនិងសវនកម្ម |
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFD | French Development Agency | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| BSP | Budget Strategic Plan | ផែនការយុទ្ធសាស្ត្រថវិកា (ផ.យ.ថ) |
| BSRS | Budget System Reform Strategy | យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា |
| CAP | Consolidated Action Plan | ផែនការសកម្មភាពរួម |
| CoA | Chart of Accounts | ប្លង់គណនេយ្យ |
| DMFAS | Debt management and financial analysis system | ប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុល |
| EFI | Economics and Finance Institute | វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វ.ស.ហ.) |
| GDICDM | General Department of International Cooperation and Debt Management | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អ.ស.ប.) |
| FMIS | Financial Management Information System | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| FMWG | FMIS project Management Working Group | ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| GDB | General Department of Budget | អគ្គនាយកដ្ឋានថវិកា (អ.ថ.) |
| GDCE | General Department of Customs and Excise | អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អ.គ.រ.) |
| GDIA | General Department of Internal Audit | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង (អ.ស.ក.) |
| GDNT | General Department of National Treasury | អគ្គនាយកដ្ឋានរតនាគារជាតិ (អ.រ.ជ.) |
| GDPP | General Department of Public Procurement | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ (អ.ល.ស.) |
| GDSNAF | General Department of Sub-National Administration Finance | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ (អ.ហ.ថ.) |
| GDSPNR | General Department of State Property and Non-Tax Revenue | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (អ.ទ.ច.) |
| GDT | General Department of Taxation | អគ្គនាយកដ្ឋានពន្ធដារ (អ.ព.ដ.) |
| GDP | General Department of Policy<br>Gross Domestic Product | អគ្គនាយកដ្ឋានគោលនយោបាយ (អ.គ.ប.)<br>ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) |
| GFS | Government Financial Statistics | ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល |
| GSC | General Secretariat of Public Financial Management Reform Steering Committee | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(អ.គ.ហ) |
| IMF | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| LM | Line ministry | ក្រសួង ស្ថាប័ន |

| | | |
|---|---|---|
| LCs | Legal Council Secretariate | លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម (ល.ក.ន.) |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) |
| MTBF | Medium-Term Budget Framework | ក្របខ័ណ្ឌថវិការយៈពេលមធ្យម |
| MTFF | Medium-Term Fiscal Framework | ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម |
| NAA | National Audit Authority | អាជ្ញាធរសវនកម្មជាតិ (អ.ស.ជ.) |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| PFM | Public Financial Management | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| WB | World Bank | ធនាគារពិភពលោក |
| PFMRC | Public Financial Management Reform Commission | គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PFMSC | Public Financial Management Reform Steering Committee | គណៈកម្មាធិការដឹកនាំការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| MOEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| EFMS | Education Financial Management System | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជននិងកីឡា |
| PB | Program Budgeting | ថវិកាកម្មវិធី |
| NRMIS | Non-tax Revenue Management Information System | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ |
| SARMIS | State Asset Register Management Information System | ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ |
| PPCA | Phnom Penh Capital Administration | រដ្ឋបាលរាជធានីភ្នំពេញ |
| PPCC | Phnom Penh Capital Council | ក្រុមប្រឹក្សារាជធានីភ្នំពេញ |

## បញ្ជីតារាង


តារាងទី 1 ÷ រចនាសម្ព័ន្ធផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២ ឆ្នាំ២០២១-២០២២ ........................ ៨

តារាងទី 2 ÷ ស្ថានភាពនៃការប្រមូលចំណូលពន្ធដារធៀបនឹងផែនការ.................................................. ១៣

តារាងទី 3 ÷ ការដាក់ឱ្យអនុវត្តប្រព័ន្ធ E-Payment តាមដំណាក់កាល ................................................ ១៥

តារាងទី 4 ÷ សូចនាករបំណុលសាធារណៈឆ្នាំ២០១៨-២០២២.......................................................... ២៤

តារាងទី 5 ÷ ផែនការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលរាជធានី-ខេត្ត.................................................... ៣០

តារាងទី 6 ÷ ការគ្រប់គ្រងហានិភ័យ................................................................................................ ៥៤


## បញ្ជីដ្យាក្រាម


ដ្យាក្រាមទី 1 ÷ វឌ្ឍនភាពនៃការអនុវត្ត GDAP/MAP/PDAP តាមអង្គភាព ឆ្នាំ២០២១-២០២២........................ ១១

ដ្យាក្រាមទី 2 ÷ ចំណូលថវិការដ្ឋ (ចំណូលចរន្ត + ចំណូលមូលធន) និងកំណើនចំណូលចរន្តឆ្នាំ២០១៣-២០២២... ១២

ដ្យាក្រាមទី 3 ÷ ចំណូលពន្ធអាករគយធៀបនឹងផែនការ ឆ្នាំ២០១៨-២០២២ ........................................... ១៣

ដ្យាក្រាមទី 4 ÷ ការអនុវត្តចំណាយថវិការដ្ឋឆ្នាំ២០១៣-២០២២ ......................................................... ១៦

ដ្យាក្រាមទី 5 ÷ រំហូរការអនុវត្តថវិការដ្ឋប្រចាំត្រីមាសចាប់ពីឆ្នាំ២០១៦-២០២២ ...................................... ១៦

ដ្យាក្រាមទី 6 ÷ សន្និធិបំណុលសាធារណៈក្រៅប្រទេស (គិតត្រឹមឆមាសទី១ ឆ្នាំ២០២២) ............................. ២៣

# សេចក្តីសង្ខេបប្រតិបត្តិ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីកែទម្រង់ស្នូលមួយនៃកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីឈានឆ្ពោះទៅពង្រឹងអភិបាលកិច្ច ដែលបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤។ ក្នុងរយៈពេលជិត ២ ទសវត្សរ៍នេះ ក្រោមភាពជាម្ចាស់ និងការដឹកនាំរបស់រាជរដ្ឋាភិបាល កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រេចបានជាសារវន្តតាមខឿន និងដំណាក់កាលនីមួយៗ ដែលបានកសាង និងកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យកាន់តែរឹងមាំ និងមានភាពធន់នឹងវិបត្តិ។

ដើម្បីមានមូលដ្ឋានព័ត៌មានក្នុងការសម្រេចចិត្តលើការកំណត់វិធានការអនុវត្តបន្ត និងជាធាតុចូលបន្ថែមលើការរៀបចំក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៤ ***របាយការណ៍វាយតម្លៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២ ឆ្នាំ២០២១-២០២២*** ត្រូវបានរៀបចំឡើង ក្នុងគោលបំណងបូកសរុបវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរយៈពេល២ឆ្នាំ (២០២១-២០២២) និងវាយតម្លៃលើការសម្រេចបានតាមខឿននិងគោលបំណងនីមួយៗ ក្នុងដំណាក់កាលទី៣ (២០១៦-២០២២)។ របាយការណ៍នេះក៏វាយតម្លៃលើការសម្រេចបាននូវបុរេលក្ខខណ្ឌសំខាន់ៗក្នុងការឈានទៅអនុវត្តដំណាក់កាលទី៤។

លទ្ធផលវាយតម្លៃនៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២ សម្រេចបានដូចតទៅ÷

*ផ្នែកទី១ "ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា"*÷ ភាពជឿទុកចិត្តនៃថវិកានៅតែរក្សាបានស្ថានភាពរឹងមាំ និងធន់នឹងវិបត្តិ។ ក្នុងអំឡុងពេលនៃវិបត្តិសេដ្ឋកិច្ចដែលបង្កដោយការរីករាលដាលជំងឺកូវីដ-១៩ និងក្រោយមកផលវិបាកនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន រាជរដ្ឋាភិបាលមានថវិកាគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយ និងវិធានការអន្តរាគមន៍ទាំងឡាយ ដើម្បីរក្សាលំនឹងសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន។ ពីឆ្នាំ២០១៦-២០២២ ចំណូលចរន្តមានកំណើនជាមធ្យមប្រមាណ ០,៦៤ ពិន្ទុភាគរយនៃ ផ.ស.ស. ដែលខ្ពស់ជាងគោលដៅកំណត់ក្នុងយុទ្ធសាស្ត្រ។ ក្នុងនោះ ការប្រមូលចំណូលក្នុងឆ្នាំ២០១៩ មានកំណើនខ្ពស់រហូតដល់ ៣,១៧ ពិន្ទុភាគរយនៃ ផ.ស.ស. មុននឹងថមថយចាប់ពីឆ្នាំ២០២០ ដោយសារវិបត្តិនៃការរីករាលដាលជំងឺកូវីដ-១៩។ ទោះជាសម្រេចបានកំណើនអវិជ្ជមានក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ ក៏ការប្រមូលចំណូលមានកំណើនវិជ្ជមានឡើងវិញប្រមាណ ១,៧៥ ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ២០២២។ ក្នុងនោះ ការអនុវត្តការប្រមូលចំណូលសម្រេចបានតាមផែនការក្នុងរង្វង់ +/-៥% ដោយចំណូលថវិកាជាតិ (ចំណូលចរន្ត និងចំណូលមូលធនក្នុងប្រទេស) កើនដល់ ២៦ ៨៥៧ ប៊ីលានរៀល ធៀបនឹងឆ្នាំ២០១៦ ដែលមានត្រឹមតែ ១៤ ៧១៥ ប៊ីលានរៀល។ ភាពល្អប្រសើរនៃការប្រមូលចំណូលនេះ គឺមានបច្ច័យពីការបន្តពង្រឹងរដ្ឋបាលប្រមូលចំណូល ក្នុងនោះបន្តធ្វើទំនើបកម្មប្រព័ន្ធប្រមូលចំណូល រួមមាន ការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការប្រមូលចំណូលនានា ដូចជា ការជំរុញការបង់ពន្ធទាន់ពេលវេលា, ការដោះស្រាយបណ្តឹងតវ៉ា, ការធ្វើចំណាត់ថ្នាក់ និងតឹងទារបំណុលពន្ធ, ការដាក់ឱ្យអនុវត្តសេវាអេឡិចត្រូនិក និងការពង្រីកការប្រើប្រាស់ប្រព័ន្ធ NRMIS នៅគ្រប់អង្គភាពប្រមូលចំណូលនៅរដ្ឋបាលថ្នាក់ជាតិចំនួន ២៣ ក្រសួង-ស្ថាប័ន, មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្ត ព្រមទាំងអង្គភាពប្រមូលចំណូលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង ប្រព័ន្ធ e-Payment នៅក្រសួង-ស្ថាប័នចំនួន ២៣។

ផ្អែកលើមូលដ្ឋានកើនឡើងនៃការប្រមូលចំណូល រាជរដ្ឋាភិបាលមានលទ្ធភាពបង្កើនការចំណាយរហូតដល់ ២៨ ៧៣៧ ប៊ីលានរៀលក្នុងឆ្នាំ២០២២ ធៀបនឹងឆ្នាំ២០១៦ ដែលមានត្រឹម ១៤ ៩៨៣ ប៊ីលានរៀល។ ក្នុងនោះ នីតិវិធី និងប្រសិទ្ធភាពចំណាយត្រូវបានបន្តពង្រឹងបន្ថែមទៀតជាបន្តបន្ទាប់ តាមរយៈការដាក់ឱ្យអនុវត្ត និងកែសម្រួលបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងនីតិវិធីអនុវត្តចំណាយសំដៅពន្លឿននិងបង្កើនប្រសិទ្ធភាពចំណាយ និងគណនេយ្យភាព ព្រមទាំងការប្រគល់សិទ្ធសម្រេចកាន់តែច្រើនដល់ក្រសួង-ស្ថាប័នចំណាយ អង្គភាពប្រតិបត្តិ និងអង្គភាពបម្រើសេវាសាធារណៈ, ការប្រើប្រាស់វិធីសាស្ត្រលទ្ធកម្មប្រកួតប្រជែង និងការផ្តល់សិទ្ធិសម្រេចលទ្ធកម្មជាបន្តបន្ទាប់។ ទោះបីជាយ៉ាងនេះក្តី វឌ្ឍនភាពទាំងនេះហាក់ពុំទាន់មានបច្ច័យគ្រប់គ្រាន់នៅឡើយទៅលើប្រសិទ្ធភាពអនុវត្តថវិកា។ ចំណាយថវិកាជាតិសរុបប្រចាំឆ្នាំ២០២២ (គិតត្រឹមថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៣) សម្រេចបាន ៨១,៦៩% ធៀបនឹងច្បាប់ថវិកា ក្នុងនោះ ចំណាយបៀវត្សសម្រេចបាន ៩៦,២៣% ធៀបនឹងច្បាប់ថវិកា, ចំណាយទំនិញសេវា ៨៣,៧៧% ធៀបនឹងច្បាប់ថវិកា, និងចំណាយមូលធន ៧៤,៥៣% ធៀបនឹងច្បាប់ថវិកា។ ដោយឡែក ការអនុវត្តចំណាយតាមត្រីមាសនៅមានកម្រិតទាប មិនទាន់អនុលោមទាំងស្រុងតាមផែនការចំណូល-ចំណាយ ពោលគឺការទូទាត់មាននិន្នាការបង្គរនៅត្រីមាសទី៤ ជាពិសេសចំពោះចំណាយដែលតម្រូវឱ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។ ទន្ទឹមនឹងនេះ ការប្រើប្រាស់វិធីសាស្ត្រលទ្ធកម្មប្រកួតប្រជែងចំពោះថវិកាចរន្ត និងមូលធន ក្នុងឆ្នាំ២០២១ អនុវត្តបានត្រឹម ៥៦% ដែលថយចុះប្រមាណ ៥% ធៀបនឹងការអនុវត្តនៅក្នុងឆ្នាំ២០២០ ហើយការបង្កើនសិទ្ធិសម្រេចលទ្ធកម្មជំហានទី២ ក៏ពុំទាន់បានដាក់ឱ្យអនុវត្តនៅឡើយ។

**សន្និដ្ឋានជារួម÷** ភាពជឿទុកចិត្តនៃថវិកានៅរក្សាបានស្ថានភាពរឹងមាំ ក៏ប៉ុន្តែត្រូវបន្តយកចិត្តទុកដាក់បន្ថែមទៀតលើការធ្វើពិពិធកម្មចំណូល។ ដោយឡែក វិហ្វរ និងប្រសិទ្ធភាពចំណាយត្រូវបន្តយកចិត្តទុកដាក់ខ្ពស់។ ការពន្លឿនការអនុវត្តថវិកាតាមផែនការចំណាយប្រចាំត្រីមាសនីមួយៗ ត្រូវបន្តយកចិត្តទុកដាក់ តាមរយៈ (ទី១) ការជំរុញបញ្ចប់ការរៀបចំក្របខ័ណ្ឌផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ ដើម្បីកំណត់បញ្ហាប្រឈមជាក់ស្តែងនៃការបង្គរ ការអនុវត្តថវិកានៅចុងឆ្នាំ, និង (ទី២) ការដាក់ឱ្យអនុវត្តសិទ្ធិសម្រេចលទ្ធកម្ម ជំហានទី២ និងការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម ដែលត្រូវពង្រឹងតាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

*ផ្នែកទី២ "ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"÷* គណនេយ្យភាពហិរញ្ញវត្ថុត្រូវបានបន្តពង្រឹងជាបន្តបន្ទាប់តាមរយៈការពង្រឹង និងពង្រីកប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ ប្រព័ន្ធ FMIS ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗចាប់ពីឆ្នាំ២០១៤ ដែលបានក្លាយជាឆ្អឹងខ្នងសំខាន់ក្នុងការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុជាបណ្តើរៗ។ មុខងារស្នូល និងចំណាត់ថ្នាក់ថវិកាត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធ និងបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន, រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត, រតនាគាររាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្ត ជាផ្លូវការ។ ដោយឡែក រដ្ឋបាលស្រុកចំនួន ៧៥ និងរដ្ឋបាលឃុំចំនួន ១៨៥ បានប្រើប្រាស់សាកល្បងប្រព័ន្ធឯកសារឌីជីថល (FMIS Portal V1) ជាផ្លូវការ។ បន្ថែមលើនេះ ការធ្វើសន្ធានកម្មរវាងប្រព័ន្ធ FMIS ជាមួយប្រព័ន្ធខាងក្រៅ និង ធនាគារពាណិជ្ជនានា ដើម្បីទទួលបាននូវព័ត៌មាន ឬទិន្នន័យពេញលេញ និង ទាន់ពេលវេលា។ ព្រមទាំងការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក (EFT) នៅថ្នាក់កណ្តាល និង នៅថ្នាក់មូលដ្ឋាន ដើម្បីជួយសម្រួលដល់ការទូទាត់ទៅអ្នកផ្គត់ផ្គង់បានឆាប់រហ័សទាន់ពេលវេលា។ ជាមួយគ្នានេះ, មុខងារថ្មីត្រូវបាន

រៀបចំ និងដាក់ឱ្យប្រើប្រាស់ជាជំហានៗ ក្នុងនោះ មុខងារថ្មីចំនួន២ (មុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញ) បានដាក់ឱ្យអនុវត្តនៅតាមក្រសួង-ស្ថាប័ន ក្នុងនោះមុខងាររៀបចំផែនការថវិកាបានដាក់ឱ្យអនុវត្តនៅក្រសួង-ស្ថាប័នចំនួន ១៣ និងមុខងារលទ្ធកម្មពេញលេញត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន។ នីតិវិធីចំណាយថវិកាចរន្តលើគ្រប់មុខសញ្ញាតាមប្រព័ន្ធ FMIS ទាំងស្រុង ត្រូវបានដាក់ឱ្យអនុវត្តនៅ កសហវ. និងក្រសួងបរិស្ថាន ខណៈនីតិវិធីចំណាយបៀវត្ស និងនីតិធីចំណាយទូទាត់ត្រង់តាមប្រព័ន្ធ FMIS ទាំងស្រុងត្រូវបានដាក់ឱ្យអនុវត្តនៅក្រសួង-ស្ថាប័នចំនួន ៣៤។

ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក៏ត្រូវបានពង្រឹងជាបណ្តើរៗ តាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តជាបណ្តើរៗនូវក្របខ័ណ្ឌគតិយុត្ត។ ការពង្រីកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) បានជួយជំរុញឱ្យការរៀបចំបញ្ជីសារពើភណ្ឌមានការកើនឡើង ទោះបីគុណភាពបញ្ជី និងភាពទាន់ពេលវេលានៃការរៀបចំនៅមានកម្រិត។ ក្នុងឆ្នាំ២០២១ ការរៀបចំបញ្ជីសារពើភណ្ឌកើនដល់ ៨៧% (២៦៤៣/៣០៥៣ អង្គភាពប្រើប្រាស់) និងរំពឹងថាមានការកើនឡើងបន្ថែមទៀតបន្ទាប់ពីដាក់ឱ្យអនុវត្តប្រព័ន្ធ SARMIS ដល់រដ្ឋបាលឃុំ សង្កាត់។

ដោយឡែក ការគ្រប់គ្រងបំណុលសាធារណៈវិញ, សូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានបន្តរក្សាក្រោមពិតាន (ឆ្នាំ២០២២ ប៉ាន់ស្មាន)÷ តម្លៃបច្ចុប្បន្ននៃបំណុលសារធារណៈសរុប ២៥,២% ធៀបនឹង ផ.ស.ស., តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈ ក្រៅប្រទេស ២៤,៩០% ធៀបនឹង ផ.ស.ស. និង ៣៣,៩០% ធៀបនឹងការនាំចេញ, សេវាបំណុលសាធារណៈក្រៅប្រទេស ២,១០% ធៀបនឹងការនាំចេញ និង ៧,៨% ធៀបនឹងចំណូលថវិកាជាតិ។ ដោយឡែក វឌ្ឍនភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ នៅមានកម្រិតនៅឡើយ ដែលត្រូវបន្តយកចិត្តទុកដាក់បន្ថែមទៀត។ កិច្ចការនេះនឹងត្រូវបានពង្រឹងជាបណ្តើរៗ តាមរយៈការដាក់ឱ្យអនុវត្តលក្ខណវិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងការដាក់ចេញនូវឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ ដែលឯកសារយុទ្ធសាស្ត្រនេះ រំពឹងថាអាចដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២៣។

**សន្និដ្ឋានជារួម÷** គណនេយ្យភាពហិរញ្ញវត្ថុត្រូវបានបន្តពង្រឹងជាបណ្តើរៗ តាមរយៈការពង្រឹងនិងពង្រីកការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS នៅគ្រប់ក្រសួង-ស្ថាប័ន, រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, និងគ្រប់រដ្ឋបាលរាជធានី-ខេត្ត ពិសេសការដាក់ឱ្យអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS និងការដាក់ឱ្យអនុវត្តនូវមុខងារលទ្ធកម្មពេញលេញ និងមុខងាររៀបចំថវិកាតាមក្រសួង-ស្ថាប័នជាជំហានៗ។ ទោះបីជាយ៉ាងនេះក្តី ការអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS ទាំងស្រុង ត្រូវបន្តជំរុញបន្ថែមទៀត ដែលកិច្ចការនេះតម្រូវឱ្យមានចូលរួមកាន់តែខ្លាំងឡើង និងការគាំទ្រទាំងកម្រិតបច្ចេកទេស និងនយោបាយពីគ្រប់ភាគីពាក់ព័ន្ធទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ និន្នាការនេះ ឬឌីជីថលូបនីយកម្ម តម្រូវឱ្យមានការគិតគូរអំពីហត្ថលេខាអេឡិចត្រូនិក និងគោលនយោបាយឌីជីថល។ ដោយឡែក ក៏ត្រូវយកចិត្តទុកដាក់បន្ថែមទៀតលើការបិទបញ្ជីគណនេយ្យទាន់ពេលវេលា ស្របតាមទិសដៅនៃការកែទម្រង់។ ខាងផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅមានកម្រិត ក្នុងនោះត្រូវបន្តយកចិត្តទុកដាក់លើគុណភាព និងភាពទាន់ពេលវេលានៃការរៀបចំបញ្ជីសារពើភណ្ឌ ដែលកិច្ចការនេះនឹងត្រូវបានពង្រឹងតាមរយៈការបន្តពង្រឹង និងពង្រីកការប្រើប្រាស់ប្រព័ន្ធ

SARMIS និងការដាក់ឱ្យអនុវត្ត ឯកសារគោលស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។ ចំណែកឯ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ត្រូវបន្តយកចិត្តទុកដាក់បន្ថែមទៀត តាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តក្របខ័ណ្ឌគតិយុត្តនានា។

*ផ្នែកទី៣ "ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"*÷ ការដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រកែទម្រង់គន្លឹះ និងក្របខ័ណ្ឌគតិយុត្តនានាក្នុងដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានតម្រង់ទិសដល់ការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ការពង្រឹង និងពង្រីកការដាក់ឱ្យអនុវត្តក្របខ័ណ្ឌថវិកាកម្មវិធីនៅគ្រប់ក្រសួង-ស្ថាប័ន (ឆ្នាំ២០១៥-២០១៨) និងគ្រប់រដ្ឋបាលរាជធានី-ខេត្ត (ឆ្នាំ២០១៧-២០២១) បានក្លាយជាឧបករណ៍សំខាន់ក្នុងការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេសបានកែប្រែការគ្រប់គ្រងថវិកាទាំងស្រុងពីការគ្រប់គ្រងលក្ខណៈមជ្ឈការមកវិមជ្ឈការតាមរយៈការបង្កើតឱ្យមានអង្គភាពថវិកា។ គិតត្រឹមឆ្នាំ២០២២ អង្គភាពថវិកាមានចំនួនសរុប ៩៤០ ដែលក្នុងនោះរដ្ឋបាលថ្នាក់កណ្ដាលមានចំនួន ៣៣៧ និងថ្នាក់មូលដ្ឋាន (មន្ទីរជំនាញរាជធានី-ខេត្ត) ចំនួន ៦០៣។ សម្រាប់ថ្នាក់កណ្ដាល មានអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ៨៧ និងផ្ទេរសិទ្ធិមិនពេញលេញចំនួន ២៥០ និងសម្រាប់ថ្នាក់មូលដ្ឋាន គ្រប់អង្គភាពថវិកាទាំងអស់ ត្រូវបានផ្ទេរសិទ្ធិជាអាណាប័កផ្ទេរសិទ្ធិពេញលេញ។ ទន្ទឹមនឹងនេះ ការរៀបចំផែនការយុទ្ធសាស្ត្រ និងថវិកាប្រចាំឆ្នាំមានវឌ្ឍនភាពល្អប្រសើរ ដោយក្នុងនោះ (ទី១) ក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ត្រូវបានអនុវត្តសាកល្បងចាប់ពីឆ្នាំ២០១៩ ដោយមានការកំណត់ពិតានចំណាយគោលតាមវិស័យ និងតាមក្រសួង-ស្ថាប័ន, (ទី២) គម្លាតរវាងពិតានចំណាយគោលដែលកំណត់ក្នុងសារាចរណែនាំ និងលទ្ធផលកញ្ចប់ថវិកាប្រចាំឆ្នាំទាបជាង ១០%, (ទី៣) គ្រប់ក្រសួង-ស្ថាប័នបានរៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយមានសូចនាករសមិទ្ធកម្មគន្លឹះ, និង (ទី៤) ការធ្វើសមាហរណកម្មថវិកាវិនិយោគត្រូវបានពង្រឹងនិងពង្រីកជាបណ្ដើរៗ និងសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិកានៅ រដ្ឋបាល រាជធានី ខេត្ត រវាងរដ្ឋបាលរាជធានី-ខេត្តជាមួយថវិកាក្រុង ស្រុក និងថវិកាឃុំ សង្កាត់ នៅគ្រប់រាជធានី-ខេត្ត ហើយការតម្រឹមផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិរវាងរដ្ឋបាលរាជធានី-ខេត្តជាមួយនឹងថវិកា មន្ទីរជំនាញ ក៏កំពុងមានវឌ្ឍនភាព ប៉ុន្តែគុណភាពនៅមានកម្រិតនៅឡើយ។

ទោះបីជាយ៉ាងនេះក្ដី ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) ២០២៣-២០២៥ ត្រូវបានរៀបចំជាសេចក្ដីព្រាង ប៉ុន្តែពុំទាន់បានអនុវត្តនៅឡើយ ដោយនៅបន្តអនុវត្តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ថវិកាឆ្នាំ២០២៣។ ដោយឡែក ចំពោះ ក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) ២០២៣-២០២៥ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ ប៉ុន្តែពុំទាន់ត្រូវបានដាក់ឱ្យអនុវត្តនៅឡើយ។ ការដាក់ឱ្យអនុវត្ត MTBF នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងជួយពង្រឹងដំណើរការនៃការរៀបចំគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី-ខេត្ត។

**សន្និដ្ឋានជារួម**÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ត្រូវបានបន្តពង្រឹងជាបន្តបន្ទាប់ តាមរយៈការដាក់ឱ្យអនុវត្តក្របខ័ណ្ឌថវិកាកម្មវិធីពេញលេញ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទោះបីជាយ៉ាងនេះក្ដី ការបន្តពង្រឹងគុណភាពនៃការរៀបចំកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកា ត្រូវបន្តយកចិត្តទុកដាក់ តាមរយៈការរៀបចំនិងដាក់ឱ្យអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យមឱ្យបានពេញលេញ។ ខណៈប្រព័ន្ធ

ថវិកាកម្ពុជាបាននិងកំពុងឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ដែលសិទ្ធិអំណាច និងថវិកានឹងត្រូវផ្ទេរវិមជ្ឈការទៅអង្គភាពអនុវត្តផ្ទាល់កាន់តែច្រើន, ការបង្កើនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញគួរត្រូវបន្តជំរុញបន្ថែមទៀត។ បន្ថែមពីនេះ ការធ្វើសមាហរណកម្មរវាងចំណាយថវិកាមូលធន និងថវិកាចរន្ត ព្រមទាំង គុណភាពផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ត្រូវបន្តយកចិត្តទុកដាក់បន្ថែមទៀតក្នុងដំណាក់កាលបន្ទាប់។

*ផ្នែកទី៤ "ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម"÷* បុរេលក្ខខណ្ឌសំខាន់ៗនៃការឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្មត្រូវបានរៀបចំ និងឈានទៅបញ្ចប់ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០២៣។ ក្នុងនោះ សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ត្រូវបានពិនិត្យ និងសម្រេចដោយគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២៣ និងបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣។ រីឯការកែសម្រួលអនុក្រឹត្យលេខ ៨១ អនក្រ.បក និងអនុក្រឹត្យលេខ៨២ អនក្រ.បក ត្រូវបានដាក់បញ្ចូលគ្នា និងកំណត់ឈ្មោះថ្មីជាសេចក្តីព្រាងអនុក្រឹត្យស្តីពី "ការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ" ដែលរំពឹងថានឹងត្រូវបញ្ចប់នៅក្នុងកំឡុងឆមាសទី១ ឆ្នាំ២០២៣នេះផងដែរ។ ទន្ទឹមនេះ កិច្ចព្រមព្រៀងសមិទ្ធកម្មក្នុងឆ្នាំរវាង កសហវ. និងក្រសួង-ស្ថាប័នចំនួន ៧ ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងសម្រាប់ថវិកាឆ្នាំ២០២៣។ ការដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម គឺជាចំណុចចាប់ផ្តើមនៃការឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម។ ដោយឡែក ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ និងមុខងារសវនកម្មផ្ទៃក្នុងដែលផ្តោតលើសវនកម្មសមិទ្ធកម្ម និងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងមុខងារអធិការកិច្ចនៅគ្រប់ក្រសួង-ស្ថាប័ន ត្រូវពង្រឹងបន្ថែមជាបណ្តើរៗ តាមរយៈការដាក់ឱ្យអនុវត្តក្របខ័ណ្ឌគតិយុត្ត និងគោលការណ៍ណែនាំនានា។ ចាប់ពីឆ្នាំ២០២០ ការកសាងសមត្ថភាពដល់មន្ត្រីនៃអង្គភាពពាក់ព័ន្ធត្រូវបានអនុវត្ត ហើយការធ្វើសវនកម្មសមិទ្ធកម្ម និងបច្ចេកវិទ្យាព័ត៌មានត្រូវបានសាកល្បងអនុវត្តនៅតាមក្រសួង-ស្ថាប័នមួយចំនួន និងបានសាកល្បងរៀបចំជារបាយការណ៍សវនកម្មសមិទ្ធកម្ម។

**សន្និដ្ឋានជារួម÷** ការឈានទៅអនុវត្តដំណាក់កាលទី៤ ត្រូវបានត្រៀមខ្លួនរួចរាល់ចាប់ពីឆ្នាំ២០២៣ តទៅ តាមរយៈការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ(ថ្មី) និង សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ ដែលនឹងត្រូវចូលជាធរមាននៅក្នុងកំឡុងឆមាសទី១ ឆ្នាំ២០២៣។ ក្របខ័ណ្ឌតាមដាននិងវាយ-តម្លៃ និងមុខងារសវនកម្មផ្ទៃក្នុងដែលផ្តោតលើសវនកម្មសមិទ្ធកម្ម និងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងមុខងារអធិការកិច្ចនៅគ្រប់ក្រសួង-ស្ថាប័ន ត្រូវពង្រឹងបន្ថែមជាបណ្តើរៗ ដើម្បីធានាថាក្រសួង ស្ថាប័នមានប្រព័ន្ធត្រួតពិនិត្យតាមដានរឹងមាំស្របពេលរាជរដ្ឋាភិបាលបាននិងកំពុងផ្ទេរវិមជ្ឈការហិរញ្ញវត្ថុដល់ក្រសួង-ស្ថាប័ន កាន់តែច្រើន។ ទោះជាយ៉ាងនេះក្តីមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចនៅបន្តស្ហួននៅឡើយ។ ក្នុងន័យនេះ ត្រូវបញ្ចប់ការរៀបចំ និងដាក់ឱ្យអនុវត្តក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច។

*ផ្នែកទី៥ "ការកែទម្រង់ប្រកបដោយចីរភាពនិងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត"÷* កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅរក្សាបានចលនការ ទោះបីស្ថិតក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ ក្នុងរយៈពេលជិត ៣ឆ្នាំមកនេះ។ ក្នុងនោះ ការចូលរួមអនុវត្តការងារកែទម្រង់កាន់តែមានភាពសកម្ម ដែលឆ្លុះបញ្ចាំងតាមរយៈការរៀបចំផែនការសកម្មភាពលម្អិត (GDAP3/PDAP3/MAP3) និងរបាយការណ៍អំពីវឌ្ឍនភាពជាប្រចាំ។ នេះបានបង្ហាញអំពីឆន្ទៈការចូលរួម និងការទទួលខុសត្រូវក្នុងការងារកែទម្រង់។ ម្យ៉ាងវិញទៀត ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្ត យន្តការត្រួតពិនិត្យនិងវាយតម្លៃ និងការលើកទឹកចិត្ត ត្រូវបានពិនិត្យ រៀបចំ និងកែលម្អបន្ថែមទៀត ក្នុងនោះ

(ទី១) សម្រួចលក្ខខណ្ឌយោងការងារនៃក្រុមការងារកែទម្រង់នៅតាមអង្គភាពនីមួយៗ, (ទី២) រៀបចំជាសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងផ្អែកលើលទ្ធផល, (ទី៣) រៀបចំនិងគ្រោងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មនិងគណនេយ្យភាព (PMAS)ដល់គ្រប់អង្គភាព, និង (ទី៤) រៀបចំនិងគ្រោងដាក់ឱ្យអនុវត្តមូលនិធិគ្រប់ជ្រុងជ្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ម្យ៉ាងវិញទៀត តាមរយៈការអនុវត្តផែនការសកម្មភាពអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមត្ថភាពជំនាញពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រឹងជាបណ្តើរៗ និងកាន់តែល្អប្រសើរឡើងថែមទៀតនៅពេលដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីវិញ្ញាបនបត្រ។ ដោយឡែក ការងារកែទម្រង់ប្រទាក់ក្រឡាត្រូវបានពង្រឹង តាមរយៈការដាក់ឱ្យអនុវត្តឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ និងយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១។

**សន្និដ្ឋានជារួម÷** ចលនការនៃការកែទម្រង់ត្រូវបានបន្តចីរភាព ដែលឆ្លុះបញ្ចាំងតាមរយៈការចូលរួមអនុវត្តកម្មវិធីកែទម្រង់ពីគ្រប់តួអង្គដែលមានការពាក់ព័ន្ធ។ ការងារកែទម្រង់ប្រទាក់ក្រឡា ត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ និងយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១។ ទោះជាយ៉ាងនេះក្តី ការចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹង PFMRP ដំណាក់កាលទី៤ ផ្តោតលើការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្មសម្រាប់ស្ថាប័ននីតិប្បញ្ញត្តិ នៅពុំទាន់បានរៀបចំនៅឡើយ។ ចលនការឈានឆ្ពោះទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម នឹងតម្រូវឱ្យស្ថាប័ននីតិប្បញ្ញត្តិ ផ្តោតលើព័ត៌មានសមិទ្ធកម្មច្រើនជាងការអនុវត្តបច្ចុប្បន្ន។ ដោយឡែក តួនាទីមន្ត្រីរាជការនឹងត្រូវបានរៀបចំកាន់តែច្បាស់ តាមរយៈការដាក់ឱ្យអនុវត្តសេចក្តីណែនាំស្តីពីការពិពណ៌នាមុខដំណែង។ បន្ថែមពីនេះ សមត្ថភាពជំនាញពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីវិញ្ញាបនបត្រ។

## ១. សេចក្តីផ្តើម

### ១.១. សាវតារ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីកែទម្រង់ស្នូលមួយនៃកម្មវិធីកែទម្រង់សំខាន់ៗ របស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីឈានឆ្ពោះទៅពង្រឹងអភិបាលកិច្ច ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានចក្ខុវិស័យប្រកបដោយមហិច្ឆិតា និង ប្រាកដនិយមក្នុងការកសាង***"ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យស្របតាមស្តង់ដា និងឧត្តមានុវត្តន៍អន្តរជាតិ ដោយផ្លាស់ប្តូរប្រព័ន្ធថវិកាដែលផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការឆ្ពោះទៅជាប្រព័ន្ធដែលផ្តោតលើធាតុចេញ ឬ លទ្ធផល និងវិមជ្ឈការ"***។ វិសាលភាពនៃការកែទម្រង់នេះ គឺគ្របដណ្តប់លើដំណាក់កាលសំខាន់ៗនៃវដ្តថវិការួមមាន ការរៀបចំថវិកា, ការអនុម័តថវិកា, ការអនុវត្តថវិកា និងការត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផល ដែលនឹងនាំឱ្យមានបច្ច័យមកលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាឱ្យកាន់តែរឹងមាំ ដែលឈានទៅសម្រេចបានលទ្ធផលចុងក្រោយទាំង ៣ នៃមុខងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល រួមមាន *(១) បូរណភាពនៃការគោរពវិន័យថវិកា, (២) ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍ និងផ្នែកប្រតិបត្តិការ,* និង *(៣) ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ*។ ដើម្បីសម្រេចបានទស្សនវិស័យខាងលើ ការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ផ្តោតលើការធ្វើទំនើបកម្មប្រព័ន្ធ និងការកែទម្រង់លើសមាសធាតុស្នូលសំខាន់ៗនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈ*ការកសាង និងកែលម្អប្រព័ន្ធ, ក្របខ័ណ្ឌគតិយុត្ត, ស្ថាប័ននីយកម្ម និងធនធានមនុស្ស*។

រាជរដ្ឋាភិបាលបានប្រកាន់យកនូវ ***"អភិក្រមជាខឿន ឬជាដំណាក់កាល"*** ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយចែកចេញជា ៤ ដំណាក់កាល រួមមាន ÷

- ដំណាក់កាលទី១ "**ភាពជឿទុកចិត្តនៃថវិកា**" ឆ្នាំ២០០៤-ឆ្នាំ២០០៨
- ដំណាក់កាលទី២ "**គណនេយ្យភាពហិរញ្ញវត្ថុ**" ឆ្នាំ២០០៩-ឆ្នាំ២០១៥
- ដំណាក់កាលទី៣ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" ឆ្នាំ២០១៦-ឆ្នាំ២០២២ និង
- ដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" ឆ្នាំ២០២៣-២០២៧។

ក្រោមភាពជាម្ចាស់និងភាពដឹកនាំរបស់រាជរដ្ឋាភិបាល, ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រេចបានជាសារវន្តនូវដំណាក់កាលទី១ និងដំណាក់កាលទី២ ដោយកសាងបាននូវខឿននៃ "ភាពជឿទុកចិត្តនៃថវិកា" និងខឿននៃ "គណនេយ្យភាពហិរញ្ញវត្ថុ" ទន្ទឹមនឹងបានកសាងបាននូវខឿនទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ក៏ដូចជាសម្រេចបានជាបណ្តើរៗនូវបុរេលក្ខខណ្ឌសម្រាប់ឈានទៅអនុវត្តខឿនទី៤ គឺ "គណនេយ្យភាពសមិទ្ធកម្ម"។ ក្នុងដំណាក់កាលទី៣ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្តោតលើការឈានទៅអនុវត្តជាបណ្តើរៗនូវប្រព័ន្ធគ្រប់គ្រងដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ តាមរយៈការពង្រឹង និងពង្រីកការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការអនុវត្តថវិកាកម្មវិធី និងការអនុវត្តអង្គភាពថវិកា រួមទាំងការពង្រឹងសមិទ្ធផលដែលសម្រេច

បានក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២កន្លងទៅ។ ផ្អែកលើការវាយតម្លៃការអនុវត្តដំណាក់កាលទី៣ ឆ្នាំ២០១៦-២០២០, រាជរដ្ឋាភិបាលបានសម្រេចពន្យារការអនុវត្តរយៈពេល ២ឆ្នាំ ២០២១-២០២២ ដើម្បីបន្តពង្រឹងមូលដ្ឋានគ្រឹះនៃការកែទម្រង់ក្នុងខឿនទាំងបី មុននឹងឈានទៅខឿនទី៤ ដែលជាដំណាក់កាលចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដំណាក់កាលអន្តរកាលឆ្ពោះទៅដំណាក់កាលទី៤ នេះ មានគោលដៅសំខាន់ឆ្ពោះទៅកសាងនូវបុរេលក្ខខណ្ឌចាំបាច់ទាំងឡាយ ដើម្បីឈានទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ដែលជាគន្លឹះក្នុងការកសាង “**វប្បធម៌សមិទ្ធកម្ម**” ក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូល។ ក្នុងរយៈពេលអន្តរកាលនេះ ផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២ ឆ្នាំ២០២១-២០២២ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដោយរក្សាអភិក្រមជាខឿន និងបែងចែកជា ៥ផ្នែក មានគោលបំណងសរុបចំនួន ១៩ ដោយមានចង្កោមសកម្មភាពចំនួន ៥៨ ដូចមានបង្ហាញលម្អិតក្នុងតារាងទី១។

តារាងទី 1 ÷ រចនាសម្ព័ន្ធផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២ ឆ្នាំ២០២១-២០២២

| ផ្នែក | គោលបំណង | | ចង្កោមសកម្មភាព | |
|---|---|---|---|---|
| | ចំនួន | សូចនាករ | ចំនួន | សូចនាករ |
| ផ្នែកទី ១ | ៣ | ៧ | ៨ | ២៣ |
| ផ្នែកទី ២ | ៥ | ១១ | ១៥ | ២៦ |
| ផ្នែកទី ៣ | ៤ | ១០ | ១៦ | ២៩ |
| ផ្នែកទី ៤ | ៤ | ៨ | ១២ | ១៧ |
| ផ្នែកទី ៥ | ៣ | ៨ | ៨ | ១៨ |
| **សរុប** | **១៩** | **៤៤** | **៥៩** | **១១៣** |

## ១.២. គោលបំណង

របាយការណ៍វាយតម្លៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២ ឆ្នាំ២០២១-២០២២ ត្រូវបានរៀបចំឡើងក្នុងគោលបំណងបូកសរុបវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរយៈពេល ២ឆ្នាំ ២០២១-២០២២ និងវាយតម្លៃលើការសម្រេចបានតាមខឿន និងគោលបំណងនីមួយៗ ពិសេស ការសម្រេចបាននូវបុរេលក្ខខណ្ឌសំខាន់ៗសម្រាប់ឈានទៅអនុវត្តដំណាក់កាលទី៤ “**គណនេយ្យភាពសមិទ្ធកម្ម**”។ ក្នុងន័យនេះ របាយការណ៍វាយតម្លៃនេះ ផ្តល់ព័ត៌មានជាមូលដ្ឋានជូន **គ.ម.ស.** ដើម្បីធ្វើសេចក្តីសម្រេចចិត្តលើការឈានទៅអនុវត្តដំណាក់កាលទី៤ និងជាធាតុចូលសំខាន់សម្រាប់រៀបចំក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៤ និងកិច្ចការងារសេសសល់ដែលត្រូវបន្តយកចិត្តទុកដាក់ ដើម្បីធានាថា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ថិតលើវិថីកែទម្រង់ដ៏ត្រឹមត្រូវ និងអាចបោះជំហានឈានទៅដំណាក់កាលទី៤ ប្រកបដោយជវភាព និងគណនេយ្យភាព។

## ១.៣. វិធីសាស្ត្រវាយតម្លៃ

របាយការណ៍វាយតម្លៃនេះ ត្រូវបានរៀបចំ ដោយធ្វើការវាយតម្លៃលើការសម្រេចបាននៃខឿននីមួយៗនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយធ្វើការវាយតម្លៃការអនុវត្តតាមផ្នែក និងគោលបំណងនីមួយៗ នៃផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២ ដែលបានដាក់ចេញ ដោយផ្អែកតាមវិធីសាស្ត្ររៀបចំ ដូចខាងក្រោម÷

- ការពិនិត្យលើវឌ្ឍនភាព និងសមិទ្ធកម្មនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ ២០២១ និងប្រចាំឆ្នាំ២០២២ ដោយផ្ទៀងផ្ទាត់វឌ្ឍនភាពនៃការអនុវត្តតាមចង្កោមសកម្មភាព និងវាយតម្លៃការសម្រេចបានសូចនាករនៅកម្រិតផ្នែក និងគោលបំណងនៃផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២។
- ការប្រមូលធាតុចូលបន្ថែមពីអង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន តាមរយៈការស្នើសុំផ្តល់វឌ្ឍនភាព, បញ្ហាប្រឈម, វិធានការអនុវត្តបន្ត និងការគ្រប់គ្រងហានិភ័យ ពាក់ព័ន្ធសមាសធាតុសំខាន់ៗនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- ការពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការវាយតម្លៃជាមួយមតិយោបល់ និងរបាយការណ៍វាយតម្លៃផ្សេងៗរបស់ដៃគូអភិវឌ្ឍន៍ ដោយមានការសម្របសម្រួលពី **អ.គ.ហ.** រួមមាន÷ ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS), ការវាយតម្លៃថវិកាយេនឌ័រ, និងការវាយតម្លៃចំណាយសាធារណៈដោយផ្តោតលើការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, វិស័យកសិកម្ម, វិស័យធារាសាស្ត្រនិងឧតុនិយម, វិស័យសុខាភិបាល និងរដ្ឋបាលខេត្តព្រះសីហនុ។

តាមរយៈការប្រើប្រាស់វិធីសាស្ត្រខាងលើ, របាយការណ៍នេះ បានឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក២ ឆ្នាំ២០២១-២០២២ និងការវាយតម្លៃអំពីប្រសិទ្ធភាពប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាបច្ច័យនៃការអនុវត្តការកែទម្រង់កន្លងមក ថាតើមានភាពរឹងមាំ និងការត្រៀមខ្លួនរួចរាល់សម្រាប់បោះជំហានឈានទៅដំណាក់កាលទី៤ ប្រកបដោយជវភាព និងគណនេយ្យភាព។

## ១.៤. ការខារបន្តក្នុងដំណាក់កាលទី៣ បូក ២

ក្នុងឆ្នាំ២០២១ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) បានធ្វើការវាយតម្លៃការអនុវត្តដំណាក់កាលទី៣ ឆ្នាំ២០១៦-២០២០ ដើម្បីពិនិត្យលទ្ធភាពនៃការឈានទៅអនុវត្តដំណាក់កាលទី៤។ តាមការវាយតម្លៃអំពីការអនុវត្តនៃដំណាក់កាលទី៣ បានបង្ហាញថា ខឿនទី១ ស្តីពីការបង្កើនភាពជឿទុកចិត្តនៃថវិកា រក្សាបាននូវភាពរឹងមាំ, ខឿនទី២ ស្តីពីការពង្រឹង និងពង្រីកគណនេយ្យភាពហិរញ្ញវត្ថុ បន្តមានវឌ្ឍនភាពល្អ, ខឿនទី៣ ស្តីពីការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ បានសម្រេចជាសារវ័ន្ត និងខឿនទី៤ ស្តីពីការត្រៀមខ្លួនឆ្ពោះទៅកាន់គណនេយ្យភាពសមិទ្ធកម្ម នៅមិនទាន់សម្រេចបានតាមការគ្រោងទុកនៅឡើយ។ ក្នុងបរិការណ៍នៃការចាប់ផ្តើមរីករាលដាលជំងឺកូវីដ-១៩ លើសកលលោកដែលបានផ្តើមឱ្យមានបច្ច័យអវិជ្ជមានលើសេដ្ឋកិច្ច និងផ្អែកលើលទ្ធផលនៃការវាយតម្លៃបុរេលក្ខខណ្ឌសំខាន់ៗ សម្រាប់ឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម **គ.ហ.ស.** បានសម្រេចពន្យារការអនុវត្តដំណាក់កាលទី៣ រយៈពេល ២ឆ្នាំ ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២២ ដើម្បីបន្តអនុវត្តឱ្យសម្រេចបានការងារសេសសល់ក្នុងដំណាក់កាលទី៣ និងបុរេលក្ខខណ្ឌចាំចាច់សម្រាប់ជាមូលដ្ឋានឈានទៅការអនុវត្តដំណាក់កាលទី៤។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃខាងលើ ផែនការសកម្មភាពរួម ដំណាក់កាលទី ៣ បូក ២ ឆ្នាំ ២០២១-២០២២ ត្រូវរៀបចំដោយសម្រួចលើចំណុចផ្តោតនៃខឿននីមួយៗ ដូចខាងក្រោម÷

- ***ខឿនទី ១*** "បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា" ដោយផ្តោតលើ÷ (ទី១) ការធ្វើពិពិធកម្មប្រភពចំណូលនៅក្នុងបរិការណ៍កូវីដ-១៩ ដែលមានបច្ច័យលើផ្នែកចំណូល, (ទី២) ការពន្លឿននីតិវិធីចំណាយ និងការទូទាត់, និង (ទី៣) ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ។
- ***ខឿនទី ២*** "បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ" ដោយផ្តោតលើ÷ (ទី១) អនុវត្តពេញលេញនូវចំណាត់ថ្នាក់នៃមាតិកាថវិកា និងពង្រីកការប្រើប្រាស់ប្លង់គណនេយ្យ, (ទី២) បន្តជំរុញការប្រើប្រាស់ប្រព័ន្ធ FMIS ក្នុងនោះមានការដោះស្រាយបញ្ហាបច្ចេកទេសក្នុងការអនុវត្តប្រព័ន្ធ FMIS ដែលមានស្រាប់, ការបន្តធ្វើសន្ទានកម្មជាមួយនឹងប្រព័ន្ធផ្សេងទៀត, ការពង្រឹងមុខងារបន្ថែមនៃប្រព័ន្ធ និងការជំរុញការប្រើប្រាស់ប្រព័ន្ធ FMIS សម្រាប់ផលិតរបាយការណ៍, (ទី៣) បន្តពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ, និង (ទី៤) ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។
- ***ខឿនទី ៣*** "បន្តពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" រួមមាន÷ (ទី១) ដាក់ឱ្យអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ និងក្របខ័ណ្ឌថវិការយៈពេលមធ្យម, (ទី២) ពង្រឹងគុណភាពនៃថវិកាកម្មវិធីតាមរយៈការពង្រឹងគុណភាពសូចនាករ, ការពង្រឹងការគ្រប់គ្រងកម្មវិធី, ការរៀបចំអង្គភាពថវិកានៅថ្នាក់កណ្តាល, និងសមាហរណកម្មថវិកាចរន្ត និងវិនិយោគ, និង (ទី៣) ធ្វើសមាហរណកម្មនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាទៅនឹងថវិកាកម្មវិធី ។
- ***ខឿនទី ៤*** ការត្រៀមខ្លួនឈានឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម រួមមាន÷(ទី១) ដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម, ក្របខ័ណ្ឌតាមដាន និងពិនិត្យការអនុវត្តថវិកា, និងទម្រង់របាយការណ៍អនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម, (ទី២) បញ្ចប់ការរៀបចំច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី និងអនុក្រឹត្យ ៨១ និង ៨២ (ថ្មី), (ទី៣) បញ្ចប់គោលការណ៍ណែនាំសវនកម្មសមិទ្ធកម្ម និងគោលការណ៍ណែនាំសវនកម្មបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងចាប់ផ្តើមអនុវត្តសាកល្បងធ្វើសវនកម្មផ្អែកលើសមិទ្ធកម្ម និងបច្ចេកវិទ្យាព័ត៌មាន, និង (ទី៤) អនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ដំណាក់កាលទី ៤។
- ***ខឿនទី ៥*** ដោយផ្តោតលើ÷ (ទី១) បន្តចីរភាពនៃការកែទម្រង់ តាមរយៈការកៀរគរធនធានដើម្បីអនុវត្តសកម្មភាពកែទម្រង់ ជំរុញការចូលរួម និងការតាមដានវឌ្ឍនភាពនៅក្នុងគ្រប់ស្ថានភាព, និង (ទី២) កំណត់ឱ្យបាននូវក្របខ័ណ្ឌប្រទាក់ក្រឡារវាងការដ្ឋាននៃការកែទម្រង់ផ្សេងទៀត ដើម្បីធានាការបោះជំហានស្របគ្នា ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

## ២. ការវាយតម្លៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២

### ២.១. សង្ខេបវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់អង្គភាព

អង្គភាពអនុវត្តគម្រោងក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន អង្គភាពក្រោមឱវាទ កសហវ., ក្រសួង-ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត បានរៀបចំផែនការសកម្មភាពលម្អិត ដើម្បីចូលរួមអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២។ ផ្អែកលើរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ, ជារួម ការអនុវត្តរបស់អង្គភាពសម្រេចបានវឌ្ឍនភាពប្រមាណ ៨៥% ធៀបនឹងផែនការ។

ដ្យាក្រាមទី 1 ៖វឌ្ឍនភាពនៃការអនុវត្ត GDAP/MAP/PDAP តាមអង្គភាព ឆ្នាំ២០២១-២០២២




### ២.២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២

#### ផ្នែកទី១៖ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា

ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកាផ្តោតលើគោលបំណងចំនួន ៣ គឺ៖ (១) បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល, (២) ពង្រឹងការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ, និង (៣) កែលម្អដំណើរការនៃការអនុវត្តថវិកា។

*គោលបំណង ១១៖ បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល*

តាមរយៈការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលឆ្នាំ២០១៩-២០២៣ ការប្រមូលចំណូលនៅរក្សាបានភាពរឹងមាំ ក្នុងនោះ ចំណូលចរន្តមានកំណើនជាមធ្យមប្រមាណ ០,៦៤ ពិន្ទុភាគរយ នៃ ផ.ស.ស. ក្នុងមួយឆ្នាំ ខ្ពស់ជាងគោលដៅ ០,៣ ពិន្ទុភាគរយ នៃ ផ.ស.ស. ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រគៀរគរចំណូលឆ្នាំ២០១៩-២០២៣។ ក្នុងនោះ រដ្ឋបាលប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ត្រូវបានធ្វើទំនើបភាវូបនីយកម្ម ដែលបានធានាឱ្យការប្រមូលចំណូលកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់ ដែលបានផ្តល់ជាបច្ច័យដល់ការជំរុញមានកំណើននៃចំណូលថវិកាយ៉ាងឆាប់រហ័ស បន្ទាប់ពីមានការថមថយនៃការរីករាលដាលជំងឺកូវីដ-១៩។

ដ្យាក្រាមទី 2 ៖ ចំណូលថវិការដ្ឋ (ចំណូលចរន្ត + ចំណូលមូលធន) និងកំណើនចំណូលចរន្តឆ្នាំ២០១៣-២០២២




*ប្រភព៖ អគ្គនាយកដ្ឋានរតនាគារជាតិ (តួលេខឆ្នាំ២០២២ គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣)*

- **ចំណូលពន្ធដារ**

ការប្រមូលចំណូលពន្ធដារ សម្រេចបានលទ្ធផលល្អប្រសើរតាមរយៈការដាក់ចេញនូវវិធានការចម្បងៗក្នុងការពង្រឹងនិងគ្រប់គ្រងការប្រមូលចំណូលពន្ធអាករនានា រួមមាន ពន្ធលើប្រាក់ចំណូល, អាករលើតម្លៃបន្ថែម, អាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce), អាករពិសេស, អាករសម្រាប់បំភ្លឺសាធារណៈ, ពន្ធលើអចលនទ្រព្យ, របបលើកទឹកចិត្តពន្ធនៅក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម។ ក្នុងឆ្នាំ២០២២ ចំណូលពន្ធអាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន និងបង់ចូលថវិកាជាតិ មានចំនួន ១៣ ៥៨៩,២៨ ប៊ីលានរៀល (ប្រមាណជា ៣ ៣៥៥,៣៨ លានដុល្លារអាមេរិក) ស្មើនឹង ១១៩,០% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ និងមានការកើនឡើងចំនួន ២ ៤៣៣,០៥ ប៊ីលានរៀល (ប្រមាណ ៦០០,៧៦ លានដុល្លារអាមេរិក) ស្មើនឹង ២១,៨១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១។ លើសពីនេះ, សម្រាប់រយៈពេល ១២ខែ ក្នុងឆ្នាំ២០២២ ចំណូលពីប្រភេទពន្ធសំខាន់ៗរក្សាបានកំណើនធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ ក្នុងនោះពន្ធលើប្រាក់ចំណូល កើនឡើង ២៣,៨៨% ពន្ធលើប្រាក់បៀវត្ស កើនឡើង ២២,៧៦% អាករលើតម្លៃបន្ថែម កើនឡើង ២៤,៩១% អាករពិសេស កើនឡើង ២៦,២៦% និងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ កើនឡើង ១០,២៧%។

តារាងទី 2 ÷ ស្ថានភាពនៃការប្រមូលចំណូលពន្ធដារធៀបនឹងផែនការ




| បរិយាយ | 2018 | 2019 | 2020 | 2021 | 2022 |
|---|---|---|---|---|---|
| ផែនការ (ប៊ីលានរៀល) | 7,693.5 | 9,153.6 | 11,543.3 | 9,084.4 | 11,419.1 |
| អនុវត្ត(ប៊ីលានរៀល) | 8,791.7 | 11,279.2 | 11,608.8 | 11,156.2 | 13,589.3 |
| % ធៀបនឹងផែនការ | **114.27%** | **123.22%** | **100.57%** | **122.81%** | **119.00%** |

** សម្គាល់ ÷ តួលេខខាងលើជាតួលេខដែលបានរៀបចំបែបបទបង្វែរចូលថវិកាជាតិរួចរាល់*

ប្រភព÷ អគ្គនាយកដ្ឋានពន្ធដារ

ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ បូក ២ ឆ្នាំ ២០២១-២០២២ វិធានការប្រមូលពន្ធដារត្រូវបានអនុវត្តនិងសម្រេចបានតាមគោលដៅ ក្នុងនោះរួមមាន÷ (ទី១) អ្នកជាប់ពន្ធបង់ប្រាក់ពន្ធទាន់ពេលវេលាសម្រេចបាន ៨៨,៧០% នៃអ្នកជាប់ពន្ធសរុប, (ទី២) បណ្ដឹងតវ៉ានៃករណីកំណត់ពន្ធឡើងវិញចំនួន ១៦៤ ករណី ត្រូវបានដោះស្រាយ ស្មើនឹងប្រមាណ ៥៣,០៧% ធៀបនឹងបណ្ដឹងតវ៉ាសរុបចំនួន ៣០៩ ករណី, និង (ទី៣) បំណុលពន្ធដែលអាចប្រមូលបានក្នុងឆ្នាំ២០២១ មានចំនួន ៧ ២៥៩ ពាន់លានរៀល ហើយក្នុងឆ្នាំ២០២២ សម្រេចបានចំនួន ១ ០៧០ ពាន់លានរៀល ស្មើនឹងប្រមាណ ១៤,៧៤% នៃបំណុលពន្ធដែលអាចប្រមូលបានក្នុងឆ្នាំ២០២១។ ទន្ទឹមនេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារ ក៏ត្រូវបានកែសម្រួល រួមមាន÷ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស, ប្រព័ន្ធគ្រប់គ្រងទទួលប្រាក់ពន្ធ, ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីសហគ្រាស, ប្រព័ន្ធគ្រប់គ្រងសវនកម្មសហគ្រាស, ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ និងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ។ បន្ថែមពីនេះ, ក្នុងក្របខ័ណ្ឌនៃការពង្រីកមូលដ្ឋានពន្ធ, សេចក្ដីព្រាងក្របខ័ណ្ឌគោលនយោបាយសម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គលត្រូវបានរៀបចំនិងដាក់ជូនថ្នាក់ដឹកនាំ ពិនិត្យ និងសម្រេច។

- **ចំណូលពន្ធគយ**

ការអនុវត្តការប្រមូលចំណូលពន្ធគយប្រមូលក្នុងឆ្នាំ២០២២ សម្រេចបានចំនួន ១០ ៩៩៨,៩ ប៊ីលានរៀល ស្មើនឹង ១០៤,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ដែលកើនឡើងប្រមាណ ១៨,៣% ធៀបនឹងចំណូលដែលប្រមូលបានក្នុងឆ្នាំ២០២១។

ដ្យាក្រាមទី 3 ÷ ចំណូលពន្ធអាករគយធៀបនឹងផែនការ ឆ្នាំ២០១៨-២០២២




*ប្រភព÷ របាយការណ៍បូកសរុបលទ្ធផលការងាររបស់អគ្គ.គយនិងរដ្ឋាករកម្ពុជាប្រចាំឆ្នាំ២០២២ (ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៣)*

ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣បូក២ ឆ្នាំ២០២១-២០២២ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានសម្រេចគួរឱ្យកត់សម្គាល់រួមមាន÷ ការបង្កើនសមាជិកក្រុមធុរជនល្អបំផុតក្នុងឆ្នាំ២០២១ មានចំនួន ៣ និងឆ្នាំ២០២២ មានចំនួន ៦។ ទន្ទឹមនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលរួមអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិដំណាក់កាលទី២ ខណៈគម្រោងប្រព័ន្ធបញ្ជរតែមួយជាតិ ដំណាក់កាលទី៣ ត្រូវបានរៀបចំរួចរាល់ និងបានប្រកាសដាក់ឱ្យអនុវត្តនៅខែមករា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ដោយពង្រីកវិសាលភាពទៅកាន់ក្រសួង-ស្ថាប័នចំនួន ៩ បន្ថែមទៀត រួមមាន÷ ក្រសួងមហាផ្ទៃ, ក្រសួងការពារជាតិ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងបរិស្ថាន, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្រសួងរ៉ែ និងថាមពល, ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, និង ធនាគារជាតិនៃកម្ពុជា។ បន្ថែមពីនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សម្រេចបានវឌ្ឍនភាពលើការងារផ្សេងៗទៀត ដូចជា÷ (១) ការពង្រឹងការងារបច្ចេកទេសនិងការអនុវត្តច្បាប់, (២) ការងារបង្ការនិងបង្ក្រាបអំពើរត់គេចពន្ធ, (៣) ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម, (៤) ការងារសវនកម្មនិងការគ្រប់គ្រងហានិភ័យ, (៥) ការលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការធ្វើទំនើបកម្ម និងសាមញ្ញកម្មនីតិវិធីគយ, (៦) ការធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ, និង (៧) ការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន។

- **ចំណូលមិនមែនសារពើពន្ធ**

បច្ចុប្បន្ន ចំណូលមិនមែនសារពើពន្ធ នៅមានទំហំតូចបើធៀបនឹងចំណូលសារពើពន្ធ ប៉ុន្តែចំណូលនេះនៅមានសក្ដានុពលទូលំទូលាយក្នុងការចូលរួមដល់ចំណូលជាតិទាំងមូល។ ចំណូលមិនមែនសារពើពន្ធមានលក្ខណៈពិសេសទៅតាមប្រភេទនីមួយៗ ដែលតម្រូវឱ្យមានយន្តការគ្រប់គ្រង ការបែងចែកតួនាទី និងនីតិវិធីគ្រប់គ្រងច្បាស់លាស់។ ក្នុងក្របខ័ណ្ឌនៃផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២, ការកសាងក្របខ័ណ្ឌគតិយុត្ត និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ពង្រឹងការប្រមូលនិងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។

***ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)*** ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់អង្គភាពប្រមូលចំណូលនៅរដ្ឋបាលថ្នាក់ជាតិចំនួន ២៣ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្ត

ព្រមទាំងអង្គភាពប្រមូលចំណូលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយនឹងពង្រីកការអនុវត្តដំណាក់កាលទី២ ជំហានទី៣ ដល់រដ្ឋបាលឃុំ សង្កាត់ក្នុងឆ្នាំ២០២៣។ ប្រព័ន្ធនេះក៏ត្រូវបានធ្វើសន្ទានកម្មជាមួយប្រព័ន្ធ FMIS ជាផ្លូវការនៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០២០។ បន្ថែមពីនេះ, ក្នុងពេលថ្មីៗនេះ ប្រព័ន្ធ NRMIS ក៏បានដាក់ឱ្យធ្វើសន្ទានកម្មជាមួយប្រព័ន្ធគ្រប់គ្រងចំណូលនៅច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីជាយ៉ាងនេះក្តី, ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ NRMIS នៅក្នុងដំណាក់កាលទី២ ជំហានទី១ ដល់រដ្ឋបាលរាជធានី-ខេត្ត សម្រាប់ការប្រមូលចំណូលនៅអង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្តអនុវត្តបានតែរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខេត្តកំពង់ចាមតែប៉ុណ្ណោះ ដោយឡែក រដ្ឋបាលខេត្ត ២៣ ទៀត នៅពុំទាន់អាចអនុវត្តបាននៅឡើយ ដោយបញ្ហាទិន្នន័យនៅមិនទាន់ត្រឹមត្រូវ និងផ្ទៀងផ្ទាត់គ្នាបាននៅឡើយ។

*ប្រព័ន្ធ E-payment* ត្រូវបានពង្រីកការអនុវត្តដល់ក្រសួង-ស្ថាប័នជាបន្តបន្ទាប់ ដែលបច្ចុប្បន្ន មានក្រសួង-ស្ថាប័នចំនួន ២៣ បានប្រើប្រាស់ប្រព័ន្ធនេះសម្រាប់ការទូទាត់តាមអេឡិចត្រូនិកលើការបង់ចំណូលមិនមែនសារពើពន្ធ។

តារាងទី 3 ÷ ការដាក់ឱ្យអនុវត្តប្រព័ន្ធ E-Payment តាមដំណាក់កាល

| **ក. ដំណាក់កាលទី១** | **ខ. ដំណាក់កាលទី២** | **គ. ដំណាក់កាលទី៣** |
|---|---|---|
| ១. កសហវ.<br>២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>៣. ក្រសួងរៀបចំដែនដី និងនគរូបនីយកម្ម | ១. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>២. ក្រសួងសាធារណការ និងដឹកជញ្ជូន<br>៣. ក្រសួងអប់រំ យុវជន និងកីឡា<br>៤. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>៥. ក្រសួងបរិស្ថាន<br>៦. ក្រសួងទេសចរណ៍<br>៧. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>៨. ក្រសួងរ៉ែ និងថាមពល<br>៩. ក្រសួងពាណិជ្ជកម្ម<br>១០. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ | ១. ក្រសួងព្រះបរមរាជវាំង<br>២. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល<br>៣. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>៤. ក្រសួងការពារជាតិ<br>៥. ក្រសួងមហាផ្ទៃ<br>៦. ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ<br>៧. ក្រសួងព័ត៌មាន<br>៨. ក្រសួងសុខាភិបាល<br>៩. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>១០. ក្រសួងយុត្តិធម៌ |

***ការរៀបចំបទដ្ឋានគតិយុត្តសម្រាប់ប្រមូលចំណូលមិនមែនសារពើពន្ធ÷*** ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធត្រូវបានដាក់ឱ្យអនុវត្តកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២។ ទន្ទឹមនឹងនេះ ឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបាននិងកំពុងរៀបចំ និងគ្រោងបញ្ចប់ក្នុងឆ្នាំ២០២៣។ ឯកសារគោលនេះដាក់ចេញនូវចក្ខុវិស័យ គោលបំណង គោលដៅ និងវិធានការជាក់លាក់សំខាន់ៗ ក្នុងការពង្រឹងប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាព ក្នុងការគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធ ដោយចែកចេញជាបីដំណាក់កាលគឺ÷ រយៈពេលខ្លី (២០២៣-២០២៤), រយៈពេលមធ្យម (២០២៥ - ២០៣០) និងរយៈពេលវែង (២០៣១ - ២០៣៥)។

សរុបមក ការគ្រប់គ្រង និងប្រមូលចំណូលមានភាពរឹងមាំ ពិសេសវឌ្ឍនភាពនៃការប្រមូលចំណូលក្នុងរយៈពេលជាង ៣ឆ្នាំ នៃវិបត្តិកូវីដ-១៩ បង្ហាញថា ប្រព័ន្ធគ្រប់គ្រងចំណូលដែលបានកសាងកន្លងមក មានភាពធន់នឹងវិបត្តិ។ ម្យ៉ាង

វិញទៀត ការធ្វើពិពិធកម្មចំណូលត្រូវបានគិតគូរជាបណ្តើរៗក្នុងដំណាក់កាលទី៣ ប្ញូក២ ក៏ប៉ុន្តែត្រូវបន្តយកចិត្តទុកដាក់ និងជំរុញបន្ថែមទៀតទន្ទឹមនឹងការបន្តពង្រឹងការប្រមូលចំណូលឱ្យកាន់តែមានប្រសិទ្ធភាព និងអស់សក្តានុពល។

## *គោលបំណង ១២÷ ពង្រឹងការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ*

ដោយសារលទ្ធភាពនៃការប្រមូលចំណូលមានការកើនឡើង រាជរដ្ឋាភិបាលមានលទ្ធភាពបង្កើនកញ្ចប់ថវិកាសម្រាប់អនុវត្តពីមួយឆ្នាំទៅមួយឆ្នាំ។ ក៏ប៉ុន្តែ វិហ្វូរនៃការអនុវត្តថវិកា ហាក់ពុំទាន់រលូននៅឡើយ ពោលគឺ÷ (ទី១)ការចំណាយតាមប្រភេទនៅទាបជាងគោលដៅសម្រាប់ប្រភេទចំណាយទំនិញ/សេវា និងមូលធន, និង (ទី២) ការចំណាយមាននិន្នាការបង្គរនៅត្រីមាសទី៣ និងត្រីមាសទី៤។ ជាក់ស្តែង បើពិនិត្យទិន្នន័យបណ្តោះអាសន្នត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២ ការអនុវត្តថវិការដ្ឋសរុបឆ្នាំ២០២១ សម្រេចបាន ២៧ ៤២៥ ០៥៧ លានរៀល ឬស្មើ ៩៥,៣៦% នៃច្បាប់ហិរញ្ញវត្ថុ (ប្រសិនបើធៀបនឹង ថវិកាបន្ទាប់ពីធ្វើវិចារណកម្មចំណាយការអនុវត្តថវិកាឆ្នាំ២០២១ សម្រេចបាន ៩៨,៧៩%)។ ការចំណាយប្រចាំត្រីមាស មានភាពយឺតជាងគោលដៅ ដែលបានកំណត់ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គោលដៅ ត.ម ១ =១៥%, ត.ម ២= ៤៥%, ត.ម ៣= ៦៧% និង ត.ម ៤= ៩៦%)។ ចំណែកឯ, ចំណាយថវិកាតាមប្រភេទ(គោលដៅកំណត់មិនត្រូវតិចជាង ៩៨% សម្រាប់បៀវត្ស ៩៥%សម្រាប់ទំនិញ/សេវា និង៨៥% សម្រាប់មូលធន) សម្រេចបាន (១) បៀវត្សសម្រេចបាន ៩៦,០៦% នៃច្បាប់ហិរញ្ញវត្ថុ, ទំនិញ/សេវា សម្រេចបាន ៩៥,១៨% នៃច្បាប់ហិរញ្ញវត្ថុ (ប៉ុន្តែបើធៀបនឹងថវិកាក្រោយវិចារណកម្មចំណាយសម្រេចបាន ១០៦,៦១%នៃច្បាប់ហិរញ្ញវត្ថុ) និងចំណាយមូលធនសម្រេចបាន ៩២,២៥% នៃច្បាប់ហិរញ្ញវត្ថុ។

ដោយឡែក, ចំណាយថវិកាជាតិសរុប គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ សម្រេចបាន ២៣ ៤៧៥ ប៊ីលានរៀល(៨១,៦៩% ធៀបនឹងច្បាប់) ក្នុងនោះចំណាយបៀវត្សរ៍សម្រេចបាន ៩ ០៥០ ពាន់លានរៀល(៩៦,២៣% ធៀបនឹងច្បាប់), ចំណាយទំនិញ-សេវា សម្រេចបាន ៣ ៨៩៣ ពាន់លានរៀល(៨៣,៧៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ), និងចំណាយមូលធន សម្រេចបាន ៦ ៣០៤ ពាន់លានរៀល (៧៤,៥៣ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុ)។ បើពិនិត្យមើលចំណាយតាមត្រីមាសវិញ÷ ត្រីមាសទី១ សម្រេចបាន ១៧,៩១%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ, ត្រីមាសទី២ សម្រេចបាន ៣៧,៣៩%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ, ត្រីមាសទី៣ សម្រេចបាន ៥៨,៦៩%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ, និងត្រីមាស៤ សម្រេចបាន ៨១,៦៩%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។ ខាងក្រោមនេះគឺជាតួលេខអនុវត្តចំណាយចាប់តាំងពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២២។

ដ្យាក្រាមទី 4÷ ការអនុវត្តចំណាយថវិការដ្ឋឆ្នាំ២០១៣-២០២២




ដ្យាក្រាមទី 5÷ ការអនុវត្តថវិការដ្ឋប្រចាំត្រីមាសចាប់ពីឆ្នាំ២០១៦-២០២២




ប្រភព÷អគ្គនាយកដ្ឋានរតនាគារជាតិ, ទិន្នន័យបណ្តោះអាសន្នគិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣

### *គោលបំណង ១៣÷ កែលម្អដំណើរការនៃការអនុវត្តថវិកា*

ក្នុងការកែលម្អដំណើរការនៃការអនុវត្តថវិកា វិធានការគន្លឹះៗនានា ត្រូវបានដាក់ចេញក្នុងក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២ ដែលមានវឌ្ឍនភាព ដូចខាងក្រោម÷

***ផែនការលទ្ធកម្ម*** ÷ ក្រសួង-ស្ថាប័ន, សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល, រដ្ឋបាលរាជធានី-ខេត្ត, និងអង្គភាពថវិកា បានភ្ជាប់គម្រោងផែនការលទ្ធកម្មមកជាមួយនឹងផែនការថវិកាសម្រាប់ការចរចារកញ្ចប់ថវិកាប្រចាំឆ្នាំ ជាមួយនឹង កសហវ.។ ដោយឡែក, ការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ ហាក់នៅមានភាពយឺតយ៉ាវនៅឡើយ។

***វិមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ៖*** ការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធសាធារណៈជំហានទី១ ត្រូវបានដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០១៩។ បច្ចុប្បន្ន, សេចក្តីព្រាងប្រកាសស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈជំហានទី២ កំពុងត្រូវបានរៀបចំ និងបានដាក់ប្រជុំពិភាក្សាផ្ទៃក្នុងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

***ការប្រើប្រាស់វិធីសាស្រ្តលទ្ធកម្មប្រកួតប្រជែង៖*** វឌ្ឍនភាពហាក់នៅមានកម្រិតនៅឡើយ។ ក្នុងឆ្នាំ២០២០ អនុវត្តបាន ៦០,៦២% នៃទំហំទឹកប្រាក់កិច្ចសន្យាសរុបប្រចាំឆ្នាំ ដោយឡែក ឆ្នាំ២០២១ អនុវត្តបានត្រឹមតែ ៥៥,៦៧% ធៀបនឹងគោលដៅប្រចាំឆ្នាំយ៉ាងតិច ៦៥% នៃទំហំទឹកប្រាក់ការប្រគល់កិច្ចសន្យាសរុប។

***សេចក្តីព្រាងស្តីពីលទ្ធកម្មសាធារណៈ (ថ្មី)*** ត្រូវបានដាក់ប្រជុំ និងពិភាក្សាក្នុងកម្រិតថ្នាក់ដឹកនាំនៃ កសហវ. កាលពីថ្ងៃទី១៣, ទី១៥ និងទី១៦ ខែធ្នូ ឆ្នាំ២០២២។ បន្ទាប់ពីកិច្ចប្រជុំផ្ទៃក្នុងនេះ, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បានកែសម្រួលសេចក្តីព្រាងច្បាប់ស្របតាមស្មារតីសម្រេចរបស់អង្គប្រជុំ និងបានរៀបចំជារបាយការណ៍គោរពរាយការណ៍អំពីវឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ថ្មី) ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងបានគោរពសុំគោលការណ៍ដ៏ខ្ពង់ខ្ពស់ដើម្បីសហការជាមួយក្រសួងយុត្តិធម៌ និងអង្គភាពប្រឆាំងអំពើពុករលួយ ពិនិត្យលើខ្លឹមសារជំពូកពាក់ព័ន្ធទោសប្បញ្ញត្តិ នៃសេចក្តីព្រាងច្បាប់នេះ មុននឹងបញ្ជូនសេចក្តីព្រាងច្បាប់នេះទៅទីស្តីការគណៈរដ្ឋមន្ត្រី។ បន្ទាប់ពីទទួលបានគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានប្រជុំពិនិត្យពិភាក្សាជាមួយក្រសួងយុត្តិធម៌ និងអង្គភាពប្រឆាំងអំពើពុករលួយចំនួន ៣ លើក កាលពីថ្ងៃទី៣០ ខែមករា, ទី២២ ខែកុម្ភៈ និងទី០២ ខែមីនា ឆ្នាំ២០២៣ ដើម្បីពិនិត្យ កែសម្រួល និងតាក់តែងខ្លឹមសារជំពូកស្តីពីទោសប្បញ្ញត្តិ នៃសេចក្តីព្រាងច្បាប់នេះ ឱ្យមានសង្គតិភាពជាមួយបទប្បញ្ញត្តិនិងគោលការណ៍ជាធរមាន។

ក្រៅពីវិធានការលើការកែលម្អការគ្រប់គ្រងលទ្ធកម្ម, វិធានការនានាត្រូវបានអនុវត្ត និងសម្រេចបានវឌ្ឍនភាពរួមមាន៖

***ចំណាយកកស្ទះ*** ដែលទូទាត់លើសពីរយៈពេល ៦០ ថ្ងៃ គឺពុំមាននោះទេ។ ចំពោះក្របខ័ណ្ឌផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាព សម្រាប់ដោះស្រាយចំណាយកកស្ទះ (ការកំណត់និយមន័យថ្មីនៃចំណាយកកស្ទះ), ក្រុមការងារបានរៀបចំកិច្ចប្រជុំ ពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍របកគំហើញរបស់ជំនាញការកាលពីថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២។ បច្ចុប្បន្ន ក្រុមជំនាញការបាននិងកំពុងប្រមូលធាតុចូលបន្ថែមទៀតពីភាគីពាក់ព័ន្ធ។

***គោលការណ៍ណែនាំស្តីពីហិរញ្ញវត្ថុសាធារណៈ (FMM)៖*** ក្រសួង ស្ថាប័នចំនួន ១៣ បានដាក់សកម្មភាពរៀបចំ ប៉ុន្តែក្រសួងចំនួន ៣ បានរៀបចំសេចក្តីព្រាង FMM។ ការរៀបចំ FMM នៅមានវឌ្ឍនភាពយឺតនៅឡើយ ដែលគួរត្រូវបានជំរុញការរៀបចំសំដៅជំរុញដល់ការអនុវត្តនីតិវិធីហិរញ្ញវត្ថុនៅតាមក្រសួង-ស្ថាប័ន។

***ផែនការឥណទានរដ្ឋទេយ្យបុរេប្រទាន៖*** ក្រសួង-ស្ថាប័នមួយចំនួនបានផ្ញើទាន់ពេលវេលានូវផែនការឥណទានរដ្ឋទេយ្យបុរេប្រទានសម្រាប់ការចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ។ ដោយឡែក ក្រសួង-ស្ថាប័នមួយចំនួនទៀតនៅមិនទាន់បានផ្ញើបានទាន់ពេលវេលានៅឡើយ។

**ចំពោះការបើកប្រាក់បេសសកម្មតាមប្រព័ន្ធធនាគារ** ការអនុវត្តនៅមានវឌ្ឍនភាពយឺតនៅឡើយ បើទោះបីជាមានការជំរុញពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងណាក៏ដោយ ពោលគឺ គិតត្រឹមឆ្នាំ២០២២ មានក្រសួង-ស្ថាប័នចំនួន

២១/៣៧ បានបានអនុវត្តការបើកប្រាក់បេសកកម្មក្នុងប្រទេស ឬស្មើនឹង ៥៥% និងក្រសួង-ស្ថាប័នចំនួន ១៣/៣៧ បានអនុវត្តការបើកប្រាក់បេសកកម្មក្រៅប្រទេស ឬស្មើនឹង ៣៥%។ កិច្ចការនេះ គួរត្រូវបានជំរុញបន្ថែមទៀត ដើម្បីធានាដល់អត្ថប្រយោជន៍ពេញលេញដល់មន្ត្រីរាជការ និងធានាតម្លាភាពក្នុងការអនុវត្តចំណាយ។

***សមិទ្ធផលផ្នែកទី១÷*** *ចំណូលថវិកាជាតិនៅតែមានស្ថានភាពរឹងមាំ ដែលជាបច្ច័យនៃការកែទម្រង់ប្រព័ន្ធ និងរដ្ឋបាលប្រមូលចំណូលកន្លងមក។ ក៏ប៉ុន្តែ ចំណូលថវិការដ្ឋពុំទាន់មានមូលដ្ឋានទូលំទូលាយនៅឡើយ ដែលមានហានិភ័យជាយថាហេតុចំពោះវិបត្តិផ្សេងៗ។ ក្នុងន័យនេះ ការធ្វើពិពិធកម្មប្រភពចំណូលថវិការដ្ឋគួរបន្តជំរុញបន្ថែមទៀត ស្របពេលបន្តពង្រឹងការប្រមូលចំណូលឱ្យកាន់តែមានប្រសិទ្ធភាព និងអស់សក្តានុពល ពិសេសការប្រមូលចំណូលមិនមែនសារពើពន្ធ ដែលនៅមានសក្តានុពលក្នុងការពង្រឹងបន្ថែមទៀត។*

*ដោយឡែក ការអនុវត្តផែនការចំណាយហាក់សម្រេចបានទាបជាងគោលដៅ ទោះបីជាវិធានការនានាត្រូវបានអនុវត្ត ដែលទាមទារឱ្យបន្តយកចិត្តទុកដាក់ខ្ពស់លើបរិបថ និងប្រសិទ្ធភាពចំណាយថវិកា។ ការដាក់ចេញនូវវិធានការនៃការភ្ជាប់ផែនការរជ្ជទេយ្យបុរេប្រទានអំឡុងពេលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ និងការអនុម័តផែនការលទ្ធកម្មប្រចាំឆ្នាំមុនឆ្នាំអនុវត្តថវិកា មានវឌ្ឍនភាពល្អប្រសើរ ប៉ុន្តែពុំទាន់មានបច្ច័យខ្ពស់គ្រប់គ្រាន់នៅឡើយសម្រាប់ពន្លឿនការអនុវត្តថវិកាតាមត្រីមាសនីមួយៗ ពោលគឺ ការអនុវត្តថវិកានៅក្នុងត្រីមាសទី៣ នៅទាបជាងពិតាន (៧០%) ដែលមាននិន្នាការគរការទូទាត់ថវិកានៅចុងឆ្នាំ។ ក្នុងន័យនេះ ការជំរុញបញ្ចប់ការរៀបចំក្របខ័ណ្ឌផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ នឹងរួមចំណែកដោះស្រាយបញ្ហាប្រឈមជាក់ស្តែងនៃការគរការទូទាត់ថវិកានៅចុងឆ្នាំ ខណៈការបញ្ចប់ការដាក់ឱ្យអនុវត្តសិទ្ធិសម្រេចលទ្ធកម្ម ជំហានទី២ ក៏នឹងរួមចំណែកដល់ការពន្លឿនការអនុវត្តថវិកាផងដែរ។ ដោយឡែក ការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្មនៅមានកម្រិត ដែលកិច្ចការនេះ នឹងត្រូវបានពង្រឹងតាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។*

## ផ្នែកទី២÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ

ក្នុងផ្នែកទី២ ផ្តោតលើគោលបំណងចំនួន ៥ គឺ÷ (១) ពង្រឹង និងពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS, (២) ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យ ប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ថ្មី, (៣) ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (ទ្រព្យសកម្មរយៈពេលវែង), (៤) ពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ រួមទាំងហានិភ័យ នៃកាតព្វកិច្ចបំណុលយថាហេតុ និងហានិភ័យបំណុលពាក់ព័ន្ធ ប្រកបដោយចីរភាព, និង (៥) ពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ។

### *គោលបំណង ២១÷ ពង្រឹង និងពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS*

ចាប់ពីឆ្នាំ២០១៤ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) បានដាក់ឱ្យអនុវត្តជាជំហានៗ និងបន្តពង្រឹង និងពង្រីកជាបន្តបន្ទាប់។ គម្រោងប្រព័ន្ធ FMIS ត្រូវបានចាប់ផ្តើមដាក់ឱ្យអនុវត្តជំហានទី១ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦, និងជំហានទី២ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០ និងផែនការពង្រីកប្រព័ន្ធ FMIS ជំហានទី៣ ចាប់ពីឆ្នាំ២០២១ដល់ឆ្នាំ២០២៥។ ប្រព័ន្ធ FMIS បានក្លាយជាឆ្អឹងខ្នងនៃការកសាងគណនេយ្យភាពហិរញ្ញវត្ថុ និងជាការធ្វើឌីជីថលូបនីយកម្មនៅទូទាំងរាជរដ្ឋាភិបាល។ ត្រឹមឆ្នាំ២០២២ នីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS លើ

ការទូទាត់ចំណាយបៀវត្ស និងចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប[1] ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅតាមក្រសួង-ស្ថាប័នចំនួន ៣៤ (រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិនៅថ្នាក់កណ្ដាល) នៃ ៣៧ ក្រសួង-ស្ថាប័ន។ ដោយឡែកស្ថាប័នចំនួន ៣ ទៀតដែលនៅសេសសល់ រួមមាន រដ្ឋសភា, ព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមការងារគ្រោងនឹងរៀបចំសិក្សាបន្ថែមទៀតនៅឆ្នាំខាងមុខ លើនីតិវិធីពិសេសដាច់ដោយឡែកចំពោះការអនុវត្តនៅស្ថាប័នទាំង ៣ ខាងលើ អំពីនីតិវិធីការទូទាត់ចំណាយបៀវត្ស និងការទូទាត់ត្រង់ដែលមានហានិភ័យទាប។ បន្ថែមពីនេះ, កសហវ. និងក្រសួងបរិស្ថានត្រូវបានប្រកាស និងដាក់ឱ្យអនុវត្តនីតិវិធីអនុវត្តការងារថ្មីលើនីតិវិធីចំណាយថវិកាចរន្តលើគ្រប់មុខសញ្ញាតាមប្រព័ន្ធ FMIS ទាំងស្រុង កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២។ បន្ថែមពីនេះ, រដ្ឋបាលស្រុកចំនួន ៧៥ និងរដ្ឋបាលឃុំចំនួន ១៨៥ បានប្រើប្រាស់សាកល្បងប្រព័ន្ធឯកសារឌីជីថល (FMIS Portal V1) ជាផ្លូវការនៅថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០២២ និង ទទួលបានការគាំទ្រលើការប្រើប្រាស់។ ជាមួយគ្នានេះ, ប្រព័ន្ធឯកសារឌីជីថល(FMIS Portal V1) ត្រូវបាន អភិវឌ្ឍ និង តេស្តសាកល្បងរួចរាល់សម្រាប់ការត្រៀមដាក់ឱ្យប្រើប្រាស់នៅរដ្ឋបាលក្រុងចំនួន ៦, រដ្ឋបាលស្រុកចំនួន ៦១, រដ្ឋបាលឃុំចំនួន ៤៤៧ និង រដ្ឋបាលសង្កាត់ចំនួន ២៨ ការដ្ឋានបន្ថែម។

ក្រៅពីនេះ មុខងាររៀបចំផែនការថវិកាត្រូវបានចាប់ផ្ដើមអនុវត្តសាកល្បងនៅក្នុងឆ្នាំ២០២១ នៅក្រសួងចំនួន ២ គឺ កសហវ. និងក្រសួងកិច្ចការនារី។ ក្នុងឆ្នាំ២០២២ មុខងាររៀបចំផែនការថវិកានេះត្រូវបានបន្តដាក់ឱ្យប្រើប្រាស់ នៅក្រសួង-ស្ថាប័នចំនួន ១១[2] បន្ថែមទៀត រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្ដាល។ ចំពោះមុខងារលទ្ធកម្មពេញលេញ ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ២០២១ នៅក្រសួងចំនួន ៣ រួមមាន កសហវ., ក្រសួងព័ត៌មាន និងក្រសួងកិច្ចការនារី។ ក្នុងឆ្នាំ២០២២ មុខងារនេះត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញទាំងអស់ដែលបាននិងកំពុងប្រើប្រាស់ប្រព័ន្ធ FMIS លើកលែងតែអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០ នៃ កសហវ. ដែលទើបបានប្រើប្រាស់ប្រព័ន្ធ FMIS ក្នុងឆ្នាំ ២០២២ នេះ។

បន្ថែមពីនេះ, ដើម្បីធានាសុក្រឹត្តភាពទិន្នន័យ និងការទាញយកទិន្នន័យបានទាន់ពេលវេលា ប្រព័ន្ធ FMIS បានធ្វើសន្ទានកម្មផ្លាស់ប្ដូរជាមួយប្រព័ន្ធផ្សេងៗរួមមាន÷ ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយនិងរដ្ឋាករកម្ពុជា (ASYCUDA), ប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុល (DMFAS) របស់អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល, ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) របស់អគ្គនាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, ប្រព័ន្ធគ្រប់គ្រងចំណូលពន្ធដារ របស់អគ្គនាយកដ្ឋានពន្ធដារ (Tax System), ប្រព័ន្ធបៀវត្សមន្ត្រីរាជការ (PRIS) នៃក្រសួងមុខងារសាធារណៈ, ការទូទាត់អេឡិចត្រូនិក (EFT) របស់ប្រព័ន្ធធនាគារកាណាឌីយ៉ា និងធនាគារអេស៊ីលីដា (ACLEDA) ព្រមទាំងសន្ទានកម្មទិន្នន័យជាមួយនឹងប្រព័ន្ធធនាគារ នៃធនាគារជាតិនៃកម្ពុជា និងធនាគារ

[1] ចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប គ្របដណ្ដប់លើមុខសញ្ញាចំណាយដូចជា÷ ថ្លៃប្រើប្រាស់អគ្គិសនី, ថ្លៃប្រើប្រាស់ទឹកស្អាត, ថ្លៃប្រមូលសំរាម, ប្រាក់កំរៃភ្នាក់ងារបរទេសជាប់កិច្ចសន្យា, ថ្លៃជាវសៀវភៅរាជកិច្ច, សោហ៊ុយប្រៃសណីយ៍, សោហ៊ុយទូរគមនាគមន៍, ប្រាក់អាហារូបករណ៍សម្រាប់ការសិក្សា និងស្រាវជ្រាវ, លតាប័ត្រសម្រាប់ចំណាយលើការបង់ពន្ធយានយន្តប្រចាំឆ្នាំ។

[2] ក្រសួង-ស្ថាប័នទាំង ១១ រួមមាន÷ ១-អង្គភាពប្រឆាំងអំពើពុករលួយ, ២-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ៣-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ, ៤-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ៥-ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ, ៦-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ៧-ក្រសួងបរិស្ថាន, ៨-ក្រសួងអភិវឌ្ឍន៍ជនបទ, ៩-ក្រសួងយុត្តិធម៌, ១០-ក្រសួងព័ត៌មាន, ១១-ក្រសួងសាធារណការ និងដឹកជញ្ជូន។

ពាណិជ្ជផ្សេងៗទៀត ដូចជា ធនាគារការណាឌីយ៉ា, ធនាគារអេស៊ីលីដា, ធនាគារកម្ពុជាសាធារណៈ, ធនាគារវឌ្ឍនៈ, ធនាគារជេត្រាស់, ធនាគារស្ថាបនា, ធនាគារប្រៃសណីយ៍កម្ពុជា និងធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA), ធនាគារពាណិជ្ជកម្មក្រៅប្រទេស (FTB) និងធនាគារជីបម៉ុង។ ការធ្វើសន្ធានកម្មទិន្នន័យរវាងប្រព័ន្ធ FMIS ជាមួយប្រព័ន្ធ PRIS របស់ក្រសួងមុខងារសាធារណៈ បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០២១។ រហូតមកពេលនេះ, សន្ធានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធ PRIS នេះត្រូវបានពង្រីកដល់ក្រសួង-ស្ថាប័នចំនួន ៨ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្ដាល រួមមាន ១-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ២-ក្រសួងមុខងារសាធារណៈ, ៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ៤-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ៥-ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ, ៦-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ៧-ក្រសួងសុខាភិបាល និង ៨-ក្រសួងអប់រំ យុវជន និងកីឡា និង បន្តកិច្ចការងារទៅជំហានបន្ទាប់លើការដាក់សន្ធានកម្មទៅក្រសួង-ស្ថាប័នចំនួន ១៩ បន្ថែមស្របតាមនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS ។

### *គោលបំណង ២២÷ ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យ ប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ថ្មី*

ស្តង់ដាគណនេយ្យនឹងចូលរួមចំណែកក្នុងការធានាបាននូវតម្លាភាព ភាពជឿទុកចិត្ត សង្គតិភាព និងភាពអាចប្រៀបធៀបគ្នាបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ គឺជាផ្នែកមួយនៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងជាដំណាក់កាលដំបូងក្នុងការកែទម្រង់ប្រព័ន្ធគណនេយ្យសាធារណៈកម្ពុជា ដែលទាមទារឱ្យមានការចូលរួម ការគាំទ្រ ការសហការយ៉ាងស្អិតរមួត និងការអនុវត្តប្រកបដោយឆន្ទៈមោះមុតពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីឱ្យទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក។ អគ្គនាយកដ្ឋានរតនាគារជាតិត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទចាប់ផ្តើមពីឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៤[3]។ ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់នេះ មិនត្រូវបានដាក់ឱ្យអនុវត្តចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល[4]។ បន្ថែមពីនេះ, យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១ ទទួលបានការអនុម័ត និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។ យុទ្ធសាស្ត្រនេះ មានគោលបំណងធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តក្របខ័ណ្ឌរបាយការណ៍ហិរញ្ញវត្ថុ និងស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ព្រមទាំងមានទិសដៅផ្លាស់ប្តូរការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា ជាដំណាក់កាលៗពីមូលដ្ឋានសាច់ប្រាក់ រហូតដល់មូលដ្ឋានបង្គរក្នុងឆ្នាំ២០៣១ ដូចខាងក្រោម÷

- ស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានសាច់ប្រាក់ ពីឆ្នាំ២០១៩-ឆ្នាំ២០២៤
- ស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានសាច់ប្រាក់កែសម្រួល ពីឆ្នាំ២០២៥-ឆ្នាំ២០២៧
- ស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរកែសម្រួល ពីឆ្នាំ២០២៨-ឆ្នាំ២០៣០
- ស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ ពីឆ្នាំ២០៣១-ឆ្នាំ២០៣៣ តទៅ។

---

[3] ប្រកាសលេខ ៥៤៥ សហវ.ប្រក ស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៩

[4] ប្រកាសលេខ ៥៤៥ សហវ.ប្រក ស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៩

របាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានចេញផ្សាយជាផ្លូវការ និងជាលើកដំបូងចាប់តាំងពីឆ្នាំ២០១៩មក រហូតដល់បច្ចុប្បន្ន បន្ទាប់ពីបានរៀបចំសាកល្បងរយៈពេល ៣ ឆ្នាំរួចមក។ របាយការណ៍ហិរញ្ញវត្ថុនេះត្រូវបានវាយតម្លៃ និងទទួលស្គាល់ដោយជំនាញការជាតិ និងជំនាញការរូបិយវត្ថុអន្តរជាតិ (IMF) ថាមានអនុលោមភាពទៅនឹងស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់ ដោយបានលាតត្រដាងកាន់តែលម្អិតនៅក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុដោយបានដាក់បង្ហាញព័ត៌មានអំពីសាច់ប្រាក់កម្ចី ដែលមិនទាន់ប្រើប្រាស់ និងព័ត៌មានអំពីអង្គភាពថវិកាដែលរាយការណ៍ជាដើម និងអាចទទួលយកបានដោយស្របតាមទិសដៅយុទ្ធសាស្រ្តកែទម្រង់ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា។ ជាក់ស្តែង របាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២១ ត្រូវបានបញ្ចប់រួចរាល់កាលពីខែវិច្ឆិកា ឆ្នាំ២០២២ កន្លងទៅនឹងត្រូវបានវាយតម្លៃថាមានភាពល្អប្រសើរជាងឆ្នាំមុនៗផងដែរ។ បើទោះជារបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជាត្រូវបានវាយតម្លៃថាមានភាពល្អប្រសើរ ប៉ុន្តែក៏នៅមានចំណុចខ្លះពុំទាន់មានអនុ-លោមភាពពេញលេញដែលទាមទារ ឱ្យមានការកែទម្រង់បន្តទៀត ដូចជា៖

- ប្រតិបត្តិការក្រៅពីគណនីទោលរតនាគារ និងតួលេខសាច់ប្រាក់បុរេប្រទានដែលនៅសល់តាមក្រសួង-ស្ថាប័នមួយចំនួន នៅមិនទាន់បានកត់ត្រាចូលក្នុងរបាយការណ៍នេះនៅឡើយ
- ការបិទបញ្ជី និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមានភាពយឺតយ៉ាវបន្ទាប់ការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិកានីមួយៗ ត្រូវបានបញ្ចប់
- ប្រព័ន្ធកត់ត្រាតម្រូវឱ្យមានភាពលំអិតច្រើនដែលត្រូវការចំណាយពេលវេលាយូរ ក្នុងការបញ្ចូល ទិន្នន័យដូចជាមាតិកាថវិកានៃចំណាត់ថ្នាក់ភូមិសាស្ត្រ ដែលតម្រូវបំបែកដល់កម្រិតឃុំ-សង្កាត់
- ការចុះប្រតិបត្តិការពុំបានត្រឹមត្រូវ ដែលតម្រូវឱ្យមានការស្នើសុំនិយ័តភាព កែសម្រួលច្រើននៅដំណាច់ឆ្នាំ
- ការធ្វើបច្ចុប្បន្នភាព និងការរៀបចំថ្មីនៃលិខិតបទដ្ឋានគតិយុត្តនានា នាំឱ្យមានការប្រែប្រួលដល់នីតិវិធីនៃ ការកត់ត្រា និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

ការកត់ត្រាត្រូវបានអនុវត្តទាំងស្រុងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ប្រកបដោយព័ត៌មានគ្រប់គ្រាន់ ត្រឹមត្រូវ សង្គតិភាព និងប្រសិទ្ធភាព សម្រាប់កិច្ចដំណើរការការបិទបញ្ជីគណនេយ្យ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលផងដែរ។ ប្រព័ន្ធ FMIS បានសម្រួលដល់ការប្រមូលសរុបតួលេខសម្រាប់រៀបចំច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋប្រចាំឆ្នាំដែលមានតារាងឧបសម្ព័ន្ធតួលេខចំណូល-ចំណាយថវិកា និងតារាងតុល្យភាពថវិកា ហើយបានរៀបចំផលិតនៅក្នុងប្រព័ន្ធនេះតែម្តង។

### *គោលបំណង ២៣៖ ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (ទ្រព្យសកម្មរយៈពេលវែង)*

តាមរយៈការដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ ក្នុងនោះ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវបានជំរុញការរៀបចំតាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS)។ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ មានវឌ្ឍនភាពល្អប្រសើរគួរឱ្យកត់សម្គាល់ ដោយអង្គភាពកាន់កាប់បានផ្តល់បញ្ជីសារពើភណ្ឌមក កសហវ. បានទាន់ពេលវេលាចំនួន ២ ៦២៨ នៃ ៣ ០៥៣ ដែលស្មើនឹង ៨៦% ក្នុងឆ្នាំ២០២១ ដោយសារការដាក់ឱ្យអនុវត្តនូវប្រព័ន្ធ SARMIS នៅគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ រហូតដល់រដ្ឋបាល

ក្រុង ស្រុក ខណ្ឌ។ ទោះជាយ៉ាងនេះក្តី, ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) នៅជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជា៖

- កង្វះច្បាប់ និងបទប្បញ្ញត្តិ ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ក្រោមជាតិ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដែលមានស្រាប់នៅមានកម្រិត
- ការធ្វើទំនើបកម្ម និងស្វ័យប្រវត្តិកម្មនៅមានកម្រិត
- កង្វះសមត្ថភាពបច្ចេកទេស និងធនធានមនុស្សនៅតាមក្រសួង ស្ថាប័ន និងអង្គភាពប្រើប្រាស់ប្រព័ន្ធ។

ទន្ទឹមនឹងនេះ ការធ្វើប័ណ្ណកម្មសិទ្ធិដីរដ្ឋក៏កំពុងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ តាមរយៈការបង្កើតឱ្យមានគណៈកម្មការអន្តរក្រសួងចំនួន ២ កម្រិត គឺ៖ (១) គណៈកម្មការអន្តរក្រសួងដើម្បីពិនិត្យ និងធ្វើបច្ចុប្បន្នភាពទីតាំងដីរដ្ឋដែលបានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង-ស្ថាប័ននៅថ្នាក់កណ្តាល និង (២) គណៈកម្មការអន្តរក្រសួងដើម្បីពិនិត្យ និងធ្វើបច្ចុប្បន្នភាពទីតាំងដីរដ្ឋដែលបានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរអង្គភាពថ្នាក់មូលដ្ឋាននៃក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីរៀបចំធ្វើប័ណ្ណកម្មសិទ្ធិ។ ក្រុមការងារនៃគណៈកម្មការអន្តរក្រសួងបានចុះទៅគោលដៅទាំង ២៥ រាជធានី-ខេត្ត ដើម្បីផ្សព្វផ្សាយ ណែនាំ និងជំរុញការធ្វើប័ណ្ណកម្មសិទ្ធិលើដីរដ្ឋព្រមទាំងពិនិត្យស្ថានភាពដីរដ្ឋ ដើម្បីប្រមូលផ្តុំទិន្នន័យ ៣ ប្រភេទ រួមមាន ដីទំនាស់, ដីកំពុងស្ថិតនៅក្នុងនីតិវិធី, និងដីដែលកំពុងចាប់ផ្តើមនីតិវិធី តាំងពីខែតុលា ឆ្នាំ២០២២ មក ហើយបានបូកសរុបទិន្នន័យទីតាំងដីរដ្ឋ (គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ ២០២៣) សរុបទាំងអស់មានចំនួន ២៦ ៣៩០ កន្លែង ក្នុងនោះ៖

- ដីដែលមានប័ណ្ណកម្មសិទ្ធិ មានចំនួន ១៣ ១២៤ កន្លែង ស្មើនឹង៤៩,៧៣%
- ដីដែលមិនទាន់មានប័ណ្ណកម្មសិទ្ធិ មានចំនួន ១៣ ២៦៦ ស្មើនឹង ៥០,២៧%
- ដីដែលបានដាក់ពាក្យស្នើសុំធ្វើប័ណ្ណកម្មសិទ្ធិ មានចំនួន ៥៧,២៣ ស្មើនឹង២១,៦៩%
    - ដីដែលបានវាស់វែងរួចរាល់ មានចំនួន ២ ១៥២ ស្មើនឹង ៨,១៥%
    - ដីដែលមិនទាន់បានវាស់វែង មានចំនួន ៣ ៥៧១ ស្មើនឹង១៣,៥៣%
- ដីដែលមានបណ្ណកម្មសិទ្ធិ និងអាចចេញបណ្ណបាន មានចំនួន ១៨ ៨៤៧ ស្មើនឹង៧១,៤២%
- ដីដែលមិនអាចធ្វើប័ណ្ណកម្មសិទ្ធិបាន មានចំនួន ១ ៣៨៤ កន្លែង ស្មើនឹង ៥,២៤%។

បន្ថែមពីនេះ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, ប្រកាសស្តីពីវិធាន និងនីតិវិធីធ្វើនីត្យានុកូលកម្មឡើងវិញនៃកិច្ចសន្យា ឬកិច្ចព្រមព្រៀងដែលមិនមានការឯកភាពពី កសហវ. ត្រូវបានរៀបចំជាសេចក្តីព្រាង។ ប្រកាសនេះ ដើរតួនាទីសំខាន់ក្នុងការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធពាក់ព័ន្ធនឹងកិច្ចសន្យា ឬកិច្ចព្រមព្រៀងជួលទ្រព្យសម្បត្តិរដ្ឋ។ ឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវបានរំកិលការរៀបចំទៅឆ្នាំ២០២៣។ ឯកសារគោលនេះ នឹងរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ជាអាទិ៍៖ ការពង្រឹងគុណភាពបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមានវឌ្ឍនភាព, ការជំរុញការធ្វើប័ណ្ណកម្មសិទ្ធិដីរដ្ឋ, និងពង្រឹងយន្តការជម្រះបញ្ជីសារពើភណ្ឌនៅមានកម្រិត។ល។

## *គោលបំណង ២៤៖ ការគ្រប់គ្រងបំណុលសាធារណៈ*

បំណុលសាធារណៈ សំដៅដល់បំណុលរបស់រដ្ឋ ដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត ដោយគិតបញ្ចូលបំណុលដែលមានការធានាពីរដ្ឋ ។ បំណុលសាធារណៈ រួមមានបំណុលសាធារណៈក្នុងប្រទេស និងបំណុលសាធារណៈក្រៅប្រទេស។ ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន, បំណុលសាធារណៈក្នុងប្រទេសកើតឡើងដោយសារការបោះផ្សាយមូលបត្ររដ្ឋ ហើយបំណុលសាធារណៈក្រៅប្រទេសកើតឡើងដោយសារ ការខ្ចីឥណទានសម្បទានពីដៃគូអភិវឌ្ឍទ្វេភាគី និងពហុភាគីក្រៅប្រទេស ព្រមទាំងបំណុលមរតកមួយចំនួនដែលបន្សល់ពីរដ្ឋាភិបាលសម័យមុន ។

ក្នុងការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាប្រកាន់ខ្ជាប់នូវស្មារតីប្រុងប្រយ័ត្នខ្ពស់ ដោយបានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍គន្លឹះៗទាំង៥ រួមមាន៖ ១).ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកានិងសេដ្ឋកិច្ចអាចទ្រាំទ្របាន ២).ខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់ ៣). ខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាព នៃកំណើនសេដ្ឋកិច្ចនិងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម និង ៤). ប្រើប្រាស់ឥណទានប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់បំផុត និង៥).ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលត្រូវមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ជាពិសេស ធានាបាននូវចីរភាពសេដ្ឋកិច្ច សង្គម បរិស្ថាន និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ ផ្អែកតាមការវិភាគចីរភាពបំណុលបង្ហាញថាអនុបាតបំណុលទាំង ៥ របស់កម្ពុជាសុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់។

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៩-២០២៣ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩។ តាមរយៈការអនុវត្តយុទ្ធសាស្ត្រនេះ សូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានបន្តរក្សាក្រោមពិតាន ក្នុងនោះ (១) អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុបធៀបនឹង ផ.ស.ស. ស្ថិតក្នុងរង្វង់ ២៥,២% ធៀបនឹងពិតាន ៥៥%, (២) អនុបាតតម្លៃបច្ចុប្បន្ន នៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផ.ស.ស. ស្ថិតក្នុងរង្វង់ ២៤,៩% ធៀបនឹងពិតាន ៤០%, (៣) អនុបាតតម្លៃបច្ចុប្បន្ន នៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹងការនាំចេញស្ថិតក្នុងរង្វង់ ៣៣,៩% ធៀបនឹងពិតាន ១៨០%, (៤) អនុបាតសេវាបំណុល សាធារណៈក្រៅប្រទេសធៀបនឹងការនាំចេញស្ថិតក្នុងរង្វង់ ២,១% ធៀបនឹង ពិតាន ១៥%, និង (៥) អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេសធៀបនឹងចំណូលថវិកាជាតិ ស្ថិតក្នុងរង្វង់ ៧,៨% ធៀបនឹងពិតាន ១៨%។ តាមបទដ្ឋានបច្ចេកទេសអន្តរជាតិលទ្ធផលនេះបញ្ជាក់ថាស្ថានភាពបំណុលសាធារណៈកម្ពុជាមាន "**ចីរភាព**" និង "**ហានិភ័យកម្រិតទាប**"។

តារាងទី 4៖សូចនាករបំណុលសាធារណៈឆ្នាំ២០១៨-២០២២

| សូចនាករ | អនុបាតគោល | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ ម |
|---|---|---|---|---|---|---|
| តម្លៃបច្ចុប្បន្ន នៃបំណុលសាធារណៈសរុប (%) | | | | | | |
| ធៀបនឹង ផសស | ៥៥ | ២១,៤៨ | ២០,៨ | ២៤,០ | ២៤,៤០ | ២៥,២ |
| តម្លៃបច្ចុប្បន្ន នៃបំណុលសាធារណៈក្រៅប្រទេស | | | | | | |
| ធៀបនឹង ផសស | ៤០ | ២១,៤៦ | ២០,៨ | ២៤,០ | ២៤,៤០ | ២៤,៩ |
| ធៀបនឹងការនាំចេញ | ១៨០ | ២៨,៤ | ២៦,៧ | ៣២,៨ | ៣២,៨២ | ៣៣,៩ |
| សេវាបំណុលសាធារណៈក្រៅប្រទេស | | | | | | |
| ធៀបនឹងការនាំចេញ | ១៥ | ១,៤ | ១,៥ | ១,៨ | ១,៨៣ | ២,១ |
| ធៀបនឹងចំណូល | ១៨ | ៤,៩ | ៤,៥ | ៦,៣ | ៦,៣៣ | ៧,៨ |

ដ្យាក្រាមទី 6 ÷ សន្និធិបំណុលសាធារណៈក្រៅប្រទេស (គិតត្រឹមឆមាសទី២ ឆ្នាំ២០២២)




*ប្រភព÷អគ្គនាយកដ្ឋានគ្រប់គ្រងបំណុលនិងសហប្រតិបត្តិការអន្តរជាតិ*

បន្ថែមពីនេះ, អនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានពិនិត្យឡើងវិញដោយភ្ជាប់ជាមួយការសិក្សាពី គោលការណ៍ណែនាំជាសកល និងសិក្សាស្រាវជ្រាវបទពិសោធននៃប្រទេសនានាក្នុងតំបន់ រួមមាន ប្រទេសថៃ វៀតណាម ហ្វីលីពីន និងឥណ្ឌូនេស៊ី។ ទន្ទឹមនេះ, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល បានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣ ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដែលមានខ្លឹមសារហានិភ័យបំណុលសាធារណៈពាក់ព័ន្ធ ដោយបង្ហាញហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities), ហានិភ័យថវិកា (Fiscal Risk), ហានិភ័យទីផ្សារ (Market Risk), ហានិភ័យប្រតិបត្តិការ (Operational Risk), ហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (Liquidity Risk), ហានិភ័យហិរញ្ញប្បទាននៃគម្រោង (Project Funding Risk) និងហានិភ័យឥណទាន (Credit Risk) ប្រចាំត្រីមាសទី១, ទី២, ទី៣, ទី៤ និងប្រចាំឆ្នាំ២០២១, ត្រីមាសទី១, ទី២, និងទី៣ ឆ្នាំ២០២២ ព្រមទាំងផ្សព្វផ្សាយលើគេហទំព័រផ្លូវការរបស់ អ.ស.ហ.។ ទំនើបកម្មឧបករណ៍វិភាគធាតុអំណោយ និងទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ (In-house Database for PDM) ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តនៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២១ ផងដែរ។

ច្បាប់ស្តីពីមូលបត្ររដ្ឋ ដែលត្រូវបានអនុម័ត និងប្រើប្រាស់កាលពីឆ្នាំ២០២០ ជាមូលដ្ឋានគតិយុត្តគ្រប់ជ្រុងជ្រោយមួយ និងស្របតាមតម្រូវការ នៃតថភាពជាក់ស្តែង ក៏ដូចជាបទបញ្ញត្តិពាក់ព័ន្ធដែលមានជាធរមាន សម្រាប់អនុញ្ញាតឱ្យរាជរដ្ឋាភិបាលប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុជាមូលបត្ររដ្ឋនេះ ក្នុងការកៀរគរហិរញ្ញប្បទានបន្ថែមពីវិស័យឯកជន ដើម្បីពង្រឹងការគ្រប់គ្រងតម្រូវការសាច់ប្រាក់របស់រាជរដ្ឋាភិបាល ឆ្លើយតបបានទៅនឹងតម្រូវការហិរញ្ញប្បទាន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ព្រមទាំងចូលរួមចំណែកដល់ការអភិវឌ្ឍទីផ្សារមូលបត្រ និងទីផ្សារហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាដើម្បីគាំទ្រដល់គម្រោង និង/ឬ កម្មវិធីអាទិភាព និងចាំបាច់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលនាពេលអនាគត។ ចំណែកឯ, ក្របខ័ណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ត្រូវបានរៀបចំ និងទទួលបានការអនុម័តដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល កាលពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពចាំបាច់ចំពោះមុខ របស់រាជរដ្ឋាភិបាលក្នុងការស្តារសេដ្ឋកិច្ចឡើងវិញពីវិបត្តិនៃជំងឺកូវីដ-១៩ ហើយផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយបឋមនេះក៏ត្រូវបានរៀបចំផងដែរ។ ក្របខ័ណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍ

មូលបត្ររដ្ឋនេះ មានគោលបំណង÷ (១)រៀបចំ និងអនុវត្តផែនការសកម្មភាព ដើម្បីត្រៀមលក្ខណៈឱ្យបានរួចរាល់ក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងទីផ្សារជាលើកដំបូង នៅឆ្នាំ២០២២ និង (២)កសាងឱ្យបាននូវប្រព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំ និងគ្រប់ជ្រុងជ្រោយ សម្រាប់ការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋ រួមមាន÷ ក្របខ័ណ្ឌគតិយុត្ត (រួមបញ្ចូលទាំងនីតិវិធីប្រតិបត្តិការនៃការបោះផ្សាយលក់មូលបត្រ), យន្តការស្ថាប័ន, យន្តការទីផ្សារ, ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស ដើម្បីកៀរគរទុនពីទីផ្សារមកបំពេញតម្រូវការហិរញ្ញប្បទាន សំដៅរួមចំណែកក្នុងការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន។ ទន្ទឹមនេះ សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយរួមស្តីពីការអភិវឌ្ឍមូល-បត្ររដ្ឋ២០២២-២០២៨ ត្រូវបាននិងកំពុងរៀបចំដោយដាក់បញ្ចូលនូវចំណុចពាក់ព័ន្ធនឹងការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ/ សញ្ញាប័ណ្ណតាមវិស័យ (thematic bonds) ដែលគ្រោងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងអនុម័តឆាប់ៗនេះ។

### *គោលបំណង ២៥÷ ពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ*

គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជានីតិបុគ្គលនៃនីតិសាធារណៈ ដែលទទួលបន្ទុកចម្បងនូវបេសកកម្មផ្នែកសេវាសាធារណៈ ជាអាទិ៍ សេវាមានលក្ខណៈរដ្ឋបាល សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស។ កិច្ចបញ្ជិកាគណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំស្របតាមវិធានទូទៅ និងប្លង់គណនេយ្យ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី កសហវ.។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងគណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល, អគ្គនាយកដ្ឋានថវិកានៃ កសហវ. បានរៀបចំ "លក្ខណវិនិច្ឆ័យអប្បបរមា នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល" ដើម្បីប្រើប្រាស់ជាមូលដ្ឋានសម្រាប់វាយតម្លៃការអនុវត្តរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលឱ្យមានអនុលោមភាពតាមលក្ខន្តិកៈគតិយុត្ត និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។ លក្ខណវិនិច្ឆ័យអប្បបរមា នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ទទួលបានគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់ពីថ្នាក់ដឹកនាំ នៃ កសហវ. នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២។ លក្ខណវិនិច្ឆ័យអប្បបរមានេះ ចែកចេញជា ៦ ប្រភេទ ហើយប្រភេទនីមួយៗមានសមាសភាពសម្រាប់ជាមូលដ្ឋានវាយតម្លៃ។

- **ប្រភេទទី១÷** មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ គណនេយ្យ និងលទ្ធកម្មដែលមានសមាសភាពពាក់ព័ន្ធរួមមាន គណនេយ្យករ, រេជ្ជទេយ្យករបុរេប្រទាន, រេជ្ជទេយ្យករចំណូល, ភ្នាក់ងារបើកផ្តល់, មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ និងមន្ត្រីអង្គភាពលទ្ធកម្ម។
- **ប្រភេទទី២÷** នីតិវិធីអនុវត្តចំណូលថវិកា រួមមាន អនុវត្តការប្រមូលចំណូល និងសលាកបត្របង់ចំណូលថវិកា
- **ប្រភេទទី៣÷** នីតិវិធីអនុវត្តចំណាយថវិកា ដែលត្រូវអនុលោមតាមដំណាក់កាលនៃបរិបទចំណាយរួមមាន ធានាចំណាយ, កិច្ចលទ្ធកម្ម, ជម្រះបញ្ជី, អាណត្តិកិច្ច និងការទូទាត់។
- **ប្រភេទទី៤÷** កិច្ចបញ្ជិកាគណនេយ្យដែលរួមមាន គណនេយ្យទូទៅ, គណនេយ្យរដ្ឋទេយ្យចំណូល, គណនេយ្យរដ្ឋទេយ្យបុរេប្រទាន។
- **ប្រភេទទី៥÷** ប្រព័ន្ធ FMIS ដែលស្របតាមគោលការណ៍ណែនាំរបស់ កសហវ.។

**-ប្រភេទទី៦÷** របាយការណ៍ ដែលត្រូវមានរបាយការណ៍អនុវត្តថវិកា, របាយការណ៍សមិទ្ធកម្ម, របាយការណ៍ហិរញ្ញវត្ថុ, តារាងតុល្យភាពរជ្ជទេយ្យចំណូល, តារាងតុល្យភាពរជ្ជទេយ្យបុរេប្រទាន, របាយការណ៍លទ្ធកម្ម, និងរបាយការណ៍បញ្ជីសារពើភណ្ឌ។

ទោះជាយ៉ាងណាក៏ដោយ, លក្ខណវិនិច្ឆ័យអប្បបរមា នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលទទួលបានគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់ពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងរៀបចំជាសេចក្តីណែនាំ ដើម្បីដាក់ឱ្យអនុវត្តសាកល្បង។ ទន្ទឹមនេះ, នៅក្នុងឆ្នាំ២០២២ មានគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ២៩ ក្នុងចំណោម ៣០ បានផ្ញើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២១ មកអគ្គនាយកដ្ឋានរតនាគារជាតិ ដែលមានរបាយការណ៍របស់គ្រឹះស្ថានចំនួន២៧ ត្រូវបានរៀបចំស្របតាមគោលការណ៍ណែនាំដាក់ឱ្យអនុវត្តសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអាចធ្វើការបូកសរុបបាន។ ក្នុងពេលបច្ចុប្បន្ននេះ, គ្រឹះស្ថានសាធារណៈរដ្ឋបាលមួយចំនួនមានប្រព័ន្ធ Access និងមួយចំនួនទៀតប្រើប្រាស់កម្មវិធី Excel សម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ ក្នុងន័យនេះ, ដើម្បីពង្រឹងប្រសិទ្ធភាព និងគណនេយ្យភាព នៃការរៀបចំកិច្ចបញ្ជិកាគណនេយ្យ និងរបាយ-ការណ៍ហិរញ្ញវត្ថុ, ក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងសិក្សា និងដាក់ឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលអនុវត្តតាមប្រព័ន្ធ FMIS ជាបណ្តើរៗសម្រាប់ការកត់ត្រា និងចុះកិច្ចបញ្ជិកាគណនេយ្យ។

សហគ្រាសសាធារណៈ គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ ដែលមានបេសកកម្មបង្កលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច ជាអាទិ៍ក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព។ ការដឹកនាំ និងការគ្រប់គ្រងរបស់សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោម អាណាព្យាបាលបច្ចេកទេសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសកម្មភាព ដែលពាក់ព័ន្ធជាមួយនឹងសហគ្រាស, អាណាព្យាបាលហិរញ្ញវត្ថុរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាណាព្យាបាលទូទៅរបស់រដ្ឋាភិបាល (តាមរយៈបទបញ្ជា)។

មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានតែងតាំងដោយ កសហវ. ថាជាតំណាងរបស់រដ្ឋទទួលបន្ទុកតាមដានជាប្រចាំនូវការប្រព្រឹត្តទៅរបស់សហគ្រាសសាធារណៈ និងផ្តល់ព័ត៌មានជូនអាជ្ញាធរអាណាព្យាបាល ជាពិសេសលើស្ថានភាពហិរញ្ញវត្ថុ។ ក្នុងក្របខ័ណ្ឌនេះ, ក្រុមការងារបច្ចេកទេសនៃ កសហវ. បានចុះត្រួតពិនិត្យ តាមដានសហគ្រាសសាធារណៈ និងបានរៀបចំរបាយការណ៍ ស្តីពីការវាយតម្លៃស្ថានភាពហិរញ្ញវត្ថុសហគ្រាសសាធារណៈ ដើម្បីដាក់ជូនថ្នាក់ដឹកនាំ កសហវ. ពិនិត្យ និងសម្រេចដោយបានផ្តោតលើចំណុចសំខាន់ៗចំនួន ៤ រួមមាន (១) ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលអាជីវកម្មសម្រាប់ការិយបរិច្ឆេទឆ្នាំ២០២០, (២) បណ្តាខ្ទង់ទូទាត់ជាមួយថវិការដ្ឋសម្រាប់ឆ្នាំ២០២០, (៣) ការបង់ភាគលាភចូលថវិការដ្ឋឆ្នាំ២០២០ របស់សហគ្រាសសាធារណៈ និង (៤) ស្ថានភាពមូលធននៃក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិចសម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០២០។

ក្នុងក្របខ័ណ្ឌនៃការរៀបចំបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងសហគ្រាសសាធារណៈ, បច្ចុប្បន្នក្រុមការងារនៃ កសហវ. កំពុងរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីកំណែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ ដោយបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ លើសេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីកំណែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ ដែលមានការចូលរួមពីបណ្តាសហគ្រាសសាធារណៈ, ក្រសួង-ស្ថាប័នអាណាព្យាបាលបច្ចេកទេស, ក្រុមការងារកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ និងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត។ បន្ថែមពីនេះ, វិធានការចំពោះមុខក្នុងការ

អនុវត្តយុទ្ធសាស្ត្រកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ គឺត្រូវធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ទៅជាសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ និងការរៀបចំសេចក្តីព្រាងអនុក្រឹត្យមួយចំនួនទៀត សម្រាប់អនុវត្តច្បាប់នេះ។ ការធ្វើវិសោធនកម្មច្បាប់នេះ ត្រូវបានពន្យារពេលការរៀបចំ និងគ្រោងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិប្បញ្ញត្តិ នៅត្រីមាសទី៤ ឆ្នាំ២០២៣។

## ផ្នែកទី៣÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

ផ្នែកទី៣ ផ្តោតលើគោលបំណងចំនួន ៤ គឺ÷ (១) រៀបចំ និងដាក់ឱ្យអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម, (២) ពង្រឹងការគ្រប់គ្រងវិនិយោគសាធារណៈ, (៣) ពង្រឹងការរៀបចំ និងការអនុវត្តថវិកាកម្មវិធី ដោយផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រថវិកា, និង (៤) ជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយគឺការកសាង និងបង្កើតប្រព័ន្ធថវិការយៈពេលមធ្យម ដែលផ្សារភ្ជាប់ជាមួយយុទ្ធសាស្ត្រចតុកោណ, ផែនយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រតាមវិស័យ ដោយផ្តោតលើអាទិភាពមួយចំនួន រួមមាន ការរៀបចំ និងដាក់ឱ្យអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម, ការគ្រប់គ្រងវិនិយោគសាធារណៈ,ការអនុវត្តថវិកាកម្មវិធី ដោយផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រថវិកា, និងការធ្វើវិមជ្ឈការហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### *គោលបំណង ៣១÷ រៀបចំ និងដាក់ឱ្យអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈនិងថវិការយៈពេលមធ្យម*

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) ត្រូវបានរៀបចំឡើងដើម្បី (១)គាំទ្រការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដោយផ្អែកលើការគិតគូរពិចារណាអំពីធនធានដែលមាន, លក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងការដាក់កំហិតគោលដៅនៃយុថ្កាហិរញ្ញវត្ថុសាធារណៈ (fiscal anchor), (២)ពង្រឹងប្រសិទ្ធភាពនៃការវិភាជថវិកា (Allocation effeciecy) និង (៣)ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុ (macro-economic and fiscal sustainability)។ MTFF ជាមូលដ្ឋានក្នុងការរៀបចំ MTBF ដែលនឹងរៀបរាប់កាន់តែលម្អិតនូវកម្រិតពិតានចំណាយគោលរបស់ក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងដាក់បញ្ចូលនូវការវិភាគអំពីហានិភ័យហិរញ្ញវត្ថុសាធារណៈ (fiscal risks) សំខាន់ៗ ដែលអាចគំរាមកំហែងដល់ស្ថានភាពហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា។

***ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF)÷*** ក្នុងឆ្នាំ២០២២, កសហវ. បានរៀបចំ MTFF ឆ្នាំ ២០២៣-២០២៥ សម្រាប់ដាក់ឆ្លងនៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក៏ប៉ុន្តែតាមការសម្រេច ត្រូវបានពន្យារពេលអនុវត្ត ១ឆ្នាំទៀត ជំនួសដោយក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ដោយសារភាពមិនប្រាកដប្រជាខ្ពស់នៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងនយោបាយសកល ដែលបណ្តាលមកពីជំងឺកូវីដ-១៩ និងវិបត្តិនយោបាយរវាងអ៊ុយក្រែន និងរុស្ស៊ី ព្រមទាំងការផ្លាស់ប្តូរកម្រងទិន្នន័យ ផ.ស.ស. ដោយប្រើប្រាស់ឆ្នាំគោលថ្មី ដែលនឹងធ្វើឱ្យរចនាសម្ព័ន្ធសេដ្ឋកិច្ចមានការប្រែប្រួល។

***ក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF)÷*** ក្របខ័ណ្ឌថវិការយៈពេលមធ្យមត្រូវបានរៀបចំទៅតាមវិស័យទាំង ៤ រួមមាន វិស័យរដ្ឋបាលទូទៅ វិស័យការពារជាតិនិងសន្តិសុខ វិស័យសង្គមកិច្ច និងវិស័យសេដ្ឋកិច្ច និងលម្អិតទៅតាមក្រសួងស្ថាប័ន ដោយផ្អែកលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF)។ ការរៀបចំក្របខ័ណ្ឌថវិកា

រយៈពេលមធ្យម ក៏ត្រូវពិចារណាផងដែរទៅដល់តម្រូវការចំណាយសម្រាប់កម្មវិធីដែលត្រូវបន្ត និងការប៉ាន់ស្មានតម្រូវការចំណាយសម្រាប់កម្មវិធី ឬគោលនយោបាយថ្មី។ ក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ដោយមានពិតានចំណាយគោល តាមវិស័យតាមក្រសួងស្ថាប័នត្រូវបានរៀបចំ និងទទួលបានការអនុម័តដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល។ ផ្អែកលើក្របខ័ណ្ឌថវិការយៈពេលមធ្យម ក្រសួង-ស្ថាប័នចំនួន៩ ត្រូវបានធ្វើសមាហរណកម្មចំណាយចរន្ត និងចំណាយមូលធនរដ្ឋចូលក្នុងកម្មវិធីផ្អែកលើពិតានថវិកាក្នុងផែនការយុទ្ធសាស្ត្រថវិកា និងក្រសួង-ស្ថាប័នចំនួន ៥ បានធ្វើសមាហរណកម្មចំណាយចរន្ត និងចំណាយមូលធនក្នុងកម្មវិធីដោយផ្អែកលើពិតានថវិកាសម្រាប់ថវិកាកម្មវិធី។

### គោលបំណង ៣២÷ ពង្រឹងការគ្រប់គ្រងវិនិយោគសាធារណៈ

តាមរយៈការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ២០១៩-២០២៥ ដែលត្រូវបានប្រមុខរាជរដ្ឋាភិបាលអនុម័តកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈរួមមួយរបស់ជាតិ ត្រូវបានកែលម្អជាបណ្តើរៗ ដើម្បីធានាបាននូវភាពឆ្លើយតប ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងពង្រឹងសមត្ថភាព ប្រកបដោយចីរភាពនៃការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈ ក្នុងន័យបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការធានាបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាបន្ន។ ក្នុងនោះ វឌ្ឍនភាពសម្រេចបានក្នុងឆ្នាំ២០២១ ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សេចក្តីព្រាងប្រកាសស្តីពីគោលការណ៍ រួមសម្រាប់ការគ្រប់គ្រងគម្រោងថែទាំហេដ្ឋា-រចនាសម្ព័ន្ធផ្លូវថ្នល់ ត្រូវបានអនុម័តជាគោលការណ៍ពីថ្នាក់ដឹកនាំ។ ជាមួយគ្នានេះ, គណៈកម្មការវិនិយោគសាធារណៈ (គ.វ.ស.) និងលេខាធិការដ្ឋានត្រូវបានបង្កើតឡើងតាមរយៈ សេចក្តីប្រកាសដែលត្រូវបានចុះហត្ថលេខាដោយ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ** នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០២១។ ចំណែកឯការរៀបចំយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោងថវិកា គឺក្រុមការងារជំនាញបច្ចេកទេសសម្រាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ ត្រូវបានបង្កើតឡើងតាមរយៈប្រកាសលេខ ៧៥០ សហវ.ប្រក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០។

ដោយឡែក, ក្នុងឆ្នាំ២០២២ ប្រកាសស្តីពីគោលការណ៍រួមសម្រាប់ការគ្រប់គ្រងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និងប្រកាសស្តីពីនីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រង រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈហិរញ្ញ-ប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់) ទទួលបានការអនុម័ត និងដាក់ឱ្យអនុវត្ត។ ម្យ៉ាងទៀត, គោលការណ៍ណែនាំស្តីពីមូលនិធិអភិវឌ្ឍន៍គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងអនុក្រឹត្យស្តីពីការអនុវត្តនីតិវិធីប្រតិបត្តិការ (SOP) សម្រាប់រៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានអនុម័តកាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ និងបានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលកាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២។ SOP នេះមានចំនួន ៣ ភាគ ក្នុងនោះ ភាគ១ អំពីគោលនយោបាយនិងនីតិវិធី SOP, ភាគ២ អំពីគោលការណ៍ណែនាំចំនួន៧ និងភាគ៣ អំពីនីតិវិធីលទ្ធកម្ម។ បន្ថែមពីនេះ, គោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការ នៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលបានការអនុម័ត និងដាក់ឱ្យអនុវត្តផងដែរ។

### គោលបំណង ៣៣÷ ពង្រឹងការរៀបចំ និងការអនុវត្តថវិកាកម្មវិធី ដោយផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រថវិកា

ស្របតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥, គ្រប់ក្រសួង-ស្ថាប័នបានចូលរួមអនុវត្តថវិកាកម្មវិធីពេញលេញត្រឹមឆ្នាំ២០១៨។ ដោយឡែក អនុលោមតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាល

ថ្នាក់ក្រោមជាតិ គ្រប់រដ្ឋបាលរាជធានី-ខេត្តទាំង ២៥ បានអនុវត្តថវិកាកម្មវិធីក្នុងឆ្នាំ២០២១។ បន្ថែមពីនេះ, រដ្ឋបាលរាជធានី-ខេត្តទាំង២៥ បានទទួលការបណ្តុះបណ្តាលអំពីនីតិវិធីនៃការអនុវត្តថវិកាកម្មវិធី ជាបន្តបន្ទាប់។

តារាងទី 5÷ ផែនការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលរាជធានី-ខេត្ត

| ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|
| កំពង់ស្ពឺ | កំពង់ឆ្នាំង | កណ្តាល | កំពង់ចាម | រាជធានីភ្នំពេញ |
| កែប | ពោធិ៍សាត់ | បាត់ដំបង | កំពង់ធំ | |
| កោះកុង | តាកែវ | បន្ទាយមានជ័យ | ព្រះវិហារ | |
| ប៉ៃលិន | កំពត | ស្វាយរៀង | ឧត្តរមានជ័យ | |
| ក្រចេះ | ព្រៃវែង | ត្បូងឃ្មុំ | សៀមរាប | |
| ស្ទឹងត្រែង | រតនគិរី | មណ្ឌលគិរី | ព្រះសីហនុ | |

ក្នុងឆ្នាំ២០២១, អគ្គនាយកដ្ឋានថវិកាបានរៀបចំឯកសារទស្សនាទានស្តីពីការញែកបន្ទុកបុគ្គលិកតាមកម្មវិធី និងបានចាប់ផ្តើមអនុវត្តសាកល្បងនៅ កសហវ. ព្រមទាំងគ្រោងឱ្យគ្រប់ក្រសួង-ស្ថាប័នទាំងអស់ចាប់ផ្តើមញែកបន្ទុកបុគ្គលិកតាមកម្មវិធីនីមួយៗសម្រាប់ថវិកាឆ្នាំ២០២៣។ តាមការអនុវត្តនៅពេលបច្ចុប្បន្ន, ចំណាយបន្ទុកបុគ្គលិកត្រូវបានដាក់ក្នុងកម្មវិធីគាំទ្រ ដែលធ្វើឱ្យក្រសួង-ស្ថាប័នមានការលំបាកក្នុងការញែកបន្ទុកបុគ្គលិកទៅតាមកម្មវិធី ដែលចាំបាច់តម្រូវឱ្យមានការអនុវត្តសាកល្បងនូវការញែកចំណាយបន្ទុកបុគ្គលិកដោយប្រើប្រាស់ថវិកាឆ្នាំ n-1 ដើម្បីក្រសួង-ស្ថាប័ននីមួយៗ សាកល្បងញែកចំណាយបន្ទុកបុគ្គលិកនេះជាបណ្តើរ និងជំហានបន្ទាប់នឹងឈានទៅញែកចំណាយបន្ទុកបុគ្គលិកតាមកម្មវិធីនីមួយៗ នៅពេលគ្រោងថវិកាសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំ។

ផែនការយុទ្ធសាស្រ្តថវិកា គឺជាផែនការបីឆ្នាំរំកិលតាមអភិក្រមពីក្រោមឡើងលើដែលក្រសួង-ស្ថាប័នត្រូវរៀបចំឡើងជារៀងរាល់ឆ្នាំ ដោយផ្សារភ្ជាប់អាទិភាពគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ទៅនឹងគោលដៅតាមវិស័យ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ។ ផែនការយុទ្ធសាស្រ្តថវិកានឹងត្រូវរៀបចំទៅតាមគោលបំណងគោលនយោបាយ និងកម្មវិធី ដោយមានសេចក្តីពន្យល់ខ្លឹមសារ និងសនិទាន ប្រភេទហិរញ្ញប្បទាន សូចនាករគន្លឹះសម្រាប់តាមដានការអនុវត្ត និងត្រួតពិនិត្យលទ្ធផល គោលដៅសមិទ្ធកម្ម ក្របខ័ណ្ឌពេលវេលា និងតម្រូវការថវិកា។ ផែនការយុទ្ធសាស្រ្តថវិកានឹងត្រូវផ្អែកលើពិដានចំណាយ ដែលមាននៅក្នុងក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF)។ ក្នុងក្របខ័ណ្ឌនៃការរៀបចំផែនការយុទ្ធសាស្រ្ត មានគម្លាតនឹងគម្រោងថវិកាប្រចាំឆ្នាំ២០២១ សម្រេចបាន ៩,៨% និងក្នុងឆ្នាំ២០២២សម្រេចបានតិចជាង ១៥% ។ បន្ថែមពីនេះ, ក្រសួងអនុវត្តថវិកាកម្មវិធីចំនួន ១៥[5]ត្រូវបានត្រួតពិនិត្យ និងវាយតម្លៃលើការរៀបចំផែនការយុទ្ធសាស្រ្តថវិកាដោយពិនិត្យឃើញដូចខាងក្រោម÷

-**<u>គោលបំណងគោលនយោបាយ÷</u>** ការរៀបចំជាទូទៅអាចទទួលយកបាន។

[5] ក្រសួងការពារជាតិ, ក្រសួងយុត្តិធម៌, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ,ក្រសួងព័ត៌មាន,ក្រសួងសុខាភិបាល, ក្រសួងរ៉ែ និងថាមពល, ក្រសួងពាណិជ្ជកម្ម, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងបរិស្ថាន, ក្រសួងកិច្ចការនារី, ក្រសួងទេសចរណ៍, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងអភិវឌ្ឍន៍ជនបទ,ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

-**កម្មវិធី÷** ភាគច្រើនអាចទទួលយកបាន តែឈ្មោះកម្មវិធី រចនាសម្ព័ន្ធផ្ទៃក្នុងកម្មវិធី និងគោលបំណងកម្មវិធីរបស់ក្រសួងខ្លះតម្រូវ ឱ្យមានការកែសម្រួលដោយក្រុមការងារបច្ចេកទេសនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្តល់កិច្ចសហការជាមួយនឹងក្រសួង-ស្ថាប័នដែលមានតម្រូវការកែសម្រួលគោលបំណងនៃកម្មវិធី រចនាសម្ព័ន្ធកម្ម ឈ្មោះកម្មវិធី តាមតម្រូវការចាំបាច់របស់ក្រសួង-ស្ថាប័ននីមួយៗ។

-**សូចនាករ÷** នៅតែជាបញ្ហាប្រឈម ព្រោះក្រសួង-ស្ថាប័នខ្លះកំណត់សូចនាករមិនទាន់ច្បាស់លាស់ និងមានគុណភាពល្អ ខណៈដែលសូចនាករខ្លះមិនអាចវាស់វែងបាន។ ទោះជាយ៉ាងណា, កសហវ. កំពុងសម្របសម្រួលជួយពង្រឹងបន្ថែម។

-**ការគ្រោងចំណូល-ចំណាយ÷** ភាគច្រើនឆ្លុះបញ្ចាំងពីលទ្ធភាពប្រមូលចំណូលជាក់ស្តែង តែការគ្រោងចំណាយនៅមិនទាន់គោរពតាមបាន។

អង្គភាពថវិកា គឺជាអង្គភាពត្រូវបានទទួលអាណត្តិកិច្ចច្បាស់លាស់ ក្នុងការអនុវត្តសកម្មភាពការងារ ដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ និងអាចវាស់វែងបាន និងរួមចំណែកក្នុងការសម្រេចគោលបំណងគោលនយោបាយអាទិភាពរបស់ក្រសួង-ស្ថាប័ន។ ក្រសួង ស្ថាប័ននីមួយៗ ត្រូវបង្កើតអង្គភាពថវិកាតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងគោលការណ៍ណែនាំស្តីពីអង្គភាពថវិកា និងបានទទួលស្គាល់ដោយប្រកាសអន្តរក្រសួងរវាងក្រសួង-ស្ថាប័នសាមី និង កសហវ.។ អង្គភាពថវិកាមានសិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពការងារ ក្នុងការរៀបចំ និងគ្រប់គ្រងការអនុវត្តថវិកា ព្រមទាំងក្នុងការត្រួតពិនិត្យលទ្ធផលនៃការអនុវត្តសកម្មភាពការងារ និងការអនុវត្តថវិការបស់ខ្លួនស្របតាមគោលការណ៍កំណត់ដោយក្រសួង-ស្ថាប័ន និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។ ទោះជាយ៉ាងក៏ដោយ, ក្រសួង-ស្ថាប័នមួយចំនួនក៏នៅរក្សាការគ្រប់គ្រងថវិកាតាមបែបប្រមូលផ្តុំនៅឡើយ ដោយអនុញ្ញាតឱ្យមានអង្គភាពថវិកាចំនួនតិចតួច ដែលមានន័យថាថវិកាផ្តល់ដល់អង្គភាពអនុវត្តផ្ទាល់ ក៏មានតិចតួចផងដែរ។ ក្នុងន័យនេះ ការបង្កើនចំនួនអង្គភាពថវិកា និងអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញ ជាការងារសំខាន់ ដែលចាំបាច់ត្រូវជំរុញ និងពង្រឹងសមត្ថភាពបន្ថែម។ ក្នុងទិសដៅវិមជ្ឈការហិរញ្ញវត្ថុនៅតាមក្រសួង-ស្ថាប័ន, រាជរដ្ឋាភិបាលបានដាក់ចេញ អនុក្រឹត្យលេខ ២៤២ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិពេញលេញជូនអង្គភាពថវិកា ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការរៀបចំ អនុវត្តថវិកា ព្រមទាំងត្រួតពិនិត្យលទ្ធផលនៃការអនុវត្តសកម្មភាពការងារ និងថវិកា។ ជាលទ្ធផល, ក្នុងឆ្នាំ២០២២ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធពេញលេញថ្មីចំនួន ៩ និងអង្គភាពថវិកាថ្មីចំនួន ២៨ បន្ថែមត្រូវបានបង្កើតឡើង។ គិតត្រឹមឆ្នាំ ២០២២ អង្គភាពថវិកាមានចំនួនសរុប ៩៤០ ដែលក្នុងនោះនៅរដ្ឋបាលថ្នាក់កណ្តាលមានចំនួន ៣៣៧ និងថ្នាក់មូលដ្ឋាន (មន្ទីរជំនាញរាជធានី-ខេត្ត)មានចំនួន ៦០៣។ សម្រាប់ថ្នាក់កណ្តាល មានអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ៨៧ និងផ្ទេរសិទ្ធិមិនពេញលេញចំនួន ២៥០ ចំណែកឯនៅថ្នាក់មូលដ្ឋាន គ្រប់អង្គភាពថវិកាទាំងអស់ត្រូវបានផ្ទេរសិទ្ធិជាអាណាប័កផ្ទេរសិទ្ធិពេញលេញ។ ទន្ទឹមនេះ, កសហវ. បានចេញប្រកាសលេខ ៩៤៤ សហវ.ប្រក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការអនុវត្តថវិកាតាមរយៈការប្រគល់អាណត្តិកិច្ចច្បាស់

លាស់ ដើម្បីសម្រេចបានសមិទ្ធកម្មការងារ។ រីឯការរៀបចំរបាយការណ៍ស្ដីពីវឌ្ឍនភាព នៃការរៀបចំ និងបង្កើតអង្គភាពថវិកា (ការត្រួតពិនិត្យនិងរៀបចំលក្ខណៈសម្បត្តិកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន និងការកសាងសមត្ថភាព) ដែលរៀបចំឡើងដោយក្រសួង-ស្ថាប័ន ពុំទាន់មានវឌ្ឍនភាពនៅឡើយ។ ទន្ទឹមនេះ, ដើម្បីធ្វើការវាយតម្លៃពីការអនុវត្ត និងការទទួលខុសត្រូវក្នុងការអនុវត្តថវិកាកម្មវិធី, ក្នុងឆ្នាំ២០២១ ក្រសួង-ស្ថាប័នចំនួន ៣៧ ត្រូវបានត្រួតពិនិត្យលក្ខណៈសម្បត្តិអង្គភាពថវិកា។

## *គោលបំណង ៣៤÷ ជំរុញការធ្វើមជ្ឈការហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ*

ផ្អែកតាមផែនការយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ ក្នុងឆ្នាំ២០២១, កសហវ. បានដាក់ឱ្យអនុវត្តប្រកាសលេខ ៥១៣ សហវ.ប្រក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីនីតិវិធីដាក់ឱ្យអនុវត្តថវិកាកម្មវិធីរដ្ឋបាលរាជធានី-ខេត្ត។ ក្នុងឆ្នាំ២០២២ រដ្ឋបាលខណ្ឌចំនួន ៥ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធី និងមានមន្ត្រីរដ្ឋបាលខណ្ឌយ៉ាងតិច ៧០ នាក់ ត្រូវបានបណ្ដុះបណ្ដាលនីតិវិធីអនុវត្តថវិកាកម្មវិធី។ ក្រៅពីនេះ គោលការណ៍ណែនាំស្ដីពីការអនុវត្តថវិកាកម្មវិធីសម្រាប់រដ្ឋបាលខណ្ឌ ក៏បានបញ្ចូលទៅនៅក្នុងសារាចរណែនាំអនុវត្តថវិកាប្រចាំឆ្នាំ២០២២។ ពាក់ព័ន្ធនឹងការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិកា, ក្នុងឆ្នាំ២០២១ បានធ្វើការតម្រឹមជាមួយមន្ទីរជំនាញ, ឆ្នាំ២០២២ បានធ្វើសមាហរណកម្មផែនការជាមួយរដ្ឋបាលក្រុង-ស្រុកចំនួន ១០២ និងក្នុងឆ្នាំ២០២៣ គ្រោងធ្វើសមាហរណកម្មផែនការជាមួយរដ្ឋបាលឃុំ-សង្កាត់។ ការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្ររដ្ឋបាលរាជធានី ខេត្ត រវាងរដ្ឋបាល រាជធានី ខេត្តជាមួយថវិកាក្រុង ស្រុក និងថវិកាឃុំ សង្កាត់ និងការតម្រឹមជាមួយថវិកាមន្ទីរ-ជំនាញ នឹងរួមចំណែកក្នុងការពង្រឹងប្រសិទ្ធភាពនៃការវិភាជន៍ និងការអនុវត្តថវិកា។ ការផ្ទេរមុខងារ ៥៥ ពីការិយាល័យជំនាញ ២០ វិស័យ ដែលបានធ្វើសមាហរណកម្មចូលក្នុងរចនាសម្ព័ន្ធ រដ្ឋបាលក្រុង ស្រុក ពុំទាន់អនុវត្តបានរលូននៅឡើយ ដែលកិច្ចការនេះគួរពន្លឿនការដោះស្រាយទាំងការផ្ទេរធនធានហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ឱ្យស្របនឹងមុខងារទាំង ៥៥ នេះ។

ចំពោះការអនុវត្តគម្រោងតាមរយៈការអនុវត្តវិធីសាស្ត្រលទ្ធកម្មដោយឡែកជាមួយស្ថាប័នរដ្ឋ គឺមិនតម្រូវឱ្យមានកក់ប្រាក់ដើម្បីធានាសុពលភាពទេ។ នៅពេលអនុវត្តគម្រោងចប់ គឺបើកប្រាក់ត្រឹម ៩០% ប៉ុណ្ណោះ ហើយសល់ ១០% ទៀត ត្រូវរក្សាទុកសម្រាប់ធានាសុពលភាពគម្រោងក្នុងរយៈពេល ១២ ខែ។ ប្រសិនបើគម្រោងនោះមាន គុណភាពល្អនោះ ១០% ទៀតនឹងបើកជូន។ ក្នុងករណីស្ថិតក្នុងឆ្នាំថវិកាតែមួយ គឺមិនមានបញ្ហាសម្រាប់ការទូទាត់នោះទេ ប៉ុន្តែក្នុងករណីឆ្លងឆ្នាំថវិកា គឺមិនអាចដកប្រាក់ ១០% ដោយសារថវិកាដែលសល់ត្រូវបង្វែរចូលថវិកាជាតិវិញអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ដូចនេះរដ្ឋបាលរាជធានីភ្នំពេញពុំមានឥណទានសម្រាប់ទូទាត់ ១០% នេះទេ។

***សន្និដ្ឋានផ្នែកទី៣÷*** *ខណៈ MTFF ត្រូវពន្យារពេលអនុវត្ត, ថវិការយៈពេលមធ្យមក៏បាននិងកំពុងដាក់ឱ្យអនុវត្ត និងកែលម្អជាបណ្ដើរៗ ដែលបានបង្កលក្ខណៈងាយស្រួលដល់ក្រសួង-ស្ថាប័ន ក្នុងការរៀបចំថវិកា ដោយមានកំណត់ថវិកាទាំងវិស័យ និងក្រសួង-ស្ថាប័ន ពិសេសការធ្វើសមាហរណកម្មថវិកាចរន្ត និងវិនិយោគ រួមទាំងពេលវេលាអនុលោមតាមប្រតិទិននៃការរៀបចំថវិកា ។ ក៏ប៉ុន្តែ ការធ្វើសមាហរណកម្មរវាងចំណាយថវិកាមូលធន និងថវិកាចរន្ត ព្រមទាំង គុណភាព BSP និង PB ត្រូវបន្តយកចិត្តទុកដាក់។ ដោយឡែក ក្រសួង-ស្ថាប័នមួយចំនួន ក៏នៅរក្សាការ*

*គ្រប់គ្រងថវិកាតាមបែបប្រមូលផ្តុំនៅឡើយ ដោយអនុញ្ញាតឱ្យមានអង្គភាពថវិកាចំនួនតិចតួច ដែលមានន័យថា ថវិកាផ្តល់ដល់អង្គភាពអនុវត្តផ្ទាល់ក៏មានតិចតួចផងដែរ ។ ក្នុងន័យនេះ ការបង្កើនចំនួនអង្គភាពថវិកា និងអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិជាការងារសំខាន់ ដែលចាំបាច់ត្រូវជំរុញ និងពង្រឹងសមត្ថភាពបន្ថែម ខណៈប្រព័ន្ធថវិកាកម្ពុជា បាន និងកំពុងឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ដែលសិទ្ធិអំណាច និងថវិកានឹងត្រូវផ្ទេរវិមជ្ឈការទៅអង្គភាពអនុវត្តផ្ទាល់កាន់តែច្រើន។ ជាមួយគ្នានេះ ការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្ររដ្ឋបាលរាជធានី ខេត្ត រវាងរដ្ឋបាលរាជធានី-ខេត្តជាមួយថវិកាក្រុង ស្រុក និងថវិកាឃុំ សង្កាត់ និងការតម្រឹមជាមួយថវិកាមន្ទីរជំនាញ នឹងរួមចំណែកក្នុងការពង្រឹងប្រសិទ្ធភាពនៃការវិភាជ និងការអនុវត្តថវិកា។ ដោយឡែក ត្រូវពង្រឹងវិមជ្ឈការហិរញ្ញវត្ថុ ក្នុងនោះ មុខងារ ៥៥ ពីការិយាល័យជំនាញ ២០ វិស័យ ដែលបានធ្វើសមាហរណកម្មចូលក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ពុំទាន់អនុវត្តបានរលូននៅឡើយ ដែលកិច្ចការនេះគួរពន្លឿនការដោះស្រាយទាំងការផ្ទេរធនធានហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ឱ្យស្រប នឹងមុខងារទាំង ៥៥ នេះ។*

## ផ្នែកទី៤÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម

ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ ត្រូវបានគិតគូររៀបចំនូវមូលដ្ឋានគន្លឹះសំខាន់ៗ នៅក្នុងដំណាក់កាលទី៣ បូក២ ដើម្បីឈានឆ្ពោះទៅដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" ដែលមានទិសដៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម (Performance-Informed Budgeting)។ ផ្នែកនេះ ផ្តោតលើគោលបំណងចំនួន ៤ រួមមាន÷ (១) ដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម, (២) ដាក់ឱ្យអនុវត្តប្រព័ន្ធតាមដាន និងពិនិត្យសមិទ្ធកម្មតាមក្រសួង-ស្ថាប័ន, (៣) ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យសមិទ្ធកម្មនិងបច្ចេកវិទ្យាព័ត៌មាន (សវនកម្មផ្ទៃក្នុងអធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្មឯករាជ្យ), និង (៤) លើកកម្ពស់តម្លាភាពថវិកា។

### *គោលបំណង ៤១÷ ដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម*

តាមផែនការសកម្មភាពនៃយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, ថវិកាព័ត៌មានសមិទ្ធកម្ម ដែលត្រូវបានហៅកាត់ថា "**ថវិកាសមិទ្ធកម្ម**" នឹងត្រូវអនុវត្តសាកល្បងនូវការរៀបចំគម្រោងថវិកាឆ្នាំ២០២៣។ ដូចនេះ សូចនាករសមិទ្ធកម្មគន្លឹះ នឹងត្រូវរៀបចំឡើង នៅពេលទម្រង់កិច្ចព្រមព្រៀងសមិទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្តសាកល្បង។ ក្នុងន័យនេះ អគ្គនាយកដ្ឋានថវិកាបានរៀបចំ និងដាក់ឱ្យអនុវត្តនូវទម្រង់កិច្ចព្រមព្រៀងសមិទ្ធកម្មតាមរយៈប្រកាសលេខ ១៤៩ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២២។ ក្នុងការរៀបចំគម្រោងថវិកាឆ្នាំ២០២៣, ក្រសួង-ស្ថាប័នបានរៀបចំតាមគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម។ បន្ថែមពីនេះ, កិច្ចព្រៀងសមិទ្ធកម្ម ត្រូវបានរៀបចំ និងផ្សព្វផ្សាយអំពីខ្លឹមសារ និងសេចក្តីពន្យល់លម្អិតអំពីទម្រង់ជូនដល់ក្រសួង-ស្ថាប័ន សម្រាប់ត្រៀមអនុវត្តក្នុងឆ្នាំ ២០២៣។ កិច្ចព្រមព្រៀងសមិទ្ធកម្មនេះ ត្រូវបានកំណត់ជា ៣ កម្រិត÷

- **<u>កម្រិតទី១</u>** គឺ រវាងក្រសួង កសហវ. និងក្រសួង-ស្ថាប័ន
- **<u>កម្រិតទី២</u>** គឺរវាងរដ្ឋមន្ត្រីក្រសួង-ស្ថាប័ន ជាមួយនឹងអ្នកគ្រប់គ្រងកម្មវិធីនៅតាមក្រសួង-ស្ថាប័នសាមី
- **<u>កម្រិតទី៣</u>** គឺរវាងអ្នកគ្រប់គ្រងកម្មវិធីជាមួយនឹងប្រធានអង្គភាពថវិកា។

សម្រាប់ការរៀបចំថវិកាឆ្នាំ២០២៣ ក្រសួង-ស្ថាប័ន ចំនួន ៧ បានអនុវត្តសាកល្បងកិច្ចព្រមព្រៀងសមិទ្ធកម្មនេះ ដែលរួមមាន÷ (១) កសហវ., (២) ក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់, (៣) ក្រសួងកសិកម្ម រុក្ខា-

ប្រមាញ់ និងនេសាទ, (៤) ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, (៥) ក្រសួងអប់រំ យុវជន និងកីឡា, (៦) ក្រសួងសុខាភិបាល, និង (៧) ក្រសួងយុត្តិធម៌។

ដើម្បីឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ចាំបាច់ត្រូវរៀបចំបទដ្ឋានគតិយុត្តឱ្យបានច្បាស់លាស់ ពេញលេញ និងគ្រប់ជ្រុងជ្រោយ រួមមាន ការរៀបចំច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី), ការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ៨១ និង ៨២, ការរៀបចំប្រកាស និងគោលការណ៍ណែនាំបច្ចេកទេសនានា។ ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ធ្វើឡើងដោយស្របតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដោយកំណត់យកគំរូ "**ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម**"។ រចនាសម្ព័ន្ធនៃសេចក្ដីព្រាងច្បាប់នេះត្រូវបានរៀបចំជា ៩ ជំពូក សរុបចំនួន ១០៩ មាត្រា ដោយបានកែសម្រួលរចនាសម្ព័ន្ធនៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ដែលមាន ៨ ជំពូក និង ៩១ មាត្រា។ ទស្សនាទានថ្មីៗ និងគោលការណ៍គន្លឹះៗមួយចំនួនក្នុងទិសដៅកែទម្រង់ត្រូវបានបញ្ចូលទៅក្នុងសេចក្ដីព្រាងច្បាប់នេះ។ សេចក្ដីព្រាងច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ត្រូវបានឆ្លងកិច្ចប្រជុំពេញអង្គ-គណៈរដ្ឋមន្ត្រីនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ និងបានបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិ ព្រមទាំងទទួលបានការអនុម័តនៅក្នុងកិច្ចប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៤ នៅព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣។

ដោយឡែក, ចំពោះការធ្វើវិសោធនកម្មអនុក្រឹត្យលេខ៨១ និង លេខ៨២ ត្រូវបានរៀបចំជាសេចក្ដីព្រាង និងបានដាក់បញ្ចូលគ្នា ដែលត្រូវបានកំណត់ឈ្មោះថ្មី "សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងថវិកា និងគណនេយ្យ-សាធារណៈ"។ អនុក្រឹត្យថ្មីនេះ មានវិសាលភាពគ្របដណ្ដប់បន្ថែមលើទិដ្ឋភាព÷

- **ចំណាយ÷** គ្របដណ្ដប់ទាំងចំណាយចរន្ត និងចំណាយមូលធន និងសមាហរន្តកម្មរវាងចំណាយទាំង២
- **ចំណូល÷** បញ្ចូលគោលការណ៍សំខាន់ៗនៃចំណូល ជាពិសេសចំណូលមិនមែនសារពើពន្ធ ដែលត្រូវកំណត់ពីកម្រិតនៃការប្រមូលចំណូល ការពង្រឹងអនុលោមភាព តម្លាភាពនៃការប្រមូល និងការប្រើប្រាស់ចំណូលមិនមែនសារពើពន្ធរបស់ក្រសួង-ស្ថាប័ន
- **លទ្ធកម្មសាធារណៈ÷** បញ្ចូលបទប្បញ្ញត្តិដែលកំណត់អំពីគោលការណ៍សំខាន់ៗរបស់លទ្ធកម្មសាធារណៈ ដោយឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងលទ្ធកម្មសាធារណៈ និងការអនុវត្តថវិកា។

សេចក្ដីព្រាងអនុក្រឹត្យថ្មីនេះ ត្រូវបានពិភាក្សាផ្ទៃក្នុង គសហវ. និងទទួលបានធាតុចូលពីជំនាញការក្រសួងហិរញ្ញវត្ថុនៃសាធារណរដ្ឋបារាំង ព្រមទាំងកំពុងកែសម្រួល និងធ្វើបច្ចុប្បន្នភាព ឱ្យស្របតាមច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសា-ធារណៈ (ថ្មី)។ អនុក្រឹត្យថ្មីនេះ នឹងក្លាយជាអនុក្រឹត្យគោលសម្រាប់អនុវត្តច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)។ ចំពោះក្របខ័ណ្ឌពេលវេលា, ក្រុមការងារបច្ចេកទេសបានស្នើសុំកំណត់យកត្រឹមត្រីមាសទី២ ឆ្នាំ២០២៣ ពោលគឺខែមិថុនា ឆ្នាំ២០២៣ ជាពេលវេលាថ្មី សម្រាប់ការបញ្ចប់ការរៀបចំសេចក្ដីព្រាងអនុក្រឹត្យថ្មីនេះ ជំនួសឱ្យពេលវេលាត្រឹមចុងត្រីមាសទី៤ ឆ្នាំ២០២២ ដែលបានកំណត់កន្លងមក ក្នុងផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដោយផ្អែកលើដំណើរការ និងវឌ្ឍនភាពនៃការរៀបចំសេចក្ដីព្រាងច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) និងសេចក្ដីព្រាងអនុក្រឹត្យនេះជាក់ស្ដែង ដើម្បីធានាគុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងថវិការយៈពេលវែង។

## *គោលបំណង ៤២÷ ដាក់ឱ្យអនុវត្តប្រព័ន្ធតាមដាន និងពិនិត្យសមិទ្ធកម្មតាមក្រសួង-ស្ថាប័ន*

ដើម្បីពង្រឹងការអនុវត្តប្រព័ន្ធតាមដាន និងត្រួតពិនិត្យសមិទ្ធកម្មតាមក្រសួង-ស្ថាប័ន ក៏ដូចជាដើម្បីជួយដល់រាជរដ្ឋាភិបាលក្នុងការរៀបចំវិភាគ និងអនុវត្តគោលនយោបាយ, កសហវ.បានចេញប្រកាសលេខ ១១៣ សហវ.ប្រកស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម កាលពីដើមឆ្នាំ២០២២។ គោលការណ៍ណែនាំស្តីពីការតាមដាន និងវាយមតម្លៃថវិកាសមិទ្ធកម្មនេះ នឹងជួយកំណត់អាទិភាពសំខាន់ៗ ដែលគាំទ្រដល់ការរៀបចំផែនការ និងគម្រោងថវិកាកាន់តែមានប្រសិទ្ធភាព ព្រមទាំងឆ្លើយតបទៅតាមលទ្ធភាពធនធាន, និងបង្កើនគណនេយ្យភាព និងតម្លាភាពក្នុងការសម្រេចនូវគោលបំណងគោលនយោបាយ ដែលបានដាក់ចេញ និងជាជំនួយដល់ការគ្រប់គ្រងសកម្មភាពការងារឱ្យបានប្រសើរជាងមុន។ ចំណែកឯ សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម និងត្រួតពិនិត្យថវិកា (មានមាតិកា) ត្រូវបានផ្លាស់ប្តូរក្របខ័ណ្ឌពេលវេលាថ្មីទៅត្រីមាសទី២ ឆ្នាំ២០២៤។ ដោយឡែក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តយន្តការសម្រាប់ធ្វើការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្មឆ្នាំ២០២៤ នឹងត្រូវរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងនៅឆ្នាំ២០២៥។

## *គោលបំណង ៤៣÷ ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យសមិទ្ធកម្ម (សវនកម្មផ្ទៃក្នុង អធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្មឯករាជ្យ)*

បន្ទាប់ពីដាក់ឱ្យអនុវត្តច្បាប់ស្តីពីសវនកម្ម ឆ្នាំ២០០០ ដែលបានកំណត់ឱ្យបង្កើតនូវមុខងារសវនកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង-ស្ថាប័ន និងបណ្តាសហគ្រាសសាធារណៈផងដែរនោះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ អនុក្រឹត្យលេខ៤០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈនៅក្នុងឆ្នាំ២០០៥។ ទន្ទឹមនេះ ដើម្បីធ្វើបច្ចុប្បន្នភាពខ្លឹមសារឱ្យស្របតាមបរិបទជាក់ស្តែង និងការវិវត្តន៍នៃសង្គមកម្ពុជា អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង បាននិងកំពុងកែលម្អក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងមុខងារសវនកម្មផ្ទៃក្នុងមួយចំនួន ដោយក្នុងនោះក៏មានការកែសម្រួលសេចក្តីព្រាងអនុក្រឹត្យថ្មីស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងផងដែរ។ បន្ថែមពីនេះ គោលការណ៍ណែនាំសវនកម្មថ្មីៗចំនួន ៣ ត្រូវបានរៀបចំគឺគោលការណ៍ណែនាំនិងស្តង់ដាសវនកម្មសមិទ្ធកម្ម, គោលការណ៍ណែនាំសវនកម្មបច្ចេកវិទ្យាព័ត៌មាន និងគោលការណ៍ណែនាំសវនកម្មលើគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍កាលពីអំឡុងខែមិថុនា ឆ្នាំ២០២០។ ក្នុងឆ្នាំ២០២២ នេះ គោលការណ៍មួយបន្ថែមទៀតស្តីពីការអនុវត្តសវនកម្មអនឡាញ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តផងដែរ។

គោលការណ៍ណែនាំ និងស្តង់ដាសវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មានត្រូវបានប្រកាសដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២០ និងបានផ្សព្វផ្សាយជូនសវនករផ្ទៃក្នុងនៃក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈ តាមរយៈសិក្ខាសាលារួចរាល់ ព្រមទាំងបានដាក់ឱ្យអនុវត្តសាកល្បងជាបន្តបន្ទាប់។

**សវនកម្មសមិទ្ធកម្ម÷** ក្នុងឆ្នាំ២០២០ បានចុះសវនកម្មសាកល្បង ២ គោលដៅ គឺ (១) សវនកម្មលើប្រធានបទ "គម្រោងអង្កេតសហគ្រាសនៅអគ្គនាយកដ្ឋានពន្ធដារ" និង (២) លើប្រធានបទ "គម្រោងស្វ័យប្រវត្តិកម្មនៃការគ្រប់គ្រងការងារពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ"។ ក្នុងឆ្នាំ២០២១ បានអនុវត្តសាកល្បងបន្ថែមទៀតនៅក្រសួងចំនួន ៦ រួម

មាន÷ ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ចំណែកក្នុងឆ្នាំ២០២២ បានអនុវត្តសាកល្បងជាករណីសិក្សានៅក្រសួងចំនួន ៦ បន្ថែមទៀត រួមមាន÷ ក្រសួងផែនការ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងទេសចរណ៍, និងក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា។

**សវនកម្មបច្ចេកវិទ្យាព័ត៌មាន÷** ក្នុងឆ្នាំ២០២០ បានចុះសវនកម្មបច្ចេកវិទ្យាព័ត៌មានសាកល្បង ១ គោលដៅលើប្រធានបទ “ប្រសិទ្ធភាពស្វ័យប្រវត្តិកម្មនៃការគ្រប់គ្រងការងារពន្ធដារ” និងក្នុងឆ្នាំ២០២១ បានអនុវត្តសាកល្បងនៅក្រសួងចំនួន ១០ រួមមាន ÷ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងព័ត៌មាន, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងយុត្តិធម៌, ក្រសួងបរិស្ថាន, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងធម្មការ និងសាសនា, ក្រសួងទេសចរណ៍, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារ និងក្រសួងផែនការ និងក្នុងឆ្នាំ២០២២ បានរៀបចំរបាយការណ៍ព្រាងសវនកម្មបច្ចេកវិទ្យាព័ត៌មានសាកល្បងជាករណីសិក្សានៅក្រសួងចំនួន ៤ រួមមាន÷ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច, ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងពាណិជ្ជ-កម្ម, និង ក្រសួងកិច្ចការនារី។ ជាមួយគ្នានេះ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង បានស្វែងយល់ និងអនុវត្តសាកល្បងការប្រើប្រាស់មុខងារ Audit log ទាក់ទងនឹង÷ ១.មុខងារបញ្ជាទិញ (PO),២. មុខងារសៀវភៅធំ (GL) នៅក្នុងប្រព័ន្ធ FMIS និង៣. មុខងារលទ្ធកម្មពេញលេញ (PR) ក្នុងប្រព័ន្ធ FMIS។

### ❖ ប្រព័ន្ធអធិការកិច្ចហិរញ្ញវត្ថុ

កសហវ. បានប្រកាសដាក់ឱ្យអនុវត្តនូវក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីអធិការកិច្ចហិរញ្ញវត្ថុ កាលពីខែកក្កដា ឆ្នាំ២០១៩ ដោយមានគោលដៅកំណត់វិធាន និងគោលការណ៍ដែលមន្ត្រីអធិការកិច្ចហិរញ្ញវត្ថុត្រូវគោរព និងប្រតិបត្តិតាមដើម្បីបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធភាព គណនេយ្យភាព និងតម្លាភាពលើការងារអធិការកិច្ចហិរញ្ញវត្ថុ។[6] គោលការណ៍គ្រឹះនៃក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីអធិការកិច្ចហិរញ្ញវត្ថុ រួមមាន ១).សមត្ថភាពវិជ្ជាជីវៈ, ២).សុចរិតភាព, ៣).អាកប្បកិរិយា, ៤).ឯករាជ្យភាព, ៥).ទំនាស់ផលប្រយោជន៍, ៦).រក្សាការសម្ងាត់, និង ៧).ការប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈ។ ទន្ទឹមនេះ អគ្គាធិការដ្ឋានបានដាក់ឱ្យប្រើប្រាស់នូវសៀវភៅណែនាំ ស្តីពីអធិការកិច្ចហិរញ្ញវត្ថុ ក្នុងគោល-បំណង ដើម្បីបង្ហាញពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចក្នុងការធ្វើអធិការកិច្ចហិរញ្ញវត្ថុ។ សៀវភៅណែនាំនេះ ជាឯកសារសម្រាប់មន្ត្រីអគ្គាធិការដ្ឋាន សិក្សាស្វែងយល់អំពីតួនាទី និងភារកិច្ចក្នុងការបំពេញការងារអធិការកិច្ចហិរញ្ញវត្ថុ ឱ្យបានច្បាស់លាស់។

ការអនុវត្តត្រួតស៊ីគ្នានៃមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចនៅតាមក្រសួង-ស្ថាប័ន ដោយសារកង្វះទស្សនា-ទានកំណត់ឱ្យដាច់ស្រេចអំពីសមត្ថកិច្ចការងារ ទើបរាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូន កសហវ. ដឹកនាំរៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចរបស់រាជរដ្ឋាភិបាលតែមួយ។ ការរៀបចំក្របខ័ណ្ឌ និង

[6] ប្រកាសលេខ ៦៧៩សហវ.ប្រក ស្តីពីការដាក់ឱ្យអនុវត្តក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីអធិការកិច្ចហិរញ្ញវត្ថុ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩

វិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចនេះ នៅមានវឌ្ឍនភាពយឺតយ៉ាវនៅឡើយ ដោយកំពុងពិភាក្សាជាមួយនឹងទីប្រឹក្សាបារាំង លើសេចក្តីព្រាងរបាយការណ៍ នៃការអនុវត្តតួនាទីភារកិច្ចរបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច និងការផ្តល់យោបល់លើទិសដៅនៃការបែងចែកភារកិច្ច។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីសម្របសម្រួលការបែងចែកតួនាទី ភារកិច្ចសវនកម្មផ្ទៃក្នុង និងអធិការកិច្ចនៃក្រសួង-ស្ថាប័នសម្រាប់រយៈពេលខ្លីបន្ទាន់ចំពោះមុខ, អគ្គាធិការដ្ឋានបានរៀបចំអនុក្រឹត្យលេខ ១៦៨ អនក្រ. បក ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដែលទទួលបានការអនុម័តនៅថ្ងៃទី៨ តុលា ឆ្នាំ២០២០។ អនុក្រឹត្យលេខ ១៦៨ នេះ គឺជាជំហានដំបូងនៃការធ្វើសុខុដុមនីយកម្មមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចនៃដែនសមត្ថកិច្ចរបស់ កសហវ. ក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច និងក្រសួងមុខងារសាធារណៈ ដែលជាតួអង្គអធិការកិច្ចរបស់រាជរដ្ឋាភិបាលលើមុខងារនីមួយៗ។ ដោយឡែកក្នុងកម្រិតក្រសួង-ស្ថាប័ន អនុក្រឹត្យនេះបានចង្អុលបង្ហាញឱ្យក្រសួង-ស្ថាប័នរៀបចំបែងចែកភារកិច្ច របៀបរបបបំពេញការងាររវាងសវនកម្មផ្ទៃក្នុង អគ្គាធិការដ្ឋាន ឬអធិការដ្ឋាន ព្រមទាំងអង្គភាពផ្សេងទៀតដែលមានសមត្ថកិច្ចត្រួតពិនិត្យ ឱ្យបានសមស្រមជៀសវាងការត្រួតពិនិត្យស្ទួនគ្នា ខណៈដែលមុខងារអធិការកិច្ចនៅតាមក្រសួង-ស្ថាប័នភាគច្រើនមានទាំងអគ្គាធិការដ្ឋាន និងអធិការកិច្ចតាមវិស័យ។

តាមរយៈផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុ២០២១-២០២៥, អគ្គាធិការដ្ឋានបានចុះស្រាវជ្រាវ និងរៀបចំរបាយការណ៍លើការអនុវត្តតួនាទីភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ចចំនួន ១២ ក្រសួង-ស្ថាប័ន។ ទន្ទឹមនេះ ស្តង់ដាអធិការកិច្ចហិរញ្ញវត្ថុក៏ត្រូវបានប្រកាស និងផ្សព្វផ្សាយឱ្យអនុវត្តកាលពីដើមឆ្នាំ២០២២ ផងដែរ។ ដោយឡែក, អនុក្រឹត្យលេខ ១០៨ អនក្រ.បក ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២ ត្រូវបានដាក់ឱ្យអនុវត្ត និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយជូនដល់អង្គភាពរងអធិការកិច្ចហិរញ្ញវត្ថុ នៅក្រសួង-ស្ថាប័ន អង្គភាពថ្នាក់កណ្តាល រដ្ឋបាលខេត្ត សាលាដំបូងខេត្ត រដ្ឋបាលក្រុងស្រុក មន្ទីរជំនាញ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈនៅក្នុងខេត្តចំនួន ១២ និងមន្ទីរជំនាញក្នុងរាជធានីភ្នំពេញ និងតំណាងរដ្ឋបាលរាជធានីភ្នំពេញ។

### ❖ ប្រព័ន្ធសវនកម្មផ្ទៃក្រៅ

អាជ្ញាធរសវនកម្មជាតិ បានរៀបចំគោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មប្រតិបត្តិការ[7] និងបានទទួលការអនុម័តកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ។ គោលបំណងចម្បងនៃការធ្វើសវនកម្មប្រតិបត្តិការ គឺដើម្បីលើកកម្ពស់អភិបាលកិច្ចប្រកបដោយភាពសន្សំសំចៃ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

បន្ទាប់ពីគោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មប្រតិបត្តិការត្រូវបានផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្ត, អាជ្ញាធរសវនកម្មជាតិ បានរៀបចំរបាយការណ៍ ចំនួន ៤ រួមមាន (១) របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការនៃការគ្រប់គ្រងផ្លូវលំជនបទ របស់ក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ការិយបរិច្ឆេទ ២០១៨, (២) របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការនៅមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា សម្រាប់ការិយបរិច្ឆេទ ២០១៨, (៣) របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការស្តីពីយន្តការនៃច្រកចេញចូលតែមួយ សម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលខេត្តព្រះសីហនុ រដ្ឋបាលក្រុងព្រះសីហនុ និងរដ្ឋបាលស្រុកព្រៃនប់ សម្រាប់ការិយបរិច្ឆេទ ២០១៨ និង (៤) របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅរដ្ឋបាលខេត្តឧត្តរមានជ័យ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៨។ នៅក្នុងឆ្នាំ២០២០,

---

[7] *អាជ្ញាធរសវនកម្មជាតិប្រើពាក្យប្រតិបត្តិការ ខណៈក្របខណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី៣ ប្រើប្រាស់ពាក្យសមិទ្ធកម្ម*

អាជ្ញាធរសវនកម្មជាតិ បានបន្តធ្វើសវនកម្មលើកិច្ចប្រតិបត្តិការចំនួន ៥ សម្រាប់ការិយបរិច្ឆេទ ២០១៩ រួមមាន (១)ការគ្រប់គ្រងប្រមូលចំណូលសួយសាររ៉ែនៅខេត្តព្រៃវែង, (២)ការរៀបចំ និងការអនុវត្តថវិការបស់រដ្ឋបាលខេត្តកំពត, (៣) ការគ្រប់គ្រងវិស័យទេសចរណ៍របស់ក្រសួងទេសចរណ៍, (៤)ការគ្រប់គ្រងការចុះបញ្ជីដីធ្លី នៅខេត្តមណ្ឌលគិរី និង (៥) ការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង និងសវនកម្មលើការអនុវត្ត FMIS សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២០ នៅក្រសួង-ស្ថាប័នចំនួន ៤ រួមមាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបានផ្ញើជូន ស្ថាប័ននីតិបញ្ញត្តិ និងចម្លងជូន ស្ថាប័នពាក់ព័ន្ធ។ ក្នុងឆ្នាំ២០២១, អាជ្ញាធរសវនកម្មជាតិ បានធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ (Performance Audit) សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ ចំនួន ៥ សម្រាប់ការិយបរិច្ឆេទ២០២០ ជូនអង្គនីតិប្បញ្ញត្តិ។ ដោយឡែកក្នុងឆ្នាំ២០២២, របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការចំនួន ២ ត្រូវបានបញ្ចប់ និងរបាយការណ៍លើកិច្ចប្រតិបត្តិការចំនួន ៤ កំពុងរៀបចំរបាយការណ៍ចុងក្រោយ ជូនទៅស្ថាប័ននីតិប្បញ្ញត្តិ។

### *គោលបំណង ៤៤÷ លើកកម្ពស់តម្លាភាពថវិកា*

គោលបំណងនៅក្នុងផ្នែកនេះ គឺសំដៅលើការផ្តល់ និងទទួលបានព័ត៌មានថវិកាកាន់តែគ្រប់ជ្រុងជ្រោយ និងកាន់តែទូលំទូលាយ ដើម្បីបង្កើនចំណាត់ថ្នាក់នៃសសរស្តម្ភទី២ នៃក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) បន្ថែមមួយកម្រិតទៀត។ វឌ្ឍនភាពនៅក្នុងផ្នែកនេះ មានដូចខាងក្រោម÷

**កសហវ. បានបន្តយកចិត្តទុកលើការបើកចំហរ** ឱ្យមានការចូលរួមមតិយោបល់ពីវិស័យឯកជន, ដៃគូអភិវឌ្ឍន៍, អ្នកសិក្សាស្រាវជ្រាវ, និស្សិត, សាធារណជន, អង្គការមិនមែនរដ្ឋាភិបាល និង បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ នៅក្នុងវេទិកាពិគ្រោះយោបល់ផ្សេងៗនៅក្នុងដំណើរការនៃការរៀបចំថវិកា និងការពង្រីកការបើកទូលាយព័ត៌មានថវិកាជាសាធារណៈ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការវិភាជថវិកា និងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព និងគណនេយ្យភាព។

**ការបង្កើនការចូលរួមពីសាធារណជនក្នុងដំណើរការថវិកា÷** ដើម្បីបង្កើនការចូលរួមពីសាធារណជន, អគ្គនាយកដ្ឋានគោលនយោបាយ និង អគ្គនាយកដ្ឋានថវិកា បានរៀបចំវេទិកាសាធារណៈស្តីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំ។ ចំពោះសៀវភៅថវិកាពលរដ្ឋ, មានការដាក់ចេញនូវសេចក្តីណែនាំស្តីពីការរៀបចំសៀវភៅថវិកាពលរដ្ឋ (Citizen Budget) និងវេទិកាផ្សព្វផ្សាយអំពីថវិកាកម្មវិធីរបស់ក្រសួង-ស្ថាប័ន ដោយឆ្នាំដំបូង ត្រូវបានផ្តោតលើក្រសួងស្ថាប័ន ស្ថិតនៅក្នុងវិស័យសង្គមកិច្ច និង វិស័យសេដ្ឋកិច្ច។

**សាធារណជន÷** សេចក្តីណែនាំស្តីពីការៀបចំវេទិកាសាធារណៈ និងសៀវភៅថវិកាពលរដ្ឋ ដើម្បីផ្សព្វផ្សាយអំពីកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងនីមួយៗ ជូនដល់ដៃគូពាក់ព័ន្ធ និងសាធារណជន ត្រូវបានដាក់ចេញតាមរយៈលិខិតលេខ ១៩៤៨ សហវ.អថ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០២២ ដោយជ្រើសរើសក្រសួងចំនួន ៤ ដែលរួមមាន÷ (១) ក្រសួងអប់រំ យុវជន និងកីឡា, (២) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, (៣) ក្រសួងធនធានទឹក និងឧតុនិយម និង (៤) ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់ការចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ២០២២។

**ការបង្កើនការផ្សព្វផ្សាយឯកសារថវិកា[8]÷** កសហវ. បានធ្វើការផ្សព្វផ្សាយជាសាធារណៈនូវឯកសារថវិកាជាច្រើនទៀតទាត់លើគេហទំព័រ រួមមាន (១) ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, (២) សារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ, (៣) ខ្លឹមសារសង្ខេបប្រតិបត្តិស្តីពីសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ, (៤)សៀវភៅថវិកាសង្ខេបនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ, (៥) សារាចរស្តីពីការអនុវត្ត ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១, (៥)របាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (ស្តង់ដា TOFE & GFS) ប្រចាំខែ, (៦)ច្បាប់ស្តីពីការទូទាត់ថវិកា, (៧)របាយការណ៍និន្នាការសេដ្ឋកិច្ចសង្គមប្រចាំខែ, (៨)ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាស និង (៩)ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ។ ជាមួយគ្នានេះ អាជ្ញាធរសវនកម្មជាតិ បានផ្សព្វផ្សាយរបាយការណ៍សវនកម្មស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ការបង្កើនតម្លាភាពកិច្ចលទ្ធកម្មសាធារណៈ÷** អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បានផ្សព្វផ្សាយព្រឹត្តិបត្រស្ថិតិលទ្ធកម្មសាធារណៈ និងផែនការលទ្ធកម្ម, សេចក្តីជូនដំណឹង និងការប្រគល់កិច្ចសន្យាលើគេហទំព័រផងដែរ។

***សន្និដ្ឋានផ្នែកទី៤÷*** *ការឈានទៅអនុវត្តដំណាក់កាលទី៤ ត្រូវបានត្រៀមខ្លួនរួចរាល់ចាប់ពីឆ្នាំ២០២៣ តទៅ តាមរយៈសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ (អនុក្រឹត្យលេខ ៨១ និងអនុក្រឹត្យលេខ ៨២) ដែលនឹងត្រូវចូលជាធរមាននៅក្នុងអំឡុងឆមាសទី១ ឆ្នាំ២០២៣ ខាងមុខ និងការរៀបចំនិងអនុវត្តជាបណ្តើរៗនូវកិច្ចព្រមព្រៀងសមិទ្ធកម្ម និងគោលការណ៍ណែនាំនានា ដើម្បីធានាប្រសិទ្ធភាពនៃការរៀបចំ និងអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម។ ទោះបីជាយ៉ាងនេះ ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ និងមុខងារសវនកម្មផ្ទៃក្នុងដែលផ្តោតលើសវនកម្មសមិទ្ធកម្មនិងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងមុខងារអធិការកិច្ចនៅគ្រប់ក្រសួង-ស្ថាប័ន ត្រូវពង្រឹងបន្ថែមជាបណ្តើរៗ ដើម្បីធានាថាក្រសួង-ស្ថាប័នមានប្រព័ន្ធត្រួតពិនិត្យតាមដានរឹងមាំ ស្របពេលរាជរដ្ឋាភិបាល បាននិងកំពុងធ្វើវិមជ្ឈការហិរញ្ញវត្ថុដល់ក្រសួង-ស្ថាប័នកាន់តែច្រើន ដែលបច្ចុប្បន្នក្របខ័ណ្ឌនិងគតិយុត្តបាននិងកំពុងរៀបចំជាបណ្តើរៗ។ ចំពោះមុខងាររវាងសវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៅបន្តស្ទួននៅឡើយ ដែលកិច្ចការនេះត្រូវដោះស្រាយ តាមរយៈការពន្លឿនការរៀបចំ និងដាក់ឱ្យអនុវត្តក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច។*

## ផ្នែកទី៥÷ ការកែទម្រង់ប្រកបដោយចីរភាពនិងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត

ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤, កំណែទម្រង់អភិបាលកិច្ចនៅតែជាធាតុស្នូលដ៏សំខាន់ និងជាទិសដៅមុខស្រួចរបស់រាជរដ្ឋាភិបាល។ ក្នុងក្របខ័ណ្ឌនៃការអនុវត្តការងារកែទម្រង់ ភាពជាអ្នកដឹកនាំ ការងារគ្រប់គ្រង ភាពជាម្ចាស់ការទទួលខុសត្រូវ ការរៀបចំ និងគ្រប់គ្រងស្ថាប័នពាក់ព័ន្ធ និងយន្តការលើកទឹកចិត្ត គឺជាកត្តាកំណត់ភាពជោគជ័យ និងចីរភាពនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងន័យនេះ ផ្នែកទី៥÷ ការកែទម្រង់ប្រកបដោយចីរភាពនិងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត នៅបន្តផ្តោតលើគោលបំណងចំនួន ៣ រួមមាន (១) បង្កើនភាពជាអ្នកដឹកនាំ, សមត្ថភាពគ្រប់គ្រង, និងបណ្តុះឆន្ទៈកំណែទម្រង់ ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ,

[8] ឯកសារថវិកាអាចស្វែងរកបាននៅលើគេហទំព័ររបស់ កសហវ. www.mef.gov.kh និងរបស់អាជ្ញាធរសវនកម្មជាតិ www.naacambodia.com។

(២) បង្កើនប្រសិទ្ធភាពនៃការ កសាងសមត្ថភាព និងវិធានការលើកទឹកចិត្ត, និង (៣) ពង្រឹងការកសាងសមត្ថភាព សម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣។

### *គោលបំណង ៥១. ពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាព ក្នុងការគ្រប់គ្រងភាពជាម្ចាស់ និងការទទួលខុសត្រូវក្នុងការកែទម្រង់*

តាមរយៈសារាចររបស់រាជរដ្ឋាភិបាល លេខ ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាន និងនីតិវិធីនៃការរៀបចំ និងអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រសួង-ស្ថាប័ន នីមួយៗត្រូវអនុវត្តផែនការសកម្មភាពដែលត្រូវបានដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករ និងគោលដៅនៃកម្មភាពនីមួយៗតាមកាលកំណត់។ ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យន្តការតាមដានវឌ្ឍនភាពជាប្រចាំត្រូវបានអនុវត្ត។ ក្នុងន័យនេះ ចំពោះសមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ កសហវ. ត្រូវរៀបចំ និងបូកសរុបរបាយការណ៍សវនកម្មប្រចាំត្រីមាស និងរបាយការណ៍ប្រចាំឆ្នាំ ព្រមទាំងផ្ញើមក **អ.គ.ហ.** តាមកាលបរិច្ឆេទកំណត់ ដែលមាននៅក្នុងសារាចរ លេខ ០៩ នេះ។

តាមរយៈការផ្តល់របាយការណ៍វឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាស និងប្រចាំឆ្នាំ មក **អ.គ.ហ.** របស់អង្គភាពអនុវត្តគម្រោងកន្លងមកបានទាន់ពេលវេលាកំណត់ គឺបានឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ដឹកនាំ និងសម្របសម្រួលរបស់ក្រសួង-ស្ថាប័ន និងអគ្គនាយកដ្ឋានក្រោមឱវាទ កសហវ. ដើម្បីពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តរបស់ស្ថាប័ន។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានក្រសួង-ស្ថាប័នមួយចំនួនតូច ដែលគួរតែពង្រឹងការយកចិត្តទុកដាក់ក្នុងការសម្របសម្រួលផ្ទៃក្នុងរបស់ខ្លួនក្នុងការពន្លឿនការបូកសរុប និងផ្តល់របាយការណ៍ឱ្យបានទាន់ពេលវេលា។ បន្ថែមពីនេះ, ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្ត និងការទទួលខុសត្រូវ, សមាសភាពក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ កសហវ. ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំឆ្នាំ។ ជាក់ស្តែង **អ.គ.ហ.** បានណែនាំដល់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធាណៈ នៃក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ កសហវ. ធ្វើបច្ចុប្បន្នភាព និងរៀបចំលក្ខខណ្ឌយោងដោយតម្រឹមជាមួយគោលបំណង/ សកម្មភាពគន្លឹះក្នុង GDAP/MAP។

ក្នុងក្របខ័ណ្ឌនៃការកសាង និងពង្រឹងសមត្ថភាព វិជ្ជាជីវៈ របស់មន្ត្រីអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាព ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ បូក២ និងដំណាក់កាលទី៤ ត្រូវបានអនុម័តដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** តាមចំណារចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១ លើលិខិតលេខ ៣៨៣ សហវ/អគហ។ ទន្ទឹមនេះ ផែនការសកម្មភាពនៃផែនការយុទ្ធសាស្ត្រខាងលើសម្រាប់រយៈពេល ៥ ឆ្នាំ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដោយបានរៀបចំការបណ្តុះបណ្តាល និង វិក្រឹតការ សម្រេចបានសរុបចំនួន ៣២ វគ្គ សិក្ខាកាមចំនួន ១៧៥៦ នាក់ ស្មើនឹង ៩៤% ធៀបនឹងផែនការប្រចាំឆ្នាំ២០២២ ព្រមទាំងបានរៀបចំឯកសារ និងមុខវិជ្ជាបណ្តុះបណ្តាលចំនួន ៣ រួមមាន÷ (១)ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, (២)គណនេយ្យសាធារណៈ, និង (៣)ការគ្រប់គ្រងវិនិយោគសាធារណៈ សម្រាប់ដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២៣។ បន្ថែមពីនេះ, ឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ-សាធារណៈ ត្រូវបានរៀបចំ និងបានគោរពស្នើសុំ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដើម្បីពិនិត្យ និង

អនុសាសន៍ណែនាំដើម្បីជាមូលដ្ឋានសម្រាប់ រៀបចំបទដ្ឋានគតិយុត្ត ដែលជាឧបករណ៍សម្រាប់កំណត់គុណវុឌ្ឍិមន្ត្រីដែលនឹងកាន់មុខងារ ឬទទួលបន្ទុកការងារ លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង-ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

### *គោលបំណង ៥២. ធានាចលនាការនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ត្រង់មុំនៃ "**ការកែទម្រង់អភិបាលកិច្ច**" កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានជំរុញការប្រើប្រាស់ការគ្រប់គ្រងផ្អែកលើលទ្ធផល ដើម្បីផ្លាស់ប្ដូរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្ដោតលើធាតុចូលទៅជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលផ្ដោតលើធាតុចេញ ឬលទ្ធផល និងវិមជ្ឈការ។ ក្នុងន័យនេះ គោលការណ៍ណែនាំការគ្រប់គ្រងផ្អែកលើលទ្ធផលត្រូវបានរៀបចំ និងផ្សព្វផ្សាយជូនគ្រប់អង្គភាពអនុវត្តគម្រោង ព្រមទាំងបានបណ្ដុះបណ្ដាលជូនក្រសួងអប់រំយុវជន និងកីឡា។ បច្ចុប្បន្ន, សេចក្ដីព្រាងក្របខ័ណ្ឌនេះកំពុងត្រូវបានកែសម្រួលចុងក្រោយ បន្ទាប់ពីបានដាក់ជូនគ្រប់អង្គភាពពិនិត្យ និងផ្ដល់យោបល់។ បន្ថែមពីនេះ, ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព (PMAS) ដំណាក់កាលទី២ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅផ្ទៃក្នុងអគ្គលេខាធិការដ្ឋានដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទៅលើការរៀបចំផែនការប្រតិបត្តិ របាយការណ៍ និងការវាយតម្លៃសមិទ្ធកម្ម។ ទោះបីជាយ៉ាងក៏ដោយ ការអនុវត្តប្រព័ន្ធ PMAS នៅក្នុងដំណាក់កាលទី ២ នេះ ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដោយសារមានតម្រូវការបន្ថែមលើការសម្រួលមុខងារក្នុងប្រព័ន្ធ ការរចនាឱ្យត្រូវនឹងតម្រូវការរបស់អ្នកប្រើប្រាស់, និងមានតម្រូវការប្រព័ន្ធលើសពីទំហំការងារដែលត្រូវបានកំណត់ក្នុងផែនការអភិវឌ្ឍន៍។

### *គោលបំណង ៥៣. ពង្រឹងភាពប្រទាក់ក្រឡាគ្នារវាងការដ្ឋាននៃកម្មវិធីកែទម្រង់ផ្សេងៗទៀត*

កម្មវិធីកែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងរដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (ដែលត្រូវបានបង្កើតក្នុងឆ្នាំ២០១៧) គឺជាកែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានបច្ច័យលើគ្រប់ក្រសួង-ស្ថាប័ន និងទាមទាឱ្យមានការឆ្លើយឆ្លងគ្នា បំពេញឱ្យគ្នាទៅវិញទៅមក និងគួរស្ថិតក្នុងល្បឿនប្រហាក់ប្រហែលគ្នា។ ក្នុងន័យនេះ, កិច្ចប្រជុំកម្មវិធីកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំប្រចាំត្រីមាស ដើម្បីសម្របសម្រួល និងកំណត់ទិសដៅរួមនៃការកែទម្រង់អភិបាលកិច្ចល្អ របស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ ឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បូក ១ និងអនុក្រឹត្យលេខ ២៤១ អនក្រ.បក ស្ដីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាលត្រូវបានអនុម័ត និងអនុវត្តនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ និងបានរៀបចំពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២។ ដោយឡែកចំពោះ គោលការណ៍ណែនាំ ស្ដីពីការ ពិណិនាមុខតំណែងត្រូវបានរៀបចំ ហើយសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការដាក់ឱ្យអនុវត្តឯកសារណែនាំស្ដីពីការរៀបចំការពិព័ណ៌នាមុខតំណែងនេះ ត្រូវបានរៀបចំរួចរាល់ក្នុងក្នុងកម្រិតអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ។

***សន្និដ្ឋានផ្នែកទី៥៖*** *ក្រុមការងារកែទម្រង់នៅតាមអង្គភាពក្រោមឱវាទ កសហវ. រួមទាំងមន្ទីរ សហវ. រាជធានី- ខេត្ត និងក្រសួង-ស្ថាប័ន បានអនុវត្តផែនការ និងបានផ្ញើរបាយការណ៍សមិទ្ធកម្មមក* ***អ.គ.ហ.*** *ទាន់ពេលវេលា បើទោះបីជាមានភាពយឺតយ៉ាវចំពោះក្រសួង-ស្ថាប័នតិចតួចក្ដី។ ចលនការនៃការកែទម្រង់ត្រូវបានបន្តចីរភាព ដែលឆ្លុះបញ្ចាំងតាម*

*រយៈការចូលរួមអនុវត្តកម្មវិធីកែទម្រង់ពីគ្រប់តួអង្គ ដែលមានការពាក់ព័ន្ធ។ ក៏ប៉ុន្តែ សង្គតិភាពនៃការរៀបចំ GDAP/MAP/PDAP ជាមួយ CAP ត្រូវបន្តពង្រឹងបន្ថែមទៀត ដើម្បីធានាថាការអនុវត្តសកម្មភាពគឺឆ្លើយតបនឹងគោលដៅសូចនាករដែលបានដាក់ចេញក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនេះ ការងារកែទម្រង់ប្រទាក់ក្រឡាត្រូវបានពង្រឹងតាមរយៈ ការដាក់ឱ្យអនុវត្តឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពីសុខដុមនីយកម្មការកែទម្រង់ ៣ ប្លុក ១ និងយន្តការសម្របសម្រួលការកែទម្រង់ ៣ ប្លុក ១។ ក៏ប៉ុន្តែ ទិសដៅសកម្មភាពនៃកម្មវិធីកែទម្រង់ទាំង ៣ ត្រូវសម្របសម្រួលតម្រឹមបន្ថែម ដើម្បីធានាថា មុខងារដែលត្រូវបានផ្ទេរពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ ត្រូវបានគាំទ្រដោយរចនាសម្ព័ន្ធរដ្ឋបាលនិងធនធានសម្រាប់អនុវត្តការផ្ដល់សេវាប្រកបដោយប្រសិទ្ធភាព។ ដោយឡែក ការកសាងសមត្ថភាពនៅតែជាកិច្ចការអាទិភាព ដែលចាំបាច់លើកកម្ពស់គុណវុឌ្ឍិនៃមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុនៅតាមក្រសួង-ស្ថាប័ន និងពង្រឹងការផ្សព្វផ្សាយ និងការបណ្ដុះបណ្ដាលជូនតួអង្គពាក់ព័ន្ធទាំងអស់។*

## ៣. ការវាយតម្លៃលើបុរេលក្ខខណ្ឌជាមូលដ្ឋានសម្រាប់ឈានទៅអនុវត្ត "គណនេយ្យភាពសមិទ្ធកម្ម"

### ផ្នែកទី១៖ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា

**ចីរភាពនៃការប្រមូលចំណូលថវិការដ្ឋ គឺជាលក្ខខណ្ឌចាំបាច់ ធានាភាពជោគជ័យនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។** គិតចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២២, ចំណូលចរន្តថវិការដ្ឋមានកំណើនជាមធ្យម ០,៦៤ ពិន្ទុភាគរយនៃ ផ.ស.ស.។ បើទោះជាមានការធ្លាក់ចុះយ៉ាងគំហុករហូតដល់ -៣,៤៣ ពិន្ទុភាគរយ ក្នុងឆ្នាំ២០២០ និង -១,១៤ ពិន្ទុភាគរយ ក្នុងឆ្នាំ២០២១ ក៏កំណើនចំណូលចរន្តជាមធ្យមដែលនៅរក្សាបាន ០,៦៤ ពិន្ទុភាគរយនៃ ផ.ស.ស. នេះ ខ្ពស់ជាងគោលដៅ ០,៥ ពិន្ទុភាគរយ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ដំណាក់កាលទី ១ (២០១៤-២០១៨) និង ០,៣ ពិន្ទុភាគរយ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ដំណាក់កាលទី២ (២០១៩-២០២៣)។ ជាក់ស្តែង បន្ទាប់ពីស្ថានភាពនៃវិបត្តិជំងឺកូវីដ-១៩ មានភាពធូរស្បើយ ដោយសារការដាក់ចេញនូវវិធានការចាំបាច់នានាដោយរាជរដ្ឋាភិបាល, ចំណូលចរន្តថវិការដ្ឋក្នុងឆ្នាំ២០២២ បានហក់ឡើងដល់ ១,៧៥ ពិន្ទុភាគរយនៃ ផ.ស.ស. (តួលេខបណ្តោះអាសន្ន)។ ចំណូលចរន្តថវិការដ្ឋ នៅឆ្នាំ២០២៣ ត្រូវបានរំពឹងថានឹងបន្តមានកំណើន ដោយផ្អែកទៅលើការបន្តកំណើនវិជ្ជមាននៃសេដ្ឋកិច្ចកម្ពុជា ពិសេសការអនុវត្តគោលនយោបាយគាំទ្រនានារបស់រាជរដ្ឋាភិបាល ដែលនឹងជួយជំរុញបន្ថែមទៀតនូវសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មក្នុងស្រុកឱ្យមានភាពរស់រវើកឡើងវិញ ក្នុងខណៈពេលដែលវិបត្តិជំងឺកូវីដ-១៩ កាន់តែមានភាពធូរស្បើយ។ ប៉ុន្តែចំណូលចរន្តថវិការដ្ឋនេះ អាចនឹងទទួលរងការប៉ះទង្គិច ជាយថាហេតុ ដែលបណ្តាលពីវិបត្តិសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ដែលបង្កផលប៉ះពាល់ដល់ថ្លៃទំនិញសកល, វិហ្វរពាណិជ្ជកម្ម, ស្ថានភាពហិរញ្ញវត្ថុ និងវិហ្វរវិនិយោគសកល។

**ចំណាយថវិការដ្ឋត្រូវបានបង្កើន និងអនុវត្តកៀកទៅនឹងគោលដៅដែលបានដាក់ចេញក្នុងច្បាប់ថវិកា ប៉ុន្តែវិហ្វរចំណាយតាមត្រីមាសនៅមិនទាន់រលូននៅឡើយ។** គិតចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ ២០២២ ការអនុវត្តចំណាយថវិការដ្ឋស្ថិតក្នុងរង្វង់ +/-៥% ធៀបទៅនឹងច្បាប់ថវិកា។ ផ្អែកតាមច្បាប់ថវិកាប្រចាំឆ្នាំ ចំណាយថវិការដ្ឋមានការកើនឡើងជាមធ្យម ១៦,៧៥% ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០[9] និងថយចុះមកត្រឹម ០,៥១% ក្នុងឆ្នាំ២០២១ និង កើនឡើង ៤,៧៨% ក្នុងឆ្នាំ២០២២ ដែលការថមថយចំណាយនេះ គឺស្ថិតក្នុងស្ថានភាពនៃវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន។ ចំណាយថវិកាក្នុងឆ្នាំ២០២១ ត្រូវបានយកចិត្តទុកដាក់ជាពិសេសទៅលើការបន្តទប់ទល់នឹងការរាតត្បាត និងកាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងដោះស្រាយផលប៉ះពាល់ធ្ងន់ធ្ងរពីជំនន់ទឹកភ្លៀងដែលកើតឡើងនៅឆ្នាំ២០២០។ ចំណាយថវិកាក្នុងឆ្នាំ២០២២ ត្រូវបានបន្តយកចិត្តទុកដាក់លើការដាក់ចេញនូវវិធានការអន្តរាគមន៍សមស្រប និងទាន់ពេលវេលា ដោយបោះជំហានលើគន្លងអភិវឌ្ឍន៍ថ្មី ផ្សារភ្ជាប់នឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មសកល និងបន្តគ្រប់គ្រងផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ និងការកែទម្រង់ជារចនាសម្ព័ន្ធដើម្បីឈាន ឆ្ពោះទៅសម្រេចបាននូវភាពធន់នឹងវិបត្តិ។ រីឯថវិកាឆ្នាំ២០២៣ ដែលជាឆ្នាំចុងអាណត្តិនៃរាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ត្រូវបានរៀបចំក្នុងបរិបទនៃការគិតគូរស្តារកំណើនសេដ្ឋកិច្ច តាមរយៈការសម្របខ្លួនបានទៅនឹងប្រក្រតីភាពថ្មី។ យ៉ាងណាមិញ

[9] ថវិការដ្ឋក្នុងឆ្នាំ២០២០ ត្រូវបានធ្វើវិចារណកម្មនូវមុខសញ្ញាចំណាយ ដោយបង្វែរឆ្ពោះទៅដោះស្រាយតម្រូវការបន្ទាន់ និងចាំបាច់ភ្លាមៗ ដោយផ្តោតអាទិភាពទៅលើការប្រយុទ្ធប្រឆាំង និងជំងឺកូវីដ-១៩ និងការដោះស្រាយផលប៉ះពាល់ដែលបណ្តាលពីពីរីករាលដាលនៃជំងឺកូវីដ-១៩

ការគិតគូរជាយុទ្ធសាស្ត្រក្នុងការប្រើប្រាស់ថវិកាឱ្យចំគោលដៅអាទិភាព ស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល និងបរិការណ៍ជាក់ស្តែង ទាមទារឱ្យមានការពង្រឹងវិហ្វូរចំណាយតាមត្រីមាសនីមួយៗ។ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២២ វិហ្វូរចំណាយតាមត្រីមាសមិនទាន់រលូននៅឡើយ ពិសេសចំណាយក្នុងត្រីមាសទី៣ ដែលនៅទាបជាងគោលដៅ(៧០%) ដែលមាននិន្នាការគរការអនុវត្តថវិកានៅចុងឆ្នាំ ហើយប្រតិបត្តិការថវិកានៅបន្តដល់ឆ្នាំបន្ទាប់។

**ខណៈដែលការគ្រប់គ្រងចំណូលសារពើពន្ធ បន្តមានវឌ្ឍនភាពល្អប្រសើរ, ការគ្រប់គ្រងចំណូលមិនមែនសារពើ-ពន្ធត្រូវបានបន្តពង្រឹងតាមរយៈការដាក់ចេញនូវបទដ្ឋានគតិយុត្ត និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ប៉ុន្តែនៅមានសក្តានុពលបន្ថែមទៀតក្នុងការកៀរគរចំណូលមិនមែនសារពើពន្ធ។** ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២។ ច្បាប់នេះ មានគោលបំណងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធសម្រាប់ចំណូលថវិកាជាតិ ដោយកំណត់ក្របខ័ណ្ឌច្បាប់ ស្ថាប័នជាគោល យន្តការ វិធាន និងនីតិវិធីនៃការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ សំដៅរួមចំណែកបម្រើឧត្តមប្រយោជន៍នៃការអភិវឌ្ឍ សេដ្ឋកិច្ចនិងសង្គមកម្ពុជា។ ទន្ទឹមនេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ត្រូវបានផ្តួចផ្តើមឡើងក្នុងឆ្នាំ២០១៨ ក្នុងគោលបំណងគ្រប់គ្រងការប្រមូល និងកត់ត្រាចំណូលមិនមែនសារពើពន្ធឱ្យមានប្រសិទ្ធភាព និងសុក្រឹតភាព។ ទន្ទឹមនេះ ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-payment) ត្រូវបានបង្កើតឡើងដើម្បីផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធ NRMIS ក្នុងគោលបំណងផ្តល់ជាជម្រើសបន្ថែម និងភាពងាយស្រួលដល់សាធារណជនក្នុងការបង់ ចំណូលមិនមែនសារពើពន្ធ ចំពោះការប្រើប្រាស់សេវាសាធារណៈ។ និយាយដោយឡែក ការប្រមូលចំណូលមិនមែនសារពើពន្ធពីការជួលទ្រព្យសម្បត្តិរដ្ឋនៅមានសក្តានុពលបន្ថែមទៀត តាមរយៈការត្រួតពិនិត្យកិច្ចសន្យាជួលឡើងវិញ ដោយផ្លាស់ប្តូរវិធីសាស្ត្រគណនាថ្លៃជួលទ្រព្យសម្បត្តិរដ្ឋ ស្របតាមបរិការណ៍នៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន។

**ការទូទាត់តាមអេឡិចត្រូនិក (EFT) ត្រូវបានដាក់ឱ្យអនុវត្ត និងមានវឌ្ឍនភាពល្អប្រសើរ។** EFT ជាមុខងារនៅក្នុងប្រព័ន្ធ FMIS ដែលត្រូវបានដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០១៨ សម្រាប់ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកជូនក្រុមហ៊ុនផ្គត់ផ្គង់ និងក្រសួង-ស្ថាប័ន ដោយមិនតម្រូវឱ្យមានការបោះផ្សាយមូលប្បទានបត្រដោយអគ្គនាយកដ្ឋានរតនាគារជាតិឡើយ។ ការប្រើប្រាស់ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច គឺសន្សំសំចៃពេលវេលា និងកាត់បន្ថយចំណាយលើការប្រើប្រាស់ក្រដាសស្នាម ជាពិសេសអាចកាត់បន្ថយនូវការជួបគ្នារវាងអ្នកទទួលផល និង អ្នកបើកផ្តល់ ដែលជាប្រការជួយពង្រឹងតម្លាភាព និង ប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ។ ការទូទាត់តាម EFT សម្រេចបានពេញលេញ ជាពិសេសការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការ ២ ដងក្នុង ១ខែទាន់ពេលវេលា ហើយមិនមានការកកើតឡើងវិញនូវបំណុលកកស្ទះ (គិតត្រឹម ៦០ ថ្ងៃ)។

**ការអនុវត្តកិច្ចលទ្ធកម្ម ជាពិសេសការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម និងការរក្សាបាននូវតម្លៃនៃលុយនឹងត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ថ្មី)។** វិមជ្ឈការកិច្ចលទ្ធកម្មគឺជាសមាសធាតុសំខាន់នៅក្នុងសេចក្តីព្រាងច្បាប់ ក្នុងនោះសិទ្ធិគ្រប់គ្រង និងសម្រេចលើកិច្ចលទ្ធកម្ម នឹងត្រូវបានផ្តល់ជូនជាបណ្តើរៗដល់ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ ការចរចាជាមួយអ្នកដេញថ្លៃតែមួយ (single source procurement) នឹងត្រូវរឹតបន្តឹង ដែលការណ៍នេះ នឹងលើកកម្ពស់ដល់កិច្ចលទ្ធកម្មប្រកួតប្រជែង ដែលឈានដល់ការរក្សាបានតម្លៃនៃលុយ។

## ផ្នែកទី២÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ

**ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) បានពង្រីកវិសាលភាពនៃការប្រើប្រាស់ទូទាំងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងកំពុងពង្រីក និងពង្រឹងការអនុវត្តជាជំហានៗ។** គិតត្រឹមឆ្នាំ ២០២២, ប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យអនុវត្តគ្រប់ក្រសួង-ស្ថាប័ន, រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, រតនាគាររាជធានី-ខេត្ត, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត, និងរដ្ឋបាលរាជធានី-ខេត្ត។ មុខងារស្នូលបន្ថែមថ្មី (មុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញ និងការតម្រង់ទិសនីតិវិធីអនុវត្តតាមប្រព័ន្ធ FMIS (Business Process Streamlining) ត្រូវបានពង្រឹងនិងពង្រីកជាបណ្ដើរៗ តាមជំហានយុទ្ធសាស្ត្រ។ ការធ្វើឌីជីថលូបនីយកម្មនៃការអនុវត្តថវិកាតាមប្រព័ន្ធ FMIS ជាលក្ខខ័ណ្ឌចាំបាច់ ក្នុងការរួមចំណែកដល់ការពង្រឹងតម្លាភាព និងគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ ជាពិសេសពន្លឿនវំហូរនៃការអនុវត្តថវិកាតាមរយៈការតម្រង់ទិសនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS (Business Process Streamlining)។

**ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តបទដ្ឋានគតិយុត្ត និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។** ច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រូវបានដាក់ឱ្យប្រើប្រាស់នៅថ្ងៃ១២ ខែវិច្ឆិកា ឆ្នាំ២០២០។ ច្បាប់នេះ មានគោលបំណងគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋគ្រប់ប្រភេទ ដោយកំណត់ក្របខ័ណ្ឌច្បាប់ និងស្ថាប័នជាគោល សំដៅរួមចំណែកបម្រើឧត្តមប្រយោជន៍នៃអភិវឌ្ឍសេដ្ឋកិច្ច-សង្គម បរិស្ថាន និងវប្បធម៌កម្ពុជា។ ជាមួយគ្នានេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ត្រូវបានផ្ដួចផ្ដើមឡើងនៅឆ្នាំ២០១៦ ក្នុងគោលបំណងត្រួតពិនិត្យ តាមដាន កត់ត្រា និងគ្រប់គ្រង ទ្រព្យសម្បត្តិរដ្ឋ តាមក្រសួង-ស្ថាប័ន, អង្គភាពប្រើប្រាស់ និងអង្គភាពកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ឱ្យមានប្រសិទ្ធភាពខ្ពស់។ ការដាក់ឱ្យអនុវត្តប្រព័ន្ធ SARMIS បានជួយជំរុញឱ្យការរៀបចំបញ្ជីសារពើភណ្ឌក្នុងឆ្នាំ២០២១ កើនដល់ ៨៧% (២៦៤៣/៣០៥៣ អង្គភាពប្រើប្រាស់) និងរំពឹងថាមានការកើនឡើងបន្ថែមទៀតបន្ទាប់ពីដាក់ឱ្យអនុវត្តដល់រដ្ឋបាល ឃុំ សង្កាត់។

**ចំណាត់ថ្នាក់ថវិកាទាំង ៧ ត្រូវបានដាក់ឱ្យអនុវត្ត និងបញ្ចូលកូដទៅក្នុងប្រព័ន្ធ FMIS ប៉ុន្តែការអនុវត្តពុំទាន់បានពេញលេញនៅឡើយ។** ចំណាត់ថ្នាក់ភូមិសាស្ត្រ ចំណាត់ថ្នាក់មុខងារ និងចំណាត់ថ្នាក់ប្រភពមូលធិធិ ពុំទាន់ត្រូវបានអនុវត្តពេញលេញ ដែលទិន្នន័យពុំទាន់អាចប្រើប្រាស់បានពេញលេញតាមតម្រូវការនៅឡើយ។ ទន្ទឹមនេះ ការអនុវត្ត ចំណាត់ថ្នាក់កម្មវិធីក៏នៅមានកម្រិត ដែលឆ្លុះបញ្ចាំងតាមរយៈការមិនអាចកត់ត្រាបានពេញលេញនូវចំណាយពាក់ព័ន្ធបន្ទុកបុគ្គលិក និងចំណាយវិនិយោគ ដែលស្ថិតក្រោមកម្មវិធីជាក់លាក់នីមួយៗ។

**ការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានពង្រឹងជាប្រចាំ ដែលឆ្លុះបញ្ចាំងតាមរយៈសូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានបន្តរក្សាក្រោមពិតានរហូតមកទល់ឆ្នាំ២០២២។** ក្នុងការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាលប្រកាន់ ខ្ជាប់នូវស្មារតីប្រុងប្រយ័ត្នខ្ពស់ ដោយបានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍គន្លឹះៗ ទាំង ៥ រួមមាន÷ (១) ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន (២) ត្រូវខ្ចីតែឥណទានដែលមានកម្រិត សម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់ (៣) ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យ បង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម (៤) ត្រូវប្រើប្រាស់ឥណទាន ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត (៥) ត្រូវប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធ

សាធារណៈ ដែលត្រូវមានស្តង់ដារ និងគុណភាពខ្ពស់ ស្របតាមគោលការណ៍ នៃការគ្រប់គ្រង ការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេសការធានាបាននូវចីរភាពសេដ្ឋកិច្ច សង្គម បរិស្ថាន និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ តាមរយៈការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍គន្លឹះៗ ទាំងនេះ បានធ្វើឱ្យស្ថានភាពបំណុលសាធារណៈរបស់កម្ពុជាមានលក្ខណៈល្អប្រសើរជាលំដាប់។ ជាក់ស្តែង ផ្អែកតាមការវិភាគចីរភាពបំណុល បង្ហាញថា អនុបាតបំណុលទាំង ៥ របស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់ ក្នុងនោះ អនុបាតបំណុលសំខាន់ជាងគេ គឺអនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស. មានត្រឹម ២៤,៩០% នៅឆ្នាំ២០២២ ដែលមានកម្រិតទាបជាងអនុបាតគោល (៤០%)។

**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ត្រូវបន្តយកចិត្តទុកដាក់បន្ថែមទៀត**។ កិច្ចការនេះ នឹងត្រូវបានពង្រឹងជាបណ្តើរៗ តាមរយៈការដាក់ឱ្យអនុវត្តលក្ខណវិនិច្ឆ័យ អប្បបរមា នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងការដាក់ចេញនូវឯកសារ យុទ្ធសាស្ត្រនៃ ការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ ដែលឯកសារយុទ្ធសាស្ត្រនេះ រំពឹងថាអាចដាក់ឱ្យអនុវត្ត ក្នុងឆ្នាំ២០២៣។

### ផ្នែកទី៣: ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

**ការដាក់ឱ្យអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) និងក្របខ័ណ្ឌថវិការយៈពេលមធ្យម នឹងជួយពង្រឹងវិន័យថវិកា និងកែលម្អម៉ូដែលព្យាករណ៍ហិរញ្ញវត្ថុសាធារណៈ ជាពិសេសពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹង គោលនយោបាយរបស់រាជរដ្ឋាភិបាល**។ MTFF ត្រូវបានរៀបចំឡើងក្នុងគោលបំណង (១) គាំទ្រការផ្សារភ្ជាប់ថវិកាទៅនឹង គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដោយផ្អែកលើការគិតគូរអំពីលទ្ធភាពធនធាន, លក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងការដាក់គោលដៅយុថ្កាហិរញ្ញវត្ថុសាធារណៈ, (២) ពង្រឹងប្រសិទ្ធភាពនៃការវិភាជថវិកា និង (៣) ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុ។ MTFF ត្រូវបានផ្តួចផ្តើមរៀបចំឡើងក្នុងឆ្នាំ២០១៩ ប៉ុន្តែរហូតមកដល់ឆ្នាំ ២០២២ ពុំទាន់បានអនុវត្តនៅឡើយ ដោយសារស្ថានភាពសេដ្ឋកិច្ចមិនប្រាកដប្រជា ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ និង វិបត្តិសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ដោយបន្តអនុវត្តដូចរាល់ឆ្នាំនូវក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ សម្រាប់ជាមូលដ្ឋានរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី។ តាមការគ្រោងទុក, MTFF នឹងត្រូវដាក់ឱ្យអនុវត្ត ក្នុងឆ្នាំ២០២៤ សម្រាប់ក្របខ័ណ្ឌថវិកាឆ្នាំ២០២៥-២០២៧។ ដោយឡែក MTBF ត្រូវបានរៀបចំឡើងដើម្បីប៉ាន់ស្មាននូវ លទ្ធភាពធនធាន សម្រាប់ជាមូលដ្ឋាននៃការវិភាជថវិកាទៅតាមវិស័យ និងក្រសួង-ស្ថាប័ន នីមួយៗ ដោយគិតគូរអំពីការ ព្យាករតម្រូវការនៃកម្មវិធី ដែលត្រូវប្រើប្រាស់ថវិកាសម្រាប់ផ្តល់សេវាសាធារណៈ ជូនសាធារណជន និងការវិភាជថវិកា ពហុឆ្នាំ ដែលរាជរដ្ឋាភិបាលនឹងអាចវិភាជថវិកាបន្ថែមទៅតាមវិស័យអាទិភាព ស្របតាម គោលនយោបាយអាទិភាព។ MTBF ត្រូវបានអនុវត្តសាកល្បងតាំងពីឆ្នាំ២០១៩ ដោយមានការកំណត់ពិតានចំណាយគោលតាមវិស័យ និងតាមក្រសួង-ស្ថាប័ន។ រីឯ MTBF ២០២៣-២០២៥ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំប៉ុន្តែ ពុំទាន់ត្រូវបានដាក់ឱ្យអនុវត្តនៅ ឡើយ។ ការដាក់ឱ្យអនុវត្ត MTBF នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងជួយពង្រឹងដំណើរការ នៃការរៀបចំគម្រោងផែនការថវិកា ប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត។

**ផែនការយុទ្ធសាស្ត្រថវិកា (BSP) ត្រូវបានដាក់ឱ្យអនុវត្តទូទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និង ត្រូវបានកែលម្អជាលំដាប់ ប៉ុន្តែការធ្វើសមាហរណកម្មផែនយុទ្ធសាស្ត្រថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបន្តយកចិត្ត**

**ទុកដាក់**។ BSP គឺជាឧបករណ៍សំខាន់សម្រាប់(១)ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងគោលនយោបាយរបស់រាជរដ្ឋាភិបាល, (២)បង្កើនវិចារណកម្មអាទិភាពចំណាយឱ្យកាន់តែឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន, (៣) ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង-ស្ថាប័ន ដើម្បីសម្រេចគោលបំណងគោល-នយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ(៤)ជាមូលដ្ឋានសម្រាប់ការពន្យល់ និងការបង្ហាញសេចក្ដីសំអាងអំពីតម្រូវការថវិកាសម្រាប់អនុវត្តគោលនយោបាយ និង(៥)ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំចំគោលដៅអាទិភាព។ ការរៀបចំ BSP ត្រូវបានកែលម្អជាលំដាប់ ប៉ុន្តែត្រូវបន្តពង្រឹងគុណភាពបន្ថែមទៀត។ ដោយឡែក ការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្ររដ្ឋបាលរាជធានី ខេត្ត រវាងរដ្ឋបាលរាជធានី ខេត្តជាមួយថវិកា ក្រុង ស្រុក និងថវិកាឃុំ សង្កាត់ និងការតម្រឹមជាមួយថវិកាមន្ទីរជំនាញ ដែលនឹងរួមចំណែកក្នុងការពង្រឹងប្រសិទ្ធភាព នៃការវិភាជ និងការអនុវត្តថវិកា ត្រូវបន្តយកចិត្តខ្ពស់ ដោយបច្ចុប្បន្នការធ្វើសមាហរណកម្មមិនទាន់បានរលូននៅឡើយ។

**ថវិកាកម្មវិធី ដែលជាឧបករណ៍ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយត្រូវបានពង្រីកវិសាលភាពអនុវត្តទូទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ខណៈចំនួនអង្គភាពថវិកាត្រូវបានបង្កើន ហើយសិទ្ធិអំណាចត្រូវបានផ្ទេរទៅអង្គភាពថវិកាជាបណ្ដើរៗ**។ គិតត្រឹមឆ្នាំ២០២២ អង្គភាពថវិកាមានចំនួនសរុប ៩៤០ ដែលក្នុងនោះរដ្ឋបាលថ្នាក់កណ្ដាល មានអង្គភាពថវិកាអណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ៨៧/៣៣៧ ឬប្រមាណ ២៦% និង ថ្នាក់មូលដ្ឋាន (មន្ទីរជំនាញរាជធានី ខេត្ត)មានអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ៦០៣/៦០៣ ឬ ១០០%។ ការបង្កើន អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅរដ្ឋបាលកណ្ដាល នៅមានចំនួនទាបនៅឡើយ ដែលកិច្ចការនេះគួរត្រូវ បន្តជំរុញបន្ថែមទៀត ខណៈប្រព័ន្ធថវិកាកម្ពុជា បាននិងកំពុងឈានទៅអនុវត្តថវិកាព័តិមានសមិទ្ធកម្ម ដែលសិទ្ធិអំណាច និងថវិកាត្រូវផ្ទេរវិមជ្ឈការទៅអង្គភាពអនុវត្ត ផ្ទាល់កាន់តែច្រើន។ បន្ថែមពីនេះ ការធ្វើសមាហរណកម្មចំណាយចរន្ត និងចំណាយមូលធន ដែលត្រូវរៀបចំសម្រាប់ក្រសួងចំនួន៩ នឹងរួមចំណែកដល់ការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។

**ការគ្រប់គ្រងការវិនិយោគសាធារណៈត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តបទដ្ឋានគតិយុត្ត**។ បទដ្ឋានគតិយុត្តគោលដែលត្រូវបានដាក់ឱ្យអនុវត្តក្នុងនោះ រួមមាន÷ ច្បាប់ស្ដីពីការវិនិយោគ, ច្បាប់ស្ដីពីយន្តការភាពជាដៃគូរវាង រដ្ឋនិងឯកជន, អនុក្រឹត្យគោលស្ដីពីការគ្រប់គ្រងការវិនិយោគសាធារណៈ, និងអនុវត្តស្ដីពីការដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានក្រៅប្រទេស។ រីឯបទដ្ឋានគតិយុត្តគាំទ្រដែលត្រូវបានដាក់ឱ្យអនុវត្តរួមមាន÷ ប្រកាសស្ដីពីនីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រង រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ ហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ, ប្រកាសស្ដីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្ដីពីនីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ, ប្រកាសស្ដីពីគោលការណ៍រួមសម្រាប់ការគ្រប់គ្រងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ, ប្រកាសស្ដីពីគោលការណ៍រួមសម្រាប់ការគ្រប់គ្រងគម្រោងថែទាំហេដ្ឋា-រចនាសម្ព័ន្ធផ្លូវថ្នល់, ប្រកាសស្ដីពីការបង្កើតគណៈកម្មការវិនិយោគសាធារណៈ និង ប្រកាសអន្តរក្រសួងស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបំពេញបន្ថែមលើសេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

## ផ្នែកទី៤÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម

**ការឈានទៅអនុវត្តដំណាក់កាលទី៤ ត្រូវបានត្រៀមខ្លួនជាបណ្ដើរៗ ចាប់ពីឆ្នាំ២០២៣ តទៅ តាមរយៈការចូលជាធរមាននូវច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) និង សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ។** ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) បានកំណត់អំពីគោលការណ៍ជាមូលដ្ឋាន សម្រាប់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងការរៀបចំច្បាប់ហិរញ្ញវត្ថុ ជាពិសេសជំហានទីមួយៗ នៃដំណើរការរៀបចំ អនុម័ត និងអនុវត្តថវិកា និងការត្រួតពិនិត្យលទ្ធផលថវិកា ព្រមទាំងការកំណត់មុខងារ និងការទទួលខុសត្រូវរបស់តួអង្គ ពាក់ព័ន្ធ ដើម្បីសម្រេចបាននូវភាពជឿទុកចិត្តថវិកា គណនេយ្យភាពហិរញ្ញវត្ថុ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្ម សំដៅធានាប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ច និងសមធម៌សង្គម។ រីឯសេចក្ដីព្រាងអនុក្រឹត្យស្ដីពី ការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ គឺជាការដាក់បញ្ចូលរួមគ្នារវាងអនុក្រឹតលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈ និងអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ មានគោលបំណងធ្វើសមាហរណកម្មប្រព័ន្ធត្រួតពិនិត្យថវិកា ដោយធ្វើឱ្យច្បាស់លាស់ និងឱ្យខ្លីនូវនីតិវិធីអនុវត្ត និងត្រួតពិនិត្យថវិកា ទាំងនៅក្រសួង-ស្ថាប័ន និងនៅ កសហវ.។

**កិច្ចព្រមព្រៀងសមិទ្ធកម្ម ដែលឆ្លុះបញ្ចាំងអំពីលទ្ធផលដែលត្រូវសម្រេចបានក្នុងឆ្នាំថវិកា ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងជាបណ្ដើរៗ។** សម្រាប់ថវិកាឆ្នាំ២០២៣ ក្រសួងចំនួន ៧ ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនូវកិច្ចព្រមព្រៀងសមិទ្ធកម្ម។ កិច្ចព្រមព្រៀងសមិទ្ធកម្មនេះ ត្រូវបានកំណត់ជា ៣ កម្រិត។ **កម្រិតទី១** គឺ រវាង កសហវ. និងក្រសួង-ស្ថាប័ន។ **កម្រិតទី២** គឺរវាងរដ្ឋមន្ត្រីក្រសួង-ស្ថាប័ន ជាមួយនឹងអ្នកគ្រប់គ្រងកម្មវិធីនៅតាមក្រសួង-ស្ថាប័នសាមី។ **កម្រិតទី៣** គឺរវាងអ្នកគ្រប់គ្រងកម្មវិធីជាមួយនឹងប្រធានអង្គភាពថវិកា។

**ក្របខ័ណ្ឌតាមដាន និងវាយតម្លៃត្រូវបានពង្រឹងជាបណ្ដើរតាមរយៈការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម ប៉ុន្តែត្រូវបន្តយកចិត្តទុកចំពោះការតាមដានវាយតម្លៃនៅតាមក្រសួង-ស្ថាប័ន។** ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មល្អ តម្រូវឱ្យមានការតាមដាន និងវាយតម្លៃជាទៀងទាត់។ ប្រព័ន្ធនេះ ផ្តល់ជាយន្តការទទួលព័ត៌មានត្រឡប់មកវិញ សម្រាប់ការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត និងឈ្វេងយល់អំពីវឌ្ឍនភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃកម្មវិធីនីមួយៗ ហើយសំខាន់ជាងនេះ គឺការដាក់វិធានការកែតម្រូវទាន់ពេលវេលានៅពេលដែលម្មវិធីមិនមានវឌ្ឍនភាពល្អ ឬមានវឌ្ឍនភាពលឿនជ្រុលទៅមុខ។ ស្របតាមទិសដៅនេះ គោលការណ៍ណែនាំស្ដីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីជាយន្តការចាំបាច់ក្នុងការជំរុញការអនុវត្តថវិកាសមិទ្ធកម្ម តាមរយៈការរៀបចំជាយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផលប្រកដោយប្រសិទ្ធភាព។ ប៉ុន្តែ កត្តាដែល គួរឱ្យព្រួយបារម្ភ ការរៀបចំប្រព័ន្ធតាមដាននិងវាយតម្លៃថវិកាសមិទ្ធកម្មសម្រាប់ផ្ទៃក្នុងក្រសួង ស្ថាប័ននីមួយៗ ពុំទាន់ទទួលបានការយកចិត្តទុកខ្ពស់នៅឡើយ។

**និន្នាការនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុដល់ក្រសួង ស្ថាប័នកាន់តែច្រើន តម្រូវឱ្យមានការពង្រឹងការធ្វើសវនកម្មសមិទ្ធកម្ម និងសវនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។** ស្របតាមទិសដៅនេះ គោលការណ៍ណែនាំសវនកម្មសមិទ្ធកម្ម និង

គោលការណ៍ណែនាំសវនកម្មបច្ចេកវិទ្យាព័ត៌មាន ត្រូវបានដាក់ឱ្យអនុវត្ត។ គោលការណ៍ណែនាំសវនកម្មសមិទ្ធកម្ម បានជួយឱ្យសវនករយល់ដឹងអំពីនីតិវិធីធ្វើសវនកម្មសមិទ្ធកម្ម រួមបញ្ចូលទាំង ការរៀបចំផែនការ ការអនុវត្ត និងការរៀបចំរបាយការណ៍មានលក្ខណៈស្តង់ដា។ រីឯ គោលការណ៍ណែនាំសវនកម្មបច្ចេកវិទ្យាព័ត៌មាន មានគោលបំណងជួយដល់ការធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៅក្នុងបរិស្ថានបច្ចេកវិទ្យាព័ត៌មាន ដែលអនុវត្តក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល។ ថ្វីត្បិតគោលការណ៍ទាំងនេះ ត្រូវបានដាក់ឱ្យអនុវត្ត ប៉ុន្តែពុំទាន់ត្រូវបានយកចិត្តទុកខ្ពស់នៅឡើយនៅតាមក្រសួង-ស្ថាប័ន ដែលជាប្រការត្រូវពង្រឹងបន្ថែមទៀត។

**ការស្ទួនមុខងារសវកម្មផ្ទៃក្នុង និងអធិការកិច្ច នៅតែបន្តជាបញ្ហាប្រឈម។** អង្គភាពមួយអាចទទួលការត្រួតពិនិត្យ ៦ ដងក្នុងមួយឆ្នាំ ក្នុងនោះពីសមត្ថកិច្ចផ្ទៃក្នុងរបស់ខ្លួន គឺអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង។ រីឯសមត្ថកិច្ចផ្ទៃក្រៅរួមមាន÷ ក្រសួងទំនាក់ទំនងសភា ព្រឹទ្ធសភា និងអធិការកិច្ច, អាជ្ញាធរសវនកម្មជាតិ, អគ្គាធិការដ្ឋាន កសហវ, និងសវនកម្មលទ្ធកម្ម កសហវ.។ កិច្ចការនេះត្រូវបានសម្របសម្រួលបានមួយចំណែកតាមរយៈការដាក់ចេញនូវ អនុក្រឹត្យ លេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ២០២០ ស្តីពី ក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សនកម្មផ្ទៃក្នុង និងអធិការកិច្ច។ ទោះជាយ៉ាងណា កិច្ចការទាំងនេះ នឹងត្រូវបានដោះស្រាយតាមរយៈ ការរៀបចំក្របខ័ណ្ឌ និងវិធាននៃសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដែលនៅមានវឌ្ឍនភាពយឺតនៅឡើយ។

## ផ្នែកទី៥÷ ការកែទម្រង់ប្រកបដោយចីរភាពនិងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត

**ធនធានមនុស្សពាក់ព័ន្ធនឹងជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រឹងជាបណ្តើរៗតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរយៈពេល ៥ ឆ្នាំ និងការដាក់ចេញនូវកម្មវិធីវិញ្ញាបនបត្រ។** ផែនការយុទ្ធសាស្ត្រនេះ មានគោលបំណងអភិវឌ្ឍសមត្ថភាព ជំនាញវិជ្ជាជីវៈ និងកោសល្យឯកទេស ប្រកបដោយគុណភាព នវានុវត្តន៍ និង មនសិកាជូនមន្ត្រីរាជការក្នុងមុខងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីបំពេញតួនាទី ភារកិច្ច ប្រកបដោយ ឆន្ទៈ ស្មារតី ទទួលខុសត្រូវ និងភាពជាម្ចាស់សម្រាប់រួមចំណែកសម្រេចគោលដៅនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងការកសាងគណនេយ្យភាពចំពោះសមិទ្ធកម្ម។ ការកសាងធនធានមនុស្សនឹងត្រូវលើកកម្ពស់ថែមមួយកម្រិតទៀត តាមរយៈការដាក់ចេញនូវអនុក្រឹត្យស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលផ្សារភ្ជាប់ជាមួយនឹងកម្មវិធីវិញ្ញាបនបត្រ។

**ការងារកែទម្រង់ប្រទាក់ក្រឡា ត្រូវបានពង្រឹង តាមរយៈការដាក់ឱ្យអនុវត្តឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ និងយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១។** ឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំឡើងដោយអនុលោមតាមអភិក្រមចំនួន ៤ គឺ÷ ទី១) អភិក្រមរក្សាគំហើញទាំងមូល ដែលសំដៅដល់ប្រការដែលកម្មវិធីកែទម្រង់មួយត្រូវពឹងផ្អែកនិងអាស្រ័យលើកម្មវិធីកែទម្រង់មួយទៀត ដោយប្រទាកក្រឡាគ្នានិងមានទំនាក់ទំនងមិនអាចខ្វះបាន, ទី២) អភិក្រមចូលរួមចំណែកតាមតួនាទី សំដៅដល់កម្មវិធីកែទម្រង់នីមួយៗ បំពេញឱ្យគ្នាមិនអាចខ្វះបានទៅតាមតួនាទី និងសមត្ថកិច្ចនៅក្នុងក្របខណ្ឌនៃមុខងារស្ថាប័នរៀងៗខ្លួនដែលមានកំណត់ដោយច្បាប់ និងបទបញ្ញត្តិជាធរមាន, ទី៣) អភិក្រមរក្សាភាពជាម្ចាស់ និងគាំទ្រកិច្ចសហការ គឺការគោរពភាពជាម្ចាស់លើវឌ្ឍនភាព និងគណនេយ្យភាពចំពោះកម្មវិធីកែទម្រង់របស់ខ្លួនផង និងផ្តល់ការគាំទ្រ និងកិច្ចសហការប្រកបដោយឆន្ទៈ ជាមួយនឹងកម្មវិធីកែទម្រង់ផ្សេងទៀតផង និង ទី៤) អភិក្រមបុរេសកម្មគឺការប្រមើល និងត្រៀមលក្ខណៈ

ដោះស្រាយបញ្ហាជាមួយគ្នាតាមរយៈយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ ដោយមិនរង់ចាំ បញ្ហាកើតឡើងទើបមានសកម្មភាពនោះឡើយ។

**ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ នឹងមានថវិកាទ្រទ្រង់គ្រប់គ្រងតាមរយៈការអនុវត្តមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២ ជាយថាហេតុបដិភាគពីរាជរដ្ឋាភិបាល**។ មូលនិធិនេះ គឺជាការបង់ភាគទាននៃចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នប្រមូលចំណូលមិនមែនសារពើពន្ធ។ ការដាក់ឱ្យអនុវត្តមូលនិធិនេះ ក្នុងគោលដៅបង្កើតឱ្យមានកញ្ចប់ថវិកាគ្រប់ជ្រុងជ្រោយមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលអាចទ្រទ្រង់ និងជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយចីរភាព និងប្រសិទ្ធភាពក្នុងភាពជាម្ចាស់ពេញលេញលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងបរិការណ៍ដែលនិន្នាការនៃការផ្តល់ជំនួយហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍នឹងមានការថមថយ បន្តិចម្តងៗ នៅពេលកម្ពុជាឈានឆ្ពោះទៅរកការអភិវឌ្ឍទាំងផ្នែកសង្គម-សេដ្ឋកិច្ច។ បន្ថែមពីនេះ បដិភាគរបស់រាជរដ្ឋាភិបាលនឹងត្រូវបំពេញបង្គ្រប់បន្ថែមក្នុងករណីចាំបាច់។ អនុក្រឹត្យស្តីពីការបង្កើតមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវចូលធរមាន ដើម្បីអនុវត្តនូវមូលនិធិ ដំណាក់កាលទី២ នេះ ។

## ៤. អាទិភាពក្នុងដំណាក់កាលទី៤

ទន្ទឹមនឹងការសម្រេចបាននូវខឿនទី១/ដំណាក់កាលទី១ និងខឿនទី២/ដំណាក់កាលទី២, ការអនុវត្តដំណាក់កាលទី៣ ពីឆ្នាំ២០១៦-២០២២ សម្រេចបានជាសារវន្តនូវគោលបំណងនៃខឿនទី៣ ពោលគឺ វឌ្ឍនភាពសម្រេចបានកសាងមូលដ្ឋានរឹងមាំគ្រប់គ្រាន់ ដោយបានបញ្ចប់ការដាក់ឱ្យអនុវត្តថវិកាកម្មវិធី និងការកសាងមូលដ្ឋានចាំបាច់សម្រាប់ការអនុវត្តថវិកាសមិទ្ធកម្ម ទន្ទឹមនឹងការបន្តពង្រឹងខឿនទី១ និងពង្រីកការអនុវត្តខឿនទី២។ ក្នុងនោះ ក្របខ័ណ្ឌថវិការយៈពេលមធ្យមត្រូវបានរៀបចំប្រកបដោយសុក្រឹតភាព ក្នុងគោលដៅជំរុញឱ្យក្រសួង-ស្ថាប័នរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ ឱ្យកាន់តែមានសុក្រឹតភាព, គ្រប់ជ្រុងជ្រោយ និងតម្លាភាព ព្រមទាំងកំណត់គោលបំណងគោលនយោបាយ, កម្មវិធី, អនុកម្មវិធ, ចង្កោមសកម្មភាព, សកម្មភាព និងសូចនាករមានភាពប្រទាក់ក្រឡាគ្នា។ ដោយឡែក ការគ្រប់គ្រង, ការវិភាគម៉ាក្រូសេដ្ឋកិច្ច និងការវិភាគហានិភ័យបានគ្រប់ជ្រុងជ្រោយដោយរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច (កំណើន ផសស. ៧% ក្នុងមួយឆ្នាំ, អតិផរណាក្រោម ៥%, កាត់បន្ថយឱនភាពថវិកា, ពង្រីកលំហរថវិកា និងស្ថិរភាពអត្រាប្តូរប្រាក់។ ចំណែក ប្រព័ន្ធគណនេយ្យ, ប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ពេញលេញដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងផ្ទៃក្រៅត្រូវពង្រឹងជាបណ្តើរៗ, និងប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម និងប្រព័ន្ធថវិកាផ្អែកលើព័ត៌មានសមិទ្ធកម្ម ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់។

ទោះបីជាយ៉ាងនេះក្តី តាមលទ្ធផលនៃការវាយតម្លៃខាងលើ ទន្ទឹមនឹងវឌ្ឍនភាពជាទីមោទន ក៏នៅមានការងារសេសសល់ដែលចាំបាច់ត្រូវជំរុញបញ្ចប់ការរៀបចំ និងទិសដៅអាទិភាពដែលត្រូវបន្តពង្រឹងក្នុងខឿនទីមួយៗ ក្នុងដំណាក់កាលបន្ទាប់ គឺ "**គណនេយ្យភាពសមិទ្ធកម្ម**" និយាយម្យ៉ាងទៀត គឺ ដំណាក់កាលទី៤ នឹងផ្តល់អាទិភាពខ្ពស់លើការកសាងប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ទន្ទឹមនឹងការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា, គណនេយ្យភាពហិរញ្ញវត្ថុ និងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ រួមមានជាអាទិ៍÷

- **ផ្នែកទី១÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា** ត្រូវបន្តពង្រឹងការដ្ឋានកែទម្រង់ដែលមានស្រាប់ រួមមាន ការបន្តធ្វើទំនើបកម្មរដ្ឋបាលចំណូល និងបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធនិងសេវាប្រមូលចំណូលតាមអនឡាញ, ការធ្វើពិពិធកម្មចំណូលដោយចាប់ផ្តើមអនុវត្តប្រភេទពន្ធថ្មី និងការប្រមូលចំណូលពីប្រភពដែលមានស្រាប់ឱ្យអស់សក្តានុពល ជាពិសេស បន្តផ្តោតលើការកសាងគតិយុត្ត និងយន្តការអនុវត្តសម្រាប់ពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រមូលនិងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធបន្ថែម, និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។ ចំណែក, ការអនុវត្តផែនការចំណាយ នៅតែរក្សានិន្នាការបង្គរនៅត្រីមាសទី៣ និងត្រីមាសទី៤ ទោះបីមានវឌ្ឍនភាពលើការអនុវត្តវិធានការពន្លឿនការអនុវត្តចំណាយ ដូចជាការភ្ជាប់ផែនការលទ្ធកម្ម និងផែនការផលទានរដ្ឋទេយ្យបុរេប្រទានជាមួយសំណើផែនការថវិកាប្រចាំឆ្នាំ ព្រមទាំងការរៀបចំ និងកែសម្រួលបទដ្ឋានគតិយុត្តមួយចំនួនសំដៅកែពន្លឿន និងសម្រួលនីតិវិធីអនុវត្តចំណាយ។ ក្នុងន័យនេះ ក្នុងជំហានបន្ទាប់ ត្រូវបន្តជំរុញការរៀបចំគតិយុត្តដើម្បីបង្កើនប្រសិទ្ធភាពនីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្ម រួមមាន ដាក់ឱ្យអនុវត្តការបង្កើនសិទ្ធិសម្រេចកិច្ចលទ្ធកម្ម ជំហានទី២ និងបង្កើនការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងកិច្ចលទ្ធកម្ម តាមរយៈការដាក់ឱ្យអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ទន្ទឹមនឹងការបន្តពន្លឿនការអនុវត្ត

ផែនការចំណាយរបស់ក្រសួង-ស្ថាប័ននៅដើមឆ្នាំ និងការបិទបញ្ជប់ប្រតិបត្តិការថវិកានៅចុងឆ្នាំ ស្របតាមទិសដៅនៃការកែទម្រង់។

- **ផ្នែកទី២÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ** ត្រូវបន្តពង្រឹងនិងពង្រីកការដ្ឋានប្រព័ន្ធ FMIS បន្ថែមទៀត ទោះបីជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងដំណាក់កាលជាបន្តបន្ទាប់ និងបានក្លាយជាឆ្អឹងខ្នងនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល។ អាទិភាពនាពេលខាងមុខ ត្រូវបន្តផ្ដោតលើការពង្រឹងការប្រើប្រាស់មុខងារដែលមានស្រាប់និងគ្រោងអភិវឌ្ឍន៍បន្ថែមក្នុងប្រព័ន្ធ FMIS ហើយអនុវត្តដើម្បីឱ្យក្លាយជាប្រព័ន្ធស្វ័យប្រវត្តិកម្មនៃនីតិវិធីរៀបចំនិងអនុវត្តថវិកា (រួមទាំងប្រតិបត្តិការចំណាយបុរេប្រទាន), គ្រប់គ្រងលទ្ធកម្ម, សន្និធិ និងទ្រព្យសម្បត្តិរដ្ឋ, និងការផលិតរបាយការណ៍ស្របតាមស្តង់ដាគណនេយ្យជាតិ និងអន្តរជាតិ និងត្រូវយកចិត្តទុកដាក់បន្ថែមទៀតលើការបិទបញ្ជីគណនេយ្យទាន់ពេលវេលា ស្របតាមទិសដៅនៃការកែទម្រង់។ ម្យ៉ាងទៀតក៏គិតគូរជំរុញការរៀបចំរបាយការណ៍អនុវត្តថវិកាតាមចំណាត់ថ្នាក់នៃមាតិកាថវិកាទាំង ៧ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ស្របតាមស្តង់ដាគណនេយ្យសាធារណៈ។ ទន្ទឹមនេះ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវបន្តពង្រីកការប្រើប្រាស់ប្រព័ន្ធ SARMIS, ពង្រឹងគុណភាពនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងជំរុញការរៀបចំ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងនោះរួមមានឯកសារគោលស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។ ដោយឡែក ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ត្រូវបន្តយកចិត្តទុកដាក់ តាមរយៈការកសាងក្របខ័ណ្ឌគតិយុត្ត។
- **ផ្នែកទី៣÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅគោលនយោបាយ** ត្រូវបន្តពង្រឹងការរៀបចំ និងអនុវត្តផែនការថវិកា និងកម្មវិធី/អនុកម្មវិធី/គម្រោងក្នុងផែនការថវិកា។ ក្នុងនោះ បន្តជំរុញការដាក់ឱ្យអនុវត្ត MTFF និង MTBF ឱ្យក្លាយជាពិដានចំណាយគោល សម្រាប់រៀបចំនិងអនុវត្តផែនការថវិកាប្រកបដោយភាពជឿទុកចិត្តខ្ពស់ និងពង្រឹងអនុលោមភាពទៅនឹងពិដានចំណាយគោលពហុឆ្នាំ។ ចំពោះការគ្រប់គ្រងការវិនិយោគសាធារណៈ ត្រូវបន្តជំរុញការធ្វើសមាហរណកម្មថវិកាវិនិយោគទៅក្នុងកម្មវិធី និងការរៀបចំនិងការអនុវត្តគោលការណ៍ណែនាំនានា ដើម្បីពង្រឹងការគ្រប់គ្រងវិនិយោគសាធារណៈ ជាមួយគ្នានឹងការបន្តពង្រឹងការតម្រឹមផែនការយុទ្ធសាស្ត្រថវិការបស់ រដ្ឋបាលថ្នាក់ក្រោមជាតិរវាងរាជធានី-ខេត្តជាមួយនឹងថវិកាមន្ទីរជំនាញ និងការធ្វើវិមជ្ឈការហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ។ ទន្ទឹមនឹងនេះ បន្តពង្រឹងយន្តការរៀបចំ តាមដាន និងវាយតម្លៃការអនុវត្តថវិកានៅតាមក្រសួង-ស្ថាប័ន ក្នុងនោះបន្តបង្កើនសិទ្ធិសម្រេចថវិកា តាមរយៈការបង្កើនចំនួនអង្គភាពថវិកា និងការតម្រឹមតួនាទី និងការទទួលខុសត្រូវតាមកម្មវិធីនៃផែនការថវិកា។
- **ផ្នែកទី៤÷ ការកសាងគណនេយ្យភាពសមិទ្ធកម្ម** ត្រូវបានសម្រេចជាសារវន្តនូវការត្រៀមខ្លួនក្នុងការអនុវត្តជាបណ្ដើរៗនូវថវិកាព័ត៌មានសមិទ្ធកម្ម។ ទោះជាយ៉ាងនេះក្ដី ការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្មទាមទាឱ្យមានការកែសម្រួលនីតិវិធីរៀបចំ អនុវត្ត កត់ត្រា និងរាយការណ៍ថវិកា ហើយការផ្លាស់ប្ដូរឥរិយាបថក្នុងការអនុវត្តនីតិវិធីថ្មីត្រូវមានការបញ្ជ្រាបព័ត៌មាននិងការបណ្ដុះបណ្ដាល ដើម្បីផ្ដល់លទ្ធភាព និងភាពទន់ភ្លន់បន្ថែមជូនអង្គភាពថវិកាគ្រប់កម្រិតអាចប្រើប្រាស់ធនធាន ដោយផ្ដោតលើសមិទ្ធកម្ម និងប្រកបគណនេយ្យភាព។ ក្នុងន័យនេះ ក្របខ័ណ្ឌសម្រាប់ការអនុវត្ត និងត្រួតពិនិត្យថវិកាព័ត៌មានសមិទ្ធកម្ម ត្រូវបន្តជំរុញការរៀបចំ និងដាក់ឱ្យអនុវត្តបន្ថែមទៀត។

ជាមួយគ្នានេះ និន្នាការនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុដល់ក្រសួង-ស្ថាប័នកាន់តែច្រើន តម្រូវឱ្យមានការពង្រឹងការធ្វើសវនកម្មសមិទ្ធកម្ម និងសវនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលកិច្ចការនេះតម្រូវឱ្យបន្តយកចិត្តទុកដាក់បន្ថែមទៀតក្នុងដំណាក់កាលបន្ទាប់ ពិសេសការរៀបចំឱ្យរួចរាល់នូវប្រព័ន្ធនិងក្របខ័ណ្ឌសម្រាប់អនុវត្តមុខងារ និងភារកិច្ច នៃសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដែលកន្លងមក ការស្ទួនមុខងារសវកម្មផ្ទៃក្នុង និងអធិការកិច្ច នៅតែបន្តជាបញ្ហាប្រឈម។

- **ផ្នែកទី៥÷ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត** ទាមទារឱ្យមានការយកចិត្តទុកដាក់បន្តទៀត ដោយសារការបណ្តុះបណ្តាលកន្លងមកនៅមិនទាន់ឆ្លើយនឹងនិន្នាការកែទម្រង់បានពេញលេញនៅឡើយ។ ក្នុងជំហានបន្ទាប់ ការបន្តបណ្តុះបណ្តាលសម្រាប់ក្រសួង-ស្ថាប័ននឹងត្រូវបានយកចិត្តទុកដាក់បន្ថែមទៀត។ ក្នុងនោះ ការដាក់ចេញនូវអនុក្រឹត្យស្តីពីគុណវុឌ្ឍិរបស់មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលផ្សារភ្ជាប់ជាមួយកម្មវិធីវិញ្ញាបនបត្រ នឹងលើកកម្ពស់មួយកម្រិតទៀតលើការកសាងធនធានមនុស្សនេះ។ បន្ថែមពីនេះ ទិសដៅសកម្មភាពនៃកម្មវិធីកែទម្រង់ទាំង ៣ ក៏គួរតែត្រូវសម្របសម្រួលតម្រឹមបន្ថែម ដើម្បីធានាថា មុខងារដែលត្រូវបានផ្ទេរពីថ្នាក់ជាតិ ទៅថ្នាក់ក្រោមជាតិ ត្រូវបានគាំទ្រដោយរចនាសម្ព័ន្ធរដ្ឋបាលនិងធនធាន សម្រាប់អនុវត្តការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព។

## ៥. ការគ្រប់គ្រងហានិភ័យ

ភាពរឹងមាំនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាឧបករណ៍គោលនយោបាយដ៏ចាំបាច់បំផុត សម្រាប់គាំទ្ររាជរដ្ឋាភិបាលក្នុងការរៀបចំនិងអនុវត្តគោលនយោបាយសង្គម-សេដ្ឋកិច្ច ឆ្លើយតបទៅនឹងវិបត្តិ និងក្រោយពីវិបត្តិជំងឺកូវីដ-១៩ និងសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន។ កម្ពុជានឹងបន្តពង្រឹង និងស្តារវិស័យដែលជាចន្ទល់កំណើនឡើងវិញ ព្រមទាំងឆ្ពោះទៅចាប់យកឱកាសថ្មីៗបន្ថែមទៀត ស្របនឹងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃនិន្នាការសេដ្ឋកិច្ចសកល និងតំបន់ សំដៅកសាងម៉ូដែលកំណើនសេដ្ឋកិច្ចរយៈពេលវែង ដើម្បីធានាការកសាងភាពធន់នៃសេដ្ឋកិច្ច និងសង្គម ឱ្យកាន់តែរឹងមាំ និងមានភាពឆ្លើយតបខ្ពស់។

ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យតាមដានផែនការសកម្មភាពរួម ដំណាក់កាលទី៣ ប្លុក២ ហានិភ័យត្រូវបានកំណត់ ដើម្បីដោះស្រាយជាជំហាន ស្របតាមទិសដៅការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ កម្រិតហានិភ័យត្រូវបានបែងចែកជាបីម្រិត រួមមាន ខ្ពស់, មធ្យម និងទាប ដែលផ្អែកលើលក្ខខណ្ឌកំណត់ចំនួន ២ រួមមាន សារៈសំខាន់នៃការធានាបាននូវការសម្រេចចក្ខុវិស័យ និងក្របខ័ណ្ឌពេលវេលាដែលបានកំណត់។

តារាងទី 6 ÷ ការគ្រប់គ្រងហានិភ័យ

| ល.រ | ហានិភ័យ | កម្រិត | វិធានការ |
|---|---|---|---|
| ១ | ***សេដ្ឋកិច្ច និងហិរញ្ញវត្ថុសកល***<br>ការប្រែប្រួល និងការគំរាមកំហែងបរិបទសេដ្ឋកិច្ចសកល, និងការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ និងភាពតានតឹងនៃភូមិសាស្ត្រនយោបាយ ដែលជះឥទ្ធិពលលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | មធ្យម | - វិភាគកម្មថវិកា និងពង្រឹងគុណភាពចំណាយថវិកា<br>- ពង្រីកមូលដ្ឋានពន្ធ<br>- ពង្រឹងជវភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងជំរុញការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម លើការគ្រប់គ្រងចំណូលនិងចំណាយ។ |
| ២ | ***ការត្រួតពិនិត្យ និងការគ្រប់គ្រងថវិកា***<br>- សម្ពាធថវិកា ម្យ៉ាងមកពីការកើនឡើងថវិកាចរន្ត និងការថមថយថវិកាដៃគូអភិវឌ្ឍន៍ ដែលបណ្តាលឱ្យមានហានិភ័យហិរញ្ញវត្ថុ និងបង្កើនបន្ទុកបំណុលសាធារណៈ ទាំងមានមុខសញ្ញា និងលាក់មុខ<br>- វិប្បូរ និងភាពរលូននៃការអនុវត្តថវិកាគឺនៅមានកម្រិត និងមិនទាន់សម្រេចបានតាមគោលដៅនៅឡើយ។ | មធ្យម | - ដាក់ចេញវិធានការដោះស្រាយបំណុលកកស្ទះ<br>- ជំរុញការស្វ័យប្រវត្តិកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>- ដោះស្រាយការស្ទួនមុខងាររវាងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងរតនាគារ។ |

| ល.រ | ហានិភ័យ | កម្រិត | វិធានការ |
| --- | --- | --- | --- |
| ៣ | ***ការអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្រនៃការកែទម្រង់គន្លឹះៗ***<br>- ការពន្យារពេលនៃការអនុវត្តសកម្មភាពកែទម្រង់ណាមួយនឹងប៉ះពាល់ដល់ការកែទម្រង់ផ្សេងទៀត។ | ខ្ពស់ | ពង្រឹងយន្តការត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រគន្លឹះនីមួយៗ ដោយត្រូវរៀបចំរបាយការណ៍ និងកិច្ចប្រជុំតាមដានប្រចាំឆមាស និងឆ្នាំជាទៀងទាត់ ដើម្បីឱ្យគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់អនុវត្តយុទ្ធសាស្ត្រគន្លឹះៗនីមួយៗ នៃកម្មវិធីកែទម្រង់ ប្រកបដោយឆន្ទៈ មនសិការ និងការទទួលខុសត្រូវខ្ពស់។ |
| ៤ | ***ការសម្របសម្រួល***<br>- ខណៈការងារកែទម្រង់កាន់តែកើនឡើង អ.គ.ហ. ត្រូវសម្របសម្រួលជាមួយក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំ កសហវ., ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត។<br>- ការយល់ដឹងរបស់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើប្រព័ន្ធរបស់ខ្លួន និងភាពជាម្ចាស់នៃការកែទម្រង់ការគ្រងចាំបាច់ត្រូវបង្កើនការយកចិត្តទុកដាក់បន្ថែម។ | ខ្ពស់ | - ការកំណត់ភាពលំដាប់លំដោយអាទិភាពការងារកែទម្រង់ក្នុងផ្នែកនីមួយៗ នៃ CAP នឹងជួយសម្រួចការងារកែទម្រង់, បន្ថយបន្ទុកសម្របសម្រួល និងងាយស្រួលក្នុងការត្រួតពិនិត្យតាមដានវឌ្ឍនភាព ហើយលទ្ធផលសម្រេចបាននឹងជួយកែទម្រង់ប្រព័ន្ធជាបណ្តើរៗ<br>- ត្រូវកំណត់ទិសដៅការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានច្បាស់លាស់ ផ្សារភ្ជាប់ជាមួយធនធនហិរញ្ញវត្ថុ<br>- ដាក់ចេញឧបករណ៍វាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង ស្ថាប័ន ដើម្បីកំណត់ភាពខ្លាំង និងភាពខ្សោយ។ |
| ៥ | ***អន្តរការកែទម្រង់***<br>ការកែទម្រង់ប្រព័ន្ធថវិកា និង PFM ដំណាក់កាលទី៣ និងទី៤ គឺក្រសួង-ស្ថាប័នមានតួនាទីសំខាន់ ដើម្បីឈានទៅសម្រេចបង្គោលចរដែលបានដាក់ចេញ។ ក្នុងន័យនេះ, ប្រសិនបើភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់គន្លឹះ របស់រាជរដ្ឋាភិបាលពុំមានក្របខ័ណ្ឌរួមមួយនោះទេ ល្បឿននៃការកែទម្រង់អាចបន្ថយបង្អាក់ ឬត្រូវការពេលវេលាច្រើន។ | ខ្ពស់ | - ជំរុញការរៀបចំផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រសម្រាប់កម្មវិធីកែទម្រង់បីបួកមួយ។ |
| ៦ | ***រចនាសម្ព័ន្ធ***<br>- រចនាសម្ព័ន្ធរដ្ឋបាលនៅតាមក្រសួងស្ថាប័នពុំទាន់សមស្របទិសដៅការងារការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ- | ខ្ពស់ | - ការដាក់ឱ្យប្រើប្រាស់ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលកំណត់បន្ទាត់គណនេយ្យភាព និងពង្រឹងការគ្រប់គ្រងថវិកា |

| ល.រ | ហានិភ័យ | កម្រិត | វិធានការ |
|---|---|---|---|
| | សាធារណៈ។ ស្ថានភាពបច្ចុប្បន្ន ការរៀបចំកម្មវិធីគឺផ្អែកលើរចនាសម្ព័ន្ធរដ្ឋបាល ពោលគឺពុំទាន់ឆ្លុះបញ្ចាំងនូវការអនុវត្តថវិកាកម្មវិធី/ សមិទ្ធកម្ម។<br>- ការកំណត់បន្ទាត់គណនេយ្យភាពទាំងស្ថាប័នរដ្ឋាភិបាល និងស្ថាប័ននីតិប្បញ្ញត្តិ | | |
| ៧ | ***ធនធានមនុស្ស***<br>ការកសាងសមត្ថភាពត្រូវផ្តោតលើទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកា និងសមត្ថភាពពុំទាន់សមាមាត្រទៅនឹងល្បឿននៃកិច្ចការកែទម្រង់។ | មធ្យម | - ការអភិវឌ្ឍសមត្ថភាពមន្ត្រីបង្គោលនៅតាមក្រសួងស្ថាប័នប្រែក្លាយជាមន្ត្រីវិភាគថវិកា និងមានចំណេះដឹងផ្នែកសេដ្ឋកិច្ច និងគោលនយោបាយសារណៈដើម្បីឈានអនុវត្តការរៀបចំថវិកាផ្សារភ្ជាប់ទៅនឹងគោលនយោបាយ និងថវិកាព័តិមានសមិទ្ធកម្ម។<br>- ការពង្រឹងសមត្ថភាពជំនាញទន់ (Soft skill) និងជំនាញបច្ចេកទេសមានភាពចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ |
| ៨ | ***វប្បធម៌សមិទ្ធកម្ម***<br>- ការបណ្តុះវប្បធម៌សមិទ្ធកម្មនៅគ្រប់ក្រសួង-ស្ថាប័នគឺពុំទាន់ត្រូវបានផ្តល់អាទិ-ភាពនៅឡើយ ដែលអាចប៉ះពាល់ដល់ការអនុវត្តប្រព័ន្ធថវិកាសមិទ្ធកម្ម<br>- យន្តការប្រតិតុល្យភាពរវាងស្ថាប័ននីតិប្រតិបត្តិ និងនីតិប្បញ្ញត្តិលើការប្រើប្រាស់ធនធានហិរញ្ញវត្ថុសាធារណៈ។ | មធ្យម | - ជំរុញការរៀបចំរបាយការណ៍សមិទ្ធកម្មគ្រប់ក្រសួងស្ថាប័ន និងសាកល្បងបូកសរុបសមិទ្ធកម្មតាមកម្មវិធីកម្រិតរដ្ឋាភិបាល។<br>- កសហវ. និងក្រសួង ស្ថាប័នត្រូវសហការ និងជំរុញលើការបង្កើតអង្គភាពថវិកា និងរៀបចំវេទិកាសាធារណៈ និងផ្សព្វផ្សាយឯកសារថវិកាឱ្យកាន់តែទូលំទូលាយ។<br>- ការពង្រឹងការអនុវត្តបញ្ញត្តិលើទោសទណ្ឌ (Sanction) ចំពោះការមិនគោរពតាមអនុលោមភាពនៃច្បាប់ និងបទប្បញ្ញត្តិ ។ |
| ៩ | **ការគ្រប់គ្រងគម្រោង** FMIS<br>ការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន គឺជាយន្តការមួយដើម្បីធានាបានគណនេយ្យភាពហិរញ្ញវត្ថុ ប៉ុន្តែចាំបាច់ត្រូវបន្តគិតគូរលើនីតិវិធីអនុវត្តការងារ, ការផលិតរបាយការណ៍ហិរញ្ញវត្ថុ | ខ្ពស់ | បង្កើនកិច្ចសហការជាមួយក្រសួង ស្ថាប័នលើតម្រូវរបាយការណ៍ហិរញ្ញវត្ថុ, នីតិវិធីអនុវត្តការងារ និងជំរុញការដោះស្រាយបញ្ហាប្រឈមរបស់ក្រសួង ស្ថាប័ន។ |

| ល.រ | ហានិភ័យ | កម្រិត | វិធានការ |
|---|---|---|---|
| | និងការដោះស្រាយលើបញ្ហាប្រឈមនៃការអនុវត្តថវិកានៅតាមក្រសួង ស្ថាប័ន។ | | |
| ១០ | **ផែនការសកម្មភាពរួមនិងផែនការសកម្មភាពតាមអង្គភាពអនុវត្ត**<br>- ការដាក់ចេញផែនការសកម្មភាពកែទម្រង់ (MAP) របស់ក្រសួង ស្ថាប័នពុំទាន់ឆ្លើយតបតាមការដ្ឋានកែទម្រង់អាទិភាពនៅឡើយ ដែលចាំបាច់ធានាក្រសួង ស្ថាប័នចូលរួមអនុវត្តផែនការសកម្មភាពតាមលំដាប់លំដោយអាទិ-ភាព។<br>- តាមរយៈរបាយការណ៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ, បង្ហាញអំពីបញ្ហាមួយចំនួនពាក់ព័ន្ធកង្វះខាតលើការគ្រប់គ្រងធនធានសាធារណៈ។ យើងសង្កេតឃើញយន្តការការជំរុញជាប្រចាំ (reinforcement) នៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ | មធ្យម | - អ.គ.ហ. និងអគ្គនាយកដ្ឋានបង្គោលនៃ កសហវ. កំណត់ផែនកសកម្មភាពកែទម្រង់អាទិភាព ដើម្បីជំរុញក្រសួង ស្ថាប័នរៀបចំ MAP និងអនុវត្តប្រចាំឆ្នាំ។<br>- ជំរុញការប្រើប្រាស់របាយការណ៍សវនកម្មជាឧបករណ៍កែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃអង្គភាពសាធារណៈ<br>- ពង្រឹងការបើកផ្ដល់ប្រាក់ឧបត្ថម្ភមុខងារផ្សារភ្ជាប់នឹងសមិទ្ធកម្ម។ |

ការបោះជំហានទៅអនុវត្ត PFMRP ខឿនទី៤ ជាកាលានុវត្តភាព សម្រាប់អង្គភាពពាក់ព័ន្ធទាំងអស់ ចូលរួមពិនិត្យអភិក្រម និងវិធីសាស្ត្រនៃការអនុវត្តកន្លងមក ដើម្បីធ្វើទំនើបកម្មសមាសធាតុនានានៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្នុងន័យនេះ, ការជំរុញការកសាងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបន្តលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និងសមត្ថភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុឱ្យកាន់តែមានពិពិធភាព រឹងមាំធន់នឹងវិបត្តិ និងប្រកបដោយបរិយាប័ន្ន សំដៅគាំទ្រសកម្មភាពសេដ្ឋកិច្ចទាំងមូល និងការសម្របខ្លួន ក៏ដូចជាឆ្លើយតបទៅនឹងការប្រែប្រួលនៃសមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងតំបន់ និងសកល។ ការបន្តពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបន្តផ្តោតលើការធ្វើទំនើបកម្ម និងវិចារណកម្មប្រព័ន្ធគ្រប់គ្រងចំណាយថវិកា និងគ្រប់គ្រងបំណុលសាធារណៈឱ្យមានប្រសិទ្ធ-ភាព និងចីរភាព។

## ៦. សន្និដ្ឋាន

ផ្អែកលើវឌ្ឍនភាព និងការវាយតម្លៃលើសមាសធាតុមូលដ្ឋាននៃការឈានទៅអនុវត្តគណនេយ្យភាពសមិទ្ធកម្ម, ការអនុវត្តកម្មវិធីកែទម្រង់ ក្នុងដំណាក់កាលទី ៣ រយៈពេល ៧ ឆ្នាំ ២០១៦-២០២២ សម្រេចបានជាសារវន្តនូវគោលដៅនៃការកែទម្រង់គឺ៖ ការបញ្ចប់ការដាក់ឱ្យអនុវត្តថវិកាកម្មវិធី និងការកសាងមូលដ្ឋានចាំបាច់សម្រាប់ការអនុវត្តថវិកាសមិទ្ធកម្ម ទន្ទឹមនឹងការបន្តពង្រឹងខឿនទី១ និង ពង្រីកការអនុវត្តខឿនទី២ រួមមានជាអាទិ៍៖

- ***ភាពជឿទុកចិត្តនៃថវិកា*** នៅតែរក្សាបាននូវស្ថានភាពរឹងមាំ ដែលបានបន្តក្លាយជាកម្លាំងចលករក្នុងការទ្រទ្រង់ និងជំរុញកំណើនសេដ្ឋកិច្ច ដែលស្ថិតក្នុងទស្សនវិស័យសុទិដ្ឋិនិយមក្រោយវិបត្តិនៃជំងឺកូវីដ-១៩ មានភាពធូរស្បើយ។ ប៉ុន្តែត្រូវធ្វើ ពិពិធកម្មចំណូលបន្ថែម និងពង្រឹងការកៀរគរចំណូលឱ្យអស់សក្តានុពល ទន្ទឹមនឹងនេះត្រូវពង្រឹងប្រសិទ្ធភាពនៃការអនុវត្តចំណាយ ជាពិសេសរំហូរចំណាយតាមត្រីមាស។
- ***បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពហិរញ្ញវត្ថុ*** ត្រូវបានកសាង និងពង្រឹងបន្ថែម ដែលឆ្លុះបញ្ចាំងតាមរយៈការពង្រីកការដ្ឋាននិងពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ប្រព័ន្ធគណនេយ្យនឹងត្រូវពង្រឹងបន្ថែមទៀត តាមរយៈការអនុវត្តជាដំណាក់កាលនូវយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១។
- ***ក្របខ័ណ្ឌថវិកាកម្មវិធី*** ត្រូវបានរៀបចំ ពង្រឹង និងពង្រីកការអនុវត្តទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ប៉ុន្តែត្រូវបន្តយកចិត្តទុកដាក់លើការបង្កើនអង្គភាពថវិកា និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ខណៈការឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម សិទ្ធិអំណាច និងថវិកានឹងត្រូវផ្ទេរវិមជ្ឈការ ទៅអង្គភាពអនុវត្តផ្ទាល់កាន់តែច្រើន។
- ***បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពសមិទ្ធកម្ម*** ត្រូវបាននិងកំពុងរៀបចំបញ្ចប់ ដែលឆ្លុះបញ្ចាំង តាមរយៈការរៀបចំ សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ ដែលរំពឹងថានឹងត្រូវចូលជាធរមានក្នុងឆមាសទី១ ឆ្នាំ២០២៣។ ទន្ទឹមនេះ ត្រូវបន្តយកចិត្តទុកដាក់លើ ការពង្រឹងការអនុវត្ត ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ និង ការអនុវត្តសវនកម្មសមិទ្ធកម្ម និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៅតាមក្រសួង ស្ថាប័ន។

ជារួម ទោះជាមានកិច្ចការងារសេសសល់មួយចំនួនត្រូវបន្តពង្រឹង និងអនុវត្តបន្ត ក៏វឌ្ឍនភាពសម្រេចបានក្នុងរយៈពេល ៧ ឆ្នាំ ២០១៦-២០២២ ធ្វើឱ្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈខឿនទី៣ និងដំណាក់កាលទី៣ បានកសាង និងកែលម្អប្រព័ន្ធ គតិយុត្ត យន្តការស្ថាប័ន និងធនធានមនុស្ស ដែលជាលក្ខខណ្ឌចាំបាច់ និងក្លាយជាមូលដ្ឋានរឹងមាំគ្រប់គ្រាន់ សម្រាប់អនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ដែលជាគន្លឹះក្នុងការកសាង និងបញ្ជ្រាប "**វប្បធម៌សមិទ្ធកម្ម**"។ ជាមួយគ្នានេះ សមិទ្ធផលសម្រេចបានពីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកន្លងមកបានពង្រឹងប្រសិទ្ធភាពនៃស្ថាប័នរាជរដ្ឋាភិបាលតាមរយៈការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដែលមានបច្ច័យដល់ (១) ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច, (២) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង (៣) ការផ្តល់សេវាសាធារណៈកាន់តែមាន

ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ក្នុងន័យនេះ រាជរដ្ឋាភិបាលអាចបោះជំហានទៅកាន់ខឿនទី៤ និងដំណាក់កាលទី៤ “**គណនេយ្យភាពសមិទ្ធកម្ម**” ដោយកសាងលើមូលដ្ឋាននៃសមិទ្ធផលសម្រេចបានក្នុងដំណាក់កាលទាំង ៣ កន្លងមក និង បន្តយកចិត្តទុកដាក់លើចំណុចខ្វះខាត និងកិច្ចការងារដែលត្រូវបន្តពង្រឹង និងអនុវត្តបន្ត ដោយរក្សានូវការអនុវត្តអភិក្រម ជា “**ខឿន**”។

# ឧបសម្ព័ន្ធ

**សូមស្កេន QR Code ខាងក្រោម សម្រាប់ទាញយកឯកសារឧបសម្ព័ន្ធ**

របាយការណ៍វាយតម្លៃការអនុវត្តផែនការសកម្មភាពរួម
ដំណាក់កាលទី៣ ឆ្នាំ២០១៦-២០២០ ក្រោមកម្មវិធី
កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ចក្ខុវិស័យ និង យុទ្ធសាស្ត្រ កម្មវិធីកែទម្រង់ការ
គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣
“ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ”

របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែ
ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២១

ផែនការសកម្មភាពរួម
ដំណាក់កាលទី៣ បូក ២
ឆ្នាំ២០២១-២០២២

## ការវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២ ឆ្នាំ២០២១-២០២២

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មឆ្នាំ២០២១ | លទ្ធផលសម្រេចបានឆ្នាំ២០២១ | ពណ៌ | គោលដៅសូចនាករសមិទ្ធកម្មឆ្នាំ២០២២ | លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| **ផ្នែកទី/ខឿនទី ១ ÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា**<br>លទ្ធផលនៃការអនុវត្តថវិកា (ចំណូល-ចំណាយ) ប្រចាំត្រីមាស និងប្រចាំឆ្នាំមានភាពរលូន និងអាចប៉ាន់ប្រមាណបានស្ថិតនៅក្នុងរង្វង់ +/- ៥%នៃច្បាប់ថវិកា និង ឆ្លើយតបបានតាមសភាពការណ៍។ | | | | | | | |
| ១១. បន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល | <u>សគ[10] ១.</u><br>ភាគរយនៃការអនុវត្តចំណូលថវិកាធៀបនឹងច្បាប់ថវិកា | ការអនុវត្តចំណូលចរន្តសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកាជារៀងរាល់ឆ្នាំ | ប្រមូលចំណូលថវិការដ្ឋឆ្នាំ២០២១ (ថ្នាក់ជាតិ+ថ្នាក់ក្រោមជាតិកម្រិតរដ្ឋបាលរាជធានី ខេត្ត) សម្រេចបាន ១០៤,៤៩% (២២ ១៥៥ ប៊ីលានរៀល) ។ | | ការអនុវត្តចំណូលចរន្តសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកាជារៀងរាល់ឆ្នាំ | ចំណូលថវិការដ្ឋឆ្នាំ២០២២ សម្រេចបាន ៩៦,៩% (២៤ ៥៣៣ ប៊ីលានរៀល) ធៀបនឹងច្បាប់ថវិកា។ | |
| | <u>សគ ២.</u><br>កំណើនចំណូលចរន្តធៀបនឹងផ.ស.ស. | យ៉ាងតិច ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស[11] | កំណើនចំណូលចរន្តធៀបនឹង ផ.ស.ស. សម្រេចបាន -២,៦៨ ពិន្ទុភាគរយ ។ | | យ៉ាងតិច ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស. | សម្រេចបាន ១,២ ពិន្ទុភាគរយ នៃ ផ.ស.ស. | |
| ១១.១. អនុវត្តគោលនយោបាយ និងកែទម្រង់រដ្ឋបាលគយ និងពន្ធដារ | <u>សច[12] ១.</u><br>ភាគរយនៃអ្នកជាប់ពន្ធបង់ប្រាក់ពន្ធទាន់ពេលវេលា | អ្នកជាប់ពន្ធ ៧៦% បានបង់ពន្ធទាន់ពេលវេលា | ភាគរយនៃអ្នកជាប់ពន្ធ បង់ប្រាក់ពន្ធទាន់ពេលវេលាប្រចាំឆ្នាំ២០២១ សម្រេចបានជារួមប្រមាណ ៧៨% ។ | | អ្នកជាប់ពន្ធ ៧៨% បានបង់ពន្ធទាន់ពេលវេលា | ភាគរយនៃអ្នកជាប់ពន្ធបង់ប្រាក់ពន្ធទាន់ពេលវេលាប្រចាំឆ្នាំ២០២២សម្រេចបានជារួមប្រមាណ ៨២.៥៦% | |
| | <u>សច ២.</u><br>ភាគរយនៃការអនុវត្តផែនការសវនកម្ម | ភាគរយនៃការអនុវត្តផែនការសវនកម្មមានការកើនឡើង ៥% រៀងរាល់ឆ្នាំ | ការអនុវត្តផែនការសវនកម្មជារួមសម្រេចបានប្រមាណ ៧៨.១៦% (អនុវត្តបាន ៦ ៥៣៥ សហគ្រាស ធៀបនឹងផែនការចំនួន ៨ ៣៦១ សហគ្រាស) ។ | | ភាគរយនៃការអនុវត្តផែនការសវនកម្មមានការកើនឡើង ៥% រៀងរាល់ឆ្នាំ | ការអនុវត្តផែនការសវនកម្មជារួមសម្រេចបានប្រមាណ ៩៩.៧% (អនុវត្តបាន ១ ៩៣៥ សហគ្រាស ធៀបនឹង ផែនការចំនួន ១ ៩៤០ សហគ្រាស) | |
| | <u>សច ៣.</u><br>បំណុលពន្ធត្រូវបានកាត់បន្ថយជាភាគរយ | យ៉ាងហោចណាស់ ៥% នៃបំណុលពន្ធដែលអាចប្រមូលបាននឹងត្រូវកាត់បន្ថយ | - បំណុលពន្ធដែលអាចប្រមូលបានក្នុងឆ្នាំ២០២០ មានចំនួន ៦ ៣១០ ០៣៩ ០៦៥ ១៤៨ រៀល<br>- ការប្រមូលបំណុលពន្ធក្នុងឆ្នាំ២០២១សម្រេចបានចំនួន ១ ០៨៧ ០៥៧ ៦៩៣ ៧៣៦ រៀល ស្មើនឹងប្រមាណ ១៧.២៣% នៃបំណុលពន្ធដែលអាចប្រមូលបានក្នុងឆ្នាំ២០២០ | | យ៉ាងហោចណាស់ ៥% នៃបំណុលពន្ធដែលអាចប្រមូលបាននឹងត្រូវកាត់បន្ថយ | -បំណុលពន្ធដែលអាចប្រមូលបានក្នុងឆ្នាំ២០២១ មានចំនួន ៧ ២៥៩ ១១៧ ៣៧៤ ៩៤៩ រៀល<br>-ការប្រមូលបំណុលពន្ធក្នុងឆ្នាំ២០២២ សម្រេចបានចំនួន ១ ០៧០ ២៧៣ ៩៨២ ៥១៥ រៀល ស្មើនឹងប្រមាណ **១៤.៧៤%** នៃបំណុលពន្ធដែលអាចប្រមូលបានក្នុងឆ្នាំ២០២១ | |

[10] សគ÷ សូចនាករគោលបំណង

[11] គោលដៅកំណត់ក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ។ គោលដៅសូចនាករនេះអាចនឹងប្រែប្រួលដោយផលប៉ះពាល់បណ្តាមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ។

[12] សច÷ សូចនាករចង្កោមសកម្មភាព

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មឆ្នាំ ២០២១ | លទ្ធផលសម្រេចបានឆ្នាំ២០២១ | ពណ៌ | គោលដៅសូចនាករសមិទ្ធកម្មឆ្នាំ២០២២ | លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| | **<u>សច ៤.</u>** ចំនួនបណ្ដឹងតវ៉ានៃករណីកំណត់ពន្ធឡើងវិញត្រូវបានដោះស្រាយ | ការដោះស្រាយបណ្ដឹងតវ៉ាលើករណីកំណត់ពន្ធឡើងវិញមានការកើនឡើង ៥% ជារៀងរាល់ឆ្នាំ | បណ្ដឹងតវ៉ានៃករណីកំណត់ពន្ធឡើងវិញចំនួន១ ៨៥២ករណីត្រូវបានដោះស្រាយដែលស្មើនឹងប្រមាណ៧៩.៧៥%ធៀបនឹងបណ្ដឹងតវ៉ាសរុបចំនួន ២៣២១ ករណី ។ | | ការដោះស្រាយបណ្ដឹងតវ៉ាលើករណីកំណត់ពន្ធឡើងវិញមានការកើនឡើង ៥% ជារៀងរាល់ឆ្នាំ (ឆ្នាំ ២០២២ ត្រូវសម្រេចបាន៦៥%) | បណ្ដឹងតវ៉ានៃករណីកំណត់ពន្ធឡើងវិញចំនួន ១៦៤ ករណី ត្រូវបានដោះស្រាយ ដែលស្មើនឹងប្រមាណ ៥៣.០៧% ធៀបនឹងបណ្ដឹងតវ៉ាសរុបចំនួន ៣០៩ ករណី | |
| | **<u>សច ៥.</u>** ចំនួនសមាជិកក្រុមធុរជនល្អបំផុត ត្រូវបានបង្កើន | ចំនួនធុរជនល្អបំផុតត្រូវបានបង្កើនយ៉ាងតិច ៥ ក្នុងមួយឆ្នាំ | បានបង្កើនសមាជិកក្រុមធុរជនល្អបំផុតចំនួន ៣ | | ចំនួនធុរជនល្អបំផុតត្រូវបានបង្កើនយ៉ាងតិច ៥ ក្នុងមួយឆ្នាំ | បានបង្កើនសមាជិកក្រុមធុរជនល្អបំផុតចំនួន ៦ | |
| | **<u>សច ៦.</u>** ចំនួនការដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ចរតែមួយជាតិ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានដាក់ អនុវត្តប្រព័ន្ធបញ្ចរតែមួយជាតិ ដំណាក់កាលទី ២ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចូលរួមអនុវត្តប្រព័ន្ធបញ្ចរតែមួយជាតិ ។ | | បានរៀបចំគម្រោងប្រព័ន្ធបញ្ចរតែមួយជាតិ ដំណាក់កាលទី៣ រួចរាល់ និងបានប្រកាសអនុវត្តនៅថ្ងៃទី៣ ខែមករា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី។ (បន្ថែម)[13] | -ប្រព័ន្ធបញ្ចរតែមួយជាតិ ដំណាក់កាលទី៣ ត្រូវបានប្រកាសដាក់ប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការទៅកាន់ក្រសួង-ស្ថាប័នចំនួន ៩ បន្ថែមនៅថ្ងៃទី៣ ខែមករា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី។ | |
| | **<u>សច ៧.</u>** ភាគរយនៃការអនុវត្ត Post - Clearance Audit (PCA) ធៀបនឹងផែនការ | ការអនុវត្តសវនកម្មគយសម្រេចបានយ៉ាងតិច ៩៥% ធៀបនឹងផែនការ | គិតត្រឹមត្រីមាសទី៤ ឆ្នាំ២០២១ បានធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយសរុប១៦ក្រុមហ៊ុនស្មើនឹង២.៧%នៃផែនការប្រចាំឆ្នាំ (៥៧៦ក្រុមហ៊ុន) ។ | | ការអនុវត្តសវនកម្មគយសម្រេចបានយ៉ាងតិច ៩៥% ធៀបនឹងផែនការ | ចំនួនសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយត្រឹមត្រីមាសទី៤ សម្រេចបាន ៨៥% ធៀបនឹងផែនការ (ចំនួន ក្រុមហ៊ុនរងសវនកម្ម ១៥៣/ចំនួនក្រុមហ៊ុនសរុបក្នុងផែនការ ១៨០) | |
| | **<u>សច ៨.</u>** សន្ធានកម្មប្រព័ន្ធពន្ធដារ និងប្រព័ន្ធអាស៊ីគូដា | សន្ធានកម្មប្រព័ន្ធពន្ធដារ និងប្រព័ន្ធអាស៊ីគូដា ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការ | - ការធ្វើសន្ធានកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យ រវាងអគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ ដែលអនុញ្ញាតឱ្យអគ្គ-នាយកដ្ឋានទាំងពីរផ្ដល់ជូនគ្នាទៅវិញទៅមកនូវព័ត៌មាន និងទិន្នន័យដែលអាចបម្រើឱ្យ | | N/A | | |

[13] ក្រសួងមហាផ្ទៃ, ក្រសួងការពារជាតិ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងបរិស្ថាន, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្រសួងរ៉ែនិងថាមពល, ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, និងធនាគារជាតិនៃកម្ពុជា

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មឆ្នាំ ២០២១ | លទ្ធផលសម្រេចបានឆ្នាំ២០២១ | ពណ៌ | គោលដៅសូចនាករសមិទ្ធកម្ម ឆ្នាំ២០២២ | លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| | | | ការសិក្សាវិភាគលើកវិធានការពង្រឹងការគ្រប់គ្រងនិងបង្កើនការប្រមូលចំណូលពន្ធដារ និងចំណូលពន្ធគយ ។ | | | | |
| ១១.២. អនុវត្តគោល-នយោបាយ និងកែទម្រង់រដ្ឋបាលចំណូលមិនមែនពន្ធ | **<u>សច ៩.</u>** ភាគរយនៃការកាត់បន្ថយបំណុលមិន-មែនសារពើពន្ធ | នៅឆ្នាំ២០២១បំណុលមិនមែនសារពើពន្ធថយចុះ ១០% ធៀបនឹងបំណុលសរុបឆ្នាំ២០២០ | បានរៀបចំតារាងបំណុលមិនមែនសារពើពន្ធរួចរាល់ ។ (ពុំទាន់ទទួលបានព័ត៌មានពេញលេញ) | | នៅឆ្នាំ២០២២បំណុលមិនមែនសារពើពន្ធថយចុះ១០%ធៀបនឹងបំណុលសរុបឆ្នាំ២០២១ | - នៅឆ្នាំ២០២២បំណុលមិនមែនសារពើពន្ធថយចុះ ០៧% ធៀបនឹងបំណុលសរុបឆ្នាំ២០២១<br>- បានរៀបចំតារាងបំណុលមិនមែនសារពើពន្ធរួចរាល់។ | |
| | **<u>សច ១០.</u>** ចំនួនក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់-ក្រោមជាតិប្រើប្រាស់ប្រព័ន្ធNRMIS និង E-payment | - ប្រព័ន្ធ NRMIS ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់អង្គភាពប្រមូលចំណូលនៅរដ្ឋបាលថ្នាក់ជាតិ<br>- ដាក់ឱ្យសាកល្បងប្រព័ន្ធNRMIS នៅសាលារាជធានីភ្នំពេញ<br>- ប្រព័ន្ធ NRMIS ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅសាលារាជធានី ខេត្តទាំង ២៥<br>- ការបង់ចំណូលតាមE-Payment ដល់ ១០ ក្រសួង-ស្ថាប័ន បន្ថែម | **១. ប្រព័ន្ធ NRMIS ÷**<br>-បានរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់រដ្ឋបាលរាជធានីភ្នំពេញនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ និងរដ្ឋបាលខេត្តទាំង២៤ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១<br>-បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រព័ន្ធ NRMIS ដំណាក់-កាលទី២ ជំហានទី១ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១<br>-បានចេញសារាចរលេខ០០៧ សហវ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ NRMIS ដំណាក់កាលទី២ ជំហានទី១ ដល់រដ្ឋបាលរាជ-ធានី ខេត្ត<br>**២. E-Payment ÷**<br>-បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការដាក់ឱ្យប្រើ-ប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកសម្រាប់ការបង់ចំណូលមិនមែនសារពើពន្ធ (E-Payment) ជំហានទី២ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១<br>-បានចេញសារាចរលេខ០០៨ សហវ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យអនុវត្ត E-Payment ជំហានទី២ | | - ប្រព័ន្ធ NRMIS ត្រូវបានដាក់ឱ្យអនុវត្តនៅរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ជាផ្លូវការ<br>- ការបង់ចំណូលតាម E-Payment ដល់ក្រសួង ស្ថាប័នដែលនៅ សេសសល់ (សរុប ២៣) | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសារាចរណែនាំ លេខ០១១ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០២២ ស្តីពីការដាក់ ឱ្យប្រើប្រាស់ប្រព័ន្ធ NRMIS ដំណាក់កាលទី២ ជំហានទី២ ដល់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ<br>-បានធ្វើការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធ NRMIS ជូនដល់រដ្ឋបាលក្រុង-ស្រុក-ខណ្ឌទាំង **២០៣** ដំណាក់កាលទី២ ជំហានទី២ នៅថ្ងៃទី២៦ តុលា ឆ្នាំ២០២២។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសារាចរលេខ០០៣ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ ស្តីពីការដាក់ ឱ្យប្រើប្រាស់ប្រព័ន្ធ E-payment ជំហានទី៣។ | |
| | **<u>សច ១១.</u>** ការរៀបចំបទដ្ឋានគតិយុត្តសម្រាប់ប្រមូលចំណូលមិនមែនសារពើពន្ធ | - ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធត្រូវបានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី<br>- ឯកសារគោល (Blueprint) ស្តីពីការកែ-ទម្រង់ការគ្រប់គ្រងចំណូលមិន | -សេចក្តីព្រាងច្បាប់នេះបានដាក់ឆ្លងកិច្ចប្រជុំនាថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០២១ ជាមួយអន្តរក្រសួង ស្ថាប័ន (ចំនួន៣៥) ដោយមានការចូលរួមពីដៃគូអភិវឌ្ឍន៍ (ចំនួន០៥) និងតំណាងសង្គមស៊ីវិល ក្នុងការពិគ្រោះយោបល់ និងប្រមូលធាតុចូលបន្ថែម ។ | | - ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធត្រូវបានដាក់ឆ្លងអង្គនីតិប្បញ្ញត្តិ<br>- ឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ការគ្រប់គ្រង | - ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានអនុម័ត និងផ្សព្វផ្សាយដាក់ឱ្យអនុវត្ត<br>- បានធ្វើសិក្ខាសាលាពិគ្រោះយោបល់នាថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០២២ស្តីពីសេចក្តីព្រាងឯកសារគោល (Blueprint) ស្តីពីការកែ | |

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មឆ្នាំ ២០២១ | លទ្ធផលសម្រេចបានឆ្នាំ២០២១ | ពណ៌ | គោលដៅសូចនាករសមិទ្ធកម្ម ឆ្នាំ២០២២ | លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| | | មែនសារពើពន្ធ ដាក់ជូនថ្នាក់ដឹកនាំ. កសហវ.<br>- អនុក្រឹត្យចំនួន ១ និងប្រកាសចំនួន ១ ត្រូវបានអនុម័ត ស្របតាមការណែនាំដោយច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម | ២.**<u>បច្ចុប្បន្ន:</u>**បាននិងកំពុងប្រជុំពិនិត្យពិភាក្សាលើជំពូកទី១០ (ស្តីពីទោសប្បញ្ញត្តិ) ជាមួយក្រសួងយុត្តិធម៌ និងអង្គភាពប្រឆាំងអំពើពុករលួយ។<br>៣.**<u>ដំណើរការបន្ត:</u>**បន្ទាប់ពីកិច្ចប្រជុំខាងលើខាងលើផ្តល់ធាតុចូលចប់សព្វគ្រប់ នឹងបន្តដាក់ចូលគណៈកម្មាធិ-ការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។<br>៤.**<u>ជំហានបន្ទាប់:</u>** នឹងដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី *(យោងលិខិតលេខ៨៤៨៦.សហវ.អទច. ចុះថ្ងៃទី ១៤ តុលា ២០២១)*<br>-ក្រុមការងារ.អទច. បានពិនិត្យឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដោយសម្រួលខ្លឹមសារពីភាសាអង់គ្លេសទៅខ្មែរឱ្យត្រឹមត្រូវតាម ពាក្យពេចន៍, អក្ខរាវិរុទ្ធ និងទិដ្ឋភាពបច្ចេកទេសរួចរាល់កម្រិត អទច. ហើយកិច្ចការងារនេះនឹងបន្តដាក់ជូនក្រុមការងារកម្រិតអន្តរអគ្គនាយកដ្ឋានកសហវ. បានពិនិត្យកែសម្រួលចុងក្រោយនាខែកុម្ភៈ ឆ្នាំ២០២២។ | | ចំណូលមិនមែនសារពើពន្ធដាក់ឱ្យអនុវត្ត | ទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ ជាមួយក្រសួង ស្ថាប័នអង្គភាពនីតិបុគ្គលសាធា-រណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។ ហើយសេចក្តីព្រាងនេះនឹងក្លាយជាឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ពង្រឹងប្រសិទ្ធភាព នៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ សេចក្តីព្រាងនេះនឹងដាក់ឆ្លងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាត្រីមាសទី១ ឆ្នាំ ២០២៣នេះ ដើម្បីបន្តនីតិវិធី។ | |
| ១១.៣. ជំរុញការតាម-ដានការអនុវត្តយុទ្ធ-សាស្ត្រកៀរគរចំណូល និងកែលម្អគោល-នយោបាយសារពើពន្ធ | **<u>សច ១២.</u>**<br>ភាគរយសម្រេចបាននៃការអនុវត្តសកម្មភាព កែទម្រង់នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូល | យ៉ាងហោចណាស់ ៨០% នៃសកម្មភាពកែទម្រង់ដែលបានដាក់ចេញ សម្រេចបានតាមផែនការ | - របាយការណ៍ត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលប្រចាំឆ្នាំ២០២០និងឆមាសទី១ឆ្នាំ២០២១ត្រូវបានរៀបចំ ។ (ពុំទាន់ទទួលបានព័តិមានពេញលេញ) | | យ៉ាងហោចណាស់ ៨០% នៃសកម្មភាពកែទម្រង់ដែលបានដាក់ចេញ សម្រេចបានតាមផែនការ | - របាយការណ៍ចុងក្រោយត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ពាក់កណ្តាល អាណត្តិ ត្រូវបានរៀបចំ<br>- របាយការណ៍ត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ប្រចាំឆមាសទី ១ ឆ្នាំ ២០២២ ត្រូវបានរៀបចំ | |
| | **<u>សច ១៣.</u>**<br>បទដ្ឋានគតិយុត្តពាក់ព័ន្ធគោលនយោបាយសារពើ-ពន្ធ ត្រូវបានរៀបចំ និងពិនិត្យឡើងវិញ | - សេចក្តីព្រាងច្បាប់ស្តីពីអាករពិសេស ត្រូវបានរៀបចំត្រឹមកម្រិតក្រុមការងារ<br>- សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយសម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្ត-បុគ្គល ត្រូវបានរៀបចំ និងដាក់ជូន | មិនមានរាយការណ៍ | | - សេចក្តីព្រាងច្បាប់ស្តីពីអាករពិសេសត្រូវបានដាក់ជូនថ្នាក់ដឹកនាំ កសហវ ពិនិត្យ និងសម្រេច<br>- រដ្ឋបាលសារពើពន្ធដែលមានសមត្ថ-ភាព និងឯកទេសត្រូវបានរៀបចំ សម្រាប់ត្រៀមលក្ខ | -បានរៀបចំសេចក្តីព្រាងនៃក្របខ័ណ្ឌគោលនយោបាយអាករពិសេស ២០២៣-២០២៨,<br>-បានរៀបចំរបាយការណ៍វឌ្ឍនភាពគោរពជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ដើម្បីជម្រុញឱ្យការអនុវត្តនិងការចូលរួមពីភាគីពាក់ព័ន្ធ សំដៅឱ្យសម្រេចបាន “ក្របខ័ណ្ឌគោលនយោបាយអាករពិសេស ២០២៣-២០២៨” យ៉ាងយូរត្រឹមត្រីមាសទី៣ ឆ្នាំ២០២៣ ស្របតាមផែនការសកម្មភាព GDAP ៤ ឆ្នាំ២០២៣ របស់ អ.គ.ប.។ | |

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មឆ្នាំ ២០២១ | លទ្ធផលសម្រេចបានឆ្នាំ២០២១ | ពណ៌ | គោលដៅសូចនាករសមិទ្ធកម្ម ឆ្នាំ២០២២ | លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| | | ថ្នាក់ដឹកនាំ កសហវ ពិនិត្យ និង សម្រេច | | | ណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល | -សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយសម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល ត្រូវបានរៀបចំ និងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច | |
| **១២.ពង្រឹងការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ** | <u>*សគ ៣.*</u><br>*ភាគរយនៃការអនុ-វត្តចំណាយធៀបនឹងច្បាប់ថវិកាប្រចាំឆ្នាំ* | **ការចំណាយថវិកាសរុបប្រចាំឆ្នាំសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកា** | **ការចំណាយថវិកាសរុបប្រចាំឆ្នាំសម្រេចបាន ៩៥,៣៦% ។** | | **ការចំណាយថវិកាសរុបប្រចាំឆ្នាំសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកា** | **ការអនុវត្តថវិការជាតិក្នុងឆ្នាំ២០២២ សម្រេចបានក្នុងទំហំ ២២ ៦៧៩ ប៊ីលានរៀល ស្មើនឹង ៧៨,៩២% ធៀបនឹងច្បាប់ថវិកាប្រចាំឆ្នាំ។** | |
| ១២.១. រៀបចំកម្មវិធីចំណាយស្របតាមផែនការប្រតិបត្តិប្រចាំឆ្នាំ | <u>*សច ១៤.*</u><br>ភាគរយនៃការអនុ-វត្តចំណាយធៀបនឹងច្បាប់ប្រចាំត្រី-មាស | ថវិកាជាតិអនុវត្តប្រចាំត្រីមាសធៀបនឹងច្បាប់ថវិកា÷<br>ត.ម ១=២០%<br>ត.ម ២=៤៥%<br>ត.ម ៣ =៧០%<br>ត.ម ៤=៩៦% | ថវិកាជាតិអនុវត្តប្រចាំត្រីមាសធៀបនឹងច្បាប់ថវិកា÷<br>ត.ម ១=១៩,៩៨%%<br>ត.ម ២=៣៩,១០%<br>ត.ម ៣ =៦៤,០៧%<br>ត.ម ៤=៩៥,៣៦% | | ថវិកាជាតិអនុវត្តប្រចាំត្រីមាសធៀបនឹងច្បាប់ថវិកា÷<br>ត.ម ១=២០%<br>ត.ម ២=៤៥%<br>ត.ម ៣ =៧០%<br>ត.ម ៤=៩៦% | ចំណាយថវិកាជាតិសម្រេចបាន÷<br>• ត្រីមាសទី១: ១៧,៩១%<br>• ត្រីមាសទី២: ៣៧,៣៩%<br>• ត្រីមាសទី៣: ៥៨,៦៤%<br>• ត្រីមាសទី៤: ៧៨,៩២% | |
| ១២.២. គ្រប់គ្រងសាច់ប្រាក់ប្រកបដោយប្រសិទ្ធភាព | <u>*សច ១៥.*</u><br>ភាគរយការអនុវត្តចំណូលចំណាយ ជាក់ស្តែងធៀបនឹងការព្យាករប្រចាំត្រីមាស | លទ្ធផលស្ថិតក្នុងចន្លោះ +/-៥% | សម្រេចបាន១០០%<br>(ពុំទាន់ទទួលបានព័ត៌មានពេញលេញ) | | លទ្ធផលស្ថិតក្នុងចន្លោះ +/-៥% | បានបញ្ចប់របាយការណ៍ស្តីពីស្ថានភាពលំហូរសាច់ប្រាក់ក្នុងគណនីទោលរតនាគារទូទាំងប្រទេសសម្រាប់ត្រីមាសទី១, ត្រីមាសទី២, ត្រីមាសទី៣ និងត្រីមាសទី៤ ឆ្នាំ២០២២។ | |
| **១៣. កែលម្អដំណើការនៃការអនុវត្តថវិកា** | <u>*សគ ៤.*</u><br>*ភាគរយនៃផែនការលទ្ធកម្មត្រូវបានអនុម័តមុនថ្ងៃទី ៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា* | **៩០% ផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា** | **គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១ស្ថាប័នអនុវត្តលទ្ធ-កម្ម/អង្គភាពថវិកា ដែលបានផ្ញើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ២០២២មក កសហវ និងត្រូវបានអនុវត្តពី កសហវ មានដូចខាងក្រោម÷**<br>**- ក្រសួងស្ថាប័នបានផ្ញើមកសរុបចំនួន ៥៣ ស្ថាប័ន (៩៨.១៥%) និងបានអនុវត្តរួចរាល់ចំនួន ៤៩ ស្ថាប័ន (៩២.45%)**<br>**- សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល បានផ្ញើមកសរុបចំនួន៣៨ស្ថាប័ន (៩៤.៨៧%) និងបានអនុវត្តរួចរាល់ចំនួន២៥ស្ថាប័ន(១០០%) និងបានអនុវត្តរួចរាល់ចំនួន២៥ស្ថាប័ន (១០០%)** | | **៩៥% ផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានអនុម័តឱ្យបានមុនថ្ងៃទី ៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា** | **គិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ស្ថាប័នអនុវត្តលទ្ធកម្ម ដែលបានផ្ញើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៣ មក កសហវ មានចំនួន ១១៥ស្ថាប័ន (៩៣.៥០%) និងត្រូវបានអនុម័តរួចរាល់ពី កសហវ ចំនួន ១១០ស្ថាប័ន (៩៥.៦៥%)។** | |

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មឆ្នាំ២០២១ | លទ្ធផលសម្រេចបានឆ្នាំ២០២១ | ពណ៌ | គោលដៅសូចនាករសមិទ្ធកម្មឆ្នាំ២០២២ | លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| | | | - អង្គភាពថវិកា បានផ្ញើមកសរុបចំនួន ៦១៨ អង្គភាព (៩៦.១១%) និងបានអនុម័តរួចរាល់ចំនួន ៥៩៣ ស្ថាប័ន (៩៥.៩៥%) ។ | | | | |
| **សគ ៥.** ភាគរយនៃអង្គភាពថវិការបស់ក្រសួង ស្ថាប័នផ្តល់របាយ-ការណ៍អនុវត្តកិច្ច-លទ្ធកម្ម | យ៉ាងតិច ៦០% នៃអង្គភាពថវិកាផ្តល់របាយការណ៍ កិច្ចលទ្ធកម្មទាន់ពេលវេលា មក កសហវ | ក្នុងឆ្នាំ២០២០ អង្គភាពថវិកាបានផ្ញើរបាយការណ៍កិច្ចលទ្ធកម្មទាន់ពេលវេលា មក កសហវ មានសរុបចំនួន ៣៩១អង្គភាព ស្មើនឹង ៦១,១៨ភាគរយ ។ | | យ៉ាងតិច ៧០% នៃអង្គភាពថវិកាផ្តល់របាយការណ៍កិច្ចលទ្ធកម្មទាន់ពេលវេលា មក កសហវ | ក្នុងឆ្នាំ២០២១ អង្គភាពថវិកាផ្តល់របាយការណ៍អនុវត្តកិច្ចលទ្ធកម្មទាន់ពេលវេលា មក កសហវ មានចំនួន ៤៥៧ ក្នុងចំណោមអង្គភាពថវិកាសរុបចំនួន ៦៣៩ ឬស្មើនឹង ៧១,៥២% | |
| **សគ ៦.** ការបោះជំហានទៅបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធារណៈរបស់ស្ថាប័នអនុវត្តលទ្ធកម្ម | ការបន្តអនុវត្តជំហានទី១ នៃការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធារណៈ | បានអនុវត្តជំហានទី១ នៃការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធារណៈ ។ ជំហានទី២ នឹងចាប់ផ្តើមនៅឆ្នាំ២០២២ ។ | | ជំហានទី ២ បង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធា-ណៈ របស់ស្ថាប័នអនុវត្តលទ្ធកម្មនៅឆ្នាំ ២០២២ | -នៅឆ្នាំ២០១៩ ជំហានទី១ ត្រូវបានដាក់ឱ្យអនុវត្តដោយបានបង្កើនទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធារណៈ របស់ស្ថាប័នអនុវត្តលទ្ធកម្ម។<br>-សេចក្តីព្រាងប្រកាសស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ ជំហានទី២ ត្រូវបានរៀបចំ និងបានដាក់ប្រជុំពិភាក្សាផ្ទៃក្នុងអគ្គនាយកដ្ឋាន | |
| **សគ ៧.** កំណើនជាភាគរយនៃការប្រើប្រាស់ វិធីសាស្ត្រប្រកួតប្រជែងលទ្ធកម្ម | យ៉ាងតិច ៦០% នៃទំហំទឹកប្រាក់ការប្រគល់កិច្ចសន្យាសរុប | ក្នុងឆ្នាំ២០២០ ទំហំទឹកប្រាក់កិច្ចសន្យាសរុបប្រចាំឆ្នាំប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងលទ្ធកម្ម មានចំនួន៦០.៦២% (លើកលែងកិច្ចសន្យារបស់ក្រសួងចំនួន ៣ គឺ MPWT, MoWRAM, MRD) ។ | | យ៉ាងតិច ៦៥% នៃទំហំទឹកប្រាក់ការប្រគល់កិច្ចសន្យាសរុប | នៅក្នុងឆ្នាំ២០២១ ការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងលទ្ធកម្មអនុវត្តបាន ៥៥,៦៧% នៃទំហំទឹកប្រាក់ប្រគល់កិច្ចសន្យាសរុប | |
| ១៣.១. អនុវត្តយុទ្ធ-សាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារ-ណៈឆ្នាំ២០១៩-២០២៥ | **សច ១៦.** វិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ ២០១២ | សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ត្រូវបានបញ្ជូនទៅទីស្តីការគណៈ រដ្ឋមន្ត្រី ដើម្បីពិនិត្យ និងអនុម័ត | សេចក្តីព្រាងទី១តារាងម៉ាទ្រីសសម្រាប់ការធ្វើវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈត្រូវបានបានដាក់ប្រជុំកម្រិតក្រុមការងារបច្ចេកទេស (អន្តរអគ្គនាយកដ្ឋាន) និងបានកែសម្រួលជាសេចក្តីព្រាងចុងក្រោយរួចរាល់ ។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបានរៀបចំរបាយការណ៍ស្តីពីលទ្ធផលបឋមនៃកិច្ចប្រជុំពិភាក្សាលើតារាងម៉ាទ្រីសដើម្បីគោរពជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រីតាមរយៈលិខិត ២៦១/២១ អ.ល.សា ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។ | | - ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត<br>- រៀបចំកែសម្រួលលិខិតបទដ្ឋានគតិយុត្ត ឬរៀបចំបង្កើតថ្មីឱ្យមានសង្គតិភាពជាមួយច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ | សេចក្តីព្រាងស្តីពីលទ្ធកម្មសាធារណៈ (ថ្មី) ត្រូវបានដាក់ប្រជុំនិងពិភាក្សាក្នុងកម្រិតថ្នាក់ដឹកនាំ កសហវ កាលពីថ្ងៃទី១៣, ទី១៥ និងទី១៦ ខែធ្នូ ឆ្នាំ២០២២ ដែលដឹកនាំកិច្ចប្រជុំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី។ បច្ចុប្បន្ន អគ្គ.លទ្ធកម្មសាធារណៈបានកែសម្រួលសេចក្តីព្រាងច្បាប់ស្របតាមស្មារតីសម្រេចរបស់អង្គប្រជុំ និងបានរៀបចំជារបាយការណ៍គោរពរាយការណ៍អំពីវឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ថ្មី) ជូនសម្តេចតេជោនាយករដ្ឋមន្ត្រី និងបានគោរពសុំគោលការណ៍ដ៏ខ្ពង់ខ្ពស់ដើម្បីសហការជាមួយក្រសួងយុត្តិធម៌ និងអង្គភាពប្រឆាំងអំពើពុករលួយ | |

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មឆ្នាំ២០២១ | លទ្ធផលសម្រេចបានឆ្នាំ២០២១ | ពណ៌ | គោលដៅសូចនាករសមិទ្ធកម្មឆ្នាំ២០២២ | លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| | | | | | | ពិនិត្យលើខ្លឹមសារជំពូកពាក់ព័ន្ធទោសប្បញ្ញត្តិ នៃសេចក្តីព្រាងច្បាប់នេះ មុននឹងបញ្ជូនសេចក្តីព្រាងច្បាប់នេះទៅទីស្តីការគណៈរដ្ឋមន្ត្រី។ បន្ទាប់ពីទទួលបានគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់ពីសម្តេចតេជោនាយករដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានប្រជុំពិនិត្យពិភាក្សាជាមួយក្រសួងយុត្តិធម៌ និងអង្គភាពប្រឆាំងអំពើពុករលួយ ចំនួន៣លើក កាលពីថ្ងៃទី៣០ ខែមករា, ទី២២ ខែកុម្ភៈ និងទី០២ ខែមីនា ឆ្នាំ២០២៣ ដើម្បីពិនិត្យកែសម្រួល និងតាក់តែងខ្លឹមសារជំពូកស្តីពីទោសប្បញ្ញត្តិ នៃសេចក្តីព្រាងច្បាប់នេះ ឱ្យមានសង្គតិភាពជាមួយបទប្បញ្ញត្តិនិងគោលការណ៍ជាធរមាន។ | |
| | **<u>សច ១៧.</u>**<br>ភាគរយនៃការអនុវត្តចំនួនសកម្មភាពកែទម្រង់ដែលបានកំណត់នៅក្នុងយុទ្ធសា-ស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ | ៨០% នៃសកម្មភាពកែទម្រង់ប្រចាំឆ្នាំនៅក្នុងយុទ្ធសាស្ត្រសម្រេចបាន | ការអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ សម្រេចបានចំនួន៧៥% | | ៨០% នៃសកម្មភាពកែទម្រង់ប្រចាំឆ្នាំនៅក្នុងយុទ្ធសាស្ត្រសម្រេចបាន | គិតត្រឹមថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ២០២២ នៃផែនការសកម្មភាពយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ សម្រេចបានចំនួន ២០សកម្មភាព ក្នុងចំណោមសកម្មភាពសរុបចំនួន ២៤ ឬស្មើនឹង៨៣.៣៣% | |
| ១៣.២.កែលម្អដំណើរការអនុវត្ត និងការទូទាត់ចំណាយ | **<u>សច ១៨.</u>**<br>**ក.** ភាគរយទំហំនៃចំណាយកកស្ទះ<br>**ខ.** ក្របខ័ណ្ឌផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ (ការកំណត់និយមន័យថ្មីនៃចំណាយកកស្ទះ) | **ក.** ចំណាយកកស្ទះមិនលើសពី ២% នៃចំណាយសរុបប្រចាំឆ្នាំ (ដោយគិតចាប់តាំងពីអាណត្តិចូលដល់ អ.រ.ជ លើសពី ៦០ ថ្ងៃ)<br>**ខ.** ក្របខ័ណ្ឌផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាព សម្រាប់ដោះស្រាយចំណាយកកស្ទះ (ការកំណត់និយមន័យថ្មីនៃចំណាយកកស្ទះ) ត្រូវបានអនុម័ត | - មិនមានចំណាយកកស្ទះ<br>- សម្រាប់ក្របខ័ណ្ឌផែនទីបង្ហាញផ្លូវ និងផែនសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ ,ក្រុមជំនាញការ ស្ថិតនៅក្នុងដំណាក់កាលគ្រោងបញ្ចប់ការធ្វើសុពលភាពទៅលើរបាយការណ៍សិក្សាអំពីជំហានចំណាយនីមួយៗ ដើម្បីអាចពិភាក្សាបឋមទាក់ទងនឹងរបកគំហើញ នាពេលខាងមុខ។ | | ចំណាយកកស្ទះមិនលើសពី ២% នៃចំណាយសរុបប្រចាំឆ្នាំ (តាមនិយមន័យថ្មី) | **ក.** ពុំមានចំណាយកកស្ទះ ដែលទូទាត់លើសពីរយៈពេល៦០ថ្ងៃ។<br>**ខ.** ក្រុមការងារបានរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍របកគំហើញរបស់ជំនាញការកាលពីថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២។ បច្ចុប្បន្ន ក្រុមជំនាញការបាននិងកំពុងប្រមូលធាតុចូលបន្ថែមទៀតពីភាគីពាក់ព័ន្ធ ផ្អែកតាមការណែនាំរបស់អង្គប្រជុំ។ | |

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មឆ្នាំ ២០២១ | លទ្ធផលសម្រេចបានឆ្នាំ២០២១ | ពណ៌ | គោលដៅសូចនាករសមិទ្ធកម្មឆ្នាំ២០២២ | លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| | **<u>សច ១៩.</u>**<br>ភាគរយចំណាយសរុបធ្វើការទូទាត់តាម E-Transfer | ចំណាយថវិកាជាតិប្រមាណ ៥៥% នៃចំណាយសរុបត្រូវបានទូទាត់តាម E-Transfer | ក្នុងឆ្នាំ ២០២១ ចំណាយថវិកាជាតិ ប្រមាណ ៥៨% នៃ ចំណាយសរុបត្រូវបានទូទាត់តាម E-Transfer | | ចំណាយថវិកាជាតិប្រមាណ ៦០% នៃចំណាយសរុបត្រូវបានទូទាត់តាម E-Transfer | បានទាញទិន្នន័យនៃការទូទាត់ចំណាយតាមប្រព័ន្ធ ETF ប្រចាំត្រីមាសទី១, ត្រីមាសទី២, ត្រីមាសទី៣ និងត្រីមាសទី៤ ឆ្នាំ២០២២ ពីប្រព័ន្ធ FMIS | |
| | **<u>សច ២០.</u>**<br>ចំនួនក្រសួង ស្ថាប័ន រៀបចំគោលការណ៍ណែនាំហិរញ្ញវត្ថុសាធារណៈ (PFMM) | ក្រសួង-ស្ថាប័នចំនួន ១០ មាន PFMM (សេចក្តីព្រាង) ព្រោះ PFMM របស់រាជរដ្ឋាភិបាល ត្រូវបានពន្យារពេល | ពុំទាន់មានវឌ្ឍនភាព ។ កាលពីខែមករា ឆ្នាំ២០២២, អ.គ.ហ .បានរៀបចំកិច្ចប្រជុំជាមួយក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការយល់ដឹង និងការចូលរួមរៀបចំ FMM។ ក្នុងនោះ ក្រសួង ស្ថាប័នចំនួន១២ បានដាក់ផែនការសកម្មភាពរៀបចំ FMM តាមយន្តការ MAP និង GDAP សម្រាប់ឆ្នាំ២០២២។ | | ក្រសួង ស្ថាប័នចំនួន ១០ មាន PFMM (សេចក្តីព្រាង) ព្រោះ PFMM របស់រាជរដ្ឋាភិបាល ត្រូវបានរៀបចំ | ក្រសួង ស្ថាប័នចំនួន ១៣ បានរៀបចំ FMM ក្នុងចំណោមនោះ មាន ៣ ក្រសួង បានរៀបចំសេចក្តីព្រាង FMM របស់ខ្លួន។ | |
| | **<u>សច ២១.</u>**<br>ភាគរយនៃក្រសួងស្ថាប័នដែលបានរៀបចំ និងផ្តល់ផែនការឥណទានរជ្ជទេយ្យបុរេប្រទានសម្រាប់ការចរចារកញ្ចប់ថវិកាប្រចាំឆ្នាំ | ១០០% ក្រសួង ស្ថាប័នបានរៀបចំ និងផែនការឥណទាន រជ្ជទេយ្យបុរេ-ប្រទាន សម្រាប់ការចរចារកញ្ចប់ថវិកាប្រចាំឆ្នាំ បានទាន់ពេលវេលា | ក្រសួង ស្ថាប័នចំនួន ១០ លើ ៣៨ (ស្មើនឹង២៧%) បានរៀបចំផែនការរជ្ជទេយ្យបុរេប្រទានតាមស្មារតីប្រកាសលេខ ៦៦៣.សហវ.ប្រក ។ ដោយឡែកក្រសួង ស្ថាប័នចំនួន ២៨ ទៀតនៅមិនទាន់បានរៀបចំទាន់ពេលវេលានៅឡើយ ។ | | ១០០% ក្រសួង ស្ថាប័នបានរៀបចំ និងផែនការ ឥណទានរជ្ជទេយ្យបុរេប្រទានសម្រាប់ការចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ បានទាន់ពេលវេលា | ក្រសួង-ស្ថាប័ន ២៩% (១១ នៃ ៣៨) បានរៀបចំ និងផែនការ ឥណទានរជ្ជទេយ្យបុរេប្រទានសម្រាប់ការចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ បានទាន់ពេលវេលា | |
| ១៣.៣. ជំរុញការទូទាត់ថវិកាបុរេប្រទាន | **<u>សច ២២.</u>**<br>ចំនួនក្រសួង-ស្ថាប័នទូទាត់ថវិកាបុរេប្រទានទាន់ពេលវេលាសម្រាប់ថវិកា ចរន្ត | គ្រប់ក្រសួង ស្ថាប័នទូទាត់ថវិកាបុរេប្រទាន (សម្រាប់ថវិកាចរន្ត) ទាន់ពេលវេលា | - ១៣ ក្រសួង ស្ថាប័ន មិនទាន់បានទូទាត់បុរេប្រទាន ឱ្យបានទាន់ពេលវេលាក្នុងឆ្នាំថវិកា២០២០ ប៉ុន្តែបានទូទាត់រួចរាល់នៅក្នុងឆ្នាំ២០២១ ។<br>- ក្នុងឆ្នាំថវិកា២០២១ មាន ១៧ក្រសួង ស្ថាប័នដែលមិនទាន់បានទូទាត់បុរេប្រទានបានទាន់ពេលវេលា ។ | | ក្រសួង ស្ថាប័នទូទាត់ថវិកាបុរេប្រទាន (សម្រាប់ថវិកាចរន្ត) ទាន់ពេលវេលា | តួលេខបណ្តោះអាសន្នលើការទូទាត់បុរេប្រទានគឺមានចំនួន ៧៥.២%។ ការទូទាត់នេះនឹងមានការកើនឡើងពេលបិទបញ្ចប់ចំណាយ។ | |
| | **<u>សច ២៣.</u>**<br>ចំនួនក្រសួង ស្ថាប័ន បើកប្រាក់បេសកកម្ម តាមប្រព័ន្ធធនាគារ | គ្រប់ក្រសួង ស្ថាប័នបើកប្រាក់បេសកកម្ម តាមប្រព័ន្ធធនាគារ | ការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារនៅមិនទាន់មាននីតិវិធីលម្អិត ហើយមានក្រសួង-ស្ថាប័នមួយចំនួនតូចប៉ុណ្ណោះបាននិងកំពុងអនុវត្ត ។ ក្រសួង-ស្ថាប័នមួយចំនួនទៀតពុំទាន់មានឆន្ទៈក្នុងការដាក់ចេញជាសកម្មភាពសម្រាប់អនុវត្តសកម្មភាពនេះនៅឡើយ។ | | គ្រប់ក្រសួង ស្ថាប័នបើកប្រាក់បេសកកម្ម តាមប្រព័ន្ធធនាគារ | -ក្រសួង-ស្ថាប័នចំនួន ២១ / ៣៧ បានបានអនុវត្តការបើកប្រាក់បេសកម្មក្នុងប្រទេស ស្មើនឹង ៥៥%។<br>-ក្រសួង-ស្ថាប័នចំនួន ១៣/៣៧ បានអនុវត្តការបើកប្រាក់បេសកម្មក្រៅប្រទេស ស្មើនឹង ៣៥%។ | |

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ ២០២១ | លទ្ធផលសម្រេចបាន | ពណ៌ | គោលដៅសូចនាករសមិទ្ធកម្ម ឆ្នាំ២០២២ | លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| **ផ្នែកទី/ខឿនទី ២ ÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ**<br>ការធ្វើស្វ័យប្រវត្តិកម្ម និងពង្រីកប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ, និង ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។ | | | | | | | |
| ២១. ពង្រឹង និង ពង្រីកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) | <u>សគ ១.</u><br>ចំនួនមុខសញ្ញាចំណាយធ្វើស្វ័យប្រវត្តិកម្មសម្រាប់អនុវត្តថវិកាតាមប្រព័ន្ធ FMIS នៅរដ្ឋបាលថ្នាក់កណ្តាល | នីតិវិធីធានាចំណាយ និងទូទាត់ចំណាយផ្សេងៗ កម្រិត ១ និងកម្រិត ២ ត្រូវបានដាក់ឱ្យអនុវត្តផ្លូវការ នៅ កសហវ និង ៧ ក្រសួង ផ្សេងទៀត | - នីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS លើការទូទាត់ចំណាយបៀវត្សនិងចំណាយទូទាត់ត្រង់ដែលមានហានិភ័យក្នុងកម្រិតនីមួយៗត្រូវបានដាក់ឲ្យអនុវត្តជាផ្លូវការនៅក្រសួងស្ថាប័នចំនួន ២៧<br>- នីតិវិធីធានាចំណាយនិងទូទាត់ចំណាយផ្សេងទៀត បានធ្វើការសិក្សានិងរៀបចំសេចក្តីព្រាងលំហូរនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS ដែលមានហានិភ័យកម្រិតទី 1 និងកម្រិតទី 2 នៅក្នុងក្របខ័ណ្ឌកសហវ. | | ស្វ័យប្រវត្តិកម្មលើ នីតិវិធីទូទាត់ចំណាយបៀវត្ស និងទូទាត់ត្រង់នៅក្រសួង-ស្ថាប័នចំនួនយ៉ាងតិច ៧ បន្ថែម, នីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញា និង ចលនាឥណទានថវិកា នៅកសហវ និង ក្រសួងបរិស្ថាន និង នីតិវិធីចំណាយថវិកាលើមុខសញ្ញាដែលមិនមានធានាចំណាយជាមុននៅក្រសួង-ស្ថាប័នចំនួន ៨ | - ក្រសួង-ស្ថាប័នបន្ថែមចំនួន ៧ ក្នុងចំណោមក្រសួង-ស្ថាប័ន ១០ ចុងក្រោយ (៣៤/៣៧) ត្រូវបានប្រកាស និង ដាក់ឱ្យអនុវត្តនីតិវិធីថ្មីចំណាយបៀវត្ស និង នីតិវិធីចំណាយទូទាត់ត្រង់ តាមប្រព័ន្ធ FMIS ទាំងស្រុង លើកលែងតែ ៣ ស្ថាប័ន រួមមាន÷ រដ្ឋសភា ព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញ។<br>- កសហវ និង ក្រសួងបរិស្ថាន (២/៣៧) ត្រូវបានប្រកាស និង ដាក់ឱ្យអនុវត្តនីតិវិធីអនុវត្តការងារថ្មី លើនីតិវិធីចំណាយថវិកាចរន្តលើគ្រប់មុខសញ្ញា តាមប្រព័ន្ធ FMIS ទាំងស្រុង រួចរាល់<br>- ក្រសួង-ស្ថាប័នចំនួន ៨ (៨/៣៧) និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ ត្រូវបានប្រកាសត្រៀមចូលរួមអនុវត្ត និង ទទួលបានការបញ្ជ្រាបការយល់ដឹង "នីតិវិធីអនុវត្តការងារថ្មីសម្រាប់នីតិវិធីចំណាយលើមុខសញ្ញាដែលមិនមានធានាចំណាយជាមុនតាមប្រព័ន្ធ FMIS ទាំងស្រុង" និង គ្រោងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅត្រីមាសទី១ ឆ្នាំ ២០២៣ | |
| | <u>សគ ២.</u><br>មុខងារពីរបន្ថែមថ្មីក្នុងប្រព័ន្ធ FMIS ត្រូវបានពង្រីកការអនុវត្ត | មុខងារថ្មីពីរគឺមុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញត្រូវបានដាក់ឱ្យសាកល្បងនៅ កសហវ. និងក្រសួងព័ត៌មាន | - មុខងារថ្មី ២ ទៅលើមុខងាររៀបចំផែនការថវិកាត្រូវបានដាក់ឲ្យប្រើប្រាស់សាកល្បងនៅ កសហវ. និង ក្រសួងកិច្ចការនារី និងមុខងារលទ្ធកម្មពេញលេញត្រូវ | | មុខងាររៀបចំផែនការថវិកាត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅក្រសួងយ៉ាងតិច ១០ និង មុខងារលទ្ធកម្មពេញលេញត្រូវ | - ក្រសួង-ស្ថាប័នចំនួន ១១ បន្ថែមថ្មី រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ ត្រូវបានប្រកាស ដាក់ឱ្យប្រើប្រាស់ជាផ្លូវការលើមុខ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | បានដាក់ឱ្យប្រើប្រាស់សាកល្បងនៅ កសហវ. ក្រសួងកិច្ចការនារី និង ក្រសួងព័ត៌មាន។ | | បានដាក់ឱ្យអនុវត្តជាផ្លូវការនៅគ្រប់ក្រសួង-ស្ថាប័ន | ងាររៀបចំផែនការថវិកា និង ទទួលបានការគាំទ្រលើការប្រើប្រាស់ប្រព័ន្ធ FMIS គ្រប់ក្រសួង-ស្ថាប័ន និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការលើមុខងារលទ្ធកម្មពេញលេញ និង ទទួលបានការគាំទ្រលើការប្រើប្រាស់ប្រព័ន្ធ FMIS | |
| | <u>សគ ៣.</u><br>ចំនួនការដ្ឋានអនុវត្តគម្រោង FMIS បន្ថែមថ្មី (ពង្រីកការប្រើប្រាស់មុខងារស្នូលរបស់ប្រព័ន្ធ FMIS ទៅកាន់អង្គភាពថ្នាក់ជាតិ, អង្គភាពថ្នាក់ក្រោមជាតិ, និងគ្រឹះស្ថានសាធារណៈរដ្ឋបាល) | អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីចំនួន ២ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS និងរដ្ឋបាល រាជធានី ខេត្ត ទាំង ២៥ ត្រូវបានដាក់ដំឡើងប្រព័ន្ធ FMIS សម្រាប់ការ-ត្រៀមដាក់ឱ្យប្រើប្រាស់នៅឆ្នាំ ២០២២ | - អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីចំនួនពីរ÷ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិត្រូវបានដាក់ឲ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ<br>- រដ្ឋបាលរាជធានីខេត្តចំនួន ២៥ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីចំនួន ១០ ត្រូវបានដាក់ដំឡើងប្រព័ន្ធ FMIS សម្រាប់ប្រើប្រាស់ជាផ្លូវការនៅដើមឆ្នាំ២០២២ | | - អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីនៅថ្នាក់កណ្ដាលចំនួន ១០ យ៉ាងតិច និង រដ្ឋបាលរាជធានី-ខេត្តទាំង ២៥ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS។<br>- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីនៅថ្នាក់កណ្ដាល ចំនួន ១០ យ៉ាងតិច និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ចំនួនយ៉ាងតិច ៥ ត្រូវបានដាក់ដំឡើងប្រព័ន្ធ FMIS សម្រាប់ការត្រៀមដាក់ឱ្យប្រើប្រាស់នៅឆ្នាំ ២០២៣។<br>- ប្រព័ន្ធឯកសារឌីជីថល (FMIS Portal V1) ត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បងនៅរដ្ឋបាលស្រុកចំនួន ៧៥ និង រដ្ឋបាលឃុំចំនួន ១៨៥ | - រដ្ឋបាលរាជធានី-ខេត្តទាំង២៥ និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការសម្រាប់ប្រតិបត្តិការឆ្នាំ ២០២២<br>- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីនៅថ្នាក់កណ្ដាលចំនួន ១០ និង គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ៤ ត្រូវបានអនុវត្តកិច្ចការត្រៀមស្របតាមផែនការថ្មីលើការដាក់ឱ្យដំឡើងប្រព័ន្ធ FMIS សម្រាប់ការត្រៀមដាក់ឱ្យប្រើប្រាស់នៅឆ្នាំ ២០២៣<br>- រដ្ឋបាលស្រុកចំនួន ៧៥ និង រដ្ឋបាលឃុំចំនួន ១៨៥ បានប្រើប្រាស់សាកល្បងប្រព័ន្ធឯកសារឌីជីថល (FMIS Portal V1) ជាផ្លូវការ និង ទទួលបានការគាំទ្រលើការប្រើប្រាស់ | |
| ២១.១. ស្វ័យប្រវត្តិកម្ម និងការពង្រីកការដ្ឋានប្រើប្រាស់ប្រព័ន្ធ FMIS | <u>សច ១.</u><br>ចំនួនមុខសញ្ញាចំណាយធ្វើស្វ័យប្រវត្តិកម្មសម្រាប់ អនុវត្តថវិកាតាមប្រព័ន្ធ FMIS នៅរដ្ឋបាលថ្នាក់កណ្ដាល | នីតិវិធីធានាចំណាយ និងទូទាត់ចំណាយផ្សេងៗ កម្រិត ១ និងកម្រិត ២ ត្រូវបានដាក់ឱ្យអនុវត្តផ្លូវការ នៅ កសហវ និង ៧ ក្រសួង ផ្សេងទៀត | - ក្រសួងស្ថាប័នចំនួន ២៧ ត្រូវបានដាក់ឱ្យអនុវត្តនីតិវិធីអនុវត្តការងារថ្មីបាន FMIS ជាផ្លូវការលើការទូទាត់បៀវត្សនិងទូទាត់ត្រង់ដែលមានហានិភ័យ កម្រិតទី១ និងកំពុងបន្តរៀបចំសម្រាប់ការអនុវត្តនៅក្រសួងស្ថាប័នចំនួន ១០ ដែលនៅសល់ ។<br>- បានសិក្សានិងរៀបចំសេចក្ដីព្រាងលំហូរនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS លើការធានាចំណាយ និង | | នីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS ត្រូវបានពង្រីកការដាក់ឱ្យអនុវត្តជាផ្លូវការសម្រាប់ ១-ការទូទាត់ចំណាយបៀវត្ស និង ទូទាត់ត្រង់ហានិភ័យទាបនៅក្រសួង-ស្ថាប័នចំនួនយ៉ាងតិច ៧ បន្ថែម, ២-នីតិវិធីចំណាយថវិកាចរន្តលើគ្រប់មុខសញ្ញាក្នុងប្រព័ន្ធ FMIS ទាំងស្រុងនៅ កសហវ | - សេចក្ដីណែនាំនៃការអនុវត្តនីតិវិធីថ្មីលើនីតិវិធីទូទាត់ចំណាយបៀវត្ស និង នីតិវិធីចំណាយទូទាត់ត្រង់សម្រាប់ ក្រសួង-ស្ថាប័ន ចំនួន ៧ ក្នុងចំណោម ១០ ចុងក្រោយ ត្រូវបានរៀបចំ និង ប្រកាសដាក់ឱ្យអនុវត្តរួចរាល់ ។ ដោយឡែកស្ថាប័នចំនួន ៣ (រដ្ឋសភា ព្រឹទ្ធសភា និង ក្រុមប្រឹក្សាធម្មនុញ្ញ) | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ទូទាត់ចំណាយថវិកាផ្សេងទៀតក្រៅពីទូទាត់បៀវត្ស និងទូទាត់ត្រង់ដែលមានហានិភ័យកម្រិតទី 1 និង កម្រិតទី 2 នៅក្នុងក្របខ័ណ្ឌកសហវ. | | និង ក្រសួងបរិស្ថាន និង ៣-នីតិវិធីចំណាយលើមុខសញ្ញាដែលមិនមានធានាចំណាយជាមុន នៅក្រសួង-ស្ថាប័នចំនួន ៨ | មាននីតិវិធីពិសេសដាច់ដោយឡែក និង ពុំទាន់អាចអនុវត្តបាន ។<br>- សេចក្តីណែនាំនៃការអនុវត្តនីតិវិធីថ្មីលើនីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញា តាមប្រព័ន្ធ FMIS ទាំងស្រុង សម្រាប់ កសហវ និង ក្រសួងបរិស្ថានត្រូវបានរៀបចំ និង ប្រកាសដាក់ឱ្យអនុវត្តរួចរាល់<br>- សកម្មភាពគាំទ្ររួមមានដូចជា ការប្រកាសចូលរួមអនុវត្ត, ការបញ្ជ្រាបការយល់ដឹង, ការសិក្សា វិភាគ និង រៀបចំនីតិវិធី, ការរៀបចំឯកសារគតិយុត្តិ, ការប្រជុំឆ្លងយោបល់ និង ពិនិត្យពិភាក្សា, ការបណ្តុះបណ្តាល និង ការគាំទ្រការប្រើប្រាស់ ត្រូវបានអនុវត្តរួចរាល់សម្រាប់ការដាក់ឱ្យប្រើប្រាស់នីតិវិធីអនុវត្តការងារថ្មីលើនីតិវិធីទូទាត់ចំណាយបៀវត្ស និង នីតិវិធីចំណាយទូទាត់ត្រង់ នៅ ក្រសួង-ស្ថាប័នចំនួន ៧ និង នីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញា តាមប្រព័ន្ធ FMIS ទាំងស្រុង នៅ កសហវ និង ក្រសួងបរិស្ថាន ។ សកម្មភាពគាំទ្ររួមមានដូចជា ការប្រកាសចូលរួមអនុវត្ត និង ការបញ្ជ្រាបការយល់ដឹង ត្រូវបានអនុវត្តរួចរាល់សម្រាប់ការត្រៀមដាក់ឱ្យប្រើប្រាស់នីតិវិធីអនុវត្តការងារថ្មីសម្រាប់នីតិវិធីចំណាយលើមុខសញ្ញាដែលមិនមានធានាចំណាយជាមុន តាមប្រព័ន្ធ FMIS ទាំងស្រុង នៅ ក្រសួង-ស្ថាប័នចំនួន ៨ និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ | |
| | <u>សច ២.</u><br>ចំនួនការដ្ឋានអនុវត្តគម្រោង FMIS បន្ថែមថ្មី (ពង្រីកការប្រើ | អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីចំនួន ២ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS | អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីពី (អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមនិងឧត្តមក្រុម | | - អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីនៅថ្នាក់កណ្តាលចំនួន ១០ យ៉ាងតិច និង រដ្ឋបាលរាជធានី-ខេត្ត | - រដ្ឋបាលរាជធានី-ខេត្តទាំង២៥ និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញបន្ថែមថ្មីចំនួន ១០ ត្រូវបានប្រកាសដាក់ឱ្យ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រាស់មុខងារស្នូលរបស់ប្រព័ន្ធ FMIS ទៅកាន់អង្គភាពថ្នាក់ជាតិ អង្គភាពថ្នាក់ក្រោមជាតិ និង គ្រឹះស្ថានសាធារណៈ រដ្ឋបាល) | | ប្រឹក្សាសេដ្ឋកិច្ចជាតិ) បានប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការសម្រាប់ដល់ប្រតិបត្តិការឆ្នាំ ២០២១។ | | ទាំង ២៥ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS<br>- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីនៅថ្នាក់កណ្តាល ចំនួន ១០ យ៉ាងតិច និង គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួនយ៉ាងតិច ៥ ត្រូវបានដាក់ដំឡើងប្រព័ន្ធ FMIS សម្រាប់ការត្រៀមដាក់ឱ្យប្រើប្រាស់នៅឆ្នាំ ២០២៣ | ប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការសម្រាប់ប្រតិបត្តិការឆ្នាំ ២០២២<br>- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីនៅថ្នាក់កណ្តាលចំនួន ១០ និង គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ៤ (ក្នុងចំណោម ៥ មាន ១ គ្រឹះស្ថានសាធារណៈរដ្ឋបាលស្នើសុំពន្យារពេលអនុវត្ត) ត្រូវបានអនុវត្តកិច្ចការត្រៀមស្របតាមផែនការថ្មីលើការដាក់ឱ្យដំឡើងប្រព័ន្ធ FMIS សម្រាប់ការត្រៀមដាក់ឱ្យប្រើប្រាស់នៅឆ្នាំ ២០២៣<br>- រដ្ឋបាលស្រុកចំនួន ៧៥ និង រដ្ឋបាលឃុំចំនួន ១៨៥ បានប្រើប្រាស់សាកល្បងប្រព័ន្ធឯកសារឌីជីថល (FMIS Portal V1) ជាផ្លូវការនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០២២ និង ទទួលបានការគាំទ្រលើការប្រើប្រាស់<br>- ប្រព័ន្ធឯកសារឌីជីថល (FMIS Portal V1) ត្រូវបានរៀបចំអភិវឌ្ឍ និង តេស្តសាកល្បងរួចរាល់សម្រាប់ការត្រៀមដាក់ឱ្យប្រើប្រាស់នៅរដ្ឋបាលក្រុងចំនួន ៦, រដ្ឋបាលស្រុកចំនួន ៦១, រដ្ឋបាលឃុំចំនួន ៤៤៧ និង រដ្ឋបាលសង្កាត់ចំនួន ២៨ ការដ្ឋានបន្ថែម។ | |
| ២១.២. ធ្វើសន្ធានកម្មជាមួយប្រព័ន្ធដទៃផ្សេងទៀត | <u>**សច ៣.**</u><br>អភិវឌ្ឍន៍កែលម្អបន្ថែម និង ដាក់ឱ្យដំណើការជាផ្លូវការលើការធ្វើសន្ធានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធខាងក្រៅ | - កែលម្អមុខងារសន្ធានកម្មដែលមានស្រាប់÷ DMFAS, NBC, ពន្ធដារ<br>- អភិវឌ្ឍន៍បន្ថែមសន្ធានកម្មទិន្នន័យរវាង FMIS ជាមួយនឹងប្រព័ន្ធបៀវត្ស | អភិវឌ្ឍន៍បន្ថែមសន្ធានកម្មទិន្នន័យរវាង FMIS ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងៗ រួមមាន ÷ PIM និង EFMS របស់ក្រសួងអប់រំ យុវជន និងកីឡា ។ | | - សន្ធានកម្មដែលមានស្រាប់ជាមួយនឹង FMIS ត្រូវបានត្រួតពិនិត្យលើដំណើរការ និងកែលម្អបន្ថែម<br>-អភិវឌ្ឍន៍បន្ថែមសន្ធានកម្មទិន្នន័យរវាង FMIS ជាមួយនឹងប្រព័ន្ធខាងក្រៅ | - ក្រុមការងារបានពិនិត្យ និងធ្វើតេស្តព្រមទាំងបានរៀបចំរបាយការណ៍ស្តីពីការត្រួតពិនិត្យលើដំណើរការ និង បច្ចេកទេសនៃការធ្វើសន្ធានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធខាងក្រៅដែលបានដាក់ដំណើរការរួចរាល់<br>- សន្ធានកម្មរបាយការណ៍ធនាគាររវាងប្រព័ន្ធ FMIS ជាមួយនឹងធនាគារប្រៃសណីយ៍កម្ពុ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | ជា អ.ក ត្រូវបានរៀបចំរួចរាល់ និង ដាក់ឱ្យដំណើរការជាផ្លូវការ.<br>- សន្ធានកម្មការទូទាត់តាមអេឡិកត្រូនិក (EFT) ពីប្រព័ន្ធ FMIS ទៅប្រព័ន្ធធនាគារអេស៊ីលីដា ទាំងនៅថ្នាក់កណ្តាល និង ថ្នាក់មូលដ្ឋាន ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ចាប់ពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០២២<br>- ការធ្វើសន្ធានកម្មទិន្នន័យរវាងប្រព័ន្ធ FMIS និង ប្រព័ន្ធ NRMIS ត្រូវបានពង្រីកវិសាលភាពដល់ រដ្ឋបាលរាជធានី-ខេត្តទាំង២៥<br>- សន្ធានកម្មបន្ថែមថ្មីជាមួយប្រព័ន្ធខាងក្រៅពុំទាន់មានតម្រូវការក្នុងការសិក្សាលទ្ធភាពនៅឡើយ ក្រៅពីការបន្តសិក្សាលទ្ធភាពសន្ធានកម្មជាមួយនឹងប្រព័ន្ធ EFMS ដែលជំរុញដោយដៃគូអភិវឌ្ឍន៍ | |
| ២១.៣. ពង្រីកការអនុវត្តគម្រោង FMIS លើមុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញ | <u>**សច ៤.**</u><br>មុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញ ត្រូវបានដាក់ឱ្យអនុវត្តនៅក្រសួង-ស្ថាប័ន | កសហវ និង ក្រសួងព័ត៌មាន ត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បងលើមុខងារថ្មីពីរ | មុខងាររៀបចំផែនការថវិកា ត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បងនៅ កសហវ. និង ក្រសួងកិច្ចការនារី និង មុខងារលទ្ធកម្មពេញលេញ ត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បងនៅ កសហវ. ក្រសួងកិច្ចការនារី និង ក្រសួងព័ត៌មាន ។ | | មុខងាររៀបចំផែនការថវិកាត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅក្រសួងយ៉ាងតិច១០ និង មុខងារលទ្ធកម្មពេញលេញ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅគ្រប់ក្រសួង-ស្ថាប័ន | - មុខងាររៀបចំផែនការថវិកា ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅក្រសួង-ស្ថាប័នចំនួន ១១ បន្ថែមថ្មី និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ ព្រមទាំងទទួលបានការគាំទ្រលើការប្រើប្រាស់<br>- មុខងារលទ្ធកម្មពេញលេញ ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅគ្រប់ក្រសួង-ស្ថាប័ន និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិទាំងអស់ ដែលបាន និងកំពុងប្រើប្រាស់ប្រព័ន្ធ FMIS ព្រមទាំងទទួលបានការគាំទ្រលើការប្រើប្រាស់<br>- កិច្ចការត្រៀមមានដូចជា ការបញ្ជ្រាបការយល់ដឹង, ការសិក្សានីតិវិធីអនុវត្តការងារ, ការកំណត់ឈ្មោះនិងតួនាទីអ្នកប្រើប្រាស់, ការដាក់ដំឡើងហេដ្ឋារចនាសម្ព័ន្ធបណ្តាញតភ្ជាប់, ការរៀបចំប្រព័ន្ធ និង ការបណ្តុះប | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | ណ្តាល ត្រូវបានរៀបចំរួចរាល់ សម្រាប់ការដាក់ឱ្យប្រើប្រាស់ក្នុង ឆ្នាំ ២០២៣ នូវមុខងាររៀបចំផែនការថវិកា (នៅ១២ ក្រសួង-ស្ថាប័ន និង មន្ទីរសហវ ទាំង២៥) និង មុខងារលទ្ធកម្មពេញលេញ (នៅមន្ទីរសហវ ទាំង២៥) | |
| ២១.៤. ពង្រឹងលើសមត្ថ-ភាពអ្នកប្រើប្រាស់ និងប្រព័ន្ធ FMIS | **<u>សច ៥.</u>**<br>ចំនួនមន្ត្រីរាជការដែលប្រើប្រាស់ប្រព័ន្ធ FMIS ត្រូវបានពង្រឹងសមត្ថភាពតាមរយៈការបណ្តុះ-បណ្តាលវិជ្ជាជីវៈ និងការអនុវត្តការងារជាក់ស្តែង | - ក្រសួងចំនួន ២ និងមន្ត្រី ចំនួន ៥០រូប យ៉ាងតិច ទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈលើការប្រើប្រាស់មុខងារពីរថ្មី<br>- អ្នកប្រើប្រាស់ចំនួន ២០០ រូប យ៉ាងតិចទទួលបានការបំប៉នសមត្ថភាពចំណេះដឹងថ្មីៗបន្ថែម | - មន្ត្រីអ្នកប្រើប្រាស់ចំនួន ១០៤ រូប នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន និងក្រសួងកិច្ចការនារីត្រូវបានបណ្តុះបណ្តាលលើមុខងាររៀបចំផែនការថវិកា និង មុខងារលទ្ធកម្មពេញលេញ<br>- មន្ត្រីប្រើប្រាស់ប្រព័ន្ធ FMIS ចំនួន ៤៨៩ រូប នៅតាមក្រសួងស្ថាប័ន មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានីខេត្តទាំង ២៥ បានទទួល ការបណ្តុះបណ្តាលបំប៉នគន្លឹះថ្មីបន្ថែមលើការប្រើប្រាស់ប្រព័ន្ធ FMIS និង ការអនុវត្តនីតិវិធីតម្រង់ទិសថ្មី | | អ្នកប្រើប្រាស់ចំនួនប្រមាណជា ២៥០ រូប យ៉ាងតិច ទទួលបានការបំប៉នសមត្ថភាព ចំណេះដឹងថ្មីៗបន្ថែម លើការប្រើប្រាស់ប្រព័ន្ធ FMIS | សិក្ខាកាមដែលបាននិងកំពុងប្រើប្រាស់ប្រព័ន្ធ FMIS ចំនួន ៦២៩ រូប ទទួលបានវគ្គបណ្តុះបណ្តាលបំប៉នបន្ថែមស្តីពី "គន្លឹះថ្មីបន្ថែមលើការប្រើប្រាស់ប្រព័ន្ធ FMIS និងការអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS ទាំងស្រុង" ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០២២ ដល់ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២២ លើមុខវិជ្ជាចំនួន ១១ | |
| | **<u>សច ៦.</u>**<br>លទ្ធភាពនៃការកត់ត្រាចំណាយថវិកាដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធ FMIS | គ្រប់ក្រសួង ស្ថាប័នអនុវត្តថវិកាដៃគូមានរបាយការណ៍ បូកសរុបនៃការអនុវត្តថវិកា ស្របតាមមាតិកាថវិការដ្ឋ និងផ្ញើមក កសហវ ទាន់ពេលវេលា | - របាយការណ៍ស្តីពីការពិភាក្សា និងលទ្ធភាពក្នុងការកត់ត្រាចំណាយថវិកាដៃគូក្នុងប្រព័ន្ធ FMIS<br>- របាយការណ៍ និងផែនការសម្រាប់អភិវឌ្ឍនូវមុខងារកត់ត្រាចំណាយថវិកាដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធ FMIS | | - សិក្សា រៀបចំ និង អភិវឌ្ឍប្រព័ន្ធសម្រាប់ការកត់ត្រាថវិកាដៃគូ នៅគ្រប់ក្រសួង ស្ថាប័នអនុវត្តថវិកាដៃគូ និងមានរបាយការណ៍សិក្សានៃការអនុវត្តថវិកាស្របតាមមាតិកាថវិការដ្ឋ<br>- រៀបចំផែនការអនុវត្តការកត់ត្រាលើថវិកាដៃគូ | -បានរៀបចំឯកសារទស្សនាទានរបាយការណ៍ស្តីពីការសិក្សាសមិទ្ធលទ្ធភាពកត់ត្រាទិន្នន័យចំណាយគម្រោងវិនិយោគដែលហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធ FMIS<br>-ការសិក្សាសមិទ្ធលទ្ធភាពនៃការកត់ត្រាទិន្នន័យចំណាយគម្រោងវិនិយោគដែលហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធ FMIS នឹងបញ្ចប់នៅខែមីនា ឆ្នាំ២០២៤ | |
| | **<u>សច ៧.</u>**<br>របាយការណ៍ តាមដានលើការអនុវត្តថវិកានៅក្នុងប្រព័ន្ធ FMIS ត្រូវបានពង្រឹងគុណភាព, ធ្វើបច្ចុប្បន្នភាព និង អភិវឌ្ឍបន្ថែមនៅក្នុងប្រព័ន្ធ FMIS | - របាយការណ៍តាមចំណាត់ ថ្នាក់ថវិកាទាំង ៧ ត្រូវបាន តាមដានលើការអនុវត្តនៅក្នុងប្រព័ន្ធ FMIS និង ពង្រឹងគុណភាព ដោយធ្វើបច្ចុប្បន្នភាព និង អភិវឌ្ឍបន្ថែមនៅក្នុងប្រព័ន្ធ FMIS | - របាយការណ៍វាយតម្លៃ លើការអនុវត្តការបញ្ចូលព័ត៌មានចំណាត់ថ្នាក់ថវិកា ក្នុងប្រព័ន្ធ FMIS ត្រូវបានរៀបចំរួចរាល់ ដើម្បីជំរុញឲ្យការអនុវត្តបានពេញលេញព្រមទាំងបានពិនិត្យនិងពង្រឹងគុណភាពរបាយការណ៍ ដោយបានធ្វើបច្ចុប្បន្នភាពអភិវឌ្ឍបន្ថែមតេ | | - របាយការណ៍តាមចំណាត់ថ្នាក់ថវិកាទាំង ៧ ត្រូវបានតាមដានលើការអនុវត្តនៅក្នុងប្រព័ន្ធ FMIS និង ពង្រឹងគុណភាព ដោយធ្វើបច្ចុប្បន្នភាព និង អភិវឌ្ឍបន្ថែមនៅក្នុងប្រព័ន្ធ FMIS | - ក្រុមការងារបានបញ្ចប់ការត្រួតពិនិត្យ វិភាគទិន្នន័យ និង រៀបចំរបាយការណ៍ពិនិត្យលើការអនុវត្តការបញ្ចូលព័ត៌មានចំណាត់ថ្នាក់ថវិកាទាំង ៧ នៅរដ្ឋបាលរាជធានី-ខេត្តរួចរាល់ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | - កម្មវិធីកញ្ចក់ថវិកាជំនាន់ ១ ត្រូវបានត្រួតពិនិត្យ និង ដាក់ឱ្យប្រើប្រាស់ សម្រាប់ថ្នាក់ដឹកនាំក្រសួង និង អង្គភាពពាក់ព័ន្ធ | សួសាកល្បងនិងការដាក់ឱ្យប្រើប្រាស់របាយការណ៍ក្នុងមជ្ឈដ្ឋានផ្លូវការរបស់ប្រព័ន្ធ FMIS<br>- កម្មវិធីកញ្ចក់ថវិកាជំនាន់ 2 ត្រូវបានអភិវឌ្ឍទាល់ដោយទទួលបានការត្រួតពិនិត្យ និងការពារទាំងទាត់លើព័ត៌មាននិងទិន្នន័យដល់ អគ្គនាយកដ្ឋានពាក់ព័ន្ធ ព្រមទាំងបានបញ្ចប់ ការវាយតម្លៃប្រព័ន្ធសុវត្ថិភាពរបស់កម្មវិធី | | - កម្មវិធីកញ្ចក់ថវិកាជំនាន់ ២ ត្រូវបានត្រួតពិនិត្យ និង ដាក់ឱ្យប្រើប្រាស់ សម្រាប់ថ្នាក់ដឹកនាំក្រសួង និង អង្គភាពពាក់ព័ន្ធ | - របាយការណ៍លទ្ធផលពិនិត្យគុណភាពលើរបាយការណ៍ថវិកាតាមចំណាត់ថ្នាក់ថវិកាទាំង៧ នៅក្នុងប្រព័ន្ធ FMIS ត្រូវបានរៀបចំ និង ពិនិត្យផ្ទៀងផ្ទាត់ រួចរាល់ ព្រមទាំងបានផ្សព្វផ្សាយ និង ជំរុញការប្រើប្រាស់បន្ថែមក្នុងប្រព័ន្ធ FMIS<br>- កម្មវិធីកញ្ចក់ថវិកាជំនាន់ទី២ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការសម្រាប់កម្រិតថ្នាក់ដឹកនាំ កសហវ | |
| | **សច ៨.**<br>មានយន្តការប្រកប ដោយចីរភាពក្នុងការទ្រទ្រង់គាំទ្រ និង ដោះស្រាយបញ្ហាលើការប្រើប្រាស់ប្រព័ន្ធ FMIS | - ៨០% នៃសំបុត្របញ្ហា ត្រូវបានឆ្លើយតបទាន់ពេលវេលា<br>- ការត្រួតពិនិត្យជាប្រចាំនូវឧបករណ៍បច្ចេកវិទ្យាព័ត៌មាននៅគ្រប់អង្គភាពអ្នកប្រើប្រាស់ប្រព័ន្ធ FMIS | - 95% នៃសំបុត្របញ្ហាត្រូវបានដោះស្រាយនិងឆ្លើយតបទាន់ពេលវេលាបញ្ហាកូវីដ19 រាំងស្ទះដល់ក្រុមការងារក្នុងការចុះត្រួតពិនិត្យជាប្រចាំនូវឧបករណ៍បច្ចេកវិទ្យាព័ត៌មាននៅគ្រប់អង្គភាពអ្នកប្រើប្រាស់ប្រព័ន្ធ FMIS | | ៨៥% នៃសំបុត្របញ្ហា ត្រូវបានឆ្លើយតប សម្របសម្រួល និង ដោះស្រាយទាន់ពេលវេលា | - របាយការណ៍បូកសរុបប្រចាំឆ្នាំស្តីអំពីស្ថានភាពនៃការទ្រទ្រង់ គាំទ្រ និង ដោះស្រាយបញ្ហាដែលបានអនុវត្តនៅក្នុងឆ្នាំ ២០២១ ត្រូវបានរៀបចំរួចរាល់ និង ប្រមាណ ៩៧% នៃសំបុត្របញ្ហា ត្រូវបានឆ្លើយតប និង ដោះស្រាយរួចរាល់<br>- យន្តការ និង នីតិវិធីនៃការទ្រទ្រង់ គាំទ្រ និង ដោះស្រាយបញ្ហាលើការប្រើប្រាស់ប្រព័ន្ធ FMIS ត្រូវបានធ្វើបច្ចុប្បន្នភាពរួចរាល់<br>- ឯកសារតម្រូវការសម្រាប់រៀបចំកែលម្អ និង អភិវឌ្ឍបន្ថែមលើប្រព័ន្ធជំនួយគាំទ្រ បានប្រមូល និង រៀបចំរួចរាល់ សម្រាប់បញ្ជូនទៅកាន់ក្រុមការងារបច្ចេកទេស ដើម្បីរៀបចំកិច្ចការបន្ត | |
| | **សច ៩.**<br>ចំនួនចំណាត់ថ្នាក់ត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំថវិកា , ការអនុវត្តថវិកា និងការត្រួតពិនិត្យតាមដានថវិកា | - ចំណាត់ថ្នាក់មុខងារត្រូវអនុវត្តអនុលោមតាម COFOG និងស្របតាមប្រកាសលេខ ៩៩៦ សហវ.ប្រក ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់មុខងារនៃមាតិកា ថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | - ទិន្នន័យពីចំណាត់ថ្នាក់មុខងារ និងភូមិសាស្ត្រ មាននៅគ្រប់ប្រតិបត្តិការនៃការទូទាត់តាម អាណត្តិបើកប្រាក់ | | គ្រប់របាយការណ៍ផលិតតាមចំណាត់ថ្នាក់ទាំង ៧ អាចប្រើប្រាស់សម្រាប់ការវិភាគ | - បានត្រួតពិនិត្យជាប្រចាំ និងណែនាំដល់ក្រសួងស្ថាប័ន ដើម្បីជំរុញ ការកត់ត្រាចំណាត់ថ្នាក់មុខងារ និងចំណាត់ថ្នាក់ភូមិ-សាស្ត្របានត្រឹមត្រូវ រាល់ប្រតិបត្តិការណ៍ក្នុង FMIS ។ (អ.រតន) | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | - ចំណាត់ថ្នាក់ភូមិសាស្ត្រត្រូវបានអនុវត្តពេញលេញ | | | | | |
| | <u>សច ១០.</u><br>មជ្ឈមណ្ឌលទិន្នន័យត្រូវបានបង្កើនសមត្ថភាព និងសុវត្ថិភាព | - មជ្ឈមណ្ឌលទិន្នន័យមានសមត្ថភាពអាចទ្រទ្រង់អ្នកប្រើប្រាស់បន្ថែមយ៉ាងតិច ៥០០ នាក់<br>- មានរបាយការណ៍ប្រឹក្សាជាមួយក្រុមហ៊ុនសម្រាប់ត្រៀមយកវិញ្ញាបនបត្រ ISO/IEC:27001:2013 | - ឯកសារតម្រូវការបច្ចេកទេសសំរាប់ពង្រឹងសមត្ថភាព និងសុវត្ថិភាពរបស់មជ្ឈមណ្ឌលទិន្នន័យត្រូវបានរៀបចំរួចរាល់ និងបានដាក់ឲ្យដេញថ្លៃរួចរាល់ដោយកំពុងបន្តដំណើរការវាយតម្លៃជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់<br>- មានរបាយការណ៍ប្រឹក្សាជាមួយក្រុមហ៊ុនសម្រាប់ត្រៀមយកវិញ្ញាបនបត្រISO/IEC:27001:2013 | | គោលនយោបាយ ក្នុងការគ្រប់គ្រងសុវត្ថិភាពនៃមជ្ឈមណ្ឌលទិន្នន័យរបស់គម្រោង FMIS ត្រូវបានរៀបចំ និង បណ្តុះបណ្តាលរួចរាល់ | ឯកសារនីតិវិធីក្នុងការគ្រប់គ្រងសុវត្ថិភាពនៃមជ្ឈមណ្ឌលទិន្នន័យរបស់គម្រោង FMIS ទាំង ៥ ត្រូវបានរៀបចំ និង ដាក់ជូនថ្នាក់ដឹកនាំរួចរាល់ ព្រមទាំងបានបញ្ជ្រាបការយល់ដឹងអំពីគោលនយោបាយនេះជូនដល់ក្រុមការងារបច្ចេកទេស និង អ្នកប្រើប្រាស់ប្រព័ន្ធ FMIS ប្រមាណ ៦០០ នាក់ រួចរាល់ | |
| ២១.៥. ជំរុញការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង FMIS ជំហានទី ៣ | <u>សច ១១.</u><br>ចំនួនសកម្មភាពសម្រេចបានធៀបនឹងការគ្រោង ក្នុងមួយឆ្នាំក្នុងកម្រិតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ៩០% នៃសកម្មភាពសម្រេចបានជារៀងរាល់ឆ្នាំ | សម្រេចបានវឌ្ឍនភាពប្រចាំឆ្នាំ២០២១ចំនួន៩៥% ធៀបផែនការដែលបានដាក់ចេញ | | ៩០% នៃសកម្មភាពសម្រេចបានជារៀងរាល់ឆ្នាំ | -របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០២១ នៃការអនុវត្តគម្រោង FMIS ជំហានទី៣ ត្រូវបានរៀបចំរួចរាល់ ដែលសម្រេចបានវឌ្ឍនភាពក្នុងរង្វង់ ៩៥%<br>-របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស និងប្រចាំឆ្នាំ ២០២២ នៃការអនុវត្តគម្រោង FMIS ជំហានទី៣ ត្រូវបានរៀបចំរួចរាល់ ដែលសម្រេចបានវឌ្ឍនភាពការងារលើសពី ៩០% | |
| **២២. ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ថ្មី** | **<u>សគ ៤.</u><br>ភាពទាន់ពេលវេលានៃការបិទបញ្ជីគណនេយ្យ** | **ការបិទបញ្ជីគណនេយ្យក្នុងរយៈពេល ពី ៦ ខែ ទៅ ៩ខែ** | **ការបិទបញ្ជីគណនេយ្យត្រូវប្រើពេល៩ខែ** | | **ការបិទបញ្ជីគណនេយ្យក្នុងរយៈពេល ពី ៦ ខែ ទៅ ៩ខែ** | **ការបិទបញ្ជីគណនេយ្យឆ្នាំ២០២១នៅក្នុងខែកញ្ញា ឆ្នាំ២០២២** | |
| | **<u>សគ ៥.</u><br>កម្រិតអនុលោមភាពនៃរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដា IPSAS Cash Basis** | **របាយការណ៍ហិរញ្ញវត្ថុអាចទទួលយកបានស្របតាម IPSAS Cash Basis** | **របាយការណ៍ហិរិញ្ញវត្ថុស្របតាម IPSAS Cash basis ត្រូវបានកែលម្អកាន់តែប្រសើរឡើងតាមរយៈការវាយតម្លៃពីជំនាញការ IMF។ សមាសធាតុសំខាន់មួយចំនួនត្រូវបានកែលម្អដោយបានលាតត្រដាងកាន់តែលម្អិតនៅ ក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុ ដោយបានដាក់បង្ហាញព័ត៌មានអំពីសាច់ប្រាក់កម្ចីដែលមិនទាន់ប្រើប្រាស់និងព័ត៌មាន អំពីអង្គភាពថវិកាដែលរាយការណ៍ជាដើម** | | **របាយការណ៍ហិរញ្ញវត្ថុអាចទទួលយកបានស្របតាម IPSAS Cash Basis** | **ន.គ.ស បានពិនិត្យ និងផ្តល់យោបល់រួចរាល់លើសេចក្តីព្រាងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២១ ដែលផលិតដោយអគ្គនាយកដ្ឋានរតនាគារជាតិអនុលោមតាម IPSAS Cash Basis កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ២០២២។** | |

| | **<u>សគ ៦.</u>**<br>**ភាពទាន់ពេលវេលានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ** | **របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៩ ត្រូវបានរៀបចំរួចរាល់ក្នុងត្រីមាសទី ២ ឆ្នាំ២០២១** | **របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៩ ត្រូវបានរៀបចំរួចរាល់ក្នុងត្រីមាសទី ២ ឆ្នាំ២០២១** | | **របាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០២០ ត្រូវបានរៀបចំ រួចរាល់ក្នុងត្រីមាសទី ១ ឆ្នាំ ២០២២** | **របាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០២០ ត្រូវបានរៀបចំ រួចរាល់ក្នុងត្រីមាសទី ១ ឆ្នាំ២០២២ ដោយយកមូលដ្ឋានចេញពីប្រព័ន្ធ FMIS** | |
|---|---|---|---|---|---|---|---|
| ២២.១. រៀបចំ និងដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ-សាធារណៈកម្ពុជា | **<u>សច ១២.</u>**<br>ភាគរយនៃការអនុវត្តសកម្មភាពនៅក្នុងយុទ្ធសាស្ត្រសម្រេចបាន | ៩០% នៃសកម្មភាពសរុប សម្រេចបាន | -ន.គ.ស. បានពិនិត្យ និងផ្តល់យោបល់រួចរាល់លើសេចក្តីព្រាងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៩-២០២០ ដែលផលិតដោយអគ្គនាយកដ្ឋាន រតនាគារជាតិអនុលោមតាម IPSAS Cash Basis។<br>-ឯកសារយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជាឆ្នាំ២០២១-២០៣១ត្រូវបានទទួលបានឯកភាពដ៏ខ្ពង់ខ្ពស់ដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រីកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ និងគោរពសុំការសម្រេចដ៏ខ្ពង់ខ្ពស់ដើម្បីអនុម័តដោយប្រមុខរាជរដ្ឋាភិបាលនៅត្រីមាសទី១ ឆ្នាំ២០២២។<br>-ផែនការសកម្មភាពលម្អិតគាំទ្រទៅលើការអនុវត្តយុទ្ធសាស្ត្រនៃការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់គណនេយ្យសាធារណៈកម្ពុជា ត្រូវបានទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយរដ្ឋមន្ត្រី កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១<br>-ស្តង់ដាគណនេយ្យសម្រាប់កត់ត្រាចំណូលមិនដោះដូរ,ស្តង់ដាគណនេយ្យសម្រាប់កត់ត្រាសន្និធិនិងស្តង់ដាគណនេយ្យសម្រាប់កត់ត្រាពីការលាតត្រដាងព័ត៌មានរបស់ភាគីពាក់ព័ន្ធត្រូវបានអនុម័ត។ | | ៩០% នៃសកម្មភាពសរុប សម្រេចបាន ធៀបនឹងផែនការប្រចាំឆ្នាំ | -ន.គ.ស. បានពិនិត្យ និងផ្តល់យោបល់រួចរាល់លើសេចក្តីព្រាងរបាយការណ៍ហិរញ្ញ-វត្ថុឆ្នាំ ២០២១ ដែលផលិតដោយ អគ្គនាយកដ្ឋានរតនាគារជាតិអនុលោម តាម IPSAS Cash Basis។<br>-យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណ នេយ្យសាធារណៈមូលដ្ឋានបង្គរនៅ កម្ពុជា ២០២១-២០៣១ ទទួលបានការ ឯកភាពជាគោលការណ៍ ដោយប្រមុខ រាជរដ្ឋាភិបាល នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ និងបានរៀបចំពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ កាលពីថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ២០២២។<br>- សេចក្តីព្រាងទម្រង់និងមាតិកា ដែល បានកែសម្រួលនៃ របាយការណ៍ហិរញ្ញវត្ថុអនុលោមតាមមូលដ្ឋានគណនេយ្យសាច់ប្រាក់កែសម្រួល កំពុងត្រូវបានរៀបចំដោយ អ្នកជំនាញការក្នុងស្រុក។<br>- សេចក្តីព្រាងស្តង់ដាគណនេយ្យ សាធារណៈកម្ពុជា ស្តីពី "ចំណូលពីប្រតិបត្តិការដោះដូរ" និង "ចំណូលពី ប្រតិបត្តិការ មិនដោះដូរ កំពុង" ត្រូវបានដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយភាគីពាក់ព័ន្ធ ដើម្បីជំនួសឱ្យសេចក្តីព្រាង ស្តង់ដាលេខ ៧០ (Exposure Draft 70 Revenue with Performance Obligations) និង សេចក្តីព្រាងស្តង់ដា លេខ ៧១ (Exposure Draft 71 Revenue without Performance Obligations) ដែលកំពុងត្រូវបានរៀបចំ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | និងទទួលមតិយោបល់ ក្នុងក្របខ័ណ្ឌ អន្តរជាតិ។<br>-ច្បាប់និងបទប្បញ្ញត្តិចាំបាច់ កំពុងត្រូវបានពិនិត្យ និងកំណត់ដោយអ្នកជំនាញការ ក្នុងស្រុក និងអ្នកជំនាញការ IMF ដើម្បីអនុវត្តគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល និងស្តង់ដា IPSAS។<br>-ប្រកាសដែលតម្រូវឱ្យមានការលាតត្រដាងកំណត់សម្គាល់ និងការទទួលស្គាល់ គណនីត្រូវទទួល នៃប្រតិបត្តិការអនុវត្ត កាតព្វកិច្ចនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ កំពុង ត្រូវបានដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ។ | |
| ២២.២. រៀបចំរបាយការណ៍ហិរញ្ញវត្ថុចេញពីប្រព័ន្ធ FMIS ទាន់ពេលវេលាស្របតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា | **<u>សច ១៣.</u>**<br>មានរបាយការណ៍ហិរញ្ញវត្ថុដែលផលិត ចេញពីប្រព័ន្ធ FMIS ស្របតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជាតាមក្របខ័ណ្ឌពេលវេលាកំណត់ដែលបានកំណត់ | - របាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈ<br>- កម្ពុជាមូលដ្ឋានសាច់ប្រាក់ត្រូវបានរៀបចំលើមូលដ្ឋាន ចេញពីប្រព័ន្ធ FMIS<br>- តារាងឧបសម្ព័ន្ធចំណូលចំណាយសម្រាប់រៀបចំច្បាប់ទូទាត់ប្រចាំឆ្នាំ ២០២០ អាចផលិតសាកល្បងចេញពី FMIS ទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិកាសំខាន់ៗ<br>- សេចក្តីព្រាងបឋមច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋប្រចាំឆ្នាំត្រូវបានរៀបចំ និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិអំឡុងពេលធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំក្នុងរយៈពេល ៦ ខែ បន្ទាប់ពីបញ្ចប់ការបិទបញ្ជីចំណូល ចំណាយថវិកា ប្រចាំឆ្នាំ | -របាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដារ IPSAS Cash basis ឆ្នាំ២០១៩ និងឆ្នាំ២០២០ បានរៀបចំរួចរាល់ ដោយផ្អែកលើមូលដ្ឋាន ពីប្រព័ន្ធ FMIS។<br>-សេចក្តីព្រាងបឋមច្បាប់ទូទាត់ថវិកាទូទៅ របស់រដ្ឋប្រចាំឆ្នាំត្រូវបានរៀបចំនិងផ្ញើជូន អាជ្ញាធរសវនកម្មជាតិអំឡុងពេលធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ គឺស្ថិតក្នុង រយៈពេល ៦ ខែ បន្ទាប់ពីបញ្ចប់ ការបិទបញ្ជីចំណូលចំណាយថវិកា | | -របាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈ កម្ពុជាមូលដ្ឋានសាច់ប្រាក់ត្រូវបានរៀបចំលើមូលដ្ឋាន ចេញពីប្រព័ន្ធ FMIS<br>-តារាងឧបសម្ព័ន្ធចំណូល ចំណាយសម្រាប់រៀបចំច្បាប់ទូទាត់ប្រចាំឆ្នាំ ២០២១ អាចផលិតសាកល្បងចេញពី FMIS ទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិកាសំខាន់ៗ<br>-សេចក្តីព្រាងបឋមច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋប្រចាំឆ្នាំត្រូវបានរៀបចំ និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ អំឡុងពេលធ្វើសវនកម្ម បញ្ជាក់លើសេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំក្នុងរយៈពេល ៦ ខែ បន្ទាប់ពីបញ្ចប់ឆ្នាំការបិទបញ្ជីចំណូលចំណាយថវិកា ប្រចាំ | -របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២០ មូលដ្ឋានសាច់ប្រាក់ត្រូវបានរៀបចំរួចរាល់លើមូលដ្ឋានចេញពីប្រព័ន្ធ FMIS<br>-បានធ្វើតេស្តសាកល្បងលើតារាង Table A5 កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំសង្កាត់ គឺតួលេខចំណូលថវិកា និងចំណាយថវិកា នៅពុំទាន់ត្រឹមត្រូវលើតួលេខច្បាប់ហិរញ្ញវត្ថុ និងលេខអនុវត្ត។ ស្ថានភាពតារាងនេះ ក្រុមការងារនឹងបន្តកំណត់និងពិនិត្យលើលក្ខ័ណ្ឌចាប់ក្នុងប្រព័ន្ធFMIS ម្តងទៀត ដោយសារករណីលេខថវិកាសង្កាត់ចំណុះក្រុង និងថវិកាឃុំ នៅខុសគ្នាច្រើន។<br>-បានត្រួតពិនិត្យឡើងវិញលើតារាងទាំងអស់ ដែលរួមមាន÷Table C1, Table C2, Table C4, Annex 2,3,6,7 និង Table C5 ទើបបានពិនិត្យតម្រូវការលើ របាយ-ការណ៍, និងរៀបចំកិច្ចប្រជុំជាមួយ ITD នៅខែមិថុនាដើម្បីសំអាតការងារនៅសេសសល់ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | -បានធ្វើតេស្តសាកល្បងលើតារាងTable C2, C4, C5 និងA5 ដែលត្រូវផលិតចេញពីប្រព័ន្ធFMIS ទាំងស្រុងសម្រាប់ភ្ជាប់តាមច្បាប់ទូទាត់ប្រចាំឆ្នាំ។<br>-បានផ្ទៀងផ្ទាត់តួលេខត្រឹមត្រូវជាមួយរបាយការណ៍ សម្រេចទូទាត់របស់ក្រសួង-ស្ថាប័នមួយចំនួន ផ្នែកចំណូលថវិកា និងផ្នែកចំណាយ។<br>-សេចក្តីព្រាងបឋមច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋប្រចាំឆ្នាំត្រូវបានរៀបចំនិងផ្ញើជូនអាជ្ញាធរសវនកម្មជាតិអំឡុងពេលធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ គឺស្ថិតក្នុង រយៈពេល ៦ ខែបន្ទាប់ពីបញ្ចប់ ការបិទបញ្ជីចំណូលចំណាយថវិកា | |
| ២២.៣. រៀបចំរបាយការណ៍អនុវត្តថវិកាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំតាម FMIS | <u>សច ១៤.</u><br>ក្រសួង ស្ថាប័ន មានរបាយការណ៍អនុវត្តថវិកា | របាយការណ៍អនុវត្តថវិកាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ផលិតចេញពីប្រព័ន្ធ FMIS សម្រាប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | - មានរបាយការណ៍តាមដានវឌ្ឍនភាពប្រចាំឆ្នាំ<br>- សម្រេចបាន ១០០ %ការឧបត្ថម្ភធនថវិកាត្រី-មាសទី ៤, ការបង្វែរឥណទាន និងការបន្ថែមឥណទានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកត់ត្រានៅក្នុងប្រព័ន្ធ FMIS<br>- សម្រេចបាន ១០ ០របាយការណ៍អនុវត្តថវិកា% ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផលិតចេញពី FMIS ។ | | របាយការណ៍អនុវត្តថវិកាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ផលិតចេញពីប្រព័ន្ធ FMIS សម្រាប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍អនុវត្តថវិកាប្រចាំត្រីមាស ឆមាស និងឆ្នាំ របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផលិតចេញពី FMIS។ (អ.ហ.ក) | |
| ២៣. ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (ទ្រព្យ-សកម្មរយៈពេលវែង) | <u>សគ ៧.</u><br>មានរបាយការណ៍ប្រមូលផ្តុំសរុបទ្រព្យសម្បត្តិរដ្ឋ (Consolidation report) របស់ក្រសួង ស្ថាប័ន, មន្ទីរអង្គភាពជំនាញថ្នាក់មូលដ្ឋាននិងរដ្ឋបាលថ្នាក់ក្រោមជាតិ | មានរបាយការណ៍ប្រមូលផ្តុំសរុបទ្រព្យសម្បត្តិរដ្ឋ (Consolidation report) កម្រិតក្រសួង ស្ថាប័ន, មន្ទីរអង្គភាពជំនាញថ្នាក់មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ការរៀបចំតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ (២០២០) ដោយទទួលបាន៨៩% នៃអង្គភាពប្រើប្រាស់សរុប៣០៣៦ អង្គភាព (គិតត្រឹម ២០ មករា ២០២១)។ | | មានរបាយការណ៍ប្រមូលផ្តុំសរុបទ្រព្យសម្បត្តិរដ្ឋ (Consolidation report) កម្រិតក្រសួង ស្ថាប័ន, មន្ទីរអង្គភាពជំនាញថ្នាក់មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | តារាងកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ ២០២១÷ (វឌ្ឍនភាពគិតត្រឹម ៣០.១០.២២)<br>-ចំនួនសរុប ៣ ០៥១ អង្គភាពត្រូវផ្ញើ<br>-ក្នុងនោះចំនួន ១ ៩១៥ អង្គភាព = ៦៣% បានផ្ញើមក.កសហវ.<br>-ចំណែកឯចំនួន ១ ១៣៦ អង្គភាព = ៣៧% នៅអង្គភាពសាមីនៅឡើយ។ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៣.១. រៀបចំ និងដាក់ឱ្យអនុវត្តយន្តការ និងបទដ្ឋានគតិយុត្តគ្រប់គ្រងទ្រព្យរដ្ឋសម្បត្តិរដ្ឋ | **<u>សច ១៥.</u>**<br>លិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រងគ្រង និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ | ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីវិធាន និងនីតិវិធីនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ | ប្រកាសលេខ១១៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីវិធាន និងនីតិវធីនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានដាក់ឱ្យអនុវត្ត ។ | | ប្រកាសស្តីពីវិធាន និងនីតិវិធីធ្វើនីត្យានុកូលកម្មឡើងវិញនៃកិច្ចសន្យាឬកិច្ចព្រមព្រៀងដែលមិនមានការឯកភាពពីកសហវ | បានរៀបចំពិនិត្យកែសម្រួលសេចក្តីព្រាងតាមអនុសាសន៍របស់ក្រុមប្រឹក្សានីតិកម្មរួច-រាល់។ បន្ទាប់មក បានរៀបចំរបាយការណ៍ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ដើម្បីពិនិត្យផ្តល់ការណែនាំ ព្រមទាំងស្នើសុំប្រជុំពិគ្រោះយោបល់ជាមួយអន្តរក្រសួង១លើក មុនស្នើសុំចុះហត្ថលេខា និងដាក់ឱ្យអនុវត្ត។ | |
| | **<u>សច ១៦.</u>**<br>ភាគរយនៃការរៀបចំប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ | - ចំនួនប័ណ្ណកម្មសិទ្ធិមិនទាន់បានចុះបញ្ជី (ដីធ្លី) សរុប ត្រូវបាន រៀបចំដោយក្រុមការងារអន្តរក្រសួង<br>- ផែនការសកម្មភាពត្រូវបានរៀបចំ | -ហើយទីតាំងដែលពុំទាន់បានធ្វើប័ណ្ណកម្មសិទ្ធិមានចំនួន ១០ ៧៩៦កន្លែង ស្មើនឹង៣៨% នៃទីតាំងសរុបនឹងត្រូវបន្តជំរុញធ្វើប័ណ្ណកម្មសិទ្ធិឱ្យអស់ក្នុងឆ្នាំ ២០២៣ ។<br>-បានចេញប្រកាសអន្តរក្រសួងលេខ៩៧១ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបំពេញបន្ថែមសមាសភាព គណៈកម្មការអន្តរក្រសួង និងធ្វើស្ថិតិបច្ចុប្បន្នភាពទីតាំងដីរដ្ឋដែលបានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន នៅថ្នាក់កណ្តាល ដើម្បីរៀបចំធ្វើប័ណ្ណកម្មសិទ្ធិ។ | | ២៥% នៃប័ណ្ណកម្មសិទ្ធិមិនទាន់បានចុះបញ្ជី (ដីធ្លី) សរុប ត្រូវបានចុះបញ្ជីដោយក្រុមការងារអន្តរក្រសួង | ផែនការសកម្មភាព នៃយន្តការអន្តរក្រសួងត្រូវបានរៀបចំ និងកំពុងបានចុះទៅខេត្តគោលដៅទាំង ២៥ រាជធានី ខេត្ត ដែលគ្រោងបញ្ចប់នៅខែ ធ្នូ ឆ្នាំ ២០២២ ពិនិត្យស្ថានភាព<br>ដីរដ្ឋ ដើម្បីប្រមូលផ្តុំទិន្នន័យ ៣ ប្រភេទ÷<br>(១) ដីទំនាស់<br>(២) ដីកំពុង នៅក្នុងនីតិវិធី<br>(៣) ដី ដែលពុំទាន់ចាប់ផ្តើមនីតិវិធី។<br>***<u>សរុបមក:</u>***<br>-ក្រុមការងារអន្តរក្រសួង បានប្រជុំពិនិត្យវឌ្ឍនភាពការងាររៀងរាល់ត្រីមាស ដោយមានផែនការសកម្មភាពរួម សម្រាប់ជំរុញការងារការចុះបញ្ជីដីធ្លីរបស់រដ្ឋ។<br>-ក្រុមការងារអន្តរក្រសួង បានចុះផ្សព្វផ្សាយណែនាំ និងជំរុញការធ្វើណ្ណកម្មសិទ្ធិលើដីរដ្ឋចាប់ពីខែ តុលា ឆ្នាំ ២០២២ តទៅ ដោយមានរៀបចំ ជារបាយការណ៍លទ្ធផល ជូនគណៈកម្មាធិការអន្តរក្រសួងជ្រាប ដើម្បីផ្តល់អនុសាសន៍ណែនាំបន្ថែម។<br>-បានបន្ថែមសមាសភាព ឯកឧត្តម យ៉ែត វីណែល ជាអនុប្រធានក្រុមការងារនេះ។ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **<u>សច ១៧.</u>**<br>រៀបចំឯកសារគោល (Blueprint) ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (Nonfinancial Asset) | សេចក្តីព្រាងឯកសារគោល (Blueprint) ត្រូវបានដាក់ឆ្លងកម្រិតអនុរអគ្គនាយកដ្ឋាន កសហវ | -ឯកឧត្តមបណ្ឌិតរដ្ឋលេខាធិការកសហវ. ទទួលបន្ទុក និងក្រុមការងារបច្ចេកទេសនៃ.អទច. បានប្រជុំពិភាក្សា និងសិក្សាស្វែងរកឯកសារពាក់ព័ន្ធក្នុងការរៀបចំឯកសារគោលនេះ ។ ជាលទ្ធផលបឋមបានរៀបចំមាតិកានៃឯកសារគោលនេះនៅកម្រិតក្រុមការងារបច្ចេកទេស ហើយសេចក្តីព្រាងមាតិកានេះនឹងដាក់ឆ្លងប្រជុំជាមួយក្រុមអនុរអគ្គ-នាយកដ្ឋាន.កសហវ. នាខែកុម្ភៈ ឆ្នាំ២០២២។ | | ឯកសារគោល (Blueprint) ត្រូវបានទទួលការឯកភាព និងដាក់ឱ្យអនុវត្ត | បានរៀបចំមាតិកានៃឯកសារគោលនេះព្រមទាំងបញ្ចូលខ្លឹមសារជំពូកមួយចំនួន។ បានស្នើសុំ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ពន្យារពេល១ឆ្នាំ ដោយគ្រោងនឹងបញ្ចប់ការងារនេះយ៉ាងយូរត្រឹមឆ្នាំ២០២៣។ បន្ថែមពីលើនេះទៀត ក្រុមការងារកំពុងសិក្សាដកស្រង់បទពិសោធន៍ល្អពីប្រទេស Norway។ ក្រុមការងារក៏បានរៀបចំជាផែនការសកម្មភាពការងារ ដើម្បីជំរុញកិច្ចការងារឱ្យសម្រេចបានក្នុងឆ្នាំ២០២៣។ | |
| | **<u>សច ១៨.</u>**<br>កម្រិតទំហំទ្រព្យសកម្មរយៈពេលវែង (Fixed Asset Threshold) ត្រូវបានកំណត់/ចាត់ថ្នាក់ | ប្រកាសស្តីពីការដាក់ឱ្យអនុវត្ត fixed assets threshold ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | បានប្រមូលសរុបធាតុចូលតាមកិច្ចប្រជុំច្រើនលើក ច្រើនសារ ជាមួយអគ្គនាយកដ្ឋានគន្លឹះពាក់ព័ន្ធ និងបានរៀបចំវគ្គសិក្ខាសាលាពិគ្រោះយោបល់ប្រមូលធាតុចូលពីគ្រប់ក្រសួង-ស្ថាប័ន អង្គភាព រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំង គ្រឹះស្ថានរដ្ឋបាលសាធារណៈ ក្នុងការរៀបចំសេចក្តីព្រាងប្រកាស និងបានបូកសរុបរបាយការណ៍ពីបញ្ហាប្រឈមដល់ថ្នាក់ដឹកនាំ កសហវ.ពិនិត្យ និងសម្រេច។ | | ប្រកាសស្តីពីការដាក់ឱ្យអនុវត្ត fixed assets threshold ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពី កិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែងត្រូវបានរៀបចំ និង ដាក់ជូនថ្នាក់នាំពិនិត្យ និងចុះហត្ថលេខា រួចរាល់លើប្រកាសលេខ៣៥៤ សហវ-ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២។ (អ.រតន) | |
| ២៣.២. កែលម្អ និងដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS) | **<u>សច ១៩.</u>**<br>ចំនួនក្រសួង ស្ថាប័នដាក់ឱ្យអនុវត្ត SARMIS | ប្រព័ន្ធ SARMIS ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត | អ.ទ.ច.បាន និងកំពុងធ្វើការបណ្តុះបណ្តាលរយៈពេលវែងបន្ថែម ដល់អង្គភាពប្រើប្រាស់គ្រប់ក្រសួងស្ថាប័ន, នីតិបុគ្គលសាធារណៈ សហគ្រាសសាធារណៈ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជ-ធានីខេត្ត រួចរាល់តាមរយៈ Zoom ដើម្បីយល់កាន់តែច្បាស់មានចំណេះដឹង និងការប្រើប្រាស់ប្រព័ន្ធ SARMIS ក្នុងការពង្រឹងប្រសិទ្ធ-ភាពការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។ ហើយផែនការបន្តនឹងបណ្តុះបណ្តាល ដល់រដ្ឋបាលរាជធានី-ខេត្ត និងរដ្ឋបាលក្រុង-ស្រុក-ខណ្ឌ ទាំងអស់ចាប់ពីថ្ងៃទី 10 ខែមករា រហូតដល់ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២។ | | ប្រព័ន្ធ SARMIS ត្រូវបានដាក់ឱ្យអនុវត្ត គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (កម្រិតស្រុក) | បានប្រកាសដាក់ឱ្យប្រើប្រាស់នៅដំណាក់កាលទី១ តាមរយៈសារាចរណែនាំលេខ ០១២ សហវ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ បច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។<br>**<u>-នាថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២</u>** បានបណ្តុះបណ្តាលបន្ថែមជូនដល់ក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងនីតិបុគ្គលសាធារណៈ។<br>**<u>-នាថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២</u>** បានបណ្តុះបណ្តាលបន្ថែមជូនដល់រដ្ឋបាលរាជធានីខេត្ត | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | រដ្ឋបាលក្រុងស្រុកខណ្ឌ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានីខេត្ត។<br>-មន្ទីរ. សហវ. មានសមត្ថភាពអាចបណ្តុះបណ្តាលបន្តហើយ. អទច. នៅតែបន្តការគាំទ្រជាមួយ. EFI និងក្រសួង ស្ថាប័ន អង្គភាពដែល សំណូមពរ មានវគ្គបណ្តុះបណ្តាល។ | |
| ២៤. ពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ រួមទាំងហានិភ័យនៃកាតព្វកិច្ចបំណុលយថាហេតុ និងហានិភ័យបំណុលពាក់ព័ន្ធប្រកបដោយចីរភាព | <u>សគ ៨.</u><br>សូចនាករបំណុលគន្លឹះទាំង ៥ ធៀបទៅនឹងពិតាន | សូចនាករបំណុលគន្លឹះទាំង ៥ បានត្រូវបន្តរក្សាក្រោមពិតានដែលបានកំណត់នៅក្នុងយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងបំណុលសាធារណៈ | សូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានបន្តរក្សាក្រោមពិតានដែលបានកំណត់នៅក្នុងយុទ្ធ-សាស្រ្តស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ក្នុងនោះ÷<br>– អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុបធៀបនឹង ផសស ស្ថិតក្នុងរង្វង់ ២៤,៤% ធៀបនឹងពិតាន ៥៥%<br>– អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈ ក្រៅប្រទេ ស ធៀបនឹង ផសស ស្ថិតក្នុងរង្វង់ ២៤,៤% ធៀបនឹងពិតាន ៤០%<br>– អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈ ក្រៅប្រទេស ធៀបនឹងការនាំចេញ ស្ថិតក្នុងរង្វង់ ៣២,៨២% ធៀបនឹងពិតាន ១៨០%<br>– អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេសធៀបនឹងការនាំចេញ ស្ថិតក្នុងរង្វង់ ១,៨៣% ធៀបនឹងពិតាន ១៥%<br>– អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេសធៀបនឹងចំណូលថវិកាជាតិ ស្ថិតក្នុងរង្វង់ ៦,៣៣% ធៀបនឹងពិតាន ១៨%។ | | សូចនាករបំណុលគន្លឹះទាំង ៥ បានត្រូវបន្តរក្សាក្រោមពិតានដែលបានកំណត់នៅក្នុងយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងបំណុលសាធារណៈ | សូចនាករបំណុល គន្លឹះទាំង ៥ ត្រូវបានបន្តរក្សាក្រោម ពិតានដែលបានកំណត់នៅ ក្នុងយុទ្ធសាស្រ្តស្តីពីការគ្រប់ គ្រងបំណុលសាធារណៈ ក្នុងនោះ ÷<br>-អនុបាតតម្លៃបច្ចុប្បន្ននៃ បំណុលសាធារណៈសរុបធៀបនឹង ផសស ស្ថិតក្នុងរង្វង់ ២៥,២% ធៀបនឹងពិតាន ៥៥%<br>-អនុបាតតម្លៃបច្ចុប្បន្ន នៃ បំណុលសាធារណៈ ក្រៅ ប្រទេសធៀបនឹង ផសស ស្ថិតក្នុងរង្វង់ ២៤,៩% ធៀបនឹងពិតាន ៤០%<br>-អនុបាតតម្លៃបច្ចុប្បន្ន នៃ បំណុលសាធារណៈ ក្រៅ ប្រទេសធៀបនឹងការនាំចេញ ស្ថិតក្នុង រង្វង់ ៣៣,៩% ធៀបនឹងពិតាន ១៨០%<br>-អនុបាតសេវាបំណុល សាធារណៈក្រៅប្រទេសធៀបនឹងការនាំ ចេញស្ថិតក្នុងរង្វង់ ២,១% ធៀបនឹង ពិតាន ១៥%<br>-អនុបាតសេវាបំណុល សាធារណៈក្រៅប្រទេស ធៀបនឹងចំណូលថវិកាជាតិ ស្ថិតក្នុងរង្វង់ ៧,៨% ធៀបនឹងពិតាន ១៨%។ | |
| | <u>សគ ៩.</u><br>ហានិភ័យបំណុលត្រូវបានកំណត់ | ការវិភាគហានិភ័យបំណុលពាក់ព័ន្ធ និងហានិភ័យកាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវបានរៀបចំ ដាក់បញ្ចូលនៅក្នុងរបាយការណ៍ដាក់ជូន | ការវិភាគហានិភ័យបំណុលពាក់ព័ន្ធ និងហានិ-ភ័យកាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវបានរៀបចំ ដាក់បញ្ចូលនៅក្នុងរបាយការណ៍ដាក់ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ។ | | ការវិភាគហានិភ័យបំណុលពាក់ព័ន្ធ និងហានិភ័យកាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវបានរៀបចំ ដាក់បញ្ចូលនៅក្នុងរបាយការណ៍ដាក់ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ | បានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្រ្ត ស្តីពីការគ្រប់គ្រងបំណុល សាធារណៈ ដោយបញ្ចូលនូវការវិភាគហានិភ័យបំណុលពាក់ព័ន្ធ និងហានិភ័យកាតព្វកិច្ច | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | **គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ** | | | | **បំណុលជាយថាហេតុ ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ** | |
| ២៤.១. គ្រប់គ្រងបំណុលសាធារណៈ | ***<u>សច ២០.</u>***<br>ភាពទាន់ពេលវេលានៃការរៀបចំរបាយការណ៍គ្រប់គ្រងបំណុលដោយរួមបញ្ចូលសូចនាករបំណុលគន្លឹះទាំង ៥ ដែលបានកំណត់នៅក្នុងយុទ្ធ-សាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ | របាយការណ៍វឌ្ឍនភាពប្រចាំត្រី-មាសនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣ ដោយរួមបញ្ចូលនូវសូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានរៀបចំនិងដាក់ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈនៅក្នុងខែទី ១ បន្ទាប់ដំណាច់ត្រីមាសនីមួយៗ | បានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រប្រចាំត្រីមាសទី១, ទី២, និងទី៣ ឆ្នាំ ២០២១ ព្រមទាំងផ្សព្វផ្សាយលើគេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋាន ។ | | របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីកាគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣ ដោយរួមបញ្ចូលនូវសូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានរៀបចំនិងដាក់ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ នៅក្នុងខែទី១ បន្ទាប់ដំណាច់ត្រីមាសនីមួយៗ | បានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលប្រចាំត្រីមាសទី៤ និងប្រចាំឆ្នាំ២០២១,ត្រីមាសទី១, ទី២, និងទី៣ ឆ្នាំ២០២២ ព្រមទាំងផ្សព្វផ្សាយលើគេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋាន។ | |
| | ***<u>សច ២១.</u>***<br>ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ | ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍន៍មូលបត្ររដ្ឋ ត្រូវបានអនុម័ត | ក្របខ័ណ្ឌគោលនយោបាយបឋម ស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ត្រូវបានអនុម័តដាក់ឱ្យ អនុវត្តដ៏ខ្ពង់ខ្ពស់ ដោយសម្តេចតេជោនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ។ | | - ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍន៍មូលបត្ររដ្ឋ ២០២២-២០២៨ ត្រូវបានអនុម័ត<br>- ផែនការសកម្មភាព ត្រូវបានរៀបចំ | -សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយរួមស្តីពីការអភិវឌ្ឍន៍មូលបត្ររដ្ឋ ២០២២-២០២៨ ត្រូវការពេលវេលាបន្ថែមទៀតដោយហេតុថា÷<br>១.ត្រូវបញ្ចូលនូវចំណុចពាក់ព័ន្ធនឹងការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ (Sovereign Bonds) និងសញ្ញាប័ណ្ណតាមប្រភេទផ្សេងៗ (Thematic Bond)÷ Green Bonds, Social Bonds, Sustainability Linked Bonds ដែលទាមទារឱ្យមានការសិក្សា និងធាតុចូលបន្ថែមពីជំនាញការ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីធានាបាននូវភាពគ្រប់ជ្រុងជ្រោយ នៃក្របខ័ណ្ឌគោលនយោបាយនេះ។<br>២.កិច្ចការមូលបត្រនេះមានចរិកច្ចេកទេសខ្ពស់ និងមានភាពស្មុគស្មាញខ្លាំង។<br>-ផែនការសកម្មភាពសម្រាប់អនុវត្តក្របខ័ណ្ឌគោលនយោបាយរួមស្តីពីការ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | អភិវឌ្ឍន៍មូលបត្ររដ្ឋ ២០២២-២០២៨ ត្រូវការពេលវេលាបន្ថែមទៀត ដោយហេតុថាផែនការសកម្មភាពនេះ ជាឧបសម្ព័ន្ធនៃក្របខ័ណ្ឌគោលនយោបាយរួមស្តីពីការអភិវឌ្ឍន៍មូលបត្ររដ្ឋ ២០២២-២០២៨។ | |
| ២៤.២.ត្រួតពិនិត្យតាមដានហានិភ័យបំណុលសាធារណៈ | **<u>សច ២២.</u>** របាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារ-ណៈ មានខ្លឹមសារហានិភ័យបំណុលសាធារណៈ | របាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មានខ្លឹមសារហានិភ័យបំណុលសាធារណៈ ដោយបង្ហាញហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities), ហានិភ័យថវិកា (Fiscal Risk), ហានិភ័យទីផ្សារ (Market Risk), ហានិភ័យប្រតិបត្តិការ (Operational Risk), ហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (Liquidity Risk), ហានិភ័យហិរញ្ញប្បទាននៃគម្រោង (Project Funding Risk) និងហានិភ័យឥណទាន (Credit Risk) | បានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រ របាយការណ៍ជូន គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មានខ្លឹមសារហានិភ័យបំណុលសាធារណៈ ដោយបង្ហាញហានិភ័យនៃកាតព្វកិច្ចបំណុល ជាយថាហេតុ (Contingent Liabilities), ហានិភ័យថវិកា (Fiscal Risk), ហានិភ័យទីផ្សារ (Market Risk), ហានិភ័យប្រតិបត្តិការ (Operational Risk), ហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (Liquidity Risk), ហានិភ័យហិរញ្ញ- ប្បទាននៃគម្រោង (Project Funding Risk) និងហានិភ័យឥណទាន (Credit Risk) ប្រចាំត្រីមាសទី១, ទី២, និងទី៣ ឆ្នាំ២០២១ ព្រមទាំងផ្សព្វផ្សាយលើគេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋាន | | របាយការណ៍ជូនគណៈ កម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មានខ្លឹមសារហានិភ័យបំណុលសាធារណៈ ដោយបង្ហាញហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities), ហានិភ័យថវិកា (Fiscal Risk), ហានិភ័យទីផ្សារ (Market Risk), ហានិភ័យប្រតិបត្តិការ (Operational Risk), ហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (Liquidity Risk), ហានិភ័យហិរញ្ញប្បទាននៃគម្រោង (Project Funding Risk) និងហានិភ័យឥណទាន (Credit Risk) | បានរៀបចំរបាយការណ៍វឌ្ឍនភាពជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មានខ្លឹមសារហានិភ័យបំណុល សាធារណៈពាក់ព័ន្ធ និងហានិភ័យកាតព្វកិច្ចបំណុលជាយថាហេតុ ប្រចាំត្រីមាសទី៤ និងប្រចាំឆ្នាំ ២០២១, ត្រីមាសទី១, ទី២, និងទី៣ ឆ្នាំ ២០២២ ព្រមទាំងផ្សព្វផ្សាយលើគេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋាន | |
| ២៤.៣. ពង្រឹងប្រព័ន្ធគាំទ្រប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ | **<u>សច ២៣.</u>** ចំនួនមុខងារប្រព័ន្ធគាំទ្រប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានធ្វើទំនើបកម្ម និង ពង្រីកបន្ថែម | ប្រព័ន្ធគាំទ្រប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបាន ÷<br>- ពង្រីកបន្ថែមមុខងារចំនួន ១ គឺ÷ (១)វិភាគ ធាតុអំណោយ<br>- ធ្វើទំនើបកម្មមុខងារចំនួន៣ ពី Excel Base ទៅ Web Base គឺ÷ (១)ទូទាត់សេវាបំណុល, (២( ប្រមូលសេវាបំណុល និង (៣) គ្រប់គ្រងឯកសារ | ទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យរួម ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ប្រកាសលេខ ៨៨៨ សហវ.ប្រក ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២១ ។ | | ប្រព័ន្ធគាំទ្រប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានពង្រីកបន្ថែមមុខងារចំនួន ២ គឺ ÷ (១) ព្យាករណ៍បំណុលសាធារណៈ និង (២) ការវិភាគចង្កោមបំណុល | ឧបករណ៍វិភាគចង្កោមបំណុលសាធារណៈ និងឧបករណ៍ព្យាករបំណុលសាធារណៈ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៥. ពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ | <u>សគ ១០.</u><br>មានយន្តការច្បាស់លាស់ក្នុងការតាមដានគ្រឹះស្ថានសាធារណៈរដ្ឋបាល កម្រិត កសហវ. | - លក្ខណវិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល<br>- របាយការណ៍សិក្សាអំពីវិធីសាស្ត្រវាយតម្លៃគ្រឹះស្ថានសាធារណៈកម្រិត កសហវ. | បានរៀបចំរបាយការណ៍សិក្សាលើការកំណត់លក្ខណៈវិនិច្ឆ័យអប្បរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈ ។ | | -គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានអនុវត្តតាមលក្ខណវិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>-គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ២ ត្រូវបានសាកល្បងវាយតម្លៃ | - លក្ខណវិនិច្ឆ័យអប្បបរមាសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបានរៀបចំរួចរាល់ និងទទួលបានគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០២២។<br>- គ្រឹះស្ថានសាធារណៈរដ្ឋបាលពុំទាន់បានអនុវត្តសាកល្បងនូវលក្ខណវិនិច្ឆ័យអប្បបរមានៅឡើយ។ | |
| | <u>សគ. ១១</u><br>មានយន្តការច្បាស់លាស់ក្នុងការតាមដានសហគ្រាសសាធារណៈកម្រិត កសហវ. | សេចក្ដីព្រាងច្បាប់ស្ដីពីសហគ្រាសសាធារណៈ ត្រូវបានរៀបចំដាក់ឆ្លងថ្នាក់ដឹកនាំ កសហវ. | -មានការផ្លាស់ប្តូរសមាសភាពថ្នាក់ដឹកនាំ និងសមាជិកនៃក្រុមការងារកំណែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ (សេចក្ដីសម្រេច ថ្មី លេខ ០០៨ សហវ នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១)។<br>-សេចក្តីព្រាងច្បាប់នេះ គឺបានតាក់តែងជាទម្រង់ច្បាប់ និងខ្លឹមសាររួចរាល់កម្រិតក្រុមការងារបច្ចេកទេស កសហវ.។ ហើយក្រុមការងាររង់ចាំទទួលធាតុចូលពី ទីប្រឹក្សាបច្ចេកទេស Agence Franaise de D"veloppement (AFD) នាត្រីមាសទី១ ឆ្នាំ២០២២ បន្ទាប់មកទៀត.អទច. គ្រោងនឹងធ្វើសិក្ខាសាលាពិគ្រោះយោបល់នាត្រីមាសទី២ ឆ្នាំ២០២២ជាមួយសហគ្រាសសាធារណៈ, ក្រសួងស្ថាប័ន និងអ្នកពាក់ព័ន្ធ ។ ដំណាក់កាលបន្តគឺគ្រោងនឹងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី នាត្រីមាសទី៣ ឆ្នាំ២០២២។<br>-ស្របពេលនេះផងដែរ គឺក្រុមការងារកសហវ.កំពុងរៀបចំឯកសារយុទ្ធសាស្ត្រកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈសម្រាប់ជាផែនទីបង្ហាញផ្លូវច្បាស់លាស់ ក្នុងទិសដៅកែទម្រង់សហគ្រាសសាធារណៈ។ បន្ទាប់ពីបញ្ចប់ឯកសារយុទ្ធសាស្ត្រនេះវាក៏ជាធាតុចូលដ៏សំខាន់ជាខ្លឹមសារគោល សម្រាប់ដាក់បញ្ចូលទៅឯកសារព្រាងច្បាប់នេះសំដៅឱ្យកាន់តែប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ។ | | សេចក្ដីព្រាងច្បាប់ស្ដីពីសហគ្រាសសាធារណៈ ត្រូវបានដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី និង អង្គនីតិបញ្ញាត្តិ | ការធ្វើវិសោធនកម្ម ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ (ឈ្មោះថ្មីសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ) ត្រូវបានពន្យារពេលពីឆ្នាំ២០២២ ទៅឆ្នាំ២០២៣វិញ សម្រាប់ដាក់ឆ្លងទៅទីស្តីការគណៈរដ្ឋ មន្ត្រី និងដាក់ទៅស្ថាប័ននីតិបញ្ញត្តិ ត្រីមាសទី៤ ឆ្នាំ២០២៣ដដែល។ ការពន្យារពេលនេះ ដោយសារត្រូវ រង់ចាំការចូលជាធរមាននៃយុទ្ធសាស្ត្រ ស្តីពីការកែទម្រង់ ការគ្រប់គ្រងសហគ្រាសសាធារណៈ<br>-បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តី ព្រាងយុទ្ធសាស្រ្តស្តីពីកំណែទម្រង់ ការគ្រប់គ្រង សហគ្រាសសាធារណៈ ដោយមានការចូលរួមពី បណ្តាសហគ្រាសសាធារណៈ, ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស ,ក្រុមការងារកែទម្រង់ការគ្រប់គ្រង សហគ្រាសសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ មួយ ចំនួនទៀត<br>-រៀបចំរបាយការណ៍ បូកសរុបស្តីពីលទ្ធផលនៃសិក្ខា សាលាពិគ្រោះយោបល់លើសេចក្តីព្រាងយុទ្ធសាស្រ្ត ស្តីពីកំណែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ។ | |
| ២៥.១. រៀបចំ និងអនុវត្តលក្ខណវិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារ | <u>សច ២៤.</u><br>ចំនួនគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលអនុវត្តតាមលក្ខណ | - លក្ខណវិនិច្ឆ័យអប្បបរមាសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានរៀបចំ | បានរៀបចំរបាយការណ៍ និងស្នើសុំគោលការណ៍កំណត់អំពីលក្ខណវិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលបានធ្វើរួចហើយ ។ | | គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានអនុវត្តតាមលក្ខណវិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | លក្ខណវិនិច្ឆ័យអប្បបរមាសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបានរៀបចំរួចរាល់ និងទទួលបានគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ណៈសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល | វិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | - ការវាយតម្លៃបឋមលើការអនុវត្តត្រូវបានរៀបចំ | | | | ឧបនាយករដ្ឋមន្ត្រី នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០២២។ | |
| ២៥.២. អនុវត្តកិច្ចបញ្ជិកាគណនេយ្យថ្មី រៀបចំរបាយការណ៍ អនុវត្តថវិកា, របាយការណ៍ហិរញ្ញវត្ថុ និងវាយតម្លៃសមិទ្ធកម្ម នៃការអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ | <u>**សច ២៥.**</u><br>ចំនួនគ្រឹះស្ថានសាធារណៈរដ្ឋបាល ផ្តល់របាយការណ៍ហិរញ្ញវត្ថុស្របតាមបទដ្ឋានគតិយុត្តដែលមានជាធរមាន និងទាន់ពេលវេលា | គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុស្របតាមបទដ្ឋានគតិយុត្តដែលមានជាធរមាន | គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន២៧ ក្នុង ចំណោមគ្រឹះស្ថានទាំង២៩ បានផ្ញើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២០មកអគ្គនាយកដ្ឋានរតនាគារជាតិដើម្បីធ្វើការបូកសរុប។ហើយមានតែរបាយការណ៍របស់គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន២៣ប៉ុណ្ណោះដែលអាចយកមកបូកសរុបចូលគ្នាបានដោយឡែកគ្រឹះស្ថានចំនួន៤ទៀតមិនអាចយកជាការណ៍បានទេដោយសារតួលេខពុំមានសង្គតិភាពគ្នា និងពុំទាន់គ្រប់ជ្រុងជ្រោយ ។ | | គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុស្របតាមបទដ្ឋានគតិយុត្តដែលមានជាធរមាន | នៅក្នុងឆ្នាំ២០២២ មានគ្រឹះស្ថានចំនួន២៩ ក្នុងចំណោម៣០ គ្រឹះស្ថាន បានផ្ញើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២១ មកអគ្គនាយកដ្ឋានរតនាគារជាតិហើយមានតែ របាយការណ៍របស់គ្រឹះស្ថានចំនួន២៧ ប៉ុណ្ណោះដែលរៀបចំស្របតាមគោលការណ៍ណែនាំដាក់ឱ្យអនុវត្តសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអាចធ្វើការបូកសរុបបាន។ | |
| | <u>**សច ២៦.**</u><br>យន្តការនៃការតាមដាន និងវាយតម្លៃសមិទ្ធកម្មនៃការអនុវត្តថវិការបស់សហគ្រាសសាធារណៈ | - របាយការណ៍បូកសរុបលទ្ធផលស្ថានភាពហិរញ្ញវត្ថុនៃសហគ្រាសសាធារណៈកម្រិត កសហវ<br>- សេចក្តីព្រាងច្បាប់ស្តីពីសហគ្រាសសាធារណៈ ត្រូវបានរៀបចំដាក់ឆ្លងថ្នាក់ដឹកនាំ កសហវ. | -បានរៀបចំរបាយការណ៍រួចរាល់ស្តីពីការវាយ-តម្លៃស្ថានភាពហិរញ្ញវត្ថុសហគ្រាសសាធារណៈ ដាក់ជូនថ្នាក់ដឹកនាំ.កសហវ. តាមរយៈលិខិតលេខ ៥៩៦.អទច ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ដោយបានរាយការណ៍÷<br>១. ស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលអាជីវកម្មការិយបរិច្ឆេទឆ្នាំ២០២០,<br>២. បណ្តាខ្ទង់ទូទាត់ជាមួយថវិការដ្ឋសម្រាប់ឆ្នាំ ២០២០,<br>៣. ការបង់ភាគលាភចូលថវិការដ្ឋឆ្នាំ២០២០របស់សហគ្រាសសាធារណៈ<br>៤. ស្ថានភាពមូលធននៃក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិចការិយបរិច្ឆេទឆ្នាំ២០២០។ | | -របាយការណ៍បូកសរុបលទ្ធផលស្ថានភាពហិរញ្ញវត្ថុនៃសហគ្រាស សាធារណៈកម្រិត កសហវ<br>-សេចក្តីព្រាងច្បាប់ស្តីពីសហគ្រាសសាធារណៈ ត្រូវបានដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គនីតិបញ្ញត្តិ | -បានរៀបចំរបាយការណ៍ស្តីពីលទ្ធផលបូកសរុបវាយតម្លៃលើរបាយការណ៍ហិរញ្ញវត្ថុការិយបរិច្ឆេទ២០២១របស់សហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច ដោយបានដាក់ឆ្លងថ្នាក់ដឹកនាំ កសហវ និងទទួលបានចំណារ ដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាលពី ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ លើលិខិតលេខ ៣៦៦.អទច ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២។<br>-ការធ្វើវិសោធនកម្ម ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ (ឈ្មោះថ្មីសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ) ត្រូវបានពន្យារពេលពីឆ្នាំ២០២២ទៅឆ្នាំ២០២៣វិញ សម្រាប់ដាក់ឆ្លងទៅទីស្តីការគណៈរដ្ឋ មន្ត្រី និងដាក់ទៅស្ថាប័ននីតិបញ្ញត្តិ ត្រីមាសទី៤ ឆ្នាំ២០២៣ដដែល។ | |

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ២០២១ | លទ្ធផលសម្រេចបានឆ្នាំ២០២១ | ពណ៌ | គោលដៅឆ្នាំ២០២២ | លទ្ធផលសម្រេចបានឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| **ផែនទី/ខឿននី ៣ ÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**<br>ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម, ការពង្រឹងការអនុវត្តថវិកាកម្មវិធី, ការរៀបចំក្របខណ្ឌនៃការគ្រប់គ្រងវិនិយោគសាធារណៈ និង ការបន្តជំរុញការធ្វើវិមជ្ឈការប្រព័ន្ធថវិកាពីថ្នាក់ជាតិ ទៅថ្នាក់ក្រោមជាតិ ។ | | | | | | | |
| ៣១. រៀបចំ និងដាក់ឱ្យអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម | សគ ១.<br>ការដាក់ឆ្លងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងអនុវត្តជាប្រចាំ | ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ត្រូវបានរៀបចំ និងស្នើសុំការអនុម័តពីប្រមុខរាជរដ្ឋាភិបាល | សេចក្តីព្រាង MTFF ២០២១-២០២៣ ត្រូវបានដាក់ជូនថ្នាក់ដឹកនាំ កសហវ ប៉ុន្តែដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩, ថ្នាក់ដឹកនាំ កសហវ. បានសម្រេចពន្យារពេលក្នុងការដាក់ឱ្យអនុវត្ត ហើយជាទិសដៅនឹងដាក់ឱ្យអនុវត្តនៅឆ្នាំ២០២២ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ និងគម្រោងថវិកាឆ្នាំ២០២៣ ។ | | MTFF ឆ្នាំ ២០២៣-២០២៥ ត្រូវបានដាក់ឆ្លងនៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០២២ | ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ២០២៣-២០២៥ ត្រូវបានរៀបចំនិងដាក់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេច។ អនុវត្តតាមការសម្រេចរបស់ថ្នាក់ដឹកនាំ, អ.គ.ប. នឹងរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ជំនួសក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ២០២៣-២០២៥ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ | |
| | សគ ២.<br>ការអនុម័តក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ដោយមានពិតានថវិកាតាមវិស័យតាមក្រសួងស្ថាប័នដោយប្រមុខរាជរដ្ឋាភិបាល | សេចក្តីព្រាងថវិការយៈពេលមធ្យម (MTBF) ដោយមានពិតានថវិកាតាមវិស័យ | បានរៀបចំ និងទទួលបានការអនុម័តដោយប្រមុខរាជរដ្ឋាភិបាលលើឧបសម្ព័ន្ធស្តីពីពិតានថវិកាឆ្នាំ ២០២២-២០២៤ សម្រាប់ក្រសួង-ស្ថាប័ន នៅថ្ងៃទី ០៩ ខែមេសា ឆ្នាំ ២០២១។ | | MTBF ដោយមានពិតានថវិកាតាមវិស័យ តាមក្រសួង ស្ថាប័ន ត្រូវបានអនុម័តដោយប្រមុខរាជរដ្ឋាភិបាលនៅឆ្នាំ ២០២២ និងឆ្នាំបន្តបន្ទាប់ | ក្របខ័ណ្ឌថវិការយៈពេលមធ្យមដោយមានពិតានតាម វិស័យ តាមក្រសួង-ស្ថាប័ន ត្រូវបានរៀបចំ និងទទួលបានការសម្រេចដ៏ខ្ពង់ខ្ពស់ពីសម្តេចតេជោនាយករដ្ឋមន្ត្រី នៅថ្ងៃទី ៨ មិថុនា ២០២២។ | |
| | សគ ៣.<br>ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំដោយមានសូចនាករសមិទ្ធកម្ម | សេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិកាមានសូចនាករសមិទ្ធកម្ម | ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ មានរំលេចសូចនាករសមិទ្ធកម្ម ។ | | គ្រប់ក្រសួង ស្ថាប័នរៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយមានការកំណត់សូចនាករសមិទ្ធកម្មនៅឆ្នាំ២០២២សម្រាប់ថវិកាឆ្នាំ ២០២៣ | គ្រប់ក្រសួង ស្ថាប័នបានរៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយមានសូចនាករសមិទ្ធកម្ម | |
| ៣១.១. កែលម្អគុណភាពនៃការព្យាករម៉ាក្រូសេដ្ឋកិច្ចនិងធ្វើស្ថាប័នីយកម្មក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ | សច ១.<br>ភាគរយកម្រិតលម្អៀងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមធៀបនឹងការអនុវត្តឆ្នាំ N-1 | +/-៥% កម្រិតលម្អៀងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងការអនុវត្តឆ្នាំ N-1 | - របាយការណ៍ស្តីពីការពិនិត្យតាមដានកម្រិតលម្អៀងលទ្ធផលព្យាករណ៍ ម៉ាក្រូសេដ្ឋកិច្ច ឆ្នាំ ២០២០ ត្រូវបានរៀបចំ<br>- របាយការណ៍តាមដានកម្រិតលម្អៀង នៃក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២០ ត្រូវបានរៀបចំ | | +/-៥% កម្រិតលម្អៀងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងការអនុវត្តឆ្នាំ N-1 | របាយការណ៍ពិនិត្យតាមដានកម្រិតលម្អៀងបឋមនៃក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២១ (n-1) ត្រូវបានរៀបចំ និងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ | |

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ២០២១ | លទ្ធផលសម្រេចបានឆ្នាំ២០២១ | ពណ៌ | គោលដៅឆ្នាំ២០២២ | លទ្ធផលសម្រេចបានឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| រយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម | | | | | | | |
| | **<u>សច ២.</u>**<br>MTFF ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី | ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ត្រូវបានរៀបចំ និងស្នើសុំការអនុម័តពីប្រមុខរាជរដ្ឋាភិបាល | ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ត្រូវបានរៀបចំ និងអនុម័តពីប្រមុខរាជរដ្ឋាភិបាល | | ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) ឆ្នាំ ២០២៣-២០២៥ ត្រូវបានរៀបចំ និងដាក់ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី | ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ២០២៣-២០២៥ ត្រូវបានរៀបចំ និងដាក់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេច។ អនុវត្តតាមការសម្រេចរបស់ថ្នាក់ដឹកនាំ, អ.គ.ប. នឹងរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ជំនួសក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ២០២៣-២០២៥សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ | |
| | **<u>សច ៣.</u>**<br>MTBF មានបញ្ចូលពិតានថវិកាពហុឆ្នាំត្រូវបានធ្វើសពុលកម្ម និងដាក់ឱ្យអនុវត្ត | MTBF (កំណត់ពិតានថវិកាពហុឆ្នាំ) ត្រូវបានដាក់ឱ្យដាក់ឱ្យអនុវត្ត | ក្របខ័ណ្ឌរយពេលមធ្យម ( MTBF) ដោយមានកំណត់ពិតានពហុឆ្នាំត្រូវបានអនុម័តដោយប្រមុខរាជរដ្ឋាភិ-បាល និងបានដាក់ឱ្យអនុវត្តដល់ក្រសួង-ស្ថាប័ន ។ | | MTBF (កំណត់ពិតានថវិកាពហុឆ្នាំ) ត្រូវបានដាក់ឱ្យដាក់ឱ្យអនុវត្ត | បានរៀបចំពិតានថវិកាពហុឆ្នាំនៃថវិកាចំណាយចរន្តសម្រាប់ក្រសួង ស្ថាប័ន | |
| ៣១.២. រៀបចំស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS) ឱ្យពេញលេញប្រកបដោយគុណភាព | **<u>សច ៤.</u>**<br>ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS) ត្រូវបានរៀបចំពេញលេញទាំងវិសាលភាពទិន្នន័យ និងវិសាល-ភាពស្ថាប័នស្របតាមនិយាម(GFS ២០១៤) | -តារាង ៦÷ តារាងចំណាយតាមចំណាត់ថ្នាក់មុខងារនៃរដ្ឋាភិ-បាល (COFOG) ថ្នាក់ជាតិ ត្រូវបានរៀបចំដោយផ្តោតលើចំណាយសង្គម ដោយគ្រប់ដណ្តប់មុខងារ ០៣/ ១០ (មុខងារអប់រំ, មុខងារសុខាភិបាល, និងមុខងារគាំពារសង្គម)<br>-Statement Operation ត្រូវបានពង្រីកវិសាលភាពបន្ថែម សម្រាប់រដ្ឋាភិបាលទូទៅ (General Government) | -តារាង ៦÷ តារាងចំណាយតាមចំណាត់ថ្នាក់មុខងារនៃរដ្ឋាភិបាល (COFOG) ថ្នាក់ជាតិត្រូវបានរៀបចំដោយផ្តោតលើចំណាយសង្គម ដោយគ្រប់ដណ្តប់មុខងារ០៣/១០ (មុខងារអប់រំ, មុខងារសុខាភិបាល, និងមុខងារគាំពារសង្គម)<br>**-Statement Operation** ត្រូវបានពង្រីកវិសាលភាពបន្ថែមសម្រាប់រដ្ឋាភិបាលទូទៅ (**General Governement)** | | - វិសាលភាពទិន្នន័យ តារាងស្ថិតិទី ៧ សម្រាប់រដ្ឋបាលថ្នាក់ជាតិត្រូវបានពិនិត្យលទ្ធភាពរៀបចំ<br>- មុខងារ ០៧ ទៀត នៃតារាង ៦ : **COFOG** ត្រូវបានពង្រីកបន្ថែមឱ្យបានពេញលេញ | -តារាង ៧ ÷ ស្តីពីស្ថិតិ Integrated Statement of Flows សម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រូវបានសិក្សារៀបចំ.<br>-បានរៀបចំរបាយការណ៍សិក្សាពិនិត្យលទ្ធភាពរៀបចំ និងបានរៀបចំស្ថិតិចំណាយតាមចំណាត់ថ្នាក់មុខងារ (COFOG) ចំនួន ១០ មុខងារ ក្នុងប្រព័ន្ធស្ថិតិ GFS។ | |

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ២០២១ | លទ្ធផលសម្រេចបានឆ្នាំ២០២១ | ពណ៌ | គោលដៅឆ្នាំ២០២២ | លទ្ធផលសម្រេចបានឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| ៣២. ពង្រឹងការគ្រប់គ្រងវិនិយោគសាធារណៈ | <u>សគ ៤.</u><br>ការរៀបចំយន្តការគ្រប់គ្រងវគម្រោងវិនិយោគសាធារណៈ | អនុក្រឹត្យចំនួន ១, យន្តការ ១, ប្រកាសចំនួន ៣ និងគោលការណ៍ណែនាំចំនួន ៤ ត្រូវបានអនុម័ត និងផ្សព្វផ្សាយ | គោលការណ៍ណែនាំចំនួន៣ ត្រូវបានអនុម័ត រួមមាន (១) គោលការណ៍ណែនាំលម្អិតស្តីពីវដ្តនៃគម្រោងវិនិយោគសាធារណៈ, (២) គោលការណ៍និងនីតិវិធីគ្រប់គ្រងយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង និង (៣) គោលការណ៍ណែនាំសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ។ | | ឯកសារពាក់ព័ន្ធនឹងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈត្រូវបានដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយ | -ឯកសារស្តីពីនីតិវិធីប្រតិបត្តិរបស់គណៈកម្មការវិនិយោគសាធារណៈ ត្រូវបានរៀបចំ។<br>-អនុក្រឹត្យស្តីពីការអនុវត្តនីតិវិធីប្រតិបត្តិ (SOP) សម្រាប់រៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP ត្រូវបានអនុម័តកាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០២២។<br>- ប្រកាសអន្តរក្រសួងស្តីពីគោលការណ៍រួមសម្រាប់ការគ្រប់គ្រងគម្រោងថែទាំហេដ្ឋា-រចនាសម្ព័ន្ធធារាសាស្ត្រ ត្រូវបានដាក់ឱ្យអនុវត្ត<br>-ប្រកាសស្តីពីនីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រង រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិត្រូវបានដាក់ឱ្យអនុវត្ត<br>-បានពិនិត្យ និងកែសម្រួលអនុក្រឹត្យស្តីពីការគ្រប់គ្រងកម្មវិធីវិនិយោគ (PIP)<br>-សេចក្តីព្រាងប្រកាសដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការ (SOP) នៃ ការរៀបចំនិងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | |
| ៣២.១. រៀបចំ កែលម្អ ឬបង្កើតលិខិតបទដ្ឋានគតិយុត្តពាក់ | <u>សច ៥.</u><br>ការរៀបចំគោលការណ៍ណែនាំសម្រាប់រៀបចំកម្មវិធីវិនិយោគ | គោលការណ៍ណែនាំចំនួន៣[14] ត្រូវបានអនុម័ត | គោលការណ៍ណែនាំចំនួន៣ ត្រូវបានអនុម័ត រួមមាន(១) គោលការណ៍ណែនាំលម្អិតស្តីពីវដ្តនៃគម្រោងវិនិយោគសាធារណៈ, (២) គោលការណ៍និងនីតិវិធីគ្រប់គ្រង | | គោលការណ៍ណែនាំចំនួន៣ ត្រូវបានដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយ | ១. ប្រកាសស្តីពីការដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រងរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈហិរញ្ញ | |

[14] (១) គោលការណ៍ណែនាំសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិលត្រូវបានរៀបចំនិងផ្សព្វផ្សាយ (២០២១), (២) គោលការណ៍ណែនាំស្តីពីការរៀបចំសំណើគម្រោង (វដ្តនៃគម្រោងវិនិយោគសាធារណៈ)ត្រូវបានអនុម័ត និងប្រកាសដោយ កសហវ. (២០២១), (៣) គោលការណ៍និងនីតិវិធីគ្រប់គ្រងយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាពនិងរៀបចំគម្រោង ត្រូវបានរៀបចំនិងអនុវត្ត (២០២២)

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ២០២១ | លទ្ធផលសម្រេចបានឆ្នាំ២០២១ | ពណ៌ | គោលដៅឆ្នាំ២០២២ | លទ្ធផលសម្រេចបានឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈ | សាធារណៈចំនួន ០៣ | | យន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង និង (៣) គោលការណ៍ណែនាំសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ។ | | | ប្បទាន ដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់) ត្រូវបានអនុម័តកាលពីថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០២២។<br>២. សេចក្ដីព្រាងគោលការណ៍ណែនាំស្ដីពីនីតិវិធីប្រតិបត្តិការ (SOP) នៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>៣. ប្រកាសស្ដីពីគោលការណ៍រួមសម្រាប់ការគ្រប់គ្រងការថែទាំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ | |
| | **<u>សច ៦.</u>**<br>មានយន្តការកំណត់អត្តសញ្ញាណគម្រោងវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិនៅ កសហវ. | លិខិតបទដ្ឋានគតិយុត្តិសម្រាប់រៀបចំយន្តការកំណត់អត្តសញ្ញាណគម្រោងវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | ពុំមានការរាយការណ៍ | | -ប្រកាសស្ដីពីគោលការណ៍ណែនាំស្ដីពីនីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។<br>-គោលការណ៍ណែនាំស្ដីពីនីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ និងបណ្ដុះបណ្ដាល។<br>-ប្រព័ន្ធទិន្នន័យគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ។ | -បានរៀបចំសេចក្ដីព្រាងប្រកាសស្ដីពី គោលការណ៍ណែនាំស្ដីពីនីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។<br>-ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈជំនាន់១ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។ | |

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ២០២១ | លទ្ធផលសម្រេចបានឆ្នាំ២០២១ | ពណ៌ | គោលដៅឆ្នាំ២០២២ | លទ្ធផលសម្រេចបានឆ្នាំ២០២២ | ពណ៌ |
|---|---|---|---|---|---|---|---|
| | **<u>សច ៧.</u>**<br>គណៈកម្មការវិនិយោគសាធារណៈ សម្រាប់គាំទ្រយន្តការបុរេថវិកានីយកម្មការវិនិយោគ | - ប្រកាសស្តីពីការបង្កើត គណៈ-កម្មការវិនិយោគសាធារណៈ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>- លក្ខខណ្ឌយោងការងារសម្រាប់លេខាធិការដ្ឋានគណៈកម្មការ | -ប្រកាសស្តីពីការបង្កើតគណៈកម្មការវិនិយោគសាធារណៈ ត្រូវបានរៀបចំ | | នីតិវិធីប្រតិបត្តិរបស់គណៈកម្មាធិការវិនិយោគសាធារណៈ គោរពជូនរដ្ឋមន្ត្រីកសហវ សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំថវិកា | ឯកសារស្តីពីនីតិវិធីប្រតិបត្តិរបស់គណៈកម្ម-ការវិនិយោគសាធារណៈ (គ.វ.ស.) ត្រូវបានរៀបចំ | |
